# ទស្សនាវដ្ដីស្រាវជ្រាវ

# រាជបណ្ឌិត្យសភាកម្ពុជា

## Royal Academy of Cambodia Journal

លេខ៧ ខែធ្នូ ឆ្នាំ២០២១ | Vol.7-December-2021



រក្សាសិទ្ធិគ្រប់យ៉ាង

**នាយកការផ្សាយ**

ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច**

**និពន្ធនាយក**

ឯកឧត្តមបណ្ឌិត **យង់ ពៅ**

**គណៈកម្មការនិពន្ធ**

ឯកឧត្តមបណ្ឌិត **នូ ចាន់សុភី**
ឯកឧត្តមបណ្ឌិត **ផុន កសិកា**
ឯកឧត្តមបណ្ឌិត **អ៊ីប បុណ្ណា**
ឯកឧត្តមបណ្ឌិត **នុត សម្បត្តិ**
ឯកឧត្តមបណ្ឌិត **គិន ភា**
ឯកឧត្តមបណ្ឌិត **មាឃ បូរ៉ា**
ឯកឧត្តមបណ្ឌិត **គី សេរីវឌ្ឍន៍**
ឯកឧត្តម **សូត្រ សំណាង**
ឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម**
លោក **ហេង វីរិទ្ធិ**
លោក **សាន សុភាវនិត**

**លេខាធិការដ្ឋានបោះពុម្ពផ្សាយ**

លោកស្រី **កែវ ខេមរា**
លោក **ធឿន សុត្ថា**
លោក **ហេង ហុកវេន**
លោកស្រី **សំរិទ្ធ ចរិយា**
លោក **កៅ សុម៉ាឡេត**
លោក **ទ្រឿង មករា**
លោក **ភួយ បញ្ញា**

# អារម្ភកថា

ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងការបោះពុម្ពផ្សាយជាកត្តារួមចំណែកមួយក្នុងការអភិវឌ្ឍសង្គមជាតិដែលក្នុងនោះរាជបណ្ឌិត្យសភាកម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវលើជំនាញផ្សេងៗនិងបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រ នៃរាជបណ្ឌិត្យសភាកម្ពុជាជាច្រើនលេខរួចមកហើយ។ នៅក្នុងលេខទីប្រាំពីរនេះមានអត្ថបទជាច្រើនទៀតដែលទាក់ទងនឹងអក្សរសាស្ត្រ អប់រំ គណិតវិទ្យា ទេសចរណ៍ កសិកម្ម បុរាណវិទ្យា ទស្សនវិជ្ជា ច្បាប់ សេដ្ឋកិច្ច និងនយោបាយជាដើម សុទ្ធសឹងជាអត្ថបទសិក្សាស្រាវជ្រាវ និងវិភាគបែបវិទ្យាសាស្ត្រ ដែលអាចជាជំនួយស្មារតីដល់អ្នកសិក្សាស្រាវជ្រាវផងដែរ។

ទស្សនាវដ្ដីវិទ្យាសាស្ត្រនៃរាជបណ្ឌិត្យសភាកម្ពុជាបានរួមចំណែកផ្សព្វផ្សាយស្នាដៃស្រាវជ្រាវបែបវិទ្យាសាស្ត្ររបស់ បណ្ឌិត្យសភាចារ្យ អ្នកស្រាវជ្រាវ និងអត្ថបទសិក្សាស្រាវជ្រាវរបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងបេក្ខជនបណ្ឌិត។ ការបោះពុម្ពផ្សាយនូវស្នាដៃស្រាវជ្រាវថ្មីៗបែបវិទ្យាសាស្ត្រគឺដើម្បីផ្ដល់នូវចំណេះដឹងបែបវិទ្យាសាស្ត្រជូនដល់សង្គមជាតិ និងជួយសម្រួលដល់អ្នកសិក្សាស្រាវជ្រាវស្វែងយល់ ក៏ដូចជាជួយជម្រុញដល់អ្នកស្រាវជ្រាវទាំងឡាយកាន់តែមានឆន្ទះស្រាវជ្រាវប្រកបដោយវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំទស្សនាវដ្ដីសង្ឃឹមថា អត្ថបទទាំងអស់ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រនេះនឹងក្លាយជាឯកសារដ៏សំខាន់មួយ សម្រាប់ការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំរង់ចាំទទួលមតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកអាននិងអ្នកស្រាវជ្រាវគ្រប់មជ្ឈដ្ឋានដើម្បីកែលម្អនូវចំណុចខ្វះខាតនិងកំហុសឆ្គងដែលអាចកើតមានដោយអចេតនា ទាំងលើខ្លឹមសារ និងផ្នែកបច្ចេកទេស ឱ្យកាន់តែមានសុក្រិតភាព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១

**គណៈកម្មការទស្សនាវដ្ដីវិទ្យាសាស្ត្ររាជបណ្ឌិត្យសភាកម្ពុជា**

# មាតិកា

១. វិធីកម្លាយក្នុងភាសាខ្មែរ ៖ បញ្ហាកង្វះផ្នត់សម្រាប់ធ្វើវិធីកម្លាយឱ្យមានសម្បូរណ៍បែប, បញ្ហាវិសាលភាពតូចចង្អៀតនៃផ្នត់មួយចំនួន និង បញ្ហាសទិសសូរវេយ្យាករណ៍វិស័យ **បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់**-១

២. តើត្រូវលើកកម្ពស់និងពង្រឹងគុណភាពអប់រំគណិតវិទ្យានៅកម្ពុជាយ៉ាងដូចម្តេច ដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ **បណ្ឌិតសភាចារ្យ ច័ន្ទ រ័ត្ន**---------------------------------------- ១៣

៣. ការព្យាករណ៍អំពីចំនួនទេសចរណ៍សរុប ចំនួនទេសចរណ៍តាមផ្លូវអាកាសនិងចំណូលបានពីវិស័យទេសចរណ៍នៅកម្ពុជា **បណ្ឌិត ហាក់ ធីរោ**------------------------------------------------------------២៣

៤. សិក្សាលើកំណើនទម្ងន់របស់គោក្នុងស្រុកដោយប្រើស្មៅស្តេចផ្កាប់ **បណ្ឌិត ឈុំកិត លន់**------- ៣០

៥. ប្រាសាទថ្មី និងសិលាចារិកថ្មី១ទៀតទើបរកឃើញនៅសម្ពុបុរៈ **បណ្ឌិត ធុយ ចាន់ធួន** --------- ៣៦

៦. អន្តេបទ/-អំម.ណា-/ឬ/-អឹម.ន-/ **បណ្ឌិត វង្ស មេង** -----------------------------------------------៤២

៧. គោលវិធីសិស្សមជ្ឈមណ្ឌល **បណ្ឌិត កង ឱម** ----------------------------------------------------៥៧

៨. ហេតុផល១១យ៉ាងបញ្ជាក់ថា ហេតុអ្វីបានជាទស្សនវិជ្ជាសំខាន់ **បណ្ឌិត ឈត ប៊ុនថង** ---------៦៧

៩. សិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យនៅកម្ពុជា **បេក្ខជនបណ្ឌិត ប៉ាត បញ្ញា** ----------------------------៧៤

១០. ការយល់ដឹងអំពីរដ្ឋបាលតុលាការកម្ពុជា **បេក្ខជនបណ្ឌិត ពៅ វិបុល** ---------------------------៨១

១១. ការចូលរួមរបស់យុវជនក្នុងនយោបាយ **បេក្ខជនបណ្ឌិត វង្ស កែវសុធន** -----------------------៨៦

១២. ការវិវត្តនៃឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌលក្ខណៈសកល **បេក្ខជនបណ្ឌិត វង្ស ពេជ្របុរី**-----------------------------------------------------------------------------------៩៦

# វិធីកម្លាយក្នុងភាសាខ្មែរ : បញ្ហាកង្វះផ្នត់សម្រាប់ធ្វើវិធីកម្លាយឱ្យមានសម្បូរណ៍បែប, បញ្ហាវិសាលភាពតូចចង្អៀតនៃផ្នត់មួយចំនួន និង បញ្ហាសទិសសូរវេយ្យាករណ៍វិស័យ


## បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់


ប្រធានបទ : វិធីកម្លាយក្នុងភាសាខ្មែរ : បញ្ហាកង្វះផ្នត់សម្រាប់ធ្វើវិធីកម្លាយឱ្យមានសម្បូរណ៍បែប, បញ្ហាវិសាលភាពតូចចង្អៀតនៃផ្នត់មួយចំនួន និង បញ្ហាសទិសសូរវេយ្យាករណ៍វិស័យ[1]។

<u>កំណត់សម្គាល់</u> : ខ្ញុំប្រើពាក្យ‘សទិសសូរវេយ្យាករណ៍វិស័យ’ដែលជាបម្រែនៃពាក្យបារាំង‘homonymie grammaticale’ដែលអ្នកភាសាវិទ្យាបារាំងស្គាល់ជាទូទៅ ហើយ ដែលសម្គាល់បាតុភូតដែលមានក្នុងភាសាជាច្រើន គឺផ្នត់តែមួយត្រូវបានប្រើសម្រាប់បង្កើតពាក្យកម្លាយសម្គាល់បញ្ញត្តិនេះផងនោះផង។ ដើម្បីប្រែ‘homonymie grammaticale’មកជា‘សទិសសូរវេយ្យាករណ៍វិស័យ’ ខ្ញុំបានយកលំនាំតាមលោក តិប យក់ & ថាវ គន្ធ ដែលបានប្រែគុណនាមបារាំង‘subjectif’ថា‘អត្តវិស័យ’ នាម‘subjectivité’ថា‘អត្តវិស័យភាព’ និង នាម‘objectivité’ថា‘វត្ថុវិស័យភាព’ ក្នុងវចនានុក្រមបារាំង-ខ្មែររបស់គាត់។

## <u>សេចក្តីផ្តើម</u>

ខ្ញុំបានសង្កេតឃើញថា ភាសាខ្លះបង្កើតពាក្យបានតែតាមវិធីបន្សំ និង ភាសាខ្លះទៀតអាចបង្កើតពាក្យបានតាមវិធីបន្សំផងនិងតាមវិធីកម្លាយផង[2]។

ភាសាដែលអាចបង្កើតពាក្យបានតែតាមវិធីបន្សំ មានដូចជាភាសាបាអ៊ូឡេ (baoulé), ភាសាសេនូផូ (sénoufo) នៅប្រទេសកូឌីវ័រ (Côte d'Ivoire) ជាដើម។ ភាសាខ្មែរជាភាសាដែលនៅក្នុងក្រុមទី២ គឺអាចបង្កើតពាក្យបានតាមវិធីបន្សំផងនិងតាមវិធីកម្លាយផង។ ប៉ុន្តែវិធីកម្លាយនៃភាសាខ្មែរមិនសូវសម្បូរណ៍បែបទេ[3]។ ក្នុងចំណោមភាសាដែលស្ថិតនៅក្នុងក្រុមទី២ ភាសាបារាំងជាភាសាមួយដែលមានផ្នត់យ៉ាងសម្បូរណ៍ ដែលគេប្រើសម្រាប់ទាញនាមចេញពីនាមគ្នាឯង ចេញពីកិរិយាសព្ទ និង ចេញពីគុណនាម, ទាញកិរិយាសព្ទចេញពីនាមនិងចេញពីគុណនាម, ទាញគុណនាមចេញពីនាម, ទាញគុណកិរិយាចេញពីគុណនាម,... ឧទាហរណ៍ :

១- ផ្នត់ប្រើសម្រាប់បង្កើតពាក្យកម្លាយចេញពីកិរិយាសព្ទ :

---

[1] - តាមរយៈប្រធានបទនេះ ខ្ញុំនឹងលើកឡើងនូវកង្វះខាតមួយចំនួនក្នុងភាសាខ្មែរ ប៉ុន្តែភាសាណាក៏មានកង្វះខាតដែរ ហើយ ភាសាខ្មែរពិតជាមិនចាញ់ភាសាជាច្រើនក្នុងលោកឡើយ។

[2] - ក្រៅពីវិធីទាំងពីរនេះដែលភាសាជាច្រើនក្នុងលោកបានស្គាល់ជាយូរលង់មកហើយ គេមានវិធីបង្កើតពាក្យមួយបែបទៀតដែលមានឈ្មោះក្នុងភាសាបារាំងថា ‘procédés morphophonologiques’ ហើយ ដែលយើងបកប្រែថា ‘វិធីរូប-សទ្ទតា’, ឧ. Villes capitales > capitales (រដ្ឋ/រាជធានី), e(lectronic) mail > email, ការិយា(ល័យ) + (អ)ធិបតេយ្យ > ការិយាធិបតេយ្យ,...។

[3] - ខ្ញុំមិនលើកឡើងនូវធាតុឯទៀតដែលត្រូវបានប្រើប្រាស់ក្នុងស្ថានភាពរប៉ាត់រប៉ាយនោះទេ ដូចជា ចំណាត (< ចត), សំបក (< បក), ច្បោះ (< បោះ), ប្រណាក (ប្រដាប់សម្រាប់ ឆាក) ជាដើម។

Former, កិរិយាសព្ទ
- formation[4] ( នាមសម្គាល់អំពើ/លទ្ធផល )
- formateur ( នាមសម្គាល់ភ្នាក់ងារ )
- formatif ( គុណនាម )

២- ផ្នត់សម្រាប់បង្កើតពាក្យកម្លាយចេញពីនាម :

Forme, នាម
- former ( កិរិយាសព្ទ )
- informer ( កិរិយាសព្ទ )
- déformer ( កិរិយាសព្ទ )

Jardin, នាម
- jardiner ( កិរិយាសព្ទ )
- jardinage ( នាមសម្គាល់អំពើ )
- jardinier ( នាមសម្គាល់ភ្នាក់ងារ )

៣- ផ្នត់សម្រាប់បង្កើតពាក្យកម្លាយចេញពីគុណនាម :

Blanche,គុណនាម
- blancheur ( នាម )
- blanchâtre ( គុណនាម )
- blanchir ( កិរិយាសព្ទ )

Lent, គុណនាម
- lenteur ( នាម )
- lentement ( គុណកិរិយា )

៤- ផ្នត់ប្រើដើម្បីធ្វើកម្លាយពាក្យជាបន្តបន្ទាប់ ចេញជាប្រភេទពាក្យផ្សេងៗគ្នា :

Marge( នាម ) → marginal( គុណនាម ) → marginaliser( កិរិយាសព្ទ ) → marginalisation( នាម ).

បញ្ជាក់ : ឧទាហរណ៍ខាងលើមិនគ្របដណ្តប់លើវិធីកម្លាយនៃភាសាបារាំងទាំងអស់ទេ : ខ្ញុំគ្រាន់តែផ្តល់ភស្តុតាងដែលបង្ហាញឱ្យឃើញថា វិធីកម្លាយក្នុងភាសាបារាំងមានភាពសម្បូរណ៍បែបៗ

## សេចក្តីអត្ថាធិប្បាយ

### ០- បុព្វយោគ

**០១- តម្រូវការ**‘Alphabet Phonétique International’ ( API ) **ដើម្បីកត់ត្រាភាសាផ្សេងៗក្នុងការស្រាវជ្រាវ**

ជាទូទៅ អ្នកភាសាវិទ្យាតែងតែប្រើ‘API’ដែលមានប្រភពចេញពីអក្សរឡាតាំងសម្រាប់កត់ត្រាភាសាដែលគេសិក្សា ដើម្បីឱ្យអ្នកភាសាវិទ្យាឯទៀតអាចអានបាន ពីព្រោះភាសាមួយចំនួនប្រើអក្សរផ្សេងៗគ្នាហើយ ទោះបីចំពោះភាសាដែលប្រើអក្សរឡាតាំងក៏អក្ខរាវិរុទ្ធមានអំណានមិនដូចគ្នាពីភាសាមួយទៅ

[4] - ចំណែកក្នុងពាក្យនីមួយៗដែលមានគំនូសពីក្រោម គឺជាផ្នត់។

ភាសាមួយទៀតដែរ : ដូច្នេះខ្ញុំក៏មានការចាំបាច់ប្រើ‘API’ ដើម្បីកត់ត្រាផ្នត់ឬពាក្យខ្មែរដែលខ្ញុំផ្ដល់ជាឧទាហរណ៍ផងដែរ។

**០២- បម្រែពាក្យ**‘Alphabet Phonétique International’**មកជាពាក្យខ្មែរ**

ខ្ញុំបានប្រែ‘Alphabet Phonétique International’ថា ‘អក្ខរក្រមសូរវិស័យអន្តរជាតិ’ ដោយពឹងផ្អែកលើវចនានុក្រមបារាំង-ខ្មែរ របស់លោក តិប យក់ & ថាវ គន្ធ តាំងពីខ្ញុំចាប់សរសេរអត្ថបទជាភាសា-ខ្មែរ។ ក្នុងវចនានុក្រមបារាំង-ខ្មែរនោះ អ្នករៀបរៀងបានប្រែ‘alphabet’ ថា ‘អក្ខរក្រម’។ ចំពោះពាក្យ ‘សូរវិស័យ’ ខ្ញុំបានយកលំនាំតាមពាក្យ‘អត្តវិស័យ’(=subjectif), ‘អត្តវិស័យភាព’(=subjectivité) និង ‘វត្ថុវិស័យភាព’(=objectivité) របស់ពួកគាត់(អ្នករៀបរៀងវចនានុក្រមបារាំង-ខ្មែរនោះបានប្រើពាក្យ‘វិស័យ’ ដើម្បីបង្កើតគុណនាមចេញពីជាតុ‘អត្ត’ឬពីនាម‘វត្ថុ’)។ ‘អក្ខរក្រមសូរវិស័យអន្តរជាតិ’ អាច ជាអក្សរកាត់ ចេញជា‘អ.ស.អ.’ ប៉ុន្តែ ក្នុងបាឋកថានេះ ខ្ញុំសុំប្រើអក្សរកាត់បារាំង‘API’ តាមទម្លាប់ចាស់របស់ខ្ញុំវិញសិន ពីព្រោះ ក្រោយមក បម្រែផ្សេងមួយទៀតត្រូវបានប្រើផងដែរ ដែលជាហេតុនាំឱ្យមានបញ្ហាចម្រូងចម្រាស។

**១- <u>ការរំលឹកជាគោលៗ[5]អំពីបែបផ្សេងៗនៃវិធីកម្លាយពាក្យក្នុងភាសាខ្មែរ</u>**

**១.១- <u>ចំណុចដែលលើនោះអ្នកអក្សរសាស្ត្រខ្មែរមូលមតិគ្នា</u>**

គួររំលឹកថា អ្នកអក្សរសាស្ត្រខ្មែរបានស្រុះស្រួលមូលមតិគ្នា ទទួលស្គាល់ថា ភាសាខ្មែរសុទ្ធសាធមានផ្នត់ដើមនិងផ្នត់ដែក។

(១)- ផ្នត់ដើម

(១.១)- ផ្នត់ដើមសម្រាប់បង្កើតកិរិយាហេតុ មានដូចជា :

- [p-/ph-], ឧ. [p-] + dɔəŋ(ដឹង) > pdɔəŋ(ប្ដឹង), [p-] + juo(យួរ) > pjuo(ព្យួរ), [ph-] + sɔək(សឹក) > phsɔək(ផ្សឹក), [ph-] + cɔap(ជាប់) > phcɔap(ភ្ជាប់);
- [bɑŋ-], [bɑṇ-], [bɑn-], [bɑm-][6], ឧ. [bɑŋ-] + khaŋ(ខាំង) > bɑŋkhaŋ(បង្ខាំង), [bɑṇ-] + co:l(ចូល) > bɑṇco:l(បញ្ចូល), [bɑn-] + si(ស៊ី) > bɑnsi(បន្ស៊ី), [bɑm-] + buos(បួស) > bɑmbuos(បំបួស);
- [rum-] + kɔəl(កិល) > rumkɔəl(រំកិល),...។

(១.២)- ផ្នត់ដើម[lum-]សម្រាប់បង្កើតនាមសម្គាល់លទ្ធផល, ឧ. [lum-] + nɯŋ(នឹង) > lumnɯŋ(លំនឹង), [lum-] + hat(ហាត់) > lumhat(លំហាត់),...។

---

[5] - ចំពោះសម្រង់លំអិតនៃផ្នត់ទាំងប៉ុន្មាន សូមមើលក្នុង‘វេយ្យាករណ៍ទម្រង់និយម’ភាគទី២ ដែលមានក្នុងគន្ថនិទ្ទេសនិងដែលមានចុះផ្សាយតាម Facebook របស់បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់។

[6] - សមាជិកនៃគណៈកម្មការភាសាវិទ្យានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ បានស្រុះស្រួលគ្នាចាត់ទុក [bɑŋ-], [bɑṇ-], [bɑn-], [bɑm-] ថាជាកាឡា-រូបរបស់ផ្នត់ដើម/p-/។ គួរកត់សម្គាល់ថា ក្នុងករណីខ្លះ គេអនុវត្តការសម្របសូរ ជាពិសេសជាមួយពាក្យដើមកើតចេញពីព្យញ្ជនៈ យ, រ, ល, វ ដូចជា យារ > ពន្យារ, រាយ > ពង្រាយ, លូត > ពន្លូត, វាង > ពង្វាង,...។

(២)- ផ្នត់ដែកមាន : [-m-], [-n-], [-b-], [-αmn-/-ɔmn-], [-αm-/-ɔm-]។

(២.១)- ផ្នត់ដែក [-m-] ប្រើសម្រាប់បង្កើតពាក្យកម្លាយសម្គាល់ភ្នាក់ងារ, ឧ. cam(ចាំ) + [-m-] > cmam > chmam(ឆ្មាំ), cuoṇ(ជួញ) + [-m-] > cmuoṇ > chmuoṇ(ឈ្មួញ),...។

(២.២)- ផ្នត់ដែក [-n-] ប្រើសម្រាប់បង្កើតពាក្យកម្លាយសម្គាល់ឧបករណ៍, ឧ. kaos[7](កោស) + [-n-] > knaos > khnaos(ខ្នោស),...។

(២.៣)- ផ្នត់ដែក [-b-] សម្រាប់បង្កើតពាក្យកម្លាយសម្គាល់លទ្ធផល : jɔl(យល់) + [-b-] > jbɔl > jbαl(យ្បល់) > jọbαl(យោបល់), riep(រៀប) + [-b-] > rbiep > rɔ:biep(របៀប), lɔas(លាស់) + [-b-] > lbɔas > lbas(ល្បាស់),...។

(២.៤)- ផ្នត់ដែក [-αmn-/-ɔmn-] ប្រើសម្រាប់បង្កើតពាក្យកម្លាយសម្គាល់លទ្ធផល, ឧ. co:l(ចូល) + [-αmn-] > cαmno:l(ចំណូល), ku:s(គូស) + [-ɔmn-] > kɔmnu:s(គំនូស)។

(២.៥)- ផ្នត់ដែក [-αm-/-ɔm-] ប្រើសម្រាប់បង្កើតនាមកម្លាយសម្គាល់លទ្ធផលផង, នាមកម្លាយសម្គាល់ឧបករណ៍ផង និង កិរិយាហេតុសម្គាល់ន័យថា«ធ្វើឱ្យ»ផង (សូមអានចំណុច៤ ទាក់ទងនឹងបញ្ហាសទិសសូរវេយ្យាករណ៍វិស័យ)។

### ១.២- <u>ចំណុចដែលលើនោះអ្នកអក្សរសាស្ត្រខ្មែរមិន/មិនទាន់មូលមតិគ្នា</u>

អ្នកអក្សរសាស្ត្រខ្មែរមិន/មិនទាន់មូលមតិគ្នាលើផ្នត់ចុង/បច្ឆិមបទនៅឡើយ។ អ្នកខ្លះយល់ថា ភាសាខ្មែរឥតមានផ្នត់ចុង/បច្ឆិមបទទេ។ ពាក្យដែលខាងចុងមានធាតុ[8]‘សាស្ត្រ’(វិទ្យាសាស្ត្រ, វេជ្ជសាស្ត្រ), ‘វិទ្យា’(ភាសាវិទ្យា), ‘វិទូ’(ភាសាវិទូ), ‘ករ’(ពលករ),... ត្រូវបានអ្នកអក្សរសាស្ត្រទាំងនោះចាត់ទុកថាជាពាក្យបន្សំ/ពាក្យសមាស[9] : ដូច្នេះពួកគាត់មិនទទួលស្គាល់ថាធាតុខាងចុងនៃពាក្យទាំងប៉ុន្មានដែលទើបត្រូវបានបង្ហាញមកនេះ ជាផ្នត់ចុង/បច្ឆិមបទនោះឡើយ។

អ្នកអក្សរសាស្ត្រខ្មែរខ្លះទៀត យល់ថា ភាសាខ្មែរបច្ចុប្បន្នមានផ្នត់ចុង/បច្ឆិមបទ ដោយគេផ្អែកលើនិយមន័យនៃផ្នត់/អព្ភាសបទ ដូចនេះ : «ផ្នត់/អព្ភាសបទជាកន្ទេចពាក្យដែលមានន័យនឹងនរនិងរូបនឹងនរ

---

[7] - អ្នកសូរវិទ្យានិយមប្រើ [h] ដើម្បីជំនួសព្យញ្ជនៈ‘ស’ដែលយើងប្រើនៅចុងព្យាង្គនៃពាក្យខ្មែរ : ពាក្យ‘កោស’ ត្រូវគេសរសេរជា API ដូចនេះ : [kaoh] ប៉ុន្តែខ្ញុំសុំប្រើ [s] សម្រាប់កត់ត្រាព្យញ្ជនៈ‘ស’ខ្មែរ ដើម្បីឱ្យសាធារណជនខ្មែរងាយយល់ គឺ [kaos]។

[8] - ខ្ញុំប្រើ‘ធាតុ’សម្រាប់សម្គាល់កម្ទេចពាក្យដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសាខ្មែរបច្ចុប្បន្ន។

[9] - ក្នុងសៀវភៅវេយ្យាករណ៍ភាសាខ្មែរ(កម្រិតមធ្យមសម្រាប់ការប្រើប្រាស់ទូទៅ)បោះពុម្ពលើកទី១ ឆ្នាំ២០១៨ នៅរោងពុម្ពជី.អ៊ី.ធី. ប៊ីហ្សនេស ផ្ទះលេខ២៣២០ ផ្លូវ៤៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលគណៈកម្មការភាសាវិទ្យានៃក្រុមប្រឹក្សាជាតិភាសាខ្មែរបានរៀបរៀង សមាជិកបានមូលមតិគ្នាហៅកន្សោមពាក្យផ្សារជាប់ កើតចេញពីការផ្គុំពាក្យខ្មែរនិងពាក្យខ្មែរ, ពាក្យខ្មែរនិងពាក្យបាលី/សំស្ក្រឹតដែលចូលស៊ុបក្នុងភាសាខ្មែរ ឬ ពាក្យបាលី/សំស្ក្រឹតនិងពាក្យបាលី/សំស្ក្រឹតដែលចូលស៊ុបក្នុងភាសាខ្មែរ ហើយ ដែលមានសម្ព័ន្ធបែបខ្មែរ ថាជា‘ពាក្យបន្សំ’, ឧ. ស្បែកជើង, ខ្មៅដៃ, អ្នកប្រាជ្ញ, ប្រវត្តិរូប, ទោសឧក្រិដ្ឋ,...។ ចំពោះ‘ពាក្យសមាស’វិញ សមាជិកនៃគណៈកម្មការដដែល បានមូលមតិគ្នាប្រើសម្រាប់សម្គាល់បណ្តុំដែលកើតចេញពីការផ្គុំពាក្យឬធាតុបាលី/សំស្ក្រឹតនិងពាក្យឬធាតុបាលី/សំស្ក្រឹត ហើយ ដែលមានសម្ព័ន្ធបែបបាលី/សំស្ក្រឹត, ឧ. រដ្ឋសភា, ធនាគារ, វិទ្យាល័យ,...។

លើកលែងតែក្នុងករណីកម្រដែលមានការវិវត្តឬក្នុងករណីកាឡារូប»។ ពាក្យ'កន្ទេចពាក្យ' ជាពាក្យខ្ចីពីលោក អៀវ កើស[10] ក្នុងន័យថា «ធាតុដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសាខ្មែរឬភាសាណាមួយ» : ដូច្នេះ ចំពោះក្រុមទី២នេះ ធាតុ'សាស្ត្រ', 'វិទ្យា'[11], 'វិទូ', 'ករ',... (ដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសាខ្មែរបច្ចុប្បន្ន) គឺជាផ្នត់ចុង/បច្ឆិមបទ។

ម្យ៉ាងទៀត បើយើងផ្អែកលើពាក្យឡាតាំង'mente' ដែលបានក្លាយមកជាបច្ឆិមបទបារាំង'-ment'[12] (ដោយបានបន្សល់ទុកនូវពាក្យកម្លាយ mental និង mentalité) យើងអាចគិតថា នៅពេលអនាគតណាមួយ ពាក្យខ្លះក្នុងចំណោមពាក្យ ដូចជា 'និយម', 'កម្ម', 'ភាព',... ដែលគេប្រើជាញឹកញាប់សម្រាប់ដាក់ខាងចុងនៃពាក្យសមាស(ដូចជា សង្គមនិយម, សេរីនិយម,... ទំនើបកម្ម, ពលកម្ម,... មិត្តភាព, សុខភាព,...) អាចក្លាយទៅជាផ្នត់ចុង/បច្ឆិមបទក៏មិនដឹង។

<u>កំណត់សម្គាល់</u> : ការខ្វែងគំនិតគ្នាលើបញ្ហាផ្នត់ចុង/បច្ឆិមបទគ្រាន់តែជាការបកស្រាយផ្សេងគ្នាតែប៉ុណ្ណោះ។ ក្នុងភាពជាក់ស្តែង ការបង្កើតពាក្យដោយប្រើធាតុ 'សាស្ត្រ', 'វិទ្យា', 'វិទូ', 'ករ',... អាចធ្វើទៅបានជាច្រើន ដោយងាយ តាមសេចក្តីត្រូវការ(ទោះមានការខ្វែងគំនិតគ្នាលើបញ្ហាផ្នត់ចុង/បច្ឆិមបទរវាងអ្នកអក្សរសាស្ត្រខ្មែរក៏ដោយ)។

## ២- <u>បញ្ហាកង្វះផ្នត់ដើម្បីធ្វើវិធីកម្លាយឱ្យបានសម្បូរណ៍បែប</u>

### ២.១- <u>កង្វះផ្នត់សម្រាប់បង្កើតកិរិយាសព្ទចេញពីនាម</u>

កង្វះផ្នត់សម្រាប់បង្កើតកិរិយាសព្ទចេញពីនាម ជាកង្វះដែលបានបណ្តាលឱ្យប្រភេទពាក្យមានភាព-ច្របូកច្របល់, ឧទាហរណ៍ :

- ពាក្យ'ឯកភាព'ដែលជានាម (ដូចមាន'ភាព'ខាងចុងជាស្លាកស្នាមស្រាប់) ក្រោយមកត្រូវបានប្រើជាកិរិយាសព្ទ[13] ហើយ បើគេចង់បាននាមគេត្រូវដាក់'ការ-'នៅខាងដើម គឺ'ការឯកភាព' ប៉ុន្តែគួរកត់សម្គាល់ថា ក្នុងបរិបទខ្លះ គេនៅប្រើពាក្យ'ឯកភាព'ជានាមនៅឡើយ។

  ជាទូទៅ ពាក្យដែលមាន'ភាព'នៅខាងចុងជានាម ដូចជា : សេរីភាព, សមភាព, ភាតរភាព, មេត្រីភាព, សាមគ្គីភាព, មិត្តភាព, សហគ្រិនភាព,...។ ការដែលនាម'ឯកភាព'បានប្រែក្លាយទៅជា

---

[10] - អៀវ កើស, ភាសាខ្មែរ បណ្ណាគារមិត្តសេរី ភ្នំពេញ ឆ្នាំ១៩៦៧ ទំព័រ១៦៨។

[11] - ភាសាខ្មែរប្រើ'វិទ្យា'ជាធាតុចុងពាក្យក្នុងពាក្យជាច្រើន ដូចជាគណិតវិទ្យា, ភូមិវិទ្យា, ភាសាវិទ្យា,...។ ក្រៅពីនេះ គេសង្កេតឃើញមានប្រើនៅដើមពាក្យដែរ ដូចជា វិទ្យាល័យ, វិទ្យាស្ថាន,... ប៉ុន្តែទោះយ៉ាងណាក៏គេមិនដែលប្រទះឃើញធាតុ'វិទ្យា'នេះ ប្រើជាពាក្យឯករាជ្យដូច'វិជ្ជា'នោះឡើយ។

[12] - ខ្ញុំបានគំនិតនេះពីលោក Walther V. Wartburg, Problèmes et Méthodes de la linguistique, PUF 1963, p.95។

[13]- ថ្វីបើគ្មានរូបសាស្ត្រអ្វីជាគ្រឿងសម្គាល់ គេអាចដឹងបានថាពាក្យ'ឯកភាព'ត្រូវគេប្រើជានាមឬជាកិរិយាសព្ទ គឺដោយសារសេម្ព័ន្ធ(ក្នុងឃ្លា) :
(១)- ប្រើជានាម : រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរនៅឆ្នាំ២០០៧ ដើម្បីឱ្យកេងកភាពជូនភាសាជាតិ;
(២)- ប្រើជាកិរិយាសព្ទ : អ្នកនយោបាយខ្មែរគួរឯកភាពគ្នាលើបញ្ហាជាតិចម្បងៗ។

កិរិយាសព្ទ‘ឯកភាព’ដោយឥតមានរូបសាស្ត្រអ្វីជាគ្រឿងសម្គាល់ បានធ្វើឱ្យប្រព័ន្ធរបស់នាមដែលមាន‘ភាព’នៅខាងចុងឈប់ជាប្រព័ន្ធទាំងស្រុង (ពីព្រោះកិរិយាសព្ទ‘ឯកភាព’ក៏មាន‘ភាព’នៅខាងចុងដែរ)។

- ពាក្យ‘ទំនាក់ទំនង’ជានាមកើតចេញពីកិរិយាសព្ទ‘ទាក់ទង’តាមរយៈផ្នត់ដែក [-ɔmn-] : teak (ទាក់) + [-ɔmn-] > tɔmneak (ទំនាក់) និង tɔːŋ (ទង) + [-ɔmn-] > tɔmnɔːŋ (ទំនង) ; (ទំនាក់ + ទំនង > ទំនាក់ទំនង)។ នាម‘ទំនាក់ទំនង’ត្រូវបានគេប្រើជាកិរិយាសព្ទ‘ទំនាក់ទំនង’ជំនួសកិរិយាសព្ទ‘ទាក់ទង’ ហើយ គេបានបង្កើតនាមថ្មី‘ការទំនាក់ទំនង’ដើម្បីជំនួសនាម‘ទំនាក់ទំនង’(ដែលត្រូវបានគេយកទៅប្រើជាកិរិយាសព្ទទៅហើយ)។

<u>កំណត់សម្គាល់</u> : ផ្ទុយពីពាក្យ‘ឯកភាព’ដែលត្រូវបានប្រើជាកិរិយាសព្ទស្ទើរតែទាំងស្រុងទៅហើយ ចំពោះពាក្យ‘ទំនាក់ទំនង’វិញ ការប្រើប្រាស់ជានាមក៏នៅមានគេប្រើជាញឹកញាប់នៅឡើយ។

- ពាក្យ‘ចំណាក’(ស្រុក) ជានាមកើតចេញពីកិរិយាសព្ទ‘ចាក’(ស្រុក)ត្រូវបានបង្កើតឡើងក្រោមតម្រូវការ។ ពាក្យនេះត្រូវបានគេប្រើស្របតាមប្រភេទរបស់វា, ឧ. ប្រជាពលរដ្ឋខ្មែរជាច្រើនបានធ្វើចំណាកស្រុកទៅប្រទេសក្រៅ មានប្រទេសថៃ, ប្រទេសម៉ាលេស៊ី ជាដើម។ ប៉ុន្តែសាធារណជនយកគំរូតាម ‘ទំនាក់ទំនង’ បានប្រើ‘ចំណាក’ជាកិរិយាសព្ទ, ឧ. ប្រជាពលរដ្ឋខ្មែរជាច្រើនបានចំណាកស្រុក[14]។

កង្វះផ្នត់សម្រាប់បង្កើតកិរិយាសព្ទចេញពីនាម តម្រូវឱ្យខ្មែរយើងយកនាមមកប្រើជាកិរិយាសព្ទដោយឥតមានរូបសាស្ត្រអ្វីជាគ្រឿងសម្គាល់តាំងពីយូរយារណាស់មកហើយ។ ក្រៅពីបីករណីដែលខ្ញុំបានលើកឡើង មានករណីជាច្រើនសន្ធឹកសន្ធាប់ទៀត ដូចមានក្នុងឧទាហរណ៍នេះជាដើម : ខ្ញុំបានទូរសព្ទទៅមិត្តខ្ញុំ; តើឯងបាយហើយឬនៅ?...

<u>សង្កេត</u> : លទ្ធភាពដែលគេអាចយកនាមទៅប្រើជាកិរិយាសព្ទ ដោយឥតមានរូបសាស្ត្រអ្វីជាគ្រឿងសម្គាល់នោះ អនុញ្ញាតឱ្យសាធារណជនប្រើនាមណាមួយដែលកើតចេញពីកិរិយាសព្ទណាមួយ ទៅជំនួសកិរិយាសព្ទនោះឯង ដូចនាម ‘ទំនាក់ទំនង’ប្រើជាកិរិយាសព្ទជំនួសកិរិយាសព្ទ‘ទាក់ទង’(ដែលជាប្រភពនៃ‘ទំនាក់ទំនង’) : ការប្រើបែបនេះនាំឱ្យមានភាពច្របូកច្របល់។

---

14 - កិរិយាសព្ទ‘ឯកភាព’ដែលបានកើតចេញពីនាម‘ឯកភាព’ មិនបានយកកន្លែងកិរិយាសព្ទណាមួយដែលជាប្រភពនៃនាម‘ឯកភាព’នោះទេ : ផ្ទុយពីនេះ កិរិយាសព្ទ‘ទំនាក់ទំនង’ និង កិរិយាសព្ទ‘ចំណាក(ស្រុក)’,... បាន ជាលំដាប់លំដោយ យកកន្លែងនៃកិរិយាសព្ទ‘ទាក់ទង’ និង កិរិយាសព្ទ‘ចាក(ស្រុក)’។

សំណូមពរ : បើអ្នកអក្សរសាស្ត្រណាយល់ថា ករណីដែលខ្ញុំបានលើកឡើងនេះជាបញ្ហាពិតមែន សូមអស់លោកជួយរកដំណោះស្រាយនិងធ្វើសំណើជាសាធារណៈ ដើម្បីឱ្យអ្នកអក្សរសាស្ត្រឯទៀតពិចារណានិងធ្វើការទិតៀនស្ថាបនា(គាំទ្រឬប្រានចោល)។

## ២.២- **កង្វះផ្នត់សម្រាប់បង្កើតគុណនាមចេញពីនាម**

កង្វះផ្នត់សម្រាប់បង្កើតគុណនាមចេញពីនាម មិនបានបណ្តាលឱ្យមានភាពច្របូកច្របល់ដូចកង្វះផ្នត់សម្រាប់បង្កើតកិរិយាសព្ទចេញពីនាមទេ : ភាសាខ្មែរប្រើនាមក្នុងមុខងារជាកម្ម/កម្មបទសម្រាប់ផ្តល់លក្ខណៈឱ្យនាមមួយទៀត, ឧទាហរណ៍ :

- ‘ក្រុមប្រឹក្សាធម្មនុញ្ញ’ដែលក្នុងនោះ‘ក្រុមប្រឹក្សា’និង‘ធម្មនុញ្ញ’ជានាមទាំងពីរ ហើយ មួយជាពាក្យគោល មួយទៀតជាកម្ម/កម្មបទ;
- ‘សុវត្ថិភាពស្បៀង’ដែលក្នុងនោះ‘សុវត្ថិភាព’ជានាមគោលនិង‘ស្បៀង’ជានាមដែរ ដែលមានមុខងារជាកម្ម/កម្មបទ;
- ‘សមាជជាតិ’ដែលក្នុងនោះ‘សមាជ’និង‘ជាតិ’ជានាមទាំងពីរ ហើយ មួយជាពាក្យគោល មួយទៀតជាកម្ម/កម្មបទ។

ប៉ុន្តែ លោក តិប យក់ និង ថាវ គន្ធ អ្នកដែលតាក់តែងវចនានុក្រមបារាំង-ខ្មែរ បានប្រែគុណនាមបារាំង‘subjectif’ថា‘អត្តវិស័យ’, នាម‘subjectivité’ថា‘អត្តវិស័យភាព’ និង នាម‘objectivité’ថា‘វត្ថុវិស័យ-ភាព’។ តាមរយៈពាក្យទាំងនេះ យើងអាចវិភាគឃើញថា អ្នកវចនានុក្រមយើង បានប្រើពាក្យ‘វិស័យ’ដើម្បីបង្កើតគុណនាមចេញពីធាតុ‘អត្ត’និងនាម‘វត្ថុ’។

កំណត់សម្គាល់ : ក្នុងប្រធានបទនៃឮាថកថារបស់ខ្ញុំ ខ្ញុំបានប្រើបណ្តុំពាក្យ[15] ‘សទិសសូរវេយ្យាករណ៍វិស័យ’ ពីព្រោះខ្ញុំចង់ប្រើគុណនាម‘វេយ្យា-ករណ៍វិស័យ’វិញម្តង ដោយយកលំនាំតាមអត្តវិស័យ, អត្តវិស័យភាព, វត្ថុវិស័យភាព របស់លោក តិប យក់ & ថាវ គន្ធ (បើខ្ញុំប្រើ‘សទិសសូរវេយ្យាករណ៍’ដែលមាន‘វេយ្យាករណ៍’ជាកម្មបទនោះ ក៏បានដែរ)។

## ២.៣- **កង្វះផ្នត់សម្រាប់បង្កើតនាមចេញពីគុណនាម ដើម្បីសម្គាល់គុណភាព**

ដូចកង្វះផ្នត់សម្រាប់បង្កើតគុណនាមចេញពីនាមដែរ(មើលចំណុច២.២) កង្វះផ្នត់សម្រាប់បង្កើតនាមចេញពីគុណនាម មិនបានបណ្តាលឱ្យមានភាពច្របូកច្របល់ដូចកង្វះផ្នត់សម្រាប់បង្កើតកិរិយាសព្ទចេញពីនាមទេ(មើលចំណុច២.១) ប៉ុន្តែកន្សោមពាក្យ ដូចជា ពណ៌ខ្មៅ, ពណ៌ក្រហម,... ជាតុត្រជាក់, ជាតុ

[15] - ខ្ញុំប្រើ‘បណ្តុំពាក្យ’ ក្នុងន័យទូលាយជាង‘កន្សោមពាក្យ’(‘កន្សោមពាក្យ’ក៏ជា‘បណ្តុំពាក្យ’ដែរ)។ ខ្ញុំគិតថា ក្នុងបណ្តុំ‘សទិសសូរវេយ្យា-ករណ៍វិស័យ’ ‘វិស័យ’ដែលបានធ្វើឱ្យបណ្តុំ‘វេយ្យាករណ៍វិស័យ’មានលក្ខណៈជាគុណនាមនោះ ដើរតួជាបច្ច័មបទមួយបែប(យកលំនាំតាមអត្តវិស័យ, អត្តវិស័យភាព, វត្ថុវិស័យភាព នៃវចនានុក្រមបារាំង-ខ្មែររបស់លោក តិប យក់ & ថាវ គន្ធ)។

ក្តៅ,... ដែលក្នុងនោះ សព្ទខាងដើមនៃកន្សោមពាក្យ ជាសព្ទផ្សេងគ្នាតាមករណី ហើយ ដែលគួរតែជាសព្ទអរូបីតែមួយដែលធ្វើគុណនាមឱ្យទៅជានាមសម្គាល់គុណភាព។ ឧទាហរណ៍ទាំងនេះ បង្ហាញឱ្យឃើញថា ភាសាខ្មែរនៅមានកង្វះខាតក្នុងការបង្កើតនាមចេញពីគុណនាមដើម្បីសម្គាល់គុណភាពនៅឡើយ ពីព្រោះមិនទាន់មានសព្ទអរូបីតែមួយណាមួយសម្រាប់បង្កើតនាមចេញពីគុណនាមដើម្បីសម្គាល់គុណភាពទេ។

បញ្ជាក់ : ការលើកឡើងនូវចំណុចខ្វះខាតមួយចំនួនក្នុងភាសាខ្មែរ ឥតមានន័យថា ភាសានេះជាភាសាខ្សត់ខ្សោយនោះឡើយ : ភាសាណាក៏មានកង្វះខាតដែរ។ ដោយភាសាខ្មែរបានរីកចម្រើនជាច្រើន ជាពិសេសចាប់ពីប្រទេសខ្មែរមានឯករាជ្យ[16]មក ខ្ញុំសង្ឃឹមថាភាសានេះនឹងបន្តការរីកចម្រើន ហើយ កង្វះខាតនឹងត្រូវបានកាត់បន្ថយបន្តិចម្តងៗជាលំដាប់។

## ៣- បញ្ហាវិសាលភាពតូចចង្អៀតនៃផ្នត់មួយចំនួន

### ៣.១- សក្ខីភាព

ផ្នត់ទាំងប៉ុន្មាន ដែលយើងបានឃើញក្នុងឧទាហរណ៍នៅចំណុច១.១ ប្រើបានតែជាមួយពាក្យដើម (ពាក្យដែលជាប្រភពនៃពាក្យកម្លាយ) ដែលកើតចេញពីព្យញ្ជនៈទោល (លើកលែងតែផ្នត់[-ɑm-/-ɔm-])។

កាលណាពាក្យដើមកើតចេញពីកន្សោមព្យញ្ជនៈ (ព្យញ្ជនៈ + ព្យញ្ជនៈ) ផ្នត់ដែក[-ɑmn-/-ɔmn-] សម្រាប់បង្កើតនាមកម្លាយសម្គាល់លទ្ធផល, ផ្នត់ដែក[-n-]សម្រាប់បង្កើតនាមកម្លាយសម្គាល់ឧបករណ៍និង ផ្នត់ដើមទាំងប៉ុន្មានសម្រាប់បង្កើតកិរិយាហេតុ ត្រូវបានជំនួសដោយផ្នត់ដែក[-ɑm-/-ɔm-]តែមួយ។

កំណាត់សម្គាល់ : ផ្នត់ដែក[-m-]ឥតត្រូវបានជំនួសដោយផ្នត់ណាមួយទេ ប៉ុន្តែ តាមភាពជាក់ស្តែង គេបានប្រើវាតែក្នុងពាក្យមួយចំនួនតូចប៉ុណ្ណោះ។

### ៣.២- លទ្ធភាពពង្រីកវិសាលភាព

យើងទើបបានឃើញថា កាលណាពាក្យដើមកើតចេញពីកន្សោមព្យញ្ជនៈ ផ្នត់ដែក[-ɑmn-/-ɔmn-] សម្រាប់បង្កើតនាមកម្លាយសម្គាល់លទ្ធផល, ផ្នត់ដែក[-n-]សម្រាប់បង្កើតនាមកម្លាយសម្គាល់ឧបករណ៍ និង ផ្នត់ដើមទាំងប៉ុន្មានសម្រាប់បង្កើតកិរិយាហេតុសម្គាល់ន័យថា«ធ្វើឱ្យ» ត្រូវបានជំនួសដោយផ្នត់ដែក [-ɑm-/-ɔm-]តែមួយ។

ប៉ុន្តែ ទោះបីក្នុងករណីនៃពាក្យដើមដែលកើតចេញពីកន្សោមព្យញ្ជនៈក៏ដោយ ក៏បុព្វបុរសយើងបានបន្សល់ទុកនូវពាក្យខ្លះៗដែរ ដែលក្នុងនោះផ្នត់ដែក[-n-]សម្រាប់បង្កើតនាមកម្លាយសម្គាល់ឧបករណ៍និង

[16] - នៅថ្ងៃពុធ ២១-០៥-២០១៤ ក្រុមប្រឹក្សាជាតិភាសាខ្មែរបានអនុម័តទទួលយកពាក្យ‘អធិបតេយ្យភាព’ ដោយអនុលោមតាមទំនោរនៃភាសាខ្មែរបច្ចុប្បន្ន (ដោយមិនយកតាមក្បួនវេយ្យាករណ៍បាលីនិងន័យដើមទាំងស្រុងទេ)។ ពិតមែនហើយ តាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ‘អធិបតេយ្យភាព’ មានន័យថា «ភាពនៃភាពនៃ...ជាអធិបតី» ប៉ុន្តែពាក្យ‘តម្លាភាព’ក៏មានន័យត្រួតដូចនេះដែរ គឺ«ភាពនៃភាពថ្លា»។ សព្វថ្ងៃ មានគេប្រើជាញឹកញយនូវ ពាក្យ‘អធិបតេយ្យភាព’ជានាម ជំនួសនាម‘អធិបតេយ្យ’(ដែលត្រូវបានប្រើជាគុណនាមវិញ), ‘ឯករាជ្យភាព’ជានាម ជំនួសនាម‘ឯករាជ្យ’(ដែលត្រូវបានប្រើជាគុណនាមវិញ),... ពីព្រោះភាសាខ្មែរកំពុងវិវត្តឆ្ពោះទៅរកទម្រង់បែបខ្មែរ។

ផ្នត់ដើមនានាសម្រាប់បង្កើតកិរិយាកម្លាយសម្គាល់ន័យថា«ធ្វើឱ្យ»(កិរិយាហេតុ) មិនត្រូវបានជំនួសដោយផ្នត់ដែក[-ɑm-/-ɔm-]ទេ គឺ :

- ក្នុងនាមកម្លាយសម្គាល់ឧបករណ៍ : ទ្រាប់ > ទ្រនាប់(មានផ្នត់[-n-]) ;
- ក្នុងកិរិយាកម្លាយសម្គាល់ន័យថា«ធ្វើឱ្យ» : គ្រប់ > បង្គ្រប់(មានផ្នត់[bɑŋ-]), ជ្រាប > បញ្ជ្រាប (មានផ្នត់[bɑɲ-]), ភ្លឺ > បំភ្លឺ(មានផ្នត់[bɑm-]),...។

ឧទាហរណ៍ខាងលើអនុញ្ញាតឱ្យយើងពង្រីកវិសាលភាពនៃផ្នត់ដែក[-n-]និងផ្នត់ដើមនានាសម្រាប់បង្កើតកិរិយាហេតុ តាមរយៈពាក្យថ្មីៗដែលសេចក្ដីត្រូវការតម្រូវឱ្យយើងបង្កើតឡើង។

ម្យ៉ាងទៀត យើងក៏បានសង្កេតឃើញថា តាមរយៈពាក្យផ្គុំ[17] វិសាលភាពនៃផ្នត់មួយចំនួនត្រូវបានពង្រីកបណ្ដើរៗ, ឧទាហរណ៍ :

- ផ្នត់[-ɑmn-/-ɔmn-]តាមរយៈពាក្យ'ទាក់ទង'បង្កើតបានពាក្យ'ទំនាក់ទំនង'...;
- ផ្នត់[-ɑm-/-ɔm-]តាមរយៈពាក្យ'ប្រែប្រួល'បង្កើតបានពាក្យ'បម្រែបម្រួល'[18]...;
- ផ្នត់បម្រុះ[-b-]និង[-ɑm-/-ɔm-]តាមរយៈពាក្យ'រកឃើញ'បង្កើតបានពាក្យ'របកគំហើញ'...។

## ៤- បញ្ហាសទិសសូរវេយ្យាករណ៍វិស័យ

### ៤.១- និយមន័យនិងបម្រើបម្រាស់នៃ'សទិសសូរវេយ្យាករណ៍វិស័យ'

សទិសសូរវេយ្យាករណ៍វិស័យ គឺជាការប្រើផ្នត់ដូចគ្នា(សទិសសូរ)[19] ឬ បើនិយាយឱ្យងាយយល់ គឺផ្នត់ដដែល/តែមួយសម្រាប់បង្កើតពាក្យកម្លាយដែលសម្គាល់បញ្ញត្តិផ្សេងគ្នា ហើយ ជួនកាលសម្គាល់ប្រភេទពាក្យផ្សេងគ្នាផងទៀត។ សទិសសូរវេយ្យាករណ៍វិស័យដែលខ្ញុំនឹងលើកមកបង្ហាញនៅពេលនេះ គឺសទិស-សូរវេយ្យាករណ៍វិស័យ[-ɑm-/-ɔm-]ដែលមានការប្រើជាន់គ្នាដូចខាងក្រោម :

(១)- ប្រើសម្រាប់បង្កើតនាមសម្គាល់លទ្ធផល : krɑːŋ(ក្រង) + [-ɑm-] > kɑmrɑːŋ(កម្រង), krọŋ (គ្រោង) + [-ɔm-] > kɔmrọŋ(គម្រោង);

(២)- ប្រើសម្រាប់បង្កើតនាមសម្គាល់ឧបករណ៍ : trɑːŋ(ត្រង) + [-ɑm-] > tɑmrɑːŋ(តម្រង), krɔːp (គ្រប) + [-ɔm-] > kɔmrɔːp(គម្រប);

(៣)- ប្រើសម្រាប់បង្កើតកិរិយាហេតុសម្គាល់ន័យថា«ធ្វើឱ្យ» : trœm(ត្រឹម) + [-ɑm-] > tɑmrœm (តម្រឹម), thlus(ធ្លុះ) + [-ɔm-] > thɔmlus > tɔmlus(ទម្លុះ)។

---

[17] - ខ្ញុំគិតថា ពាក្យដូចជា ទាក់ទង, ប្រែប្រួល, រកឃើញ,... មិនមែនជាពាក្យបន្សំទេ : ខ្ញុំសុំប្រើបណ្ដោះអាសន្ននូវ«ពាក្យផ្គុំ»នេះ។

[18] - ក្រៅពីការធ្វើកម្លាយទៅលើព្យាង្គទាំងពីរដូចមានក្នុងឧទាហរណ៍ខាងលើ យើងក៏សង្កេតឃើញមានការធ្វើកម្លាយតែទៅលើព្យាង្គទី១ដែរ ដូចជា ដោះស្រាយ > ដំណោះស្រាយ, ខ្វះខាត > កង្វះខាត ជាដើម។

[19] - និយមន័យនេះ ផ្ដោតលើ'សទិសសូរវេយ្យាករណ៍វិស័យ'ទាំងមូល មិនសង្កត់តែលើ'សទិសសូរ'ដែលគេបានស្គាល់ជាទូទៅនោះទេ។

<u>សង្កេត</u> :

(១)- ក្រៅពីការប្រើផ្នត់ជែក[-ɑm-/-ɔm-]ដើម្បីបង្កើតកិរិយាហេតុដូចខ្ញុំទើបបានលើកឡើងខាងលើ(ដែលជាហេតុនាំឱ្យមានសទិសសូរវេយ្យាករណ៍វិស័យ) បុព្វបុរសខ្មែរក៏បានប្រើផ្នត់ដើម[bɑŋ-], [bɑɲ-], [bɑm-],... ដើម្បីបង្កើតកិរិយាហេតុចេញពីពាក្យដើមដែលមានទម្រង់ជាកន្សោមព្យញ្ជនៈ(ព្យញ្ជនៈ + ព្យញ្ជនៈ)ដែរ, ឧ. គ្រប់ > បង្គ្រប់, ជ្រាប > បញ្ជ្រាប, ត្លី > បំត្លី,...។ វិធីកម្លាយបែបនេះអាចបញ្ចៀសការប្រើផ្នត់ជែក[-ɑm-/-ɔm-] ដើម្បីបង្កើតកិរិយាហេតុ។

(២)- ចំពោះពាក្យកម្លាយសម្គាល់ឧបករណ៍កើតចេញពីពាក្យដើមដែលមានទម្រង់ជាកន្សោមព្យញ្ជនៈ(ព្យញ្ជនៈ + ព្យញ្ជនៈ ឬ សញ្ញាព្យញ្ជនៈផ្ញើជើង) បុព្វបុរសយើងក៏បានបន្សល់ទុកនូវពាក្យ‘ទ្រនាប់’(កើតចេញពី‘ទ្រាប់’)ផងដែរ។ តាមរយៈពាក្យ‘ទ្រនាប់’នេះ យើងអាចបង្កើតពាក្យកម្លាយសម្គាល់ឧបករណ៍ដោយមិនប្រើផ្នត់ជែក[-ɑm-/-ɔm-][20] (ដើម្បីចៀស‘សទិសសូរវេយ្យាករណ៍វិស័យ’)។

<u>កំណត់សម្គាល់</u> : ក្រៅពីផ្នត់ជែក[-ɑɑm-/-ɔm-] យើងក៏សង្កេតឃើញមានសទិសសូរវេយ្យាករណ៍វិស័យតាមរយៈផ្នត់ដើម[រ-] ផងដែរ។ ផ្នត់ដើម[រ-] នេះ ប្រើសម្រាប់បង្កើតពាក្យកម្លាយសម្គាល់ឧបករណ៍ផង និង សម្រាប់បង្កើតកិរិយាសព្ទអកម្មអត្តផល[21]ចេញពីកិរិយាសព្ទសកម្មផង, ឧទាហរណ៍ :

- ឧបករណ៍ : [រ-] + បុក > របុក[22] (ប្រដាប់សម្រាប់បុក, សម្រាប់រុកក្នុងរណ្ដៅ,...), (វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត)។
- កិរិយាសព្ទអកម្មអត្តផល : [រ-] + បើក > របើក។

ប៉ុន្តែសទិសសូរវេយ្យាករណ៍វិស័យតាមរយៈផ្នត់ដើម[រ-] នេះ មិនបានបណ្ដាលឱ្យមានបញ្ហាស្មុគស្មាញដូចសទិសសូរវេយ្យាករណ៍វិស័យតាមរយៈផ្នត់ជែក[-ɑɑm-/-ɔm-] នោះទេ។

## ៤.២- <u>**ការវិភាគ**</u>

យើងសង្កេតឃើញថា :

- ផ្នត់[-ɑm-/-ɔm-] ក្នុងពាក្យកម្លាយ(១)និង(២) សម្គាល់បញ្ញត្តិប្លែកគ្នា តែប្រភេទពាក្យដូចគ្នា (នាមដូចគ្នា);
- ក្នុង(៣) ផ្នត់ដដែលនេះសម្គាល់បញ្ញត្តិប្លែកពីបញ្ញត្តិដែលមានក្នុង(១)និង(២)ផង និង សម្គាល់ប្រភេទពាក្យប្លែកពីប្រភេទពាក្យដែលមានក្នុង(១)និង(២)ផង : (៣)សម្គាល់កិរិយាហេតុ ផ្ទុយពី(១)និង(២)ដែលសម្គាល់នាម។

---

[20] - ក្នុងករណីដែលអាចធ្វើបានដោយឥតមានបញ្ហាបែបណាមួយ។

[21]- ខ្ញុំប្រើពាក្យ‘អត្តផល’នេះសម្រាប់សម្គាល់កិរិយាសព្ទអកម្មមួយប្រភេទដែលកើតចេញពីកិរិយាសព្ទសកម្ម តាមរយៈផ្នត់ដើម[រ-]នេះឯង ដូចជា [រ-] + បើក(កិរិយាសព្ទសកម្ម) > របើក(កិរិយាសព្ទអកម្ម) ជាដើម។ កម្មបទផ្ទាល់របស់កិរិយាសព្ទសកម្មដែលរងអំពើត្រូវក្លាយជាប្រធាននៃកិរិយាសព្ទអកម្ម ហើយ ធ្វើអំពើខ្លួនឯងម្ដង, ឧ. គេបើកគម្របផ្ទាំង > គម្របផ្ទាំងរបើក(ខ្លួនឯង)។

[22] - តាមធម្មតា ខ្ញុំកត់ត្រាពាក្យខ្មែរដោយប្រើAPI ដោយដាក់ពាក្យខ្មែរជាអក្សរខ្មែរក្នុងវង់ក្រចក ប៉ុន្តែ ក្នុងករណីនេះ(ដូចករណីមួយចំនួនទៀត) ខ្ញុំប្រើតែអក្សរខ្មែរ ពីព្រោះការប្រើតែអក្សរខ្មែរជាការគ្រប់គ្រាន់និងឱ្យផលល្អ។

**<u>សេចក្ដីសន្និដ្ឋាន</u>**

យើងមិនអាចមិនទទួលស្គាល់ថា ភាសាខ្មែរមានការរីកចម្រើនជាច្រើននោះឡើយ។ ប៉ុន្តែខ្ញុំគ្រាន់តែលើកឡើងនូវចំណុចខ្វះខាតមួយចំនួនដើម្បីទាញអារម្មណ៍សាធារណជនទាំងឡាយលើកង្វះខាតទាំងនោះ ក្រែងអស់លោកយល់ដូចខ្ញុំដែរ ហើយ ព្យាយាមដោះស្រាយនិងធ្វើបែបណាឱ្យភាសាខ្មែរយើងកាន់តែប្រសើរឡើង។

ក្នុងចំណោមកង្វះផ្នត់សម្រាប់ធ្វើវិធីកម្លាយក្នុងភាសាខ្មែរឱ្យមានសម្បូរណ៍បែបនោះ កង្វះផ្នត់សម្រាប់ធ្វើឱ្យកិរិយាសព្ទកម្លាយមានរូបសាស្ត្រប្លែកពីពាក្យដើមដែលជានាមនោះ ជាបញ្ហាចម្បង ហើយ ខ្ញុំឥតបានឃើញតម្រុយអ្វីដើម្បីលើកឡើងជាសំណើទេ : សូមសាធារណជនជួយពិចារណារកដំណោះស្រាយផង បើអស់លោកគិតថា កង្វះខាតនេះជាបញ្ហាពិតប្រាកដមែន។

ចំពោះវិសាលភាពតូចចង្អៀតនៃផ្នត់មួយចំនួន ខ្ញុំគិតថា បើយើងពង្រីកវាឬបន្តពង្រីក គឺជាការល្អ ដោយយកលំនាំតាម បង្គ្រប់, បញ្ជ្រាប, ទ្រនាប់, របកគំហើញ, បម្រើបម្រាស់, ដំណោះស្រាយ, ទំនុកចិត្ត ជាដើម។

ចំពោះបញ្ហាសទិសសូរវេយ្យាករណ៍វិស័យ យើងអាចមានដំណោះស្រាយ បើសាធារណជនទាំង-ឡាយព្រមទទួលយកសំណើដូចតទៅនេះ[23] :

- ឈប់ប្រើផ្នត់ដែក[-ɑm-/-ɔm-]សម្រាប់បង្កើតនាមកម្លាយសម្គាល់ឧបករណ៍ចេញពីពាក្យដើមដែលកើតឡើងពីកន្សោមព្យញ្ជនៈ គឺឈប់យកលំនាំតាម ‘គ្រប > គម្រប’ ហើយ បែរទៅយកលំនាំតាម ‘ទ្រាប់ > ទ្រនាប់’វិញ;
- ឈប់ប្រើផ្នត់ដែក[-ɑm-/-ɔm-]សម្រាប់បង្កើតកិរិយាសព្ទកម្លាយសម្គាល់ន័យថា«ធ្វើឱ្យ» គឺកិរិយាហេតុចេញពីពាក្យដើមដែលកើតឡើងពីកន្សោមព្យញ្ជនៈ គឺឈប់យកលំនាំតាម ‘គ្រប់ > គម្រប់’, ‘ត្រឹម > តម្រឹម’,... ហើយ បែរទៅយកលំនាំតាម ‘គ្រប់ > បង្គ្រប់’, ‘ជ្រាប > បញ្ជ្រាប’, ‘ភ្លឺ > បំភ្លឺ’,... វិញ។

ដូច្នេះផ្នត់ដែក[-ɑm-/-ɔm-]ត្រូវប្រើតែសម្រាប់បង្កើតនាមកម្លាយកើតចេញពីពាក្យដើមដែលមានទម្រង់ជាកន្សោមព្យញ្ជនៈ ដើម្បីសម្គាល់លទ្ធផល ដូចជា ក្ដៅ > កម្ដៅ, គ្រោង > គម្រោង,...។

<u>កំណត់សម្គាល់</u> : សំណើខាងលើផ្អែកលើគំរូដ៏រឹងមាំដែលមានក្នុងភាសាខ្មែរ។ រីឯបណ្ដុំដូចជា អត្ថវិស័យ, អត្ថវិស័យតាព, វត្ថុវិស័យតាព ដែលក្នុងនោះ‘វិស័យ’បានធ្វើ‘អត្ថ’និង‘វត្ថុ’ឱ្យមានលក្ខណៈជាគុណនាមនោះ វាគ្រាន់តែជាបម្រើបម្រាស់របស់អ្នករៀបរៀងវចនានុក្រមបារាំង-ខ្មែរពីរនាក់ប៉ុណ្ណោះ។ ខ្ញុំបានយកលំនាំតាមពួកគាត់ ដោយបានប្រើបណ្ដុំ‘វេយ្យាករណ៍វិស័យ’និង‘សូរវិស័យ’ : បើអ្នកអក្សរសាស្ត្រឯទៀតសម្រេចបែបណាៗនោះ ស្រេចតែពួកគាត់ទៅចុះ។

[23] - សំណើទាំងប៉ុន្មានទាក់ទងតែនឹងពាក្យដែលត្រូវបង្កើតថ្មីទេ (យើងមិនត្រូវប៉ះពាល់ដល់ពាក្យដែលមានរួចមកហើយនោះឡើយ)។

ខ្ញុំសង្ឃឹមថា ការពិចារណាខាងលើ អាចជាគម្រុយឬជាចលករដែលអាចជំរុញអ្នកអក្សរសាស្ត្រឯទៀតឱ្យចង់សិក្សាឡើងវិញឬសិក្សាបន្តអំពីបម្រើបម្រាស់នៃផ្នត់ក្នុងភាសាខ្មែរ។ បើមានការភាន់ច្រឡំនិង/ឬកង្វះខាតក្នុងការពិចារណានេះ សូមអ្នកអក្សរសាស្ត្រខ្មែរទាំងឡាយជួយកែតម្រូវនិង/ឬបន្ថែមបង្គ្រប់ផង។

## គន្ថនិទ្ទេស


- កេង វ៉ាន់សាក់, មូលភាពនៃការបង្កើតពាក្យថ្មី ភាគទី១ ទ្រឹស្ដី បណ្ណាគារស្មេរកម្ពុជា ១៩៦៤ ;
- គណៈកម្មការភាសាវិទ្យានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ, សៀវភៅវេយ្យាករណ៍ភាសាខ្មែរ កម្រិតមធ្យម សម្រាប់ការប្រើប្រាស់ទូទៅ, បោះពុម្ពលើកទី១ ឆ្នាំ២០១៨ នៅរោងពុម្ពជី.អ៊ី.ធី. ប៊ីហ្សនេស ផ្ទះលេខ ២៣២០ ផ្លូវ៤៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ;
- ច័ន្ទ សំណព្វ, បង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ, រាជបណ្ឌិត្យសភាកម្ពុជា ២០១០ ;
- ពូវ អ៊ុម, វេយ្យាករណ៍ខ្មែរ, បណ្ណាគារ គឹម សេង ភ្នំពេញ ១៩៥៨ ;
- ព្រុំ ម៉ល់, វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប ភាគទី២ : អំពីសព្ទនិងពាក្យ (មានកិច្ចសហការពី កែវ លីណែត, វ៉ាន់ ម៉ូន, ក. អ៊ីង ម៉ាល័យ) ផ្សព្វផ្សាយដោយអ្នកនិពន្ធ ២០០៦ ;
- ព្រុំ ម៉ល់, «លទ្ធភាពបង្កើតពាក្យនិងការបង្កើតពាក្យ ក្នុងភាសាខ្មែរ», បទអន្តរាគមន៍ក្នុងសមាជជាតិស្តីពីការស្រាវជ្រាវក្នុងភាសាខ្មែរ រៀបចំដោយវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលបានប្រព្រឹត្តទៅ នៅភ្នំពេញ ពីថ្ងៃទី៧ ដល់ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០០, ចុះផ្សាយក្នុងទស្សនាវដ្ដីលេខ២ ខែមិថុនា ឆ្នាំ២០០១ របស់វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ;
- ព្រុំ ម៉ល់, «វិភាគសង្ខេប អំពីទម្រង់ភាសាខ្មែរ» កែសម្រួលបន្ថែមបង្គ្រប់ និង ចុះផ្សាយឡើងវិញ ក្នុងទស្សនាវដ្ដី លេខ១ នៃវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០០ ;
- អៀវ កើស, ភាសាខ្មែរ ការល្បងពិនិត្យដោយរកហេតុផល, បណ្ណាគារមូលមិត្ត ភ្នំពេញ ១៩៦៧។

# តើត្រូវលើកកម្ពស់និងពង្រឹងគុណភាពអប់រំគណិតវិទ្យានៅកម្ពុជា យ៉ាងដូចម្តេចដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤

**បណ្ឌិតសភាចារ្យ ច័ន្ទ រ័ត្ន** croath909@gmail.com, 011697038

**មូលន័យសង្ខេប៖** ព្រះរាជាណាចក្រកម្ពុជាជាប្រទេសមួយដែលមានអតីតកាលរុងរឿង និងធ្លាប់ជាអាណាចក្រខ្មែរអស់រយៈពេលជិត៦០០ឆ្នាំកាលពីជាង១០០០ឆ្នាំមុន។ ប៉ុន្តែក្រោយមកកម្ពុជាមានវិបត្តិទំនាស់ផ្ទៃក្នុងមានសង្គ្រាមរ៉ាំរ៉ៃជាមួយប្រទេសជិតខាងជាបន្តបន្ទាប់ ធ្វើឱ្យកម្ពុជាធ្លាក់ចុះខ្សោយបន្តិចម្តងៗរហូតដល់ធ្លាក់ខ្លួន នៅក្រោមអាណានិគមនិយមបារាំងជិត១០០ឆ្នាំ គឺចាប់តាំងពីឆ្នាំ១៨៦៣ រហូតដល់ឆ្នាំ១៩៥៣។ បន្ទាប់មកមានសន្តិភាពរយៈពេល១៥ឆ្នាំក៏ធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិលម្តងទៀត ចាប់ពីឆ្នាំ១៩៧០ ហើយឆ្លងកាត់សម័យកាលវិនាសកម្មរយៈពេលបីឆ្នាំប្រាំបីខែនិងម្ភៃថ្ងៃ ក្នុងរបបវាលពិឃាតកម្ពុជាប្រជាធិបតេយ្យ ហើយបានរស់ឡើងវិញនៅថ្ងៃទី៧ខែមករាឆ្នាំ១៩៧៩។ ចាប់ផ្តើមកសាងប្រទេសជាតិឡើងវិញពីបាតដៃទទេ ក្រោមជំនួយឧបត្ថម្ភពីប្រទេសវៀតណាមនិងសភាពសូវៀត។ រហូតមកដល់ឆ្នាំ១៩៩៣ទើបកម្ពុជាមានការឯកភាពជាតិពីគ្រប់ភាគីពាក់ព័ន្ធរួបរួមគ្នាជាព្រះរាជាណាចក្រកម្ពុជាទី២ ក្រោមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ។

បច្ចុប្បន្ននេះកម្ពុជាកំពុងតែ សម្លឹងមើលទៅអនាគតឆ្ពោះទៅរកសង្គមពុទ្ធិ ប្រកបដោយវិបុលភាពនាឆ្នាំ២០៣០ និងឆ្នាំ២០៥០ ដោយមានក្តីស្រម៉ៃ និងមានចក្ខុវិស័យចង់ក្លាយជាប្រទេស មានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសជឿនលឿនមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចនូវគោលដៅនេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិជាដំណាក់កាលតាមនីតិកាលនៃរដ្ឋសភាជាតិ ដែលបច្ចុប្បន្ននេះឈានដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា។ រាជរដ្ឋាភិបាលបានដាក់ចេញនូវឯកសារគោលនយោបាយ ដូចជា ៖ (១) គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ សំដៅតម្រង់ទិសទីផ្សារនិងបង្កើតលក្ខខណ្ឌអំណោយផលដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម, (២) គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ឆ្នាំ២០២០, (៣) ផែនការមេជាតិស្តីពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២០១៤-២០២០ សម្រាប់កំណើន និងគុណភាព នៃជីវិត, ហើយ(៤) ក្នុងពេលខាងមុខនឹងដាក់ចេញឱ្យអនុវត្តផងដែរនូវ "គោលនយោបាយ និងទិសដៅនៃសេដ្ឋកិច្ចឌីជីថលកម្ពុជា" ក្នុងគោលដៅធានាបានជោគជ័យនូវការជំរុញ និងអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងឌីជីថល នៅកម្ពុជា។

ឆ្លើយតបទៅនឹងនិន្នាការនេះ ដោយមានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ សម្រាប់ការជំរុញ និងអភិវឌ្ឍការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យ អប់រំ យុវជន និងកីឡា ជាពិសេសការអនុវត្តគោលនយោបាយសំខាន់ៗ ដូចជា៖ (១) គោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ(២) គោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម), (៣) គោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី, (៤). គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងវិស័យអប់រំ, (៥).គោលនយោបាយ និងផែនការសកម្មភាពស្តីពីគ្រូបង្រៀន, និង(៦) ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន។

ដោយឡែកការអប់រំគណិតវិទ្យានៅកម្ពុជានៅមានកម្រិត តើត្រូវលើកកម្ពស់និងពង្រឹងគុណភាពអប់រំគណិតវិទ្យានៅកម្ពុជាយ៉ាងដូចម្តេចដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤.០?

**ពាក្យគន្លឹះ៖** បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤, កំណែទម្រង់វិស័យអប់រំ, គន្លងអាជីពគ្រូបង្រៀន, ការអប់រំគណិតវិទ្យា

## ១. បដិវត្តន៍ឧស្សាហកម្មជំនាន់ទី ៤.0 ជាអ្វី?

បើយោងតាមប្រវត្តិសាស្ត្រទំនើប បដិវត្តន៍ឧស្សាហកម្មបានផ្លាស់ប្តូរទាំងស្រុងនូវ រចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គម ហើយត្រូវការពេលវេលារាប់ទសវត្សរ៍ ទើបអាចឃើញលទ្ធផលច្បាស់។ បដិវត្តន៍ឧស្សាហកម្មជំនាន់ទី១ បានចាប់ផ្តើមឡើងនៅក្នុងសតវត្សរ៍ទី១៨ ហើយអាចសម្គាល់បានតាមរយៈការប្រើថាមពលចំហាយទឹកក្នុងវិស័យកម្មន្តសាល។ វាបាននាំមកនូវយន្តកម្ម និងជួយកំណត់ទម្រង់នៃរចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មីដែលពឹងផ្អែកជាសំខាន់លើវាយនភណ្ឌ និងគ្រឿងដែក។ បដិវត្តន៍ឧស្សាហកម្មជំនាន់ទី២ កើតមានឡើងនៅចុងសតវត្សរ៍ទី១៩ និងបន្តរហូតដល់ដើមសតវត្សរ៍ទី២០។ ការរកឃើញប្រភពថាមពលថ្មីៗ ដូចជាអគ្គិសនី ប្រេងកាត និងឧស្ម័ន បាននាំឱ្យមានការបង្កើតម៉ាស៊ីនចំហេះក្នុង (Sentryo 2017)។ ការចាប់ផ្តើមប្រើខ្សែសង្វាក់ផ្គុំដំឡើង បានបើកផ្លូវដល់ផលិតកម្មទ្រង់ទ្រាយធំ ដែលនាំឱ្យមានការកែលំអប្រព័ន្ធដឹកជញ្ជូន ការប្រស្រ័យទាក់ទង និងប្រតិបត្តិការធនាគារ។ វាបានបន្ថែមទិដ្ឋភាពថ្មីជាច្រើនដល់រចនាសម្ព័ន្ធសេដ្ឋកិច្ច។ បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៣ បានចាប់ផ្តើមនៅចុងទសវត្សរ៍ ១៩៦០ និងជំរុញឡើងដោយសារប្រព័ន្ធអេឡិចត្រូនិក និងបច្ចេកវិទ្យាព័ត៌មាន ដែលនាំឱ្យមានការបង្កើតរ៉ូបូ និងប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនដែលគេអាចបញ្ចូលកម្មវិធីសម្រាប់គ្រប់គ្រងដំណើរការវា។ ស្វ័យប្រវត្តិកម្មកម្រិតខ្ពស់ក្នុងផលិតកម្មទ្រង់ទ្រាយធំ ក៏អាចអនុវត្តទៅបាន។បច្ចេកវិទ្យាថ្មីៗ ដូចជា អ៊ិនធើណិត សម្ភារៈប្រើប្រាស់ផ្នែកអេឡិចត្រូនិក ថាមពលអាចកកើតឡើងវិញ និងថាមពលនុយក្លេអ៊ែរ រថភ្លើងល្បឿនលឿន និងយន្តហោះ ក៏ចាប់មានយកមកប្រើ ដែលបានសម្រួលដល់ផលិតកម្មក្រៅប្រទេស (Schwab 2016)។ បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ បានចាប់ផ្តើមនៅអំឡុងទសវត្សរ៍ទី១ នៃឆ្នាំ២០០០ ហៅកាត់ថា ឧស្សាហកម្ម ៤.០ ឬ«រោងចក្រឆ្លាត»។ នៅឆ្នាំ២០១១ រដ្ឋាភិបាលសហព័ន្ធអាឡឺម៉ង់ ក្នុងឱកាសតាំងពិព័រណ៌ពាណិជ្ជកម្ម Hannover Messe នៅទីក្រុងHanover។ ឧស្សាហកម្ម៤.0 បង្ហាញនូវការផ្លាស់ប្តូរផ្នែកបច្ចេកទេសពីប្រព័ន្ធដាក់បង្កប់ ទៅជាប្រព័ន្ធសម្ភារមានកម្មវិធីកុំព្យូទ័រគ្រប់គ្រង និងមានភ្ជាប់អ៊ិនធើណិត (cyber-physical system) ដែលតភ្ជាប់បច្ចេកវិទ្យាផលិតកម្មដាក់បង្កប់ជាមួយដំណើរការផលិតកម្មឆ្លាត។ វាទំនើបជាង ការតភ្ជាប់បែបសាមញ្ញនូវប្រព័ន្ធផលិតកម្ម និងកម្មវត្ថុរបស់វាដោយផ្ទេរព័ត៌មានរូបវន្ត ចូលទៅក្នុងពិភពឌីជីថល ហើយបន្ទាប់មកមានការប្រស្រ័យទាក់ទងគ្នា ការវិភាគ និងការប្រើប្រាស់ព័ត៌មាននោះ សំដៅជួយនាំមុខសកម្មភាពឆ្លាតត្រឡប់ចូលទៅក្នុងពិភពរូបវន្តវិញ ដើម្បីអនុវត្តនូវ«អន្តរកាល ពីពិភពរូបវន្ត ទៅ ឌីជីថល និងពីឌីជីថល ទៅរូបវន្តវិញ» (Sniderman, Mahto and Cotteleer 2016, 5)។ សរុបមក ផលិតផលគឺអាចប្រស្រ័យទាក់ទងជាមួយម៉ាស៊ីនបាន ដើម្បីប្រាប់ម៉ាស៊ីននោះយ៉ាងត្រឹមត្រូវថា ត្រូវធ្វើអ្វីខ្លះក្នុងដំណើរការផលិតកម្ម។

បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ គឺជាការដាក់បញ្ចូលគ្នានូវបណ្តាញអ៊ិនធើណិតនៃសម្ភារៈ (IoT: ការភ្ជាប់សម្ភារដោយប្រើប្រព័ន្ធអ៊ិនធើណិត ដើម្បីអាចបញ្ជូន និងទទួលទិន្នន័យ) និងបណ្តាញបច្ចេកវិទ្យារូបវន្តផ្សេងៗទៀត ដូចជា បច្ចេកវិទ្យា វិភាគទិន្នន័យ ផលិតកម្មតាមការបន្ថែមស្រទាប់ (ឬការបោះពុម្ព 3D printing) បច្ចេកវិទ្យាប្រើរ៉ូបូ blockchain (ប្រតិបត្តិការតាមប្រព័ន្ធអ៊ិនធើណិត ដែលចងភ្ជាប់គ្នាជាខ្សែមិនអាចកែមួយៗបាន) ការប្រើកុំព្យូទ័រមានសមត្ថភាពខ្ពស់ (HPC) បញ្ញាសិប្បនិម្មិត និងបច្ចេកវិទ្យាប្រើកុំព្យូទ័រជំនួសខួរក្បាលមនុស្ស សម្ភារទំនើបៗ និងការពិតជំនួយដោយកុំព្យូទ័រ (augmented reality) ដែលបង្កើបាននូវវដ្ត «ពីរូបវន្ត ទៅ ឌីជីថល និងពីឌីជីថល ទៅរូបវន្តវិញ» ដ៏ពេញលេញមួយ។ (Sniderman, Mahto and Cotteleer 2016, 8)។

## ២. តើហេតុអ្វីបានជាកម្ពុជាត្រូវត្រៀមខ្លួនឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្ម ៤.0?

និន្នាការបច្ចេកវិទ្យាចំនួន៥ នៅក្នុងសកលលោក កំពុងបង្ហាញនូវការប្រឹងប្រែងរុញច្រានរបស់ផលិតករឆ្ពោះទៅរករោងចក្រឆ្លាតគឺៈ

១. ការវិវត្តន៍ និងរីកចម្រើនយ៉ាងលឿនក្នុងផ្នែកបញ្ញាសិប្បនិម្មិត (AI) បច្ចេកវិទ្យាកុំព្យូទ័រជំនួសខួរក្បាលមនុស្ស និងការរៀនចេះចាំដោយម៉ាស៊ីន (cognitive computing and machine learning) ដែលនាំឱ្យមាន ការវិភាគ ទាយទុកភ្លាមៗ (real-time and predictive analytics) ជួយសម្រួលដល់ការធ្វើសេចក្ដីសម្រេចចិត្តសំខាន់ៗ

២. ខ្សែសង្វាក់ផ្គត់ផ្គង់សកលកាន់តែស្មុគស្មាញឡើង និងការបែកខ្ញែកដាច់ដោយដុំ នៃប្រព័ន្ធផលិតកម្មនានា

៣. កំណើនសម្ពាធប្រកួតប្រជែងជាខ្លាំង និងជារឿយៗមិនបានរំពឹងទុក ដោយសារមាន បច្ចេកវិទ្យាឆ្លាតផ្សេងៗដែលបានកាត់បន្ថយបន្ទុកចំណាយ ក្នុងការចូលទៅក្នុងទីផ្សារថ្មី

៤. ការរៀបចំរចនាសម្ព័ន្ធស្ថាប័នឡើងវិញ ដោយសារមាន ការបន្សុីចូលគ្នានូវ បច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាគ្រប់គ្រងប្រតិបត្តិការ និង

៥. បញ្ហាប្រឈមចំពោះមុខនៃការគ្រប់គ្រងអ្នកមានជំនាញខ្ពស់ (Burke et al. 2017, 8-9)។

រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យរយៈពេលវែង ដើម្បីក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ រាជរដ្ឋាភិបាលកម្ពុជាក៏មានទិសដៅ«ធ្វើអន្តរកាលឱ្យចប់សព្វគ្រប់ទៅកាន់សេដ្ឋកិច្ចឌីជីថល» នៅឆ្នាំ២០២៣ ដូចមានបញ្ជាក់ក្នុងសេចក្ដីប្រកាសរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នៅដើមឆ្នាំ២០១៨ (Sum 2018)។ ដំណើររបស់កម្ពុជាទៅកាន់គោលដៅនេះ នឹងត្រូវកំណត់ឡើងតាម សមត្ថភាពរបស់ខ្លួនក្នុងការស្រូបយក និងប្រើប្រាស់បានល្អនូវ បច្ចេកវិទ្យាឌីជីថលផ្សេងៗ។ ការរីកចម្រើនឧស្សាហកម្ម៤.០ ផ្ដល់ឱ្យកម្ពុជានូវ ឱកាសសម្រាប់ឱ្យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា រីកចម្រើនលោតផ្លោះទៅកាន់អនាគតភ្លឺស្វាង តាមមធ្យោបាយយ៉ាងតិចពីរយ៉ាងគឺ៖

ទី១. និន្នាការផ្នែកបច្ចេកវិទ្យា និងជួយកម្ពុជាឈានទៅកាន់ របបសេដ្ឋកិច្ចផ្អែកលើចំណេះដឹង។ ដោយចំនួនជិតពីរភាគបីនៃប្រជាជនសរុបមានអាយុក្រោម៣០ឆ្នាំ ដូច្នេះមួយភាគធំនៃកម្លាំងពលកម្មនឹងពេញវ័យឡើងក្នុងពិភពមួយពោរពេញដោយបច្ចេកវិទ្យាឌីជីថល។ កម្ពុជាត្រូវឈានទៅមុខយ៉ាងលឿន បើសិនចង់ទាញយកចំណេញពីឱកាសល្អផ្នែកប្រជាសាស្ត្រនេះ។

ទី២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្នែកបច្ចេកវិទ្យា ជាកត្តាសំខាន់បំផុតសម្រាប់ពិពិធកម្ម កំណើនផលិតភាព និងសមត្ថភាពប្រកួតប្រជែងផ្នែកឧស្សាហកម្ម ទៅអនាគត ដូចមានឧទាហរណ៍នៅ ចិន ហុងកុង សិង្ហបុរី កូរ៉េខាងត្បូង និងតៃវ៉ាន់។ ដើម្បីសម្រេចបានកំណើនប្រកបដោយចីរភាព និងសម្រាប់គ្រប់គ្នា ប្រទេសទាំងនេះបានផ្ដល់អាទិភាពជាយូរមកហើយដល់ការធ្វើវិនិយោគខ្លាំងក្លាក្នុងឧត្តមសិក្សា និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ សំដៅបង្កើតបាននូវកម្លាំងពលកម្មមានគុណសម្បត្តិជំនាញគុណភាព និងចំណេះដឹងខ្ពស់ ហើយអាចបំពេញបានតាមតម្រូវការប្រែប្រួលចុះឡើងនៃការធ្វើឧស្សាហូបនីយកម្មយ៉ាងលឿន។

ដើម្បីត្រៀមខ្លួនសម្រាប់ឆ្លើយតបទៅនឹងឧស្សាហកម្ម៤.០ មានលក្ខណៈវិនិច្ឆ័យសំខាន់ធំពីរជួយឱ្យប្រទេសកម្ពុជាអាចយល់ដឹងកាន់តែច្បាស់ពីកម្រិតបច្ចុប្បន្នភាពនៃភាពត្រៀមខ្លួនសម្រាប់ផលិតកម្មទៅអនាគត ក៏ដូចជាឱកាសល្អ និងបញ្ហាប្រឈមជាប់ទាក់ទិននានាគឺ កត្តាជំរុញផលិតកម្ម និងរចនាសម្ព័ន្ធផលិតកម្ម។ ប៉ុន្តែកម្ពុជា ស្ថិតក្នុងចំណោមប្រទេសត្រៀមខ្លួនបានតិចបំផុតសម្រាប់ផលិតកម្មទៅអនាគត គឺស្ថិតនៅលំដាប់ទី៩១សម្រាប់កត្តាជំរុញផលិតកម្មដោយបានពិន្ទុសរុប ៣,៦៣ (គិតលើ១០) និងលំដាប់ទី៨១ សម្រាប់រចនាសម្ព័ន្ធផលិតកម្ម ដោយបានពិន្ទុសរុប ៣,៥៦ ក្នុងចំណោម១០០ប្រទេសដែលត្រូវបានវាយតម្លៃ។ មានប្រទេសចំនួនតែ២៥ ប៉ុណ្ណោះ ក្នុងនោះមាន៥នៅអាស៊ី(ចិន ជប៉ុន កូរ៉េខាងត្បូង ម៉ាឡេស៊ី សិង្ហបុរី)ដែលគេចាត់ទុកថាបានត្រៀមខ្លួនរួចជាស្រេច (WEF 2018b, 12)។

## ៣. តើបច្ចុប្បន្ននេះកម្ពុជាបានត្រៀមអ្វីខ្លះហើយជាពិសេសផ្នែកធនធានមនុស្ស និងវិស័យអប់រំ?

នៅកម្ពុជា ធនធានមនុស្សជាចំណុចខ្លាំងមួយ ដោយសារកម្លាំងពលកម្មមានវ័យក្មេងហើយក៏ជាបញ្ហាប្រឈមមួយដែរ ដោយសារកម្លាំងពលកម្មមានជំនាញទាប។ ជំនាញសមស្របមួយចំនួនត្រូវតែអភិវឌ្ឍឡើងដើម្បីដើរឱ្យទាន់ការផ្លាស់ប្តូរបរិស្ថានការងារពីតម្រូវការប្រើពលកម្មច្រើនទៅជាការប្រើចំណេះដឹងច្រើន។ ការដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា និងលើការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ បានឆ្លើយតបយ៉ាងល្អទៅនឹងតម្រូវការពិតនៃឧស្សាហកម្ម៤.០។ ឧស្សាហកម្ម៤.០ និងបច្ចេកវិទ្យាសម្រាប់អនុវត្តវា ដូចជា បញ្ញាសប្បនិមិត្ត បច្ចេកវិទ្យាប្រើរ៉ូបូ ទិន្នន័យធំ បណ្តាញអ៊ិនធើណិតនៃសម្ភារ ការតភ្ជាប់ប្រព័ន្ធអ៊ិនធើណិតក្នុងវត្ថុប្រើប្រាស់ប្រចាំថ្ងៃ ដើម្បីអាចបញ្ជូន និងទទួលទិន្នន័យ បច្ចេកវិទ្យាផ្ទុកទិន្នន័យក្លោដ នឹងប៉ះពាល់ដល់គ្រប់វិស័យសេដ្ឋកិច្ច។ ឧស្សាហកម្មថ្មីៗ ដូចជារោងចក្រឆ្លាត និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ត្រូវការជំនាញបច្ចេកទេស និងវិជ្ជាជីវៈច្រើនបែបច្រើនយ៉ាង ដូចជា ប្រតិបត្តិករ អ្នកបង្កើតកម្មវិធីប្រើរ៉ូបូ អ្នកជីកយកទិន្នន័យ និងអ្នកស្រាវជ្រាវផលិតផល និងសេវាកម្មជាដើម។ ទីផ្សារពលកម្មនឹងមានការផ្លាស់ប្តូរខ្លាំង ព្រោះបច្ចេកវិទ្យាថ្មីនឹងជំនួសការងារខ្លះ ផ្លាស់ប្តូរការងារខ្លះទៀត និងបង្កើតការងារថ្មីៗបន្ថែម។ លទ្ធផលស្រាវជ្រាវបង្ហាញថា លទ្ធភាពធ្វើស្វ័យប្រវត្តិកម្មការងារណាមួយ វាផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹង កម្រិតអប់រំ និងការបណ្តុះបណ្តាលដែលត្រូវមានដើម្បីធ្វើការងារនោះ។ មុខរបរមានលទ្ធភាពខ្ពស់បំផុតសម្រាប់ការធ្វើស្វ័យប្រវត្តិកម្ម ជាទូទៅគឺជា របរមិនទាមទារជំនាញ ឬការបណ្តុះបណ្តាលជាក់លាក់អ្វីទេ។ បន្ទាប់មកទៀត គឺមុខរបរដែលត្រូវមានការបណ្តុះបណ្តាលខ្លះ។ ហើយចុងក្រោយបំផុតគឺមុខរបរដែលត្រូវមានការអប់រំ ឬការបណ្តុះបណ្តាលកម្រិតខ្ពស់ ព្រមទាំងទំនាក់ទំនងក្នុងសង្គម គំនិតច្នៃប្រឌិត សមត្ថភាពដោះស្រាយបញ្ហា និងការយកចិត្តទុកដាក់ដល់អ្នកដទៃកម្រិតខ្ពស់ផងដែរ។

ការអង្កេតមួយរបស់ វេទិកាសេដ្ឋកិច្ចពិភពលោក (WEF) លើស្ថានភាពការងារសម្រាប់ឆ្នាំ២០១៥ដល់ឆ្នាំ ២០២០ ក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងស្ទុះឡើងសំខាន់ៗចំនួន១៥ បានបង្ហាញនូវការរំពឹងទុកថា«នឹងមានកំណើនជាខ្លាំងនូវក្រុមការងារខាងផ្នែកស្ថាបត្យកម្ម វិស្វកម្ម កុំព្យូទ័រ និងគណិតវិទ្យា ការធ្លាក់ចុះបង្គួរនូវការងារខាងផ្នែកកម្មន្តសាល និងផលិតកម្ម និងការធ្លាក់ចុះខ្លាំងខាងផ្នែកការិយាល័យ និងរដ្ឋបាល»។ ការងារខាងផ្នែកអាជីវកម្ម និងប្រតិបត្តិការហិរញ្ញវត្ថុ ការលក់ដូរ ការសាងសង់ និងការយករ៉ែ នឹងនៅដដែល។ សរុបមកយ៉ាងហោចណាស់ ៥០% នៃការងារក្នុងប្រមាណ៤០% នៃមុខរបរបច្ចុប្បន្ន គឺមានហានិភ័យខ្ពស់នៃការធ្វើស្វ័យប្រវត្តិកម្ម។ គេប៉ាន់ស្មានថាប្រមាណ៦៥% នៃការងារដែលមនុស្សជំនាន់បន្ទាប់ត្រូវធ្វើគឺវាមិនទាន់មាននៅឡើយទេក្នុងពេលសព្វថ្ងៃនេះ (WEF 2016 a, b)។

### ៣.១. ការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា(ស្ទែម) នៅឆ្នាំ២០១៦។ ការកសាង និងពង្រឹង ក្រុមអ្នកមានជំនាញខ្ពស់ដែលបណ្តុះបណ្តាលបាននៅក្នុងស្រុក សំខាន់ខ្លាំងណាស់ក្នុងការរៀបចំប្រទេសកម្ពុជាសម្រាប់ឧស្សាហកម្ម៤.០ និងកម្មន្តសាលឆ្លាត។ ការអប់រំមានគុណភាពខ្ពស់ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដើរតួនាទីសំខាន់បំផុតសម្រាប់ជោគជ័យនៃឧស្សាហូបនីយកម្ម និងកំណើនសេដ្ឋកិច្ចទៅអនាគតនៅកម្ពុជា។ គោលនយោបាយអប់រំស្ទែមបានផ្តោតអាទិភាពលើ៖

- ការបណ្តុះបណ្តាលគ្រូបង្រៀនថ្មីផ្នែកស្ទែម ដើម្បីជំរុញរបៀបវារៈនៃការអប់រំផ្នែកស្ទែម
- ការផ្តល់អាទិភាពដល់ការអប់រំផ្នែកស្ទែម ជាទូទៅការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងឧត្តមសិក្សា

- ការដាក់បញ្ចូលការអប់រំផ្នែកស្ទែម ជាមួយវិស័យផ្សេងទៀត ដូចជាសេដ្ឋកិច្ច ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ដើម្បីញាំងឱ្យផ្លូវអាជីពមានប្រសិទ្ធភាពខ្ពស់បំផុត
- ការរៀបចំឱ្យនិស្សិត និងអ្នកមានសញ្ញាបត្រផ្នែកស្ទែមអាចបំពេញបានតាមតម្រូវការនៃឧស្សាហកម្ម៤.០
- ការកសាងចំណងទាក់ទង រវាងសាកលវិទ្យាល័យ និងឧស្សាហកម្ម ដើម្បីជំរុញការស្រាវជ្រាវសម្រាប់យកទៅអនុវត្ត កិច្ចសហការផ្នែកបច្ចេកទេស និងភាពជាដៃគូផ្នែក R&D
- បង្កើនចំណេះដឹង និងជំនាញមូលដ្ឋានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។

## ៣.២. ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

តួនាទីទ្វេនៃ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ក្នុងបរិបទនៃឧស្សាហកម្ម៤.០ គឺទី១ ផ្តល់ការបណ្តុះបណ្តាលជំនាញដែលទីផ្សារពលកម្មត្រូវការ និងទី២ បណ្តុះសមត្ថភាពសម្របខ្លួនទៅនឹងបច្ចេកវិទ្យាថ្មីៗ។ តួនាទីទី១ ធានាឱ្យ TVET ជាប់ទាក់ទងល្អទៅនឹងតម្រូវការ ហើយតួនាទីទី២ ជួយការពារកម្លាំងពលកម្មឱ្យជៀសផុតពីការបាត់បង់ការងារដោយសារស្វ័យប្រវត្តិកម្ម។ TVET ត្រូវមានហួសពីការបណ្តុះបណ្តាលជំនាញជាក់ស្តែង និងតូចចង្អៀតសម្រាប់ធ្វើកិច្ចការបច្ចេកទេសជាក់លាក់អ្វីមួយដែលងាយរងគ្រោះ ដោយសារការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យា។ កន្លងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានខិតខំរៀបចំគោលនយោបាយដើម្បី៖

- ធានាថា សិស្សមានជំនាញមូលដ្ឋានរឹងមាំ គឺចេះគិតលេខ និងចេះអានអក្សរ
- លើកកម្ពស់ជំនាញទន់ រួមមាន ការដោះស្រាយបញ្ហា ជំនាញប្រស្រ័យទាក់ទង និងសម្របខ្លួន
- លើកទឹកចិត្តការយកជំនាញផ្សេងៗ ទៅអនុវត្តក្នុងស្ថានភាពត្រូវបម្រើការងារពិតជាក់ស្តែង
- បង្វែរចំណុចផ្តោតពីការបណ្តុះបណ្តាលជំនាញដើម្បីត្រៀមខ្លួនសម្រាប់បំពេញការងារជាក់លាក់ ទៅជាការរៀនសូត្រពេញមួយជីវិត
- ផ្តល់កម្មវិធីបង្កើនជំនាញ និងបង្រៀនជំនាញឡើងវិញ សម្រាប់ធ្វើជាផ្លូវឡើងទៅដល់ការអប់រំ ឬបណ្តុះបណ្តាលកម្រិតខ្ពស់ៗ ឬអាជីពផ្សេងៗទៀត
- បង្កើតផ្លូវបញ្ជាក់គុណភាពរួមគ្នា ដោយរួមសហការជាមួយគ្រឹះស្ថានឧត្តមសិក្សានានា។

## ៣.៣. យុទ្ធសាស្ត្រ សម្រាប់ការអភិវឌ្ឍជំនាញខ្ពស់ៗទៅអនាគត

យោងតាមការសិក្សារបស់វេទិកាសេដ្ឋកិច្ចពិភពលោក អំពីអនាគតនៃការងារ គឺមានជំនាញ១០ ដែលគេត្រូវការខ្លាំងបំផុត៖

1. ការដោះស្រាយបញ្ហាស្មុគស្មាញ
2. ការគិតគូរថ្លឹងថ្លែង
3. ការច្នៃប្រឌិត
4. ការគ្រប់គ្រងមនុស្ស
5. ការសម្របសម្រួលជាមួយអ្នកដទៃ
6. ភាពឆ្លាតវៃផ្នែកអារម្មណ៍
7. សុភវិនិច្ឆ័យ និងការសម្រេចចិត្ត
8. ការតម្រង់ទិសសេវាកម្ម
9. ការចរចា
10. ភាពអាចបត់បែនក្នុងការស្វែងយល់ (WEF 2016a)

### ៣.៣.១. ការគិតគូរឡើងវិញពីការអប់រំ និងការបណ្ដុះបណ្ដាល

ប្រព័ន្ធបណ្ដុះបណ្ដាលអាចកែសម្រួល និងបត់បែនបាន ដើម្បីអាចតាមទាន់ការរីកចម្រើនយ៉ាងលឿននៃបច្ចេកវិទ្យា និងការផ្លាស់ប្ដូរនៃតម្រូវការជំនាញ។ ប្រព័ន្ធបណ្ដុះបណ្ដាលត្រូវកសាងកម្លាំងពលកម្មដែលអាចសម្របខ្លួនទៅតាម ការប្រែប្រួលឥតឈប់នៅក្នុងកន្លែងធ្វើការ។ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតកម្មវិធីសាលារៀនជំនាន់ថ្មី ដែលកម្មវិធីសិក្សាមានភាពបត់បែននិងផ្ដោតលើការអប់រំវិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ជាអាទិភាព និងបង្កើតសាលារៀនចំណេះទូទៅ និងអប់រំបច្ចេកទេសផងដែរ ដើម្បីផ្ដល់ជូននូវការអប់រំមួយដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្នផង និងពេលអនាគតផង។ ជំនាញទាំងនេះមានជាអាទិ៍ចំណេះដឹងផ្នែកបច្ចេកវិទ្យា អគ្គីសនី អេឡិចត្រូនិក សហគ្រិនភាព ការសម្របខ្លួន និងការរៀនសូត្រ...។ ការបណ្ដុះបណ្ដាលបានសង្កត់ធ្ងន់លើជំនាញទន់ ដូចជាការឆ្លុះបញ្ចាំងពីខ្លួនឯង ការរៀនពីរបៀបរៀន ការដោះស្រាយបញ្ហា ភាពច្នៃប្រឌិត និងការប្រស្រ័យទាក់ទង។

### ៣.៣.២. ការលើកទឹកចិត្តដល់ការរៀនសូត្រពេញមួយជីវិត

ដោយសារបច្ចេកវិទ្យាផ្លាស់ប្ដូរយ៉ាងលឿន ចំណេះដឹងនិងជំនាញផ្សេងៗ អាចលែងស្របតាមតម្រូវការ ឬចាស់ហួសសម័យឆាប់ណាស់។ ការអប់រំតែមួយលើក(មុនផ្ដល់សេវា) មុនពេលចូលទីផ្សារការងារ វាមិនគ្រប់គ្រាន់ទេ ដើម្បីបណ្ដុះបណ្ដាលកម្លាំងពលកម្មឱ្យចេះសម្របខ្លួននិងអាចឆ្លើយតបបានលឿន និងប្រកបដោយប្រសិទ្ធភាពទៅនឹងបរិយាកាសផ្លាស់ប្ដូរចុះឡើង។ ជាការប្រសើរ គួរបណ្ដុះបណ្ដាលបុគ្គលនានាដែលកំពុងបម្រើការងារទំនងនឹងមានការធ្វើស្វ័យប្រវត្តិកម្ម ដើម្បីត្រៀមរៀបចំសម្រាប់ការផ្លាស់ប្ដូរការងារទៅអនាគត។

### ៣.៣.៣. តួនាទីរបស់គ្រឹះស្ថានឧត្តមសិក្សា/ សាកលវិទ្យាល័យ

គ្រឹះស្ថានឧត្តមសិក្សា/ សាកលវិទ្យាល័យ មានតួនាទីចម្បង ក្នុងការគ្រប់គ្រងចំណងទាក់ទងរវាងសាកលវិទ្យាល័យ នឹងឧស្សាហកម្ម និងការបណ្ដុះបណ្ដាលអ្នកមានជំនាញខ្ពស់ ដោយត្រូវគ្រប់គ្រងលំហូរហិរញ្ញវត្ថុ និងធានាថា អ្នកស្រាវជ្រាវជំនាញៗទទួលបានគ្រឿងលើកទឹកចិត្តសមរម្យ។ គ្រឹះស្ថានឧត្តមសិក្សាអាចស្វែងរកអ្នកស្រាវជ្រាវល្អៗ និងផ្ដល់បរិយាកាសដ៏ប្រសើរសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ហើយត្រូវជួយផ្ដួចផ្ដើមបង្កើតកន្លែងបណ្ដុះបច្ចេកវិទ្យា សម្រាប់សហគ្រាសទើបចាប់ផ្ដើមដំណើរការ និងនវានុវត្តន៍។

### ៣.៣.៤. តួនាទីរបស់អ្នកស្រាវជ្រាវ

អ្នកស្រាវជ្រាវត្រូវធ្វើការស្រាវជ្រាវស្របតាមវិជ្ជាជីវៈ និងក្រមសីលធម៌ ហើយផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវទៅដល់ដៃគូនានា អ្នករួមសហការ អ្នកពាក់ព័ន្ធ និងសង្គមជាទូលាយ។ អ្នកស្រាវជ្រាវគួរធ្វើការជាមួយវិស័យឧស្សាហកម្ម ដើម្បីដោះស្រាយបញ្ហាផ្សេងៗ តាមរយៈចំណងទាក់ទងរវាងគ្រឹះស្ថានឧត្តមសិក្សា និងឧស្សាហកម្ម។ម្យ៉ាងទៀតក៏គួរជួយផ្ដល់ការណែនាំដល់អ្នកស្រាវជ្រាវនៅដើមអាជីព និងនិស្សិតនានា ដើម្បីពង្រីកការយល់ដឹងពីការស្រាវជ្រាវ និងការអភិវឌ្ឍអាជីព។ កិច្ចសហការទាំងខាងក្នុង និងខាងក្រៅអង្គភាព សំខាន់ជាខ្លាំងសម្រាប់ធ្វើការស្រាវជ្រាវពហុវិស័យ។ ការកំណត់អាទិភាពស្រាវជ្រាវ គួរស្របតាមអាទិភាពនានាក្នុងគោលនយោបាយ។




រូបភាព១៖ ភាគីពាក់ព័ន្ធជាកម្លាំងជំរុញសំខាន់ៗសម្រាប់ការបណ្ដុះបណ្ដាលអ្នកមានជំនាញខ្ពស់

តារាង១៖ និន្នាការក្នុងលទ្ធភាពបានប្រើបច្ចេកវិទ្យា (ចំណាត់ថ្នាក់របស់កម្ពុជា)

| សកម្មភាព | 2013/14 (148) | 2014/15 (144) | 2015/16 (140) | 2016/17 (138) | 2017/18 (137) |
|---|---|---|---|---|---|
| សន្ទស្សន៍ប្រកួតប្រជែងសកល | 88 | 95 | 90 | 89 | 94 |
| វត្តមាននៃបច្ចេកវិទ្យាថ្មីបំផុត | 82 | 87 | 101 | 100 | 93 |
| ការស្រូបយកបច្ចេកវិទ្យានៅកម្រិតសហគ្រាស | 82 | 97 | 97 | 99 | 90 |
| ការផ្ទេរបច្ចេកវិទ្យានិង FDI | 44 | 51 | 59 | 53 | 54 |
| គុណភាពស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្រ | 101 | 118 | 122 | 123 | 114 |
| ចំណាយរបស់ក្រុមហ៊ុនលើ R&D | 57 | 79 | 91 | 84 | 82 |
| កិច្ចសហការសាកលវិទ្យាល័យ ឧស្សាហកម្មក្នុង R&D | 105 | 115 | 114 | 102 | 96 |

កំណត់សម្គាល់៖ តួលេខក្នុងវង់ក្រចក ជាចំនួនប្រទេសត្រូវបានវាយតម្លៃ

ប្រភព៖ WEF (2013-2018)

## ៤. តើត្រូវលើកកម្ពស់និងពង្រឹងគុណភាពអប់រំគណិតវិទ្យានៅកម្ពុជាយ៉ាងដូចម្ដេចដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្ម ៤.0 ?

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងអត្ថបទវិភាគរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្ដីអំពី« កំណែទម្រង់អប់រំ ឆ្ពោះទៅគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤» បានរកឃើញថា៖ គុណវុឌ្ឍិរបស់គ្រូបង្រៀននៅគ្រប់កម្រិតនិងគ្រប់មុខវិជ្ជានៅទាបនៅឡើយ។ ស្ថានភាពបច្ចុប្បន្ននេះ ១) គ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិប្រហែល៤០ភាគរយ មានសញ្ញាបត្រយ៉ាងទាបត្រឹមបរិញ្ញាបត្រ ២) គ្រូបង្រៀនភាគច្រើននៅកម្រឹតមធ្យមសិក្សាបឋមភូមិមានសញ្ញាបត្រយ៉ាងហោចណាស់មធ្យមសិក្សាទុតិយភូមិ ៣)បញ្ហាប្រឈមចម្បងនៃការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនឱ្យស្របនឹងគោលនយោបាយគ្រូបង្រៀន គឺការលើកកម្ពស់គ្រូបង្រៀនកម្រិតបឋមសិក្សា។ នៅឆ្នាំ ២០១៥ បុគ្គលិកអប់រំនៅបឋមសិក្សាចំនួន៣២,៦ភាគរយ មានកម្រិតអប់រំត្រឹមមធ្យមសិក្សាទុតិយភូមិ ដែលភាគច្រើននៅតំបន់ជនបទ និងដាច់ស្រយាល ៤) គ្រូឧទ្ទេសជាងពាក់កណ្ដាលនៅសាលាគរុកោសល្យ និងវិក្រឹតការ រាជធានី ខេត្ត មានសញ្ញាបត្របរិញ្ញាបត្រ និងប្រមាណមួយភាគបួនមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

នៅឆ្នាំ២០១៧ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តគោលនយោបាយស្ដីពី ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀនដោយផ្ដោតការយកចិត្តទុកដាក់ដូចខាងក្រោម ១) បង្កើតប្រព័ន្ធវិក្រឹតការគ្រូបង្រៀនជាទៀងទាត់ ដែលមានការហ្វឹកហាត់បីប្រភេទ ក) វិក្រឹតការនៅនឹងកន្លែង ខ) វិក្រឹតការមិនរៀបរយ គ) វិក្រឹតការជាប្រចាំដោយមានប្រព័ន្ធនិងកម្មវិធីត្រឹមត្រូវ ដើម្បីលើកកម្ពស់សមត្ថភាពគ្រូបង្រៀនផ្នែកចំណេះដឹង វិធីសាស្ត្របង្រៀន និងកម្មវិធីណែនាំ ២) បង្កើតប្រព័ន្ធក្រេឌីតសម្រាប់បង្រួបបង្រួមរាល់សកម្មភាពវិក្រឹតការ ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណវុឌ្ឍិ និងអត្ថប្រយោជន៍បន្ថែម(ប្រាក់បៀវត្ស ការឡើងឋានៈ) ៣)ពង្រឹងប្រព័ន្ធវិក្រឹតការគ្រូបង្រៀននៅនឹងកន្លែង ដើម្បីជួយដល់គ្រូបង្រៀនអំពីចំណេះដឹង និងគរុកោសល្យ និង ៤)បង្កើតកម្មវិធីវិក្រឹតការសម្រាប់គ្រូឧទ្ទេសស្របតាមស្តង់ដាអ្នកផ្ដល់សេវាអប់រំគ្រូ (TEPS)។

ដូច្នេះដើម្បីលើកកម្ពស់ និងពង្រឹងគុណភាពអប់រំគណិតវិទ្យានៅកម្ពុជាឱ្យឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្ម៤.0 គ្រូបង្រៀនគណិតវិទ្យាត្រូវមានការយល់ដឹងលើចំណុចមួយចំនួនដូចខាងក្រោម៖

១. ផ្តោតលើការរៀនសូត្ររបស់សិស្សអំពីមុខវិជ្ជាស្នូល និងជំនាញ
២. ទាញយកពីការវិភាគនៃការរៀនសូត្ររបស់សិស្សអំពីខ្លឹមសារជាក់លាក់ នៅក្នុងទម្រង់ជាក់លាក់
៣. ផ្តោតលើបញ្ហាជាក់លាក់នៃកម្មវិធីសិក្សា និងគរុកោសល្យ
៤. ទាញចេញពីការស្រាវជ្រាវ និងការអនុវត្តគំរូ
៥. ផ្សារភ្ជាប់បញ្ហាជាក់លាក់នៃការបង្រៀននិងការរៀនសូត្ររបស់សិស្ស អំពីមុខវិជ្ជានិងជំនាញទៅក្នុងបរិបទថ្នាក់រៀន
៦. អភិវឌ្ឍ ពង្រឹង និងទ្រទ្រង់ការងារជាក្រុម
៧. ធានានូវការអនុវត្តរួមគ្នានៅក្នុងសាលារៀន
៨. បណ្តាញទូទាំងសាលារៀន ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ
៩. រួមបញ្ចូលការចូលរួមយ៉ាងសកម្មរបស់ថ្នាក់ដឹកនាំសាលារៀន និងបុគ្គលិក
១០. បន្តកែលម្អក្នុងរយៈពេលមួយ
១១. ផ្តល់គំរូនៃការអនុវត្តប្រកបដោយប្រសិទ្ធភាព
១២. ផ្តល់ឱ្យដល់សាលារៀន និងថ្នាក់រៀន
១៣. ការអនុវត្តស្របនឹងខ្លឹមសារ
១៤. ប្រើប្រាស់រង្វាយតម្លៃការសិក្សារបស់សិស្ស និងការវាយតម្លៃ
១៥. ឃ្លាំមើលការរៀនសូត្ររបស់សិស្សជាប្រចាំ និង
១៦. ផ្តល់នូវយោបល់ត្រឡប់លើការរៀនសូត្ររបស់គ្រូ និងកិច្ចការបង្រៀន។

ការពិនិត្យមើលផលប៉ះពាល់នៃឥរិយាបថរបស់គ្រូបង្រៀន និងនាយកសាលារៀនលើលទ្ធផលសិក្សារបស់សិស្ស (Glewwe eds,2014) បានកំណត់ថា៖

១. ការផ្តល់គ្រូបង្រៀនដែលមានចំណេះដឹងខ្ពស់កាន់តែច្រើន ធ្វើឱ្យពិន្ទុសិស្សកាន់តែប្រសើរឡើង
២. បទពិសោធន៍របស់គ្រូបង្រៀនប្រៀបដូចជាមានឥទ្ធិពលវិជ្ជមានលើការសិក្សារបស់សិស្ស
៣. គ្រូមានចំណេះដឹងមុខវិជ្ជាគ្រប់គ្រាន់ស្របតាមការបង្រៀនរបស់ពួកគេ មានឥទ្ធិពលវិជ្ជមានយ៉ាងខ្លាំងទៅលើលទ្ធផលនៃការសិក្សារបស់សិស្ស
៤. វិក្រឹតការគ្រូបង្រៀន មានផលវិជ្ជមានយ៉ាងខ្លាំងទៅលើការសិក្សារបស់សិស្ស។

គ្រូបង្រៀនគណិតវិទ្យាត្រូវផ្លាស់ប្តូរវិធីសាស្ត្របង្រៀននិងរៀន ដោយទន្ទេញចាំមាត់ ទៅជាវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក។ នាពេលបច្ចុប្បន្ននេះ ចំណេះដឹងខាងផ្នែក nanotechnology បានកើនឡើងទ្វេដងក្នុងរយៈពេល២ឆ្នាំ ហើយចំណេះដឹងខាងផ្នែក clinic កើនឡើងទ្វេដងក្នុងរយៈពេល១៨ខែ។ ជាមធ្យមចំណេះដឹងរបស់មនុស្សកើនឡើងទ្វេដងក្នុងរយៈពេល១ឆ្នាំ។ តាមការទស្សទាយរបស់ IBM បន្ទាប់ពីមានប្រព័ន្ធ "internet of things" ចំណេះដឹងនឹងកើនឡើងទ្វេដងក្នុងរយៈពេល ១២ម៉ោងម្តង។ ប្រសិនបើសិស្សចង់ដឹងពីព្រឹត្តិការណ៍ (Facts) ណាមួយ គេអាចរកតាម Google តែក្នុងរយៈពេលពី២ ទៅ៣នាទីតែប៉ុណ្ណោះ។ ដូច្នេះគ្រូមិនចាំបាច់យកពេលបង្រៀនសិស្សក្នុងរយៈពេល ៣០នាទីទេ។ វិធីសាស្ត្របង្រៀនតាមបែបរិះរក គឺបង្រៀនសិស្សឱ្យចេះអនុវត្ត វិភាគ វាយតម្លៃ និងចូលរួមក្នុងការបង្កើតចំណេះដឹង តាមរយៈការផ្តល់នូវមតិយោបល់ផ្ទាល់ខ្លួន ជាពិសេសដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការស្រាវជ្រាវដោយខ្លួនឯង។ សិស្សក្លាយខ្លួនជាអ្នករៀនឯករាជ្យ និងយល់ពីបញ្ញត្តិ និងអាចបង្កើតបញ្ញត្តិដោយខ្លួនឯង។ ការរៀនតាមវិធីសាស្ត្ររិះរក ធ្វើឱ្យសិស្សអាចទទួលបានបំណិនរៀន ដើម្បីរៀនដោយខ្លួនឯង (Learn how to learn)។ ពួកគេអាចប្រើប្រាស់បំណិននេះ នៅពេលដែលគេចេញទៅធ្វើការ និងអាចរៀនពេញមួយជីវិត នៅពេលដែលសភាពការណ៍មានការប្រែប្រួលនាពេលអនាគត។ តាមបទពិសោធនៃសាលារៀន

ជំនាន់ថ្មី សិស្សអាចទទួលបានទាំងចំណេះដឹង បំណិនបច្ចេកទេស និងបំណិនទន់ ព្រមទាំងចរិយាសម្បទាទៀតផង។ ដូច្នេះគ្រូបង្រៀនគណិតវិទ្យា ត្រូវមានគុណសម្បត្តិដូចខាងក្រោម៖

១. របៀបគិត: ឆ្នៃប្រឌិត និងនវានុវត្តន៍, ត្រិះរិះពិចារណា ដោះស្រាយបញ្ហា និងសម្រេចចិត្ត, រៀនដើម្បីចេះរៀន

២. របៀបធ្វើការ: ទំនាក់ទំនង និងសហការធ្វើការជាក្រុម, យល់ដឹងពីភាពខុសគ្នានៃសម្បទា ល្បឿន និង របៀបសិក្សារបស់សិស្ស

៣. ឧបករណ៍ធ្វើការ: អក្ខរកម្មឌីជីថល, ICT

៤. របៀបរស់នៅ: ពលរដ្ឋល្អ ជាតិ និងសាកលលោក, មានបំណិនគ្រប់គ្រងជីវិត និងការងារ, ការទទួលខុសត្រូវផ្ទាល់ខ្លួន និងក្នុងសង្គម រួមទាំងមានកម្រិតវប្បធម៌ និងសមត្ថភាពខ្ពស់។

សរុបសេចក្តីមក តាមការីកចម្រើននៃឧស្សាហកម្ម ៤.០ ការប្រែក្លាយផ្នែកឌីជីថលអាចក្លាយជាក្បាលម៉ាស៊ីនកំណើនថ្មីដែលកម្ពុជាកំពុងត្រូវការ សំដៅសម្រេចបានតាមចក្ខុវិស័យរយៈពេលវែង ដើម្បីឈានឡើងជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ថ្វីបើកម្ពុជានៅយឺតយ៉ាវក្នុងការត្រៀមខ្លួនផ្នែកអេឡិចត្រូនិក (e-readiness) ប៉ុន្តែក៏មិនត្រូវភ្លេចដែរថា ការប្រើបច្ចេកវិទ្យាឌីជីថលជាឱកាសល្អមួយដើម្បីលោតផ្លោះចូលទៅកាន់អនាគត ហើយក្នុងនោះ ត្រូវមានការទទួលយកឱ្យបានលឿននូវ បច្ចេកវិទ្យា និងការផ្សព្វផ្សាយនវានុវត្តន៍ទាំងក្នុងវិស័យសាធារណៈ និងឯកជន។ ដើម្បីទាញយកអត្ថប្រយោជន៍បានកាន់តែច្រើនពីបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤.០ ត្រូវមានច្រើនថែមទៀតនូវលទ្ធភាពបត់បែន និងការសម្របខ្លួនតាមរយៈការគួបផ្សំគ្នាឱ្យបានត្រឹមត្រូវនូវធនធានមនុស្សជាពិសេសអ្នកមានជំនាញខ្ពស់ផ្នែកឌីជីថល បច្ចេកទេសពាណិជ្ជកម្ម និងការគ្រប់គ្រង។




រូបភាព២៖ គុណភាពគ្រូក្នុងយុគសម័យឌីជីថល ដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សហកម្មជំនាន់ទី៤.០
(Technological Pedagogical Content Knowledge (TPACK))

# បញ្ជីគន្ថនិទ្ទេស


[1]. បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន. អាទិភាពកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព, ១៩ វិច្ឆិកា ២០១៨

[2]. បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន. សាលាជំនាន់ថ្មីដើម្បីកសាងគុណភាពពលរដ្ឋនៅកម្ពុជា, ១៩ វិច្ឆិកា ២០១៨

[3]. បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន. កំណែទម្រង់អប់រំឆ្ពោះទៅគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤, រដ្ឋសភា១៩ វិច្ឆិកា ២០១៨

[4]. CDRI, សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១៩, ការប្រែក្លាយផ្នែកឌីជីថលឆ្ពោះទៅកាន់ឧស្សាហកម្ម៤.០ ២៦ មីនា ២០១៩

[5]. CDRI, ឆែម រិទ្ធី, អ៊ូច ច័ន្ទតារ៉ានី, សុង សុភក្តិ...,ឧស្សាហកម្ម៤.០៖ការប្រមើលឃើញ និងបញ្ហាប្រឈមទៅអនាគតនៃវិស័យកម្មន្តសាលនៅកម្ពុជា, ២៦ មីនា ២០១៩

[6]. CDRI (Cambodia Development Resource Institute). 2018 "Cambodia Outlook Brief: Science and Technology for Industrialization, Economic Growth and Development in Cambodia." Phnom Penh: CDRI.

[7]. Sum Manet. 2018. "Cambodia To Be a Digital Economy by 2030." Khmer Times, 7 Mar 2018. www.khmertimeskh.com/50112147/cambodia-to-be-a-digital-economy-by-2030/.

[8] WEF (World Economic Forum). 2016a. The Future of Jobs: Employment, Skills and Workforce Strategy for the Fourth Industrial Revolution. Geneva: WEF. http://reports.weforum.org/future-of-jobs-2016/employment-trends/

[9]. WEF. 2016b. Human Capital Outlook: Association of Southeast Asian Nations (ASEAN). Kuala Lumpur: WEF.

[10]. WEF. 2018a. "Employment Trends." http://reports.weforum.org/future-of-jobs2016/employment-trends/

[11]. WEF. 2018b. Readiness for the Future of Production Report 2018. Geneva: WEF.

[12]. WEF. 2013-2018. The Global Competitiveness Report. Geneva: WEF.

# ការព្យាករណ៍អំពីចំនួនទេសចរណ៍សរុប ចំនួនទេសចរណ៍តាមផ្លូវអាកាស និង ចំណូលបានពីវិស័យទេសចរណ៍នៅកម្ពុជា

បណ្ឌិត ហាក់ ធីរោ
អនុប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា

## ១. សេចក្តីផ្តើម

**១.១. គោលបំណង** ៖ ព្យាករណ៍អំពីចំនួនទេសចរណ៍សរុប ចំនួនទេសចរណ៍ចូលតាមផ្លូវអាកាស និងប្រាក់ចំណូលបានពីវិស័យទេសចរណ៍ដើម្បីធ្វើផែនការទេសចរណ៍ ពង្រីកឬសង់បន្ថែមព្រលានយន្តហោះអន្តរជាតិ ធ្វើផែនការហិរញ្ញវត្ថុនិងផែនការថវិការជាតិ។ល។

**១.២. ដែនកំណត់** ៖ វិសាលភាពនៃការស្រាវជ្រាវនេះគឺយើងប្រមូលយកទិន្នន័យបានពីក្រសួងទេសចរណ៍ រួចហើយព្យាករណ៍តែអំពីចំនួនទេសចរណ៍សរុប ចំនួនទេសចរណ៍ចូលតាមផ្លូវអាកាស និងប្រាក់ចំណូលបានពីវិស័យទេសចរណ៍ ដោយមិនបានធ្វើការព្យាករណ៍លំអិតអំពីតម្រូវការចំនួនបន្ទប់សណ្ឋាគារឬផ្ទះសំណាក់ ចំនួនភោជនីយដ្ឋាន ចំនួនទីភ្នាក់ងារទេសចរណ៍ ចំនួនមគ្គុទ្ទេសក៍ទេសចរណ៍ទៅតាមជាតិសាសន៍និងភាសានិមួយៗ ចំនួនការងារដែលបង្កើតឡើងដោយវិស័យទេសចរណ៍។ល។

**១.៣. លទ្ធផលរំពឹងទុក** ៖ បង្កើតកម្មវិធីកុំព្យូទ័រថ្មីជាភាសាខ្មែរដើម្បីរកសមីការរឺហ្គ្រេស្យុងប្រសើរបំផុតសម្រាប់ព្យាករណ៍អំពីចំនួនទេសចរណ៍សរុប ចំនួនទេសចរណ៍ចូលតាមផ្លូវអាកាស និងប្រាក់ចំណូលបានពីវិស័យទេសចរណ៍។

## ២. ការប្រមូលទិន្នន័យ

| តាងឆ្នាំ | ឆ្នាំ | ចំនួន ទេសចរណ៍សរុប | ចំនួនទេសចរណ៍ ចូលតាមផ្លូវអាកាស | ចំណូល (លានដុល្លា) |
|---|---|---|---|---|
| 1 | 1995 | 219680 | 119000 | 100 |
| 2 | 1996 | 260489 | 169000 | 118 |
| 3 | 1997 | 218843 | 219000 | 103 |
| 4 | 1998 | 289524 | 289000 | 166 |
| 5 | 1999 | 367743 | 349000 | 190 |
| 6 | 2000 | 466365 | 419000 | 228 |
| 7 | 2001 | 604919 | 489000 | 304 |
| 8 | 2002 | 786524 | 559000 | 379 |

| | | | | |
|---|---|---|---|---|
| 9 | 2003 | 701014 | 6570000 | 347 |
| 10 | 2004 | 1055202 | 738000 | 578 |
| 11 | 2005 | 1421615 | 832000 | 832 |
| 12 | 2006 | 1700041 | 1049000 | 1049 |
| 13 | 2007 | 2015128 | 1296513 | 1403 |
| 14 | 2008 | 2125465 | 1239407 | 1595 |
| 15 | 2009 | 2161577 | 1111729 | 1561 |
| 16 | 2010 | 2508289 | 1304300 | 1786 |
| 17 | 2011 | 2881862 | 1480407 | 1912 |
| 18 | 2012 | 3584307 | 1722083 | 2210 |
| 19 | 2013 | 4210165 | 2017658 | 2547 |
| 20 | 2014 | 4502775 | 2273493 | 2736 |
| 21 | 2015 | 4775231 | 2476001 | 3012 |
| 22 | 2016 | 5011712 | 2704367 | 3212 |
| 23 | 2017 | 5602157 | 3312738 | 3638 |
| 24 | 2018 | 6201077 | 4096870 | 4375 |

តារាងទី១ ៖ ទិន្នន័យក្នុងរបាយការណ៍ទេសចរណ៍នៃក្រសួងទេសចរណ៍[1]

## ៣. ប្រភេទសមីការរីក្រេស្យុងដែលយើងយកមកប្រើប្រាស់ក្នុងការព្យាករណ៍

### ៣.១. រីក្រេស្យុងលីនេអ៊ែ និង គោលការណ៍ការេតូចបំផុត[2]

ឧបមាថាគេអោយ $n$ ចំនុច $(x_i, y_i)$; $i = \overline{1,n}$។ ខ្សែកោងរីក្រេស្យុងដែលកាត់តាមរឺនៅក្បែរចំនុចទាំងអស់ដែលគេអោយមានសមីការ $y = ax + b$ ហៅថាសមីការរីក្រេស្យុងលីនេអ៊ែ។ ដើម្បីរកមេគុណ $a, b$ នៃសមីការនេះគេត្រូវគណនាភាពខុសគ្នា $\varepsilon_i = y - y_i = ax_i + b - y_i \Rightarrow \sum_{i=1}^{n} \varepsilon_i = \sum_{i=1}^{n}(ax_i + b - y_i)$។ ដើម្បីអោយខ្សែកោងរីក្រេស្យុងលីនេអ៊ែកាត់តាមរឺនៅក្បែរចំនុចទាំងអស់ដែលគេអោយ លុះត្រាតែ $\sum_{i=1}^{n} {\varepsilon_i}^2 = \sum_{i=1}^{n}(ax_i + b - y_i)^2 = f(a,b)$ តូចបំផុត។ ដូច្នេះគេត្រូវរកអប្បបរមានៃអនុគមន៍មានពីរអថេរ $f(a,b)$ គឺត្រូវដោះស្រាយប្រព័ន្ធសមីការលីនេអ៊ែខាងក្រោមរក $a$ និង $b$។

---

[1] Tourism statistics report year 2012-2018, ministry of tourism
[2] BARRY RENDER, RALPH M. STAIR, JR and MICHAEL E. HANNA, ' Quantitative Analysis for Management" eleventh edition, Prentice Hall, 2012 page 117.

$$\begin{cases} f'_a(a,b) = \sum_{i=1}^{n}(ax_i + b - y_i)x_i = 0 \\ f'_b(a,b) = \sum_{i=1}^{n}(ax_i + b - y_i) = 0 \end{cases} \Leftrightarrow \begin{cases} a\sum_{i=1}^{n} x_i^2 + b\sum_{i=1}^{n} x_i - \sum_{i=1}^{n} x_i y_i = 0 \\ a\sum_{i=1}^{n} x_i + bn - \sum_{i=1}^{n} y_i = 0 \end{cases}$$

$$\Leftrightarrow \begin{cases} a = \dfrac{n\sum_{i=1}^{n} x_i y_i - (\sum_{i=1}^{n} x_i)(\sum_{i=1}^{n} y_i)}{n\sum_{i=1}^{n} x_i^2 - \left(\sum_{i=1}^{n} x_i\right)^2} \\ b = \dfrac{(\sum_{i=1}^{n} y_i)(\sum_{i=1}^{n} x_i^2) - (\sum_{i=1}^{n} x_i)(\sum_{i=1}^{n} x_i y_i)}{n\sum_{i=1}^{n} x_i^2 - \left(\sum_{i=1}^{n} x_i\right)^2} \end{cases}$$

រូបមន្តខាងលើហៅថារូបមន្តការេតូចបំផុតសម្រាប់រឺហ្គ្រេស្យុងលីនេអ៊ែ។

### ៣.២. រឺហ្គ្រេស្យុងពហុធាដឺក្រេទី២

សមីការរឺហ្គ្រេស្យុងពហុធាដឺក្រេទី២មានរាង $y = ax^2 + bx + c$។ តាមគោលការណ៍ការេតូចបំផុត មេគុណ $a, b, c$ គណនាចេញពីប្រព័ន្ធសមីការលីនេអ៊ែខាងក្រោម

$$\begin{cases} a\sum_{i=1}^{n} x_i^4 + b\sum_{i=1}^{n} x_i^3 + c\sum_{i=1}^{n} x_i^2 = \sum_{i=1}^{n} y_i x_i^2 \\ a\sum_{i=1}^{n} x_i^3 + b\sum_{i=1}^{n} x_i^2 + c\sum_{i=1}^{n} x_i = \sum_{i=1}^{n} y_i x_i \ , \qquad n = 24 \\ a\sum_{i=1}^{n} x_i^2 + b\sum_{i=1}^{n} x_i + cn = \sum_{i=1}^{n} y_i \end{cases}$$

### ៣.៣. រឺហ្គ្រេស្យុងអ៊ិចស្ប៉ូណង់ស្យែល

សមីការរឺហ្គ្រេស្យុងអ៊ិចស្ប៉ូណង់ស្យែលមានរាង $y = ae^{bx} + c$។ តាមគោលការណ៍ការេតូចបំផុត មេគុណ $a, b, c$ គណនាចេញពីប្រព័ន្ធសមីការមិនលីនេអ៊ែខាងក្រោម

$$\begin{cases} \sum_{i=1}^{n} y_i e^{bx_i} - a\sum_{i=1}^{n} e^{2bx_i} - c\sum_{i=1}^{n} e^{bx_i} = 0 \\ \sum_{i=1}^{n} x_i y_i e^{bx_i} - a\sum_{i=1}^{n} x_i e^{2bx_i} - c\sum_{i=1}^{n} x_i e^{bx_i} = 0, \qquad n = 24 \\ \sum_{i=1}^{n} y_i - a\sum_{i=1}^{n} e^{bx_i} - cn = 0 \end{cases}$$

### ៣.៤. រឺគ្រេស្យុងស្វ័យគុណ[3]

សមីការរឺគ្រេស្យុងស្វ័យគុណមានរាង $y = ax^b + c$។ តាមគោលការណ៍ការេតូចបំផុត មេគុណ $a, b, c$ គណនាចេញពីប្រព័ន្ធសមីការមិនលីនេអ៊ែខាងក្រោម

$$\begin{cases} \sum_{i=1}^{n} y_i {x_i}^b - a\sum_{i=1}^{n} {x_i}^{2b} - c\sum_{i=1}^{n} {x_i}^b = 0 \\ \sum_{i=1}^{n} y_i {x_i}^b \ln(x_i) - a\sum_{i=1}^{n} {x_i}^{2b}\ln(x_i) - c\sum_{i=1}^{n} {x_i}^b \ln(x_i) = 0, \qquad n = 24 \\ \sum_{i=1}^{n} y_i - a\sum_{i=1}^{n} {x_i}^b - cn = 0 \end{cases}$$

## ៤. លំដាប់ពេលវេលា និង ការគណនាតាមកុំព្យូទ័រ

លំដាប់វេលាគឺជារឺគ្រេស្យុងដែលមានអថេរមួយជាពេលវេលា។ ដើម្បីជៀសវាងការគណនាដ៏ស្មុគ្រស្មាញដោយត្រូវលើកឆ្នាំជាការេ ដូចជា $1995^2$, $2018^2$ ...។ល។ យើងតាងពីឆ្នាំ១៩៩៥ដល់ឆ្នាំ២០១៨រៀងគ្នាដោយលេខ 1-24។ ចំពោះប្រព័ន្ធសមីការលីនេអ៊ែអាចដោះស្រាយដោយដៃបាន ប៉ុន្តែប្រព័ន្ធសមីការមិនលីនេអ៊ែ(ករណីរឺគ្រេស្យុងអិចស្ប៉ូណង់ស្យែលនិងរឺគ្រេស្យុងស្វ័យគុណ)ត្រូវការដោះស្រាយតាមកុំព្យូទ័រដោយមិនអាចជៀសរួចឡើយ។

ទំនាក់ទំនងរវាងឆ្នាំនិងចំនួនទេសចរណ៍សរុប ដោយប្រើកម្មវិធីកុំព្យូទ័រ[4]គេគណនាបាន៖

ក. សមីការរឺគ្រេស្យុងលីនេអ៊ែ $y = 260871.441x - 1024572.021$

ខ. សមីការរឺគ្រេស្យុងពហុធាដឺក្រេទី២ $y = 11461.074x^2 - 25655.413x + 217044.351$

គ. សមីការរឺគ្រេស្យុងអិចស្ប៉ូណង់ស្យែល $y = 985638.457e^{0.084x} - 1081752.92$

ឃ. សមីការរឺគ្រេស្យុងស្វ័យគុណ $y = 7604.605x^{2.101} + 157522.574$

| ប្រភេទរឺគ្រេស្យុង | ផលបូកល្មៀង | ចំនួនទេសចរណ៍សរុបឆ្នាំ២០១៩ | ចំនួនទេសចរណ៍សរុបឆ្នាំ២០២០ | ចំនួនទេសចរណ៍សរុបឆ្នាំ២០២១ | ចំនួនទេសចរណ៍សរុបឆ្នាំ២០២២ | ចំនួនទេសចរណ៍សរុបឆ្នាំ២០២៣ |
|---|---|---|---|---|---|---|

[3] បណ្ឌិត ហាក់ ធីពោ “ស្ថិតិសម្រាប់ពាណិជ្ជកម្ម” រាជបណ្ឌិត្យសភាកម្ពុជា ២០១៤

[4] កម្មវិធីកុំព្យូទ័រជាភាសាខ្មែរ រកសមីការរឺគ្រេស្យុងគ្រប់ប្រភេទ (**បង្កើតកម្មវិធីកុំព្យូទ័រ** ដោយបណ្ឌិតហាក់ ធីពោ)

| | | | | | | |
|---|---|---|---|---|---|---|
| លីនេអ៊ែ | 10728401 | 5497214 | 5758085 | 6018956 | 6279828 | 6540699 |
| ពហុធាដឺក្រេទី២ | 2570028 | 6738830 | 7297689 | 7879471 | 8484174 | 9111800 |
| អ៊ិចស្ប៉ូណង់ស្យែល | 3461608 | 6969507 | 7675134 | 8442602 | 9277333 | 10185221 |
| ស្វ័យគុណ | 2643063 | 6750625 | 7317116 | 7908129 | 8523758 | 9164094 |

តារាងទី២ ៖ ការព្យាករណ៍អំពីចំនួនទេសចរណ៍សរុបពីឆ្នាំ២០១៩ដល់ឆ្នាំ២០២៣ដោយប្រើរីហ្គ្រេស្យុង៤ប្រភេទផ្សេងគ្នា

ទំនាក់ទំនងរវាងឆ្នាំនិងចំនួនទេសចរណ៍ចូលតាមផ្លូវអាកាស ដោយប្រើកម្មវិធីកុំព្យូទ័រគេគណនាបាន៖

ក. សមីការរីហ្គ្រេស្យុងលីនេអ៊ែ $y = 139689.783x - 457640.376$

ខ. សមីការរីហ្គ្រេស្យុងពហុធាដឺក្រេទី២ $y = 7359.588x^2 - 44299.919x$ +339648.336

គ. សមីការរីហ្គ្រេស្យុងអ៊ិចស្ប៉ូណង់ស្យែល $y = 173834.046e^{0.128x} + 46892.249$

ឃ. សមីការរីហ្គ្រេស្យុងស្វ័យគុណ $y = 475.011x^{2.789} + 330365.635$

| ប្រភេទរីហ្គ្រេស្យុង | ផលបូកល្មៀង | ចំនួនទេសចរណ៍ផ្លូវអាកាសឆ្នាំ២០១៩ | ចំនួនទេសចរណ៍ផ្លូវអាកាសឆ្នាំ២០២០ | ចំនួនទេសចរណ៍ផ្លូវអាកាសឆ្នាំ២០២១ | ចំនួនទេសចរណ៍ផ្លូវអាកាសឆ្នាំ២០២២ | ចំនួនទេសចរណ៍ផ្លូវអាកាសឆ្នាំ២០២៣ |
|---|---|---|---|---|---|---|
| លីនេអ៊ែ | 6449627 | 3034604 | 3174293 | 3313983 | 3453673 | 3593363 |
| ពហុធាដឺក្រេទី២ | 3759190 | 3831892 | 4162931 | 4508690 | 4869167 | 5244364 |
| អ៊ិចស្ប៉ូណង់ស្យែល | 2427523 | 4314434 | 4897314 | 5559806 | 6312784 | 7168608 |
| ស្វ័យគុណ | 3288299 | 4095653 | 4530924 | 4997204 | 5495429 | 6026530 |

តារាងទី៣ ៖ ការព្យាករណ៍អំពីចំនួនទេសចរណ៍សរុបចូលតាមផ្លូវអាកាសពីឆ្នាំ២០១៩ដល់ឆ្នាំ២០២៣ដោយប្រើរីហ្គ្រេស្យុង៤ប្រភេទផ្សេងគ្នា

ទំនាក់ទំនងរវាងឆ្នាំនិងចំណូលពីវិស័យទេសចរណ៍ ដោយប្រើកម្មវិធីកុំព្យូទ័រគេគណនាបាន៖

ក. សមីការរីហ្គ្រេស្យុងលីនេអ៊ែ $y = 174.099x - 743.702$

ខ. សមីការរីហ្គ្រេស្យុងពហុធាដឺក្រេទី២ $y = 7.687x^2 - 18.091x + 89.124$

គ. សមីការរីហ្គ្រេស្យុងអ៊ិចស្ប៉ូណង់ស្យែល $y = 606.415e^{0.087x} - 712.177$

ឃ. សមីការរីហ្គ្រេស្យុងស្វ័យគុណ $y = 4.848x^{2.116} + 50.516$

| ប្រភេទរីហ្គ្រេស្យុង | ផលបូកល្មៀង | ចំណូលពីវិស័យទេសចរណ៍ឆ្នាំ២០១៩ | ចំណូលពីវិស័យទេសចរណ៍ឆ្នាំ២០២០ | ចំណូលពីវិស័យទេសចរណ៍ឆ្នាំ២០២១ | ចំណូលពីវិស័យទេសចរណ៍ឆ្នាំ២០២២ | ចំណូលពីវិស័យទេសចរណ៍ឆ្នាំ២០២៣ |
|---|---|---|---|---|---|---|
| លីនេអ៊ែ | 6653 | 3608.786 | 3782.885 | 3956.985 | 4131.084 | 4305.184 |
| ពហុធាដឺក្រេទី២ | 2031 | 4441.613 | 4815.591 | 5204.944 | 5609.673 | 6029.776 |
| អ៊ិចស្ប៉ូណង់ស្យែល | 2453 | 4629.961 | 5115.734 | 5645.679 | 6223.813 | 6854.518 |
| ស្វ័យគុណ | 2094 | 4455.636 | 4836.864 | 5234.818 | 5649.570 | 6081.192 |

តារាងទី៤ ៖ ការព្យាករណ៍អំពីប្រាក់ចំណូលបានពីវិស័យទេសចរណ៍ពីឆ្នាំ២០១៩ដល់ឆ្នាំ២០២៣ដោយប្រើរីហ្គ្រេស្យុង៤ប្រភេទផ្សេងគ្នា

## ៥. សេចក្ដីសន្និដ្ឋាន




រូបទី១៖កម្មវិធីកុំព្យូទ័រជាភាសាខ្មែរ រកសមីការរីហ្គ្រេស្យុងប្រសើរបំផុតសម្រាប់ព្យាការណ៍អំពីចំនួនទេសចរណ៍សរុប ចំនួនទេសចរណ៍ចូលតាមផ្លូវអាកាស និង ចំណូលបានពីវិស័យទេសចរណ៍

៥.១. តាមតារាងទី២ ការព្យាករណ៍ប្រសើរបំផុត[5]អំពីចំនួនទេសចរណ៍សរុបចូលមកទស្សនាប្រទេសកម្ពុជាគឺគេត្រូវព្យាករណ៍តាមសមីការរីហ្គ្រេស្យុងពហុធាដឺក្រេទី២ $y = 11461.074x^2 - 25655.413x + 217044.351$ ពីព្រោះវាមានផលបូកល្មៀងតិចជាងគេគឺ 2570028។ ប៉ុន្តែសម្រាប់ស្ថានភាពបច្ចុប្បន្នដែលមាន

[5] កម្មវិធីកុំព្យូទ័រជាភាសាខ្មែរ រកសមីការរីហ្គ្រេស្យុងប្រសើរបំផុតសម្រាប់ព្យាការណ៍អំពីចំនួនទេសចរណ៍សរុប ចំនួនទេសចរណ៍ចូលតាមផ្លូវអាកាស និងចំណូលបានពីវិស័យទេសចរណ៍ (បង្កើតកម្មវិធីកុំព្យូទ័រដោយបណ្ឌិតហាក់ ដឺពេ)

កំនើនទេសចរណ៍ចិនយ៉ាងគំហុក គេគួរព្យាករណ៍តាមសមីការរីហ្គ្រេស្សុងអ៊ិចស្ប៉ូណង់ស្យែល $y = 985638.457e^{0.084x} - 1081752.92$ ដើម្បីបង្ការការខ្វះខាតសណ្ឋាគារ ឬ ផ្ទះសំណាក់ ឬ សេវាទេសចរណ៍ផ្សេងៗជាយថាហេតុ។

៥.២. តាមតារាងទី៣ ការព្យាករណ៍ប្រសើរបំផុតអំពីចំនួនទេសចរណ៍ចូលមកទស្សនាប្រទេសកម្ពុជាតាមផ្លូវអាកាសគឺគេត្រូវព្យាករណ៍តាមសមីការរីហ្គ្រេស្សុងអ៊ិចស្ប៉ូណង់ស្យែល $y = 173834.046e^{0.128x} + 46892.249$ ពីព្រោះវាមានផលបូកល្មៀងតិចជាងគេគឺ 2427523។ រីហ្គ្រេស្សុងអ៊ិចស្ប៉ូណង់ស្យែលនេះមានការព្យាករណ៍ខ្ពស់ជាងគេ សមស្របសម្រាប់ស្ថានភាពបច្ចុប្បន្នដែលមានកំនើនទេសចរណ៍ចិនយ៉ាងគំហុកដើម្បីពង្រីកឬសង់បន្ថែមព្រលានយន្តហោះខ្នាតអន្តរជាតិថ្មីៗ បង្ការការខ្វះខាតព្រលានសម្រាប់ការចុះចតយន្តហោះខ្នាតយក្សទៅថ្ងៃអនាគត។

៥.៣. តាមតារាងទី៤ ការព្យាករណ៍ប្រសើរបំផុតអំពីចំណូលបានពីវិស័យទេសចរណ៍គឺគេត្រូវព្យាករណ៍តាមសមីការរីហ្គ្រេស្សុងពហុធាដឺក្រេទី២ $y = 7.687x^2 - 18.091x + 89.124$ ពីព្រោះវាមានផលបូកល្មៀងតិចជាងគេគឺ 2031។ តម្លៃនៃការព្យាករណ៍ដោយប្រើរីហ្គ្រេស្សុងពហុធាដឺក្រេទី២នេះ សមស្របសម្រាប់ធ្វើផែនការហិរញ្ញវត្ថុ និង ផែនការថវិកាជាតិ។

## ៦. គន្ថនិទ្ទេស

1. Tourism statistics report year 2012-2018, ministry of tourism
2. BARRY RENDER, RALPH M. STAIR, JR and MICHAEL E. HANNA, “Quantitative Analysis for Management” eleventh edition, Prentice Hall, 2012
3. បណ្ឌិត ហាក់ ធីរោ “ស្ថិតិសម្រាប់ពាណិជ្ជកម្ម” រាជបណ្ឌិត្យសភាកម្ពុជា ២០១៤

# សិក្សាលើកំណើនទម្ងន់របស់គោក្នុងស្រុក ដោយប្រើស្មៅស្ដេចផ្កាប់

បណ្ឌិត ឈុំភិត លន់ និងលោក គឹមសាន សុភ័ណ្ឌ
សកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ

## ១. សេចក្ដីផ្ដើម

ការអភិវឌ្ឍវិស័យកសិកម្មគឺជាធាតុមួយដ៏សំខាន់នៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ សម្រេចបានសុវត្ថិភាពស្បៀង និងមានិរន្តរភាពកំណើនសេដ្ឋកិច្ច។ ជាពិសេសទៅទៀតកំណើនសេដ្ឋកិច្ចជាតិគឺពឹងផ្អែកទាំងស្រុងទៅលើវិស័យកសិកម្មដែលមាន ៨៥% ប្រជាជនខ្មែររស់នៅក្នុងតំបន់ជនបទហើយក្នុងនោះ៧៥%ជាគ្រួសារកសិករក្រីក្រ(ក្រសួងផែនការ ២០០៤)។

កម្ពុជាស្ថិតនៅក្នុងតំបន់ត្រូពិចដែលមានរដូវសំខាន់ៗ ២ គឺ រដូវប្រាំង និង វស្សា ។ រដូវប្រាំងជារដូវរាំងស្ងួតចាប់ផ្ដើមពីខែវិច្ឆិកាដល់ខែមេសា រីឯរដូវវស្សាវិញឬរដូវភ្លៀងផ្ដើមពីខែឧសភាដល់ខែតុលា។

អំឡុងពេលរដូវប្រាំង ចំបើងជាចំណីមួយប្រភេទដែលសត្វគោនិយមចូលចិត្តស៊ី ចំបើងមានប្រូតេអ៊ីន ២-៥% និងសាធាតុសសៃ ៧០.២%(Wanapat,1985)។ ក្រៅពីនេះ ផេះចំបើងក៏មានប្រភេទសារធាតុផ្សេងៗទៀតផងដែរ ដូចជាអុកស៊ីតអាលុយមីញ៉ូម ($Al_2O_2$) អុកស៊ីតដែក($Fe_2O_3$) កំបោរ (CaO) អុកស៊ីតម៉ាញ៉េស្យូម (MgO) និងទ្រីអុកស៊ីតស្ពាន់ធ័រ ដែលជាសារធាតុរ៉ែមានសារៈប្រយោជន៍ខ្លាំងណាស់(**Mohamed and Taher, 2006**)។

ចំណែកឯស្មៅសម្រាប់គោស៊ីវិញ ក៏មានច្រើនប្រភេទដែរដូចជាស្មៅស្ដេច(Pennisetum purpureum × p.typhoides) ស្មៅបារាំង ស្មៅដំរី...។ល។ ដែលងាយដាំដុះ ហើយមានទិន្នផលខ្ពស់ទៀតផង។យោងតាមការស្រាវជ្រាវរបស់លោក Benavides et al., (1989)បានអោយដឹងថាស្មៅស្ដេចផ្ដល់នូវទិន្នផល ២២.៩តោន/១ហិតា ហើយអាចកាត់បាន៤ដង/ឆ្នាំ។ លើសពីនេះស្មៅស្ដេចស្ងួតមានប្រូតេអ៊ីន១១.២៣% និង ផេះ ១១.០៦% (ឈុំភិត លន់ ២០០៦)។ ចំណែកឯលោក Caceres,(1989) បានអោយដឹងថាបើគេកាត់ស្មៅក្នុងអាយុ៦អាទិត្យវាមានសារធាតុអរហ្គានិច ៨៨.៧០% និង ស្ករ ១០.៥០%។

**គោលបំណងនៃការស្រាវជ្រាវ:**

-ប្រៀបធៀកំណើនទម្ងន់គោតាមបច្ច័យផ្សេងៗ

-វាយតម្លៃលើចំណីស៊ីចូល និង សន្ទស្សន៍នៃការស៊ីចំណី

## ២. សម្ភារ: និង វិធីសាស្ត្រស្រាវជ្រាវ

### ២.១ សម្ភារ:សម្រាប់ការស្រាវជ្រាវ

## ២.១.១ ទីតាំងនៃការស្រាវជ្រាវ

ការពិសោធ៏ស្រាវជ្រាវត្រូវបានធ្វើឡើងនៅស្ថានីយពិសោធន៏សត្វនៃសកលវិទ្យាល័យភូមិន្ទកសិកម្មដែលស្ថិតនៅក្នុងសង្កាត់ដង្កោរ ខណ្ឌដង្កោរ រាជធានីភ្នំពេញ។

## ២.១.២ សម្ភារ:ការស្រាវជ្រាវ

គោ ៩ក្បាលត្រូវបានទិញពីកសិករនៅខេត្តកណ្តាល។ សត្វគោទាំងអស់នោះជាភេទញី ហើយមានអាយុនិងទម្ងន់ប្រហាក់ប្រហែលគ្នា។

## ២.១.៣ ការផ្តល់ចំណី

ស្មៅស្តេចបានដាំនៅក្នុងស្ថានីយពិសោធន៏សត្វនៃសកលវិទ្យាល័យភូមិន្ទកសិកម្ម ហើយស្មៅនេះត្រូវបានធ្វើការច្រូតកាត់ក្នុងចន្លោះពី ៣០-៤០ថ្ងៃ ម្តង។ បន្ទាប់មកកាត់ជាកំណាត់ខ្លីៗប្រមាណ ៣-៥ ស.ម រួចហើយហាលក្រោមកំដៅថ្ងៃពី ៤-៥ ម៉ោង អោយសល់សារធាតុប្រមាណ៧០% ទើបច្រកចូលទៅក្នុងថង់ប្លាស្ទិចដោយចងមាត់អោយជាប់ការពារមិនអោយខ្យល់ចូល។ ស្មៅផ្អាប់នេះ ត្រូវបានរក្សាទុកក្នុងសីតុណ្ហភាពបន្ទប់រយ:ពេល ៣-៤សប្តាហ៏ ទើបយកទៅអោយគោស៊ី។

## ២.១.៤ វិធីសាស្ត្រស្រាវជ្រាវ

ការពិសោធ៏ស្រាវជ្រាវត្រូវបានធ្វើរយ:ពេល៨៤ថ្ងៃ ដោយគោទាំង៩ក្បាលនោះ ត្រូវបានបែងចែកជា៣បច្ច័យតាមគំរូបែងចែកដោយចៃដន្យពេញលេញ(CRD=Completely Randomized Design)។ចំណែកឯបច្ច័យ (T= Treatment) និមួយៗត្រូវបានធ្វើការពិសោធ៏សារឡើង ៣សារ (three replications) ហើយក្នុងមួយបច្ច័យមានគោ១ក្បាល។

តារាងទី១: ប្លង់ពិសោធន៏

| | | |
|---|---|---|
| T0 | $T_2$ | $T_1$ |
| $T_1$ | $T_0$ | $T_2$ |
| $T_2$ | $T_1$ | $T_0$ |

សំគាល់:

$T_0$ : ចំបើង+ផ្អកស្មៅស្តេច

$T_1$ : ចំបើង+ផ្អកស្មៅស្តេច+ផេះចំបើង១%

$T_2$ : ចំបើង+ផ្អកស្មៅស្តេច+ផេះចំបើង២%

## ២.១.៥ ការផ្តល់ចំណី

ការផ្តល់ចំណីមាន២ដំណាក់ការណ៏ះ

-ផ្តល់ចំបើងដល់គោទាំងអស់ពីម៉ោង៨.០០ព្រឹក ដល់១១.០០ចំណី

-ផ្តល់ចំណីស្មៅស្តេចផ្អាប់ដោយសេរីរហូតដល់យប់

តារាងទី២: សារធាតុគីមីរបស់ស្មៅស្តេច

| **សារធាតុគីមី (%)** | **Sample** | |
|---|---|---|
| | ស្មៅស្តេចស្រស់ | ស្មៅស្តេចផ្កាប់ |
| **សារធាតុសោះទឹក (DM)** | **១៧.១៩** | **៣២.០៨** |
| **ភាគរយនៃសារធាតុសោះទឹក (DM%)** | | |
| **ផេះ** | **១២.៨៤** | **១៦.៤២** |
| **សារធាតុអរហ្គានិច(OM)** | **៨៧.១៦** | **៨៣.៥៨** |
| **ប្រូតេអ៊ីន%** | **១១.៣២** | **១០.៧៦** |

ប្រភប: មន្ទីរពិសោធន៏នៃសកលវិទ្យាល័យភូមិន្ទកសិកម្ម(២០១០)

## ២.២ ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យត្រូវបានបែងចែកជា២ផ្នែកសំខាន់ៗ៖

- ការប្រមូលទិន្នន័យចំណី: ចំណីទាំង២មានចំបើងនិងស្មៅស្តេចផ្កាប់ត្រូវបានថ្លឹង ហើយកត់ត្រាត្រឹមត្រូវមុននិងដាក់អោយសត្វគោស៊ី។មុននឹងដាក់ចំណីថ្មីអោយវាស៊ីត្រូវថ្លឹងចំណីចាស់ជាមុនសិន។

- ការប្រមូលទិន្នន័យទម្ងន់: ត្រូវសត្វគោត្រូវបានថ្លឹង ហើយកត់ត្រាទុកយ៉ាងហ្មត់ចត់រៀងរាល់២សប្តាហ៏ម្តង ដោយចាប់ផ្តើមពីម៉ោង ៧.០០មុនដាក់ចំណីថ្មី។

## ២.៣ វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលបានពីការពិសោធន៏ស្រាជ្រាវត្រូវបានបញ្ចូលទៅក្នុងកម្មវិធី Microsoft Excel 2010 ហើយធ្វើការវិភាគតាម ONE WAY ANOVA, t-test នៃកម្មវិធី SPSS version 20។

## ៣.លទ្ធផលនិងការពិភាក្សា

តារាងទី២: ប្រៀបធៀបមធ្យមភាគទម្ងន់គោក្នុងស្រុករហូតដល់អាយុ១២សប្តាហ៏(គ.ក)

| អាយុ | បារ៉ាម៉ែត្រ | T0 | T1 | T2 | Sig. |
|---|---|---|---|---|---|
| សប្តាហ៏0 | $\overline{X}$<br>S± | ១១៦.៥៦ ns<br>២.២១ | ១១៥.១៦<br>១.២០ | ១១៦.១០<br>១.១៥ | 0.៥៩ |
| សប្តាហ៏ទី២ | $\overline{X}$<br>S± | ១១៨.៨៣<br>១.៦២ | ១២១.៧៣ ns<br>១.២៨ | ១២១.១<br>0.៨១ | 0.0៨ |
| សប្តាហ៏ទី៤ | $\overline{X}$<br>S± | ១២១.១៦$^{b}$<br>១.១៩ | ១២៦.២0$^{a}$<br>១.0៥ | ១២៣.៣៣$^{b}$<br>0.៥៥ | 0.00៩ |
| សប្តាហ៏ទី៦ | $\overline{X}$ | ១២១.៤៦$^{b}$ | ១៣0.៨៦$^{a}$ | ១២៦.៤0$^{b}$ | |

| | | | | | |
|---|---|---|---|---|---|
| | S± | ២.១៥ | ១.៤១ | ១.១១ | 0.00៤ |
| សប្តាហ៍ទី៨ | $\overline{X}$ S± | ១២៦.៣៣[c] ២.៦១ | ១៣៥.៧៣[a] 0.៤១ | ១៣0.២0[b] 0.៣៤ | 0.00១ |
| សប្តាហ៍ទី១0 | $\overline{X}$ S± | ១២៨.៤0[b] ២.៣0 | ១៣៩.៥៣[a] 0.៥0 | ១៣២.៩៣[b] ១.៤0 | 0.000 |
| សប្តាហ៍ទី១២ | $\overline{X}$ S± | ១៣១.៦៦[b] ២.៣៤ | ១៤៣.៦៦[a] 0.៥0 | ១៣៥.២៦[b] ២.0៨ | 0.00១ |
| មធ្យមភាគ | $\overline{X}$ S± | ១២៣.៧៧[b] ៥.៤១ | ១៣0.៤១[a] ៩.៦២ | ១២៦.៣៥[ab] ៦.៦៥ | 0.0១៩ |

បកស្រាយ: លទ្ធផលតារាងទី២ ខាងលើបានបញ្ជាក់អោយដឹងថាមធ្យមភាគទម្ងន់ក្រុមទី១ខ្ពស់ជាងទម្ងន់ក្រុមត្រួតពិនិត្រដោយ p<0.00១ ចំណែកឯមធ្យមភាគទម្ងន់ក្រុមទី១និង មធ្យមភាគទម្ងន់ក្រុមទី២វិញ មានលក្ខណៈ ប្រហាក់ប្រហែលគ្នាដោយសារសារធាតុកំបោរអាចធ្វើអោយសារធាតុសរសៃនិងឈើនៅក្នុងស្មៅស្តេចមានលក្ខណៈទន់។ រីឯមធ្យមភាគទម្ងន់ក្រុមត្រួតពិនិត្រ និង មធ្យមភាគទម្ងន់ក្រុមទី២វិញក៏ មានលក្ខណៈ ប្រហាក់ប្រហែលគ្នាដែរ។




ក្រាហ្វិកទី១: ប្រៀបធៀបមធ្យមភាគទម្ងន់ដោយបច្ច័យខុសៗគ្នា

តារាងទី៣:មធ្យមភាគនៃការស៊ីចំណីដោយបច្ច័យខុសៗគ្នា

| លក្ខណៈ | T0 | T1 | T2 | Sig. |
|---|---|---|---|---|
| n<br>$\overline{X}$ | ៣<br>៨២១១.៥៧[ns] | ៣<br>៨១៦៥.៩៦ | ៣<br>៨0៩៨.៥៤ | 0.២0 |

| S± | ២០៣៥.០៨ | ២០០៨.៧៧ | ២០១៨.៥៣ | |
|---|---|---|---|---|

បកស្រាយ: លទ្ធផលតារាងទី៣ ខាងលើបានបញ្ជាក់អោយដឹងថាមធ្យមភាគនៃការស៊ីចំណីដោយបច្ច័យខុសៗគ្នាមានលក្ខណ: ប្រហាក់ប្រហែលគ្នាដោយ$p>0.0$៥។




ក្រាហ្វិកទី២: ប្រៀបធៀបមធ្យមភាគនៃការស៊ីចំណីដោយបច្ច័យខុសៗគ្នា

តារាងទី៤:មធ្យមភាគសន្ទស្សន៍នៃការស៊ីចំណីដោយបច្ច័យខុសៗគ្នា

| លក្ខណ: | T0 | T1 | T2 |
|---|---|---|---|
| n<br>$\overline{X}$ | ៣<br>១៤.៦៥ | ៣<br>៧.៧២ | ៣<br>១១.៣៨ |

បកស្រាយ: លទ្ធផលតារាងទី៤ ខាងលើបានបញ្ជាក់អោយដឹងថាបច្ច័យ **T1** មានលក្ខណ: ល្អជាងបច្ច័យដ៏ទៃទៀតដោយសារការស្រូបយកសារធាតុប្រូតេអ៊ីនមានលក្ខណ:ល្អប្រសើរជាងក្រុមដ៏ទៃ។

**សន្និដ្ឋាន**

លទ្ធផលនៃការស្រាវជ្រាវខាងលើនេះ អាចសន្និដ្ឋានបានថាបច្ច័យT1 ពិតជាមានមធ្យមភាគទម្ងន់ខ្ពស់ជាងគេពិតប្រាកដមែន($p<0.00$១) ហើយមានសន្ទស្សន៍នៃការស៊ីចំណីល្អជាងក្រុមត្រួតពិនិត្យដែរ។

ដូច្នេះការប្រើធាតុកំបោរ $Ca(OH)_2$ របស់ផេះដែលដុតចំបើងស្រូវអាចជួយធ្វើអោយជាតិសរសៃនិងឈើក្នុងចំបើងទន់ងាយស្រួលរំលាយអាហារពេលគោស៊ីចូលទៅ។

## ឯកសារយោង:


-ឃុំភិត លន់: មន្ទីរពិសោធន៍នៃមហាវិទ្យាល័យវិទ្យាសាស្រ្តនិងវេជ្ជសាស្រ្តសត្វ (២០០៦)

-មន្ទីរពិសោធន៏នៃសកលវិទ្យាល័យភូមិន្ទកសិកម្ម(២០១០)
-**Benavides et al., 1989.** Elevage du mouton en zone tropical humide page 11,97,98.

-**Caccers, O,Santena,H,1989.** The effect of forage quality offered upon nutrient value of the tropical grass.

-**Mohamed A. El-Sayed and Taher M. El-Samni(2006);** Physical and Chemical Properties of Rice Straw Ash and Its Effect on the Cement Paste Produced from Different Cement Types**;** Vol. 19, pp. 21-30

-**Ministry of Planning(2004):** Agricultural Sector Strategic Development (2006-2010)

-**National Institute of Statistics**, 2006

-**Wanapat, M.**,1985.Improving rice straw quality as ruminant feed by urea treatment in Thailand.

# ប្រាសាទថ្មី និងសិលាចារឹកថ្មី១ទៀតទើបរកឃើញនៅសម្ពុបុរៈ


ស្រាវជ្រាវ និងរៀបរៀងដោយ សាស្ត្រាចារ្យបណ្ឌិត ធុយ ចាន់ធួន

- អនុប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា
- អនុប្រធានសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា
- សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ

Tel: 011 424 767 Email: chanthourn@yahoo.com Face Book: Chanthourn Thuy


ក្រុមស្រាវជ្រាវអំពីទីក្រុងសម្ពុបុរៈ ដែលដឹកនាំដោយលោកសាស្ត្រាចារ្យ បណ្ឌិត ធុយ ចាន់ធួន ចូលរួមស្រាវជ្រាវដោយសាស្ត្រាចារ្យ បណ្ឌិត ម៉ៅ ឈាងឡេង និងលោកគ្រូ ហេ សុខសាយ បានធ្វើការស្រាវជ្រាវយ៉ាងសកម្មទៅលើក្រុងបុរាណ ប្រាសាទបុរាណ រម្មណីយដ្ឋានប្រវត្តិសាស្ត្រ និងទីតាំងបុរាណស្ថាន ដែលមានទំនាក់ទំនងនឹងអរិយធម៌ចេនឡាដីគោក ចាប់តាំងពីឆ្នាំ២០១៥។ វិសាលភាពនៃការស្រាវជ្រាវគឺខេត្តក្រចេះជាមជ្ឈមណ្ឌលនៃការស្រាវជ្រាវ ពាក់ព័ន្ធទៅតំបន់រណបមួយចំនួនទៀតដូចជា ភាគខាងត្បូងគឺខេត្តត្បូងឃ្មុំតំបន់ប្រាសាទជើងអង្គ ប្រសាទអណ្តោត ប្រាសាទព្រៃនគរក្នុង ... ភាគខាងកើតអតីតខេត្តកំពង់ឈើទាល និងស្រកាលិញ (ឡុកនិញ ខេត្តសុងប៊ែរ ឬបៀនហ្វឿក វៀតណាមបច្ចុប្បន្ន) ភាគឦសាននៃខេត្តមណ្ឌលគិរី និងខេត្តរតនគិរី ភាគខាងជើងគឺខេត្តស្ទឹងត្រែងប្រាសាទបាដើម ប្រាសាទបាចុង ប្រាសាទព្រះគោ... និងតំបន់អតីតភវបុរៈ (តំបន់ប្រាសាទវត្តភូចម្បាសាក់ ឡាវ) និងតំបន់ខាងលិចគឺខេត្តកំពង់ធំទល់នឹងឦសានបុរៈ ព្រៃឡង់ (ប្រាសាទសៀមកាត់សក់) និងតំបន់ភ្នំជី ឯតំបន់និរតីគឺទំនាក់ទំនងតំបន់ប្រាសាទភ្នំហាន់ជ័យក្នុងខេត្តកំពង់ចាម។

គួរបញ្ជាក់ថា៖ ក្រុមស្រាវជ្រាវយើងខ្ញុំសន្និដ្ឋានថា អរិយធម៌សម្ពុបុរៈ គឺមានរាជវាំងនៅ តំបន់វត្តសសរ ១០០ និងតំបន់កំណប់ទួល ម៉ឺនឈឹម ឬឧកញ៉ាម៉ឺនឈឹម ដោយសំអាងលើលើបុរាណវត្ថុ និងទីតាំប្រាសាទបុរាណនានា។ អរិយធម៌សម្ពុបុរៈនេះ កើតមានតាំងប្រហែលជាក្នុងដើមនៃគ្រិស្តសករាជឬក្រោយអរិយធម៌នគរភ្នំបន្តិចបន្តួចប៉ុណ្ណោះ (ដោយអរិយធម៌រីកសាយភាយពីជាយសមុទ្រមកមុន) តែលោក ហ៊ុន ឈុនតេង បានបញ្ជាក់ថា គឺដោយសារសិលាចារឹកតាកឹងK.125 នាឆ្នាំ១០០១គ.ស.នេះឯង ទើបគេដឹងថា សម្ពុបុរៈ ត្រូវនឹងស្រុកសំបូរខេត្តក្រចេះ, ព្រះបាទ សូរ្យវម៌្មទី១ មានស្រុកកំណើតនៅក្នុងតំបន់នេះ មិនដូចលោកសេដេសស្មានថា លោកមកពីជ្រោយម៉ាឡេនោះទេ។ ការអះអាងរបស់លោកសីដេសដោយផ្អែកលើគម្ពីរជិនកាលមាលិនីដែលព្រះថេរមួយអង្គតាក់តែងឡើងកាលពីសតវត្សរ៍ទី១៦នៅធៀងម៉ៃអំពីស្តេចសុជិតរាជដែលបានវាតទីកម្ពុជាទេសមកពីជ្រោយម៉ាឡេនោះ មិនពិតទេ។ វាគ្រាន់តែជារឿងព្រេងនិទានមួយ សរ

សេរជាភាសាបាលី។ ចារឹកនេះឲ្យដឹងថែមទៀតថា ក្សត្រីមួយចំនួនដែលរស់នៅតាមខេត្តដូចជាបងប្អូនស្រី ព្រះបាទជយវម៌្មទី២ ទាំងបួនរូប មានមួយរូបបានកសាង«កម្រតេងជគត តរាជ»នៅតំបន់សម្ភុបុរៈនេះ... ។ ភស្តុតាងដ៏សំខាន់មួយទៀតរបស់សម្ភុបុរៈគឺ សិលាចារិក K.127 ដែលបានយកមកពីប្រាសាទត្រពាំងព្រៃ (ជិតទួលកំណាប់ម៉ឺនឈឹម ឬឧកញ៉ាម៉ឺនឈឹម) ជាសិលាចារិកបញ្ជាក់អំពីលេខសូន្យ ដំបូងក្នុងពិភពលោក ដែលត្រូវបានប្រើក្នុងឆ្នាំ៦០៥ស.គ. ....

កាលពីថ្ងៃសៅរ៍ ២កើត ខែចេត្រ ឆ្នាំ ច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ត្រូវនឹងថ្ងៃទី៦ ខែមេសា ឆ្នាំ ២០១៩ លោកគ្រូ ហេ សុខសាយ បានរកឃើញទីតាំងគ្រឹះប្រសាទថ្មីមួយនៅខាងកើតឃុំសំបុក មានសិលាចារិកមួយផ្ទាំងថ្មី ដែលមិនទាន់មានការសិក្សានៅឡើយ ជាមេទ្វារនៃប្រាសាទនោះត្រូវបានរកឃើញ។ គ្រឹះប្រាសាទនេះមិនទាន់មានចុះផ្សាយក្នុងសៀវភៅកំណត់ត្រារបស់បារាំង ក្នុងសៀវភៅបញ្ជីប្រាសាទខ្មែរដោយលោកលុយណេដឺឡាហ្សុងគៀ បោះពុម្ពក្នុងឆ្នាំ១៩០២,១៩០៧ និង ១៩១១ (Inventaire Descriptif des Monuments du Cambodge par E. Lunet de Lajonquière. 1902, 1907,1911)។ ជាមួយគ្នានេះដែរគ្រឹះប្រាសាទនេះមិនទាន់មានចុះបញ្ជីដោយក្រុមស្រាវជ្រាវអំពីប្រាសាទដែលដឹកនាំដោយលោក ផាន់ ណាឌី និងសហការីនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហការជាមួយសាលាបារាំងចុងបូព៌ា ចុះសិក្សាទីតាំងប្រាសាទខ្មែរដោយកំណត់និយាមការភូមិសាស្ត្រ (GPS) និងបានផលិតជាផែនទីប្រាប់ពីទីតាំងប្រាសាទខ្មែរ និងបុរាណស្ថានមួយចំនួននៅឡើយ។ ប្រាសាទនោះមានឈ្មោះថា ប្រាសាទត្រពាំងព្រៃ (ស្ថិតនៅក្នុងព្រៃ) ចម្ងាយ១២.គ.ម. ខាងកើតភូមិកាកុត ឃុំសំបុក ស្រុកចិត្របុរី នៃខេត្តក្រចេះ។ បន្ទាប់ពីការរាយការណ៍ទៅខាងមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តក្រចេះ ហើយក៏បានទៅទទួលយកសិលាចារិក១ផ្ទាំងមករក្សាទុកក្នុងសារមន្ទីរខេត្ត កាលពីថ្ងៃ១២ មេសា ២០១៩ ។

ទំហំសិលាចារិកនោះមាន បណ្ដោយ១.៧៦.ម. ទទឹង០.៤៦.ម. កម្រាស់០.១.ម. មានអក្សរចំនួន២២ជួរ ។ លោកសាស្ត្រាចារ្យបណ្ឌិត វង់ សុធារ៉ា អ្នកសិលាចារិកវិទ្យានៃមហាវិទ្យាល័យប្រវត្តិសាស្ត្រ បានវាយតម្លៃសិលាចារិកនេះថា ប្រហែលបានចារនៅក្នុងកំឡុងសតវត្សទី៧នៃគ្រិស្តសករាជ ដោយយោងលើតួអក្សរបុរាណ។ លោកសាស្ត្រាចារ្យ ហ៊ុន ឈុនតេង ដែលបានបកប្រែសិលាចារឹកនេះបានអះអាងដូចគ្នានឹងសាស្ត្រាចារ្យបណ្ឌិត វង់ សុធារ៉ា ថាសិលាចារិកនេះគឺចារក្នុងកំឡុងសតវត្សទី៧ នៃគ្រិស្តសករាជ ជាភាសាខ្មែរសុទ្ធ។ លោកសាស្ត្រាចារ្យ ហ៊ុន ឈុនតេង ក៏បានបញ្ជាក់បន្ថែមថា កាសិក្សាសិលាចារិកនៅតំបន់សម្ភុបុរៈ មានភាពចម្លែល ជាងតំបន់នានា ដោយអក្សរសង្កេតឃើញមានទម្រង់អក្សរខ្មែរបុរាណតំបន់នោះមានការវិវឌ្ឍតិចតួច ក្នុងកំឡុងសតវត្សទី៦ ដល់ទី៨ នៃគ្រិស្តសករាជ មានន័យថាតួអក្សរសម័យនោះមានសភាពស្រ

ជៀងៗគ្នា។ កាលណាសិលាចារិកមិនមានកាលបរិច្ឆេទ ចារនៅក្នុងផ្ទាំងនោះពិបាកនឹងវាយតម្លៃថា នៅក្នុងសតវត្សណាឱ្យពិតប្រាកដណាស់ យើងត្រូវសិក្សាប្រៀបធៀបទៅរចនាបទបែបបុរាណវត្ថុវិទ្យាថែមទៀត។ សាស្ត្រាចារ្យ ឃៀង វីរបុត្រ បានរៀបរៀងសិលាចារឹកកម្ពុជា សម័យមុនអង្គរ ក្នុងឆ្នាំ២០១៨ (ជាឯកសារប្រើប្រាស់ផ្ទៃក្នុងសម្រាប់ការបង្រៀនថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរឆ្នាំទី២ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ) បានបញ្ជាក់ដូចគ្នាទៅនឹងការអះអាងរបស់បណ្ឌិត វង់ សុធារ៉ា និង ហ៊ុន ឈុនតេង ផងដែរ។ ការបកប្រែរបស់មិត្តអ្នកជំនាញសិលាចារិក បានបញ្ជាក់ថា៖ សិលាចារិកនេះចារឡើងក្នុងគោលដៅ ថ្វាយជាតង្វាយដល់អាទិទេពព្រហ្មញ្ញសាសនា ព្រះគម្តែងអញស្រីព្រឹទ្ធេស្វរ[1](/ស្រីព្រឹទ្ធេស្វរៈ) ជានិកាយព្រះឥសូរដែលមានវណ្ណាប់ជាច្រើនសម្រាប់ថ្វាយ សម្រាប់ថ្ងៃសីល ថ្ងៃថ្វាយផ្កាមាន អង្ករ២លិះ ប្រេងចន្ទន៍១ចន្លុរ ស្លា២ដំបរ កន្លែងគ្របយជ្ញ១ គឺសម្រាប់ចតុមាស(បួនខែ)ប៉ុណ្ណោះ។ ខ្ញុំបម្រើ ស្រែ ច្បារដំណាំ គោ គឺថ្វាយជាចតុជាតក[2]ដល់អាស្រម។ វណ្ណាប់បូជាដល់អាស្រមមានស្រូវ១កញ្ជើ សម្ល២ផ្នែក(មុខ) ស្លា២ដំបរ សម្លៀក១យៅ។

ចុងបញ្ចប់នៃសិលាចារិកនេះ បញ្ជាក់ពីបុណ និងបាបនៃអ្នកកសាង ថែរក្សាឬអ្នកបំផ្លាញ ដូចមានចែងថា៖ (ក្នុងជួរទី១១-១៥) អ្នកណាដែលយក(ទ្រព្យទាំងនេះ) អ្នកណាដែលរារាំង អ្នកណាដែលបំផ្លាញ គឺអ្នកនោះលន្លឹងក្នុងនរក២៧ជាន់ដរាបណាព្រះចន្ទ្រនិងព្រះអាទិត្យនៅតែមាន[3]។ (ហើយជួរទី១៥-២១) អ្នកសិង[4]កំឡុង(ទីនោះ) គឺម្រតាញជាបំនួសរស់នៅអាស្រម ម្រតាញជាផ្ទុះ[5] អ្នកជាប្រធានស្រុក ដែលពុំពោលប្រាប់ដល់អ្នកដែលដកយក(ទ្រព្យទាំងនោះ)ចេញពីព្រះ ចេញពីប្រាសាទ (និង)អ្នកដែលមករារាំងក៏ធ្លាក់ទៅនរកដែរ (ប្រែសម្រួលដោយលោកសាស្ត្រាចារ្យ ហ៊ុន ឈុនតេង, ខែមេសា ឆ្នាំ២០១៩)។

សូមបញ្ជាក់ផងដែរថា សិលាចារិកនៃប្រាសាទត្រពាំងព្រៃ ជាសិលាចារិកទើបនឹងរកឃើញថ្មី ដែលក្រុមអ្នកស្រាវជ្រាវសម្តុបុរៈ ដឹកនាំដោយសាស្ត្រាចារ្យបណ្ឌិត ធុយ ចាន់ធួន ទើរកឃើញគ្រឹះប្រាសាទនេះនៅក្នុងដំណើររុករុកបិតិកកណ្ឌសម្ពុបុរៈ ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៩ ថ្មីៗនេះ។ ការស្រាវជ្រាវនេះធ្វើឡើងតាមជំនាញនិងចំណេះរបស់ក្រុមយើង មិនទាន់មានមូលនិធិណាគាំទ្រនៅឡើយ។ យើងខ្ញុំសូមអំពាវនាវដល់សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី និងជនរួមជាតិ មេត្តាចូល

---

[1] ទេពអង្គនេះត្រូវនឹងពាក្យហៅក្នុងសិលាចារឹកខ្មែរសម័យមុនអង្គរថា «វ្រះចសិ»។

[2] ចតុជាតក = គ្រឿងដង្វាយដែលមានបួនមុខ។

[3] ដរាបណាព្រះចន្ទ្រនិងព្រះអាទិត្យនៅតែមាន ដរាបនោះអ្នកទាំងនោះនៅតែលន្លឹងក្នុងនរកនោះពុំ ែលង។

[4] សិង = ស្នាក់នៅរៀបចំបូជាពិធីកម្មផ្សេងៗក្នុងប្រាសាទឬអាស្រម។

[5] ម្រតាញផ្ទុះ = បព្វជិតប្រោសព្រំជម្រះមន្ទិល...។

រួមសិក្សា អភិរក្ស និងអភិវឌ្ឍន៍ កេរ្តិ៍ដំណែលដូនតារបស់យើងទាំងអស់គ្នា។ សម្ភុបុរៈជាអរិយធម៌មុនអង្គរ នៅជាប់ដងទន្លេមេគង្គក្នុងខេត្តក្រចេះ អរិយធម៌នេះមិនទាន់មានការសិក្សាច្រើននៅឡើយ ប្រាសាទថ្មីៗ ទើបនឹងរកឃើញជាច្រើនទៀត យើងខ្ញុំនឹងបង្ហាញជាបន្តបន្ទាប់! សូមជនរួមជាតិជ្រាបថា ពូជខ្មែរជាពូជអ្នកខ្លាំង ជាពូជអ្នកកសាង ជាពូជអ្នកបង្កើត មិនមែនដូចអ្នកជិតខាងជាពូជអ្នកលួច អ្នកបោក និងជាអ្នកប្លន់នោះទេ!!!!

សូមជនរួមជាតិមានសុភមង្គលជានិច្ច!

រីករាយចុងសប្តាហ៍!!!

រាជធានីភ្នំពេញ, ថ្ងៃទី៤ ខែឧសភាឆ្នាំ២០១៩

សាស្ត្រាចារ្យបណ្ឌិត ធុយ ចាន់ធួន



សាស្ត្រាចារ្យបណ្ឌិត ធុយ ចាន់ធួន នៅលើគ្រឹះប្រាសាទត្រពាំងព្រៃ



លោកគ្រូ ហេ សុខសាយ ពិនិត្យសិលាចារិកដែលទើបរកឃើញ



ទម្រង់អក្សរនៃសិលាចារិកប្រាសាទត្រពាំងព្រៃសតវត្សទី៧គ.ស ដែលទើបរកឃើញ

# អន្តេបទ/-អ់ម.ណា-/ឬ/-អ៉ំម.ន-/

បណ្ឌិត វង្ស មេង
អនុប្រធានវិទ្យាស្ថានភាសាជាតិ

## សេចក្តីផ្តើម

អន្តេបទ /-អ់ម.ណា-/ ឬ /-អ៉ំម.ន-/នៅក្នុងពេលបច្ចុប្បន្នក្លាយជាប្រធានបទមួយយ៉ាងសំខាន់នៃភាសាខ្មែរសម័យទំនើប ពីព្រោះ អន្តេបទនេះមានការសិក្សានិងសម្មតិកម្មពីរផ្សេងគ្នា។ សម្មតិកម្មទីមួយបានលើកឡើងថា អន្តេបទនេះមានតាំងពីសម័យបុរាណកាលមកម្ល៉េះ ហេតុដូច្នេះ ទម្រង់/-អ់ម.ណា-/ ឬ /-អ៉ំម.ន-/គឺជាទម្រង់មួយដែលមានលក្ខណៈជាអន្តេបទនៅក្នុងភាសាខ្មែរ ដោយរក្សាលក្ខណៈរបស់ខ្លួនតាំងពីបុរាណកាលមក ដូចមាន លោក សាស្រ្តាចារ្យ ឡុង សៀម បានអះអាងបញ្ជាក់ជាភស្តុតាងថា៖ *«តាមសិលាចារឹកមួយចំនួននាសតវត្សទី៧ ផ្នត់ដែក /-អ់ម.ណា-/ ឬ /-អ៉ំម.ន-/ មិនប្រើជាពាក្យកម្លាយជម្មតាទេ គេប្រើវាសម្រាប់សំដែងអំពើ ទម្រង់អកម្មនៃកិរិយាស័ព្ទ(le passif)។ ផ្នត់ដែកនេះទទួលន័យជាផ្នត់ដែក សម្រាប់បង្កើតនាមអរូបីនិងនាមតាងរូបធាតុដោយសារលទ្ធផលដែលទទួលបានពីបម្លែងន័យនៃភាពអកម្ម។»*[១] ជាមួយគ្នានេះ សាស្រ្តាចារ្យ ច័ន្ទ សំណព្វ បានលើកឡើងផងដែរថា៖*«ផ្នត់ដែក[-អ់ម.ណា-] ឬ [-អ៉ំម.ន-] អាចកម្លាយពាក្យឫសខ្លះឲ្យកើតបានតែជានាមសព្ទ ហើយក៏អាចកម្លាយពាក្យឫសខ្លះទៀតឲ្យកើតបានទៅជាកិរិយាសព្ទផងនិងនាមសព្ទផង។ ជាក់ស្តែងផ្នត់ដែក[-អ់ម.ណា-] កម្លាយពាក្យឫស **កើត** ឲ្យបានទៅជានាមសព្ទ **កំណើត** ដែលជានាមសព្ទ។ ផ្នត់ដែកដដែលនេះអាច កម្លាយកិរិយាសព្ទ **ចាយ** ឲ្យបានទៅជា **ចំណាយ** ដែលអាចប្រើជាកិរិយាសព្ទក៏បាន។»*[២]

សម្មតិកម្មទីមួយខាងលើសបញ្ជាក់ឲ្យឃើញថា អន្តេបទ*/-អ់ម.ណា-/ ឬ /-អ៉ំម.ន-/* មានការប្រើប្រាស់តាំងពីសម័យបុរាណរហូតមកដល់សម័យបច្ចុប្បន្ន ដោយមានភស្តុតាងនិងអំណះអំណាងដូចបានពិពណ៌នាដូចខាងលើមកស្រាប់។

សម្មតិកម្មទីពីរបានអះអាងថា ភាសាខ្មែរពុំមានអន្តេបទ*/-អ់ម.ណា-/ ឬ /-អ៉ំម.ន-/* នោះទេ ដូចសាស្រ្តាចារ្យ នៅ ស៊ុន បានពិពណ៌នាថា[៣]៖*«...បើយោលតាមទស្សនៈទីពីរ ឃើញថាគ្មាន ផ្នត់ដែក /-*

[១] ឡុង សៀម «ការស្រាវជ្រាវទាក់ទងនឹងកំណកំណើតវាក្យស័ព្ទតាមបម្រើបម្រាស់ផ្នត់នីយកម្ម» ជ.ឯ.ម. ទំព័រ១៦-១៧។

[២] ច័ន្ទ សំណព្វ ***បង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ***រាជបណ្ឌិត្យសភាកម្ពុជា ២០១០ ទំព័រ១១៣។

[៣] នៅ ស៊ុន «ដំណើរការកំលាយពាក្យខ្មែរ» អត្ថបទសិក្ខាសាលា ធ្វើឡើងនៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ទំព័រ៣។

*អំម.ណ-/ ឬ /-អ៉ំម.ន-/ នោះទេ គឺមានតែផ្នត់ដែក /-អំម-/ ឬ /-ម-/ ប៉ុណ្ណោះនៅក្នុងភាសាខ្មែរ។»* ទាក់ទងទៅនឹងគំនិតនៃការបង្ហាញថា មានទស្សនៈពីរនៅក្នុងការសិក្សានៃអន្តេបទ/-អំម.ណ-/ ឬ /-អ៉ំម.ន-/ លោកសាស្ត្រាចារ្យ ក៏បានគូសបញ្ជាក់ផងដែរថា៖ *«ដោយសារតែមានការនិយមប្រើប្រាស់សម្រាប់បង្កើតពាក្យថ្មីក៏ដោយ ហើយមានស្នាដៃជាច្រើនទាំងជនជាតិខ្មែរ និង បរទេសបង្ហាញថាការប្រើប្រាស់ផ្នត់ ក្នុងការបង្កើតពាក្យថ្មីជាមធ្យោបាយមួយពេញនិយមក៏ដោយ ក៏បើយោលទៅតាមទស្សនៈយើងផ្ទាល់ ឃើញថា អ្នកសិក្សាស្រាវជ្រាវទាំងនោះមិនបានចាប់អារម្មណ៍ខ្លាំងទៅលើដំណើរការកំលាយពាក្យក្នុងភាសាខ្មែរនោះទេ ដែលជាហេតុនាំឲ្យមានការយល់ច្រឡំ ឬ បណ្ដាលឲ្យមានភាពមិនច្បាស់លាស់ក្នុងការរកមូលដ្ឋាន ឬ ពាក្យគ្រឹះដែលពាក្យថ្មីបានក្លាយចេញ ដូចជាពាក្យ «កំណើត» អ្នកសិក្សាស្រាវជ្រាវមួយក្រុមថា ពាក្យនេះក្លាយចេញពាក្យមូលដ្ឋានឬពាក្យគ្រឹះ«កើត» ដោយប្រើផ្នត់ដែក (អន្តេបទ)* /-មន-/*ចំណែកឯអ្នកសិក្សាស្រាវជ្រាវមួយក្រុមទៀតថាពាក្យនេះក្លាយចេញពាក្យមូលដ្ឋាន ឬពាក្យគ្រឹះ«ក្នើត» (ខ្នើត) ដោយប្រើផ្នត់ដែក* /-អំម-/...។»[៤]

ទស្សនៈលើកឡើងរបស់លោក សាស្ត្រាចារ្យ នៅ ស៊ុន ខាងលើចង់បង្ហាញថា នៅក្នុងភាសាខ្មែរអាចមានដំណើរការបង្កើតពាក្យ តាមរយៈទំនាក់ទំនង ពាក្យមូលដ្ឋានឬពាក្យគ្រឹះ>កម្លាយទីមួយ> កម្លាយទីពីរ។[៥] ការបង្ហាញសម្មតិកម្មនេះឡើង គឺក្នុងបំណងអះអាងថា ភាសាខ្មែរមិនមានអន្តេបទ/-អំម.ណ-/ ឬ /-អ៉ំម.ន-/នោះទេ។ ដូចលោក បានលើកឡើងថា៖ « *យើងយល់ថាប្រភេទផ្នត់ក្នុងពាក្យមួយចំនួនដូចជា អំណោយ, អំណាន, អំណួត ជាដើម មិនមែនជាផ្នត់ដែក* /-អំម.ណ-/ ឬ /-អ៉ំម.ន-/ *ដូចដែលអ្នកសិក្សាស្រាវជ្រាវតែងតែនិយមយល់នោះទេ គឺជាផ្នត់ដើម* /-ម.ណ-/ *(ដូចជា វែក-អំវែក, រស់-អំរស់, រក(រក៍)-អំរ, ចាស់-អំចាស់(អម្ចាស់) និងផ្នត់ដែក -n- ដាក់ញែកផ្នត់ដើម និងពាក្យមូលដ្ឋានឬពាក្យគ្រឹះ។»*[៦]

សម្មតិកម្មដែលបានលើកឡើងរបស់សាស្ត្រាចារ្យ នៅ ស៊ុន ស្រប គ្នាទៅនឹងគំនិតរបស់សាស្ត្រាចារ្យ ជីជីម៉ា សុជីវណ្ណ[៧] ដោយលោកស្រីបានអះអាងថា ដំណើរការកម្លាយពាក្យនៃអន្តេបទ/-

---

[៤] ដដែល ទំព័រ២-៣។

[៥] ដដែល ទំព័រ៤។

[៦] នៅ ស៊ុន «ដំណើរការកំលាយពាក្យខ្មែរ» អត្ថបទទសិក្ខាសាលា ធ្វើឡើងនៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ទំព័រ១៥។

[៧] សាស្ត្រាចារ្យ ជីជីម៉ា សុជីវណ្ណ ជាសាស្ត្រាចារ្យបង្រៀនភាសាថៃ នៅមហាវិទ្យាល័យសិល្បៈនិងសង្គមសាស្ត្រ សាកលវិទ្យាល័យជាតិសិង្ហបុរី (National University of Singapore, NUS)។ ការលើកឡើងនេះជាការផ្ដល់យោបល់លើការដឹកនាំ និក្ខេបបទរបស់ស្មេរ នៃថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨ នៅសាកលវិទ្យាល័យជាតិសិង្ហបុរី។

អ់ម.ណ-/ ឬ /-អិ់ម.ន-/គឺកើតមកដោយសារទំនាក់ទំនងនៃអន្តេបទ/-ម-/និង/-ន-/ ដោយលោកស្រី បានពិពណ៌នាថា អន្តេបទ /-អ់ម.ណ-/ ឬ /-អិ់ម.ន-/ កើតមកអំពីពាក្យឫស ដោយប្រើវិធីកម្លាយទីមួយនៃអន្តេបទ/-ន-/ ហើយប្រើអន្តេបទ/-ម-/លើអន្តេបទ/-ន-/ សម្រាប់បង្កើតអន្តេបទ/-អ់ម.ណ-/ ឬ /-អិ់ម.ន-/។ ការណ៍នេះលោកស្រី បានលើកអំណះអំណាងបង្ហាញថា៖

កើត + /-ន-/> ខ្នើត + /-ម-/> កំណើត

កួច + /-ន-/> ឃ្នួច + /-ម-/> កំណួច

គាប + /-ន-/> ឃ្នាប + /-ម-/> គំនាប

កប់ + /-ន-/> ខ្នប់ + /-ម-/> កំណប់

ជាន់ + /-ន-/> ឈ្នាន់ + /-ម-/> ជំនាន់

បន្ថែមពីលើនេះទៀត លោកស្រីសាស្ត្រាចារ្យ បានបង្ហើបឲ្យដឹងទៀតថា ពាក្យកម្លាយដែលប្រើប្រាស់អន្តេបទ/-ន-/មិនមាន មានត្រឹមតែ /-ម-/ ដោយសារថា ដំណាក់កាលទីមួយដែលប្រើប្រាស់អន្តេបទ/-ន-/បានបាត់បង់ ហើយមានត្រឹមតែ/-ម-/ ដូចជា៖

កាត់+ /-ន-/> ខ្នាត់ ? + /-ម-/> កំណាត់

តែង + /-ន-/> ត្នែង ? + /-ម-/> តំណែង

ចាយ + /-ន-/> ច្នាយ ? + /-ម-/> ចំណាយ

ជន់ + /-ន-/> ឈ្នន់ ? + /-ម-/> ជំនន់

ទុក + /-ន-/> ធ្នុក ? + /-ម-/> ទំនុក

ការបាត់បង់អន្តេបទ /-ន-/ នៅក្នុងពាក្យកម្លាយដែលមានបុច្ឆនសញ្ញាខាងលើ ទំនងជាអាចរកឃើញឬអាចមាននៅក្នុងពាក្យខ្មែរបុរាណ។

ទោះបីជាយ៉ាងណាក៏ដោយ អ្វីដែលលោកស្រីសាស្ត្រាចារ្យបានលើកឡើងគឺជាសម្មតិកម្មមួយដែលមានលក្ខណៈសមហេតុសមផល និង អាចជាគំនិតពិចារណាសម្រាប់ការសិក្សាអំពីដំណើរការនៃពាក្យកម្លាយនៅក្នុងភាសាខ្មែរ។

លោក ហ្វីលីប ជែនន័រក៏បានពិពណ៌នាផងដែរអំពីទម្រង់នៃអន្តេបទ/-អ់ម.ណ-/ ឬ /-អិ់ម.ន-/។ លោកបានបង្ហាញថា[៨]៖ «*ភាសាខ្មែរទំនើបមានព្យាង្គអន្តេបទទោល។ អន្តេបទនេះបង្ហាញទម្រង់ពីរដែលជាវិភាគទានយ៉ាងសំខាន់បំផុត /-Vmn-/ ដែលកើតឡើងជាមួយទម្រង់មូលដ្ឋានទីមួយយ៉ាងច្បាស់លាស់ ហើយ /-Vn-/កើតឡើងនៅក្នុងទម្រង់ទីពីរ។ ទម្រង់ទាំងពីរនេះ V តំណាង «អឬអិ» ចំណែកឯ N តំណាង /ម, ន, ង/។ ទម្រង់/-Vmn-/មានកាឡារូបCចំណែកឯទម្រង់ /-Vn-/ មាន*

[៨] Philip N. Jenner, ***Affixation in Modern Khmer***, op.cit., p.165.

*កាឡរូប /-អ៉ម-, -អ៉ន-, -អ៉ង-/និង /-អ់ម-, -អ់ន-, -អ់ង-/។ កាឡរូប /-អ៉ន-, -អ៊ាន-/មានលក្ខណៈផ្សេងៗពីគ្នា។ ព្យាង្គអន្តេបទត្រូវគេបញ្ចូល ដូចនៅក្នុងអព្យាង្គអន្តេបទដែរ គេបញ្ចូលទៅក្នុងពាក្យដោយផ្ទាល់ បន្ទាប់ពីព្យញ្ជនៈដើមព្យាង្គ។ ពាក្យកម្លាយជាលទ្ធផលបានក្លាយទៅជាទ្វេព្យាង្គដែលព្យញ្ជនៈដើមព្យាង្គគឺជាបុព្វ ទ្វេព្យាង្គ។ ពាក្យកម្លាយនៃទម្រង់មូលដ្ឋានទីមួយមានព្យាង្គដើម/-n-/ បួល(to utter, talk)>ពំនោល (talking), ចាយ> ចំណាយ។ ពាក្យកម្លាយទម្រង់ទីពីរមានពាក្យឫសជាព្យាង្គបន្ទាប់ពីព្យាង្គសំខាន់ ជ្រៅ>ជម្រៅ, ផ្កាត់>បង្កាត់។»*

ទម្រង់បែបនេះមាន/-Vmn-/ ដែលកើតពីពាក្យឫសទីមួយដែលគេហៅថា ពាក្យកម្លាយទីមួយ។ ទម្រង់/-Vn-/អាចបង្កើតពាក្យជាមួយពាក្យឫសទីពីរដែលគេហៅថាពាក្យកម្លាយទីពីរ។

លោក ហ្សក ម៉ាស្ប៉េរ្ញ មិនបានកត់សម្គាល់សមានកម្មនៃអន្តេបទ/-VN-/ នោះទេ។[៩] ដោយមើលឃើញភាសាខ្មែរពីសំណេរជាដំបូង គាត់បានបែងចែកអសមានកម្មនៃ /-Vm-/ ពីសមានកម្មនៃ /(V)N-/.

លោក ស្រី ជូឌីត ចាកុប[១០] ធ្វើការកត់សម្គាល់ទាំងទម្រង់ /-Vmn-/ និង /-VN-/ ដោយលោកស្រី បានអះអាងថា ទម្រង់នេះបង្កើតពាក្យនៅក្នុងភាសាខ្មែរគឺមានមុខងារសម្រាប់បង្កើតនាមនីយកម្ម ហើយទម្រង់/-VN-/ សម្រាប់បង្កើតនាមឧបករណ៍និងនាមភ្នាក់ងារ។

ដូចបានរៀបរាប់ខាងលើ យើងអាចធ្វើការកត់សម្គាល់ថា ទម្រង់ /-អំម.ណ-/ឬ/-អ៉ម.ន-/ស្ថិតនៅលើ ការពិចារណានៅឡើយថាតើ ទម្រង់បែបនេះគ្រាន់តែជាទម្រង់កើតមាន នៅក្នុងភាសាខ្មែរបុរាណឬយ៉ាងណាឬមួយអាចជាអន្តេបទនៅក្នុងភាសាខ្មែរទំនើបផង។ គំនិតនិងទស្សនៈចំពោះទម្រង់ខាងលើ យើងសង្កេតឃើញថា យោបល់អ្នកស្រាវជ្រាវខាងបស្ចិមប្រទេសបង្ហាញថា ទម្រង់/-អំម.ណ-/ឬ/-អ៉ម.ន-/គឺជាដំណើរការឬជាទំនាក់ទំនងរវាងអន្តេបទ /-ម-/ឬ/-ន-/តែប៉ុណ្ណោះ ដោយហេតុថា ស្រៈ «អ»ខាងមុខគឺគ្រាន់តែជាអាគមសម្រាប់សម្រួលអំណាននៅក្នុងភាសាខ្មែរ។ គំនិតបែបនេះ យើងមិនទាត់ចោលទាំងស្រុងនៅក្នុងការសិក្សារបស់យើងនោះទេ តែយើងនឹងធ្វើការពិចារណា រកហេតុផលនិងតក្កភាពនៅក្នុងភាសាខ្មែរ ដោយសម្អាងទៅលើទិន្នន័យដែលយើងប្រមូលបានថាតើ ទម្រង់នោះជាអន្តេបទឬមិនមែន។ ទិន្នន័យដែលយើងមានអំពីទម្រង់/-អំម.ណ-/ឬ/-អ៉ម.ន-/និងការពន្យល់ពាក្យនោះបានបង្ហាញថា ពាក្យទាំងឡាយនោះកើតមកអំពីពាក្យឫសដូចមាននៅក្នុងការពន្យល់នៅក្នុងវចនានុក្រមបោះពុម្ពឆ្នាំ១៩៦៧ជាភស្តុតាងស្រាប់។ ផ្តើមចេញអំពី នោះទិន្នន័យទាំង១៥៩ពាក្យបាន

[៩] Georges, Maspero, ***Grammaire de la langue khmère*** (cambodgien), op.cit., p.211-115.

[១០] Judith M. Jacob, ***Introduction to Cambodian***, op.cit., p.66-69.

បង្ហាញថាពាក្យទាំងនោះមានប្រភពមកអំពី ពាក្យឫស ហើយមុខងារវេយ្យាករណ៍មាន*នាមលទ្ធផលឬអំពើ កិរិយាសព្ទ គុណនាម និងនិបាតសព្ទ*។

## ៤.១. ការវិភាគទម្រង់/-អំម.ណ-/ឬ/-អុំម.ន-/

ដោយសម្មតិកម្មពីរបានលើកឡើងខាងលើ យើងនឹងធ្វើការវិភាគថាតើទម្រង់ /-អំម.ណ-/ឬ/-អុំម.ន-/ជាអន្តេបទដើមឬមួយជាទម្រង់កម្លាយពីរជាន់។ ដូចយើងបានបង្ហាញជូននៅក្នុងសេចក្តីផ្តើមខាងលើស្រាប់ថា ទម្រង់នេះមានសម្មតិកម្មពីរ។ សម្មតិកម្មទីមួយយល់ថាមិនមានអន្តេបទ /-អំម.ណ-/ឬ/-អុំម.ន-/នោះទេ ដោយមតិនេះបានអះអាងថា ទម្រង់ /-អំម.ណ-/ឬ/-អុំម.ន-/ គឺកើតឡើងតាមវិធីកម្លាយទីមួយនឹងទីពីរ ពាក្យកម្លាយទីមួយកើតមកអំពី អន្តេបទ/-ន-/ ចំណែកឯពាក្យកម្លាយទីពីរកើតមកអំពីអន្តេបទ/-ន-/ជាមួយនឹងអន្តេបទ/-អំម-/ ដើម្បីបង្កើតទម្រង់/-អំម.ណ-/ឬ/-អុំម.ន-/ ដូចមាននៅក្នុងតារាងខាងក្រោម៖

| ពាក្យមូលដ្ឋានឬពាក្យគ្រឹះ | កម្លាយទីមួយ | កម្លាយទីពីរ |
|---|---|---|
| កប់ | ក្នប់ (ខ្នប់) | កំណប់ |
| កើត | ខ្នើត | កំណើត |
| កួច | ក្នួច (ខ្នួច) | កំនួច |
| កៀរ | ក្នៀរ (ខ្នៀរ) | កំណៀរ |
| កៀស | ក្នៀស(ខ្នៀស) | កំណៀស |
| គាប | គ្នាប (ឃ្នាប) | គំនាប |
| គូស | គ្នូស (ឃ្នូស) | គំនូស |
| ចាប់ | ច្នាប់ (ឆ្នាប់) | ចំណាប់ (អារម្មណ៍) |
| ជាប់ | ជ្នាប់ (ឈ្នាប់) | ជំនាប់ |
| ជូត | ជ្នូត (ឈ្នូត) | ជំនូត |
| ដង | ត្នង (ថ្នង) | ដំណង |
| ដូរ | ត្នូរ (ថ្នូរ) | ដំណូរ |
| ដាក់ | ត្នាក់ (ថ្នាក់) | (តំ) ដំណាក់ |

| | | |
|---|---|---|
| ដើរ | ត្នើរ (ថ្មើរ) | ដំណើរ |
| ទាក់ | ទ្នាក់ (ផ្អាក់) | ទំនាក់ |
| ទើរ | (ទ្នើរ) ផ្នើរ | ទំនើប |
| បែក | ប្នែក (ផ្នែក) | បំណែក |
| ពាក់ | ព្នាក់ (ភ្នាក់) | ពំនាក់ |

*តារាងទីមួយ*[១១]*៖ ទម្រង់ដំណើរការកម្លាយពាក្យមូលដ្ឋានឬពាក្យគ្រឹះ ទៅកម្លាយទីមួយ ដោយប្រើផ្នត់ដែកជាព្យញ្ជនៈសូរទោល -n- និងពីកម្លាយទីមួយទៅកម្លាយទីពីរដោយប្រើផ្នត់ដែកជាបន្សំសូរស្រៈផ្សំនិងព្យញ្ជនៈ*/-អំម-/និង/-ម.ណ-/

ការបកស្រាយខាងលើគឺចង់បង្ហាញថា អន្តែបទ /-អំម.ណ-/ឬ/-អឹម់.ន-/ជាទម្រង់អន្តែបទដែលកើតឡើងដោយសារ ទំនាក់ទំនង ពាក្យមូលដ្ឋានឬពាក្យគ្រឹះ> កម្លាយទីមួយ> កម្លាយទីពីរ។ នេះបានន័យថា អន្តែបទ/-អំម.ណ-/ឬ/-អឹម់.ន-/កើតមកអំពីអន្តែបទ/-ន-/ ដោយប្រើអន្តែបទ/-អំម-/។ ដូចគ្នានេះផងដែរ លោក ហ្វីលីប ជែននែរក៏បានបង្ហាញផងដែរថា៖«*ការបកស្រាយមួយបែបទៀតគឺថា /-អំម.ណ-/គឺ ជាសមាសដែលរួមមាន/-អំន-/ជាមួយនឹងCCVF ពាក្យឫសដែល ព២គឺអន្តែបទ/-ន-/៖ បួស>ផ្នួស>បំណួស; ដាំ>ថ្នាំ>ដំណាំ។ លទ្ធភាពពាក្យកម្លាយ/-អំម.ណ-/មួយចំនួនអាចត្រូវគេយកមកធ្វើការប្រៀបធៀបផ្ទាល់ពីពាក្យឫស(មានន័យថា គ្មានការសម្របសម្រួលទៅនឹងឫសនៃCCVF) ដែលគ្មានទិដ្ឋភាពផ្លាស់ប្តូរនៃមធ្យោបាយមិនសមស្របនោះទេ។*»[១២]

ទស្សនៈទីមួយនេះគឺជាលើកឡើង ដោយគ្រាន់តែជាអំណះអំណាងតែមួយប៉ុណ្ណោះហើយ យើងយល់ថាមិនទាន់មានលក្ខណៈរឹងមាំនៅឡើយ ពីព្រោះថា ដំណើរការនៃកម្លាយពាក្យ ពីពាក្យឫសទៅកម្លាយទីមួយនិងពីកម្លាយទីពីរមិនមានលក្ខណៈប្រត្យក្សភាព។ នៅក្នុងភាសាខ្មែរបច្ចុប្បន្ន វាក្យស័ព្ទខ្លះមានដំណើរការកម្លាយពាក្យត្រឹមតែពីពាក្យឫសទៅកម្លាយទីពីរ ចំណែកឯវាក្យស័ព្ទខ្លះទៀតមានត្រឹមតែពាក្យឫសទៅកម្លាយទីមួយតែម្តង ដោយយើងមិនឃើញមាននៅក្នុងកម្លាយទីពីរ ដូចមានតារាងបង្ហាញជូនខាងក្រោម៖

---

[១១] នៅ ស៊ុន ***ដំណើរការកម្លាយពាក្យខ្មែរ*** ជ.ឯ.ម. ទំព័រ៨-៩។

[១២] Philip N. Jenner, ***A Dictionary of pre-Angkorian Khmer***, Doug Cooper (ed.), Pacific Linguistics: Research school of Pacific and Asian Studies, Australian National University, 2009, p.xvii.
*<< Another interpretation is that /-amn-/ is compound, consisting of /-am-/ with a CCVF wordbase in which $C_2$ is infix /-n-/: pvas /  ' to enter holy orders', > phnvas  'holy orders', > pamnvas 'one in holy orders'; tāṃ 'to plant',>*thnāṃ (cf. Modern thnāṃ) /$t^h$nam/ 'plant', > taṃnāṃ 'plantation, land under crops'. The liklihood that some /-amn-/ derivatives may have ben minted analogicallly direct from primary wordbases. (i.e., with no mediating CCVF base) in no way invalidates this alternative view.>>*

| ពាក្យមូលដ្ឋានឬពាក្យគ្រឹះ | កម្លាយទីមួយ | កម្លាយទីពីរ |
|---|---|---|
| ក | - | កំណា |
| កត់ | - | កំណត់ |
| គរ | - | គំនរ |
| គួរ | - | គំនួរ |
| គិត | - | គំនិត |
| ជួញ | - | ជំនួញ |
| ទិញ | - | ទំនិញ |
| ចូល | - | ចំណូល |

*តារាងទីពីរ ពាក្យមួយចំនួនដែលក្នុងការកម្លាយមិនដើរតាមលំដាប់លំដោយ៖ ពាក្យមូលដ្ឋានឬពាក្យគ្រឹះ> កម្លាយទីមួយ>កម្លាយទីពីរគឺ ក្លាយពីពាក្យមូលដ្ឋាន> កម្លាយទីពីរ*[១៣]

ការពន្យល់ខាងលើ គឺក្នុងគោលបំណងបង្ហាញថាភាសាខ្មែរទាក់ទងទៅនឹងទម្រង់/-អំម.ណ-/ ហាក់ដូចជាមិនមាននោះផងទេ ដោយហេតុថា ភាសាខ្មែរអាចមានដំណើរការកម្លាយពាក្យពីពាក្យឫស > កម្លាយទីមួយ> កម្លាយទីពីរ។ សម្មតិកម្មនេះមានលក្ខណៈសមរម្យនឹងមានតក្កភាពអាចទទួលយកបាន ក៏ប៉ុន្តែសំណើនេះហាក់ដូចជា ស្រពិចស្រពិលមិនមានលក្ខណៈទូទៅនិងមិនសមស្របនៅក្នុងភាសាខ្មែរ។ ពីព្រោះ យើងសង្កេតឃើញថា ដំណើរការនេះមានតិចតួចនៅក្នុងភាសាខ្មែរ លក្ខណៈស្ងួចស្តើងបែបនេះមិនអាចធ្វើជាឧបភាសកម្មបានឡើយ ក៏ប៉ុន្តែ យើងអាចយកចំណុចឬលក្ខណៈទាំងនោះមកធ្វើការពិចារណា។

សម្មតិកម្មទីពីរយល់ថា ទម្រង់/-អំម.ណ-/ឬ/-អ៊ំម.ន-/គឺជាអន្តេបទដែលមានមុខងារសំខាន់សម្រាប់បង្កើតនាមសម្គាល់លទ្ធផលនិងអំពើ ព្រមទាំងទម្រង់ទាំងនេះមានកំណើតមកអំពី ពាក្យឫសជាមូលដ្ឋានផងដែរ។ តួយ៉ាងដូចជា សាស្ត្រាចារ្យ ព្រុំ ម៉ល់ បានលើកឡើងថា អន្តេបទ/-អំម.ណ-/ឬ/-អ៊ំម.ន-/អាចប្រើដើម្បីបង្កើតពាក្យកម្លាយ សម្រាប់នាមលទ្ធផលឬអំពើ។[១៤] លោក សាស្ត្រាចារ្យ ហ្វីលីប ជែនន័របានគូសបញ្ជាក់ផងដែរថា អន្តេបទ/-អំម.ណ-/ឬ/-អ៊ំម.ន-/ គឺជាអន្តេបទបុរាណ ដែលកើត

---

[១៣] នៅ ស៊ុន ***ដំណើរការកម្លាយពាក្យខ្មែរ*** ដ.ឯ.ម. ទំព័រ១២។

[១៤] ព្រុំ ម៉ល់ ***ភាសាវិទ្យាអនុវត្តន៍៖ វេយ្យាករណ៍ទម្រង់និយនៃភាសាខ្មែរទំនើប*** ដ.ឯ.ម. ទំព័រ៦-១១។

ឡើងដោយផ្ទាល់បន្ទាប់ពីពាក្យឫស។[១៥]

## ៤.២. មុខងារវេយ្យាករណ៍ទម្រង់/-អំម.ណា-/ឬ/-អ៊ំម.ន-/

លោក សាស្ត្រាចារ្យ ព្រុំ ម៉ល់ បានលើកបង្ហាញថា អន្តបទ/-អំម.ណា-/ឬ/-អ៊ំម.ន-/អាចជាអន្តបទដែលប្រើប្រាស់ ដើម្បីបង្កើតពាក្យកម្លាយសម្គាល់លទ្ធផលឬអំពើ។[១៦] ដូចមាននៅក្នុងឧទាហរណ៍[១៧]៖

កាត់ + /-អំម.ណា-/ > កំណាត់
គូរ + /-អ៊ំម.ន-/ > គំនូរ
ចាស់ + /-អំម.ណា-/ > ចំណាស់
ចាំ + /-អំម.ណា-/ > ចំណាំ
ធី + /-អំម.ណា-/ > ចំណី

លោក សាស្ត្រាចារ្យ ហ្វីលីប ជែនន័រ បានបែងចែកប្រភេទវេយ្យករណ៍នៃទម្រង់នេះជា៤ប្រភេទគឺ នាមដំណើរការ, នាមលទ្ធផល, នាមភ្នាក់ងារ-ឧបករណ៍-ទីកន្លែង, និង នាមសមូហភាព។[១៨] ប្រភេទដូចបានរៀបរាប់ខាងលើគឺចង់បង្ហាញថា គំនិតរបស់លោកគឺ ផ្អែកទៅលើន័យនៃពាក្យរបស់ពាក្យកម្លាយ។

ចំពោះយើងវិញ ទិន្នន័យដែលយើងបានវិភាគនិងរកប្រភេទវេយ្យាករណ៍របស់ពាក្យកម្លាយទម្រង់/-អំម.ណា-/ឬ/-អ៊ំម.ន-/នេះគឺផ្អែកទៅលើទិន្នន័យចំនួន១៥៩ ពាក្យ ដោយយើងបានបែងចែកទៅជា នាមសម្គាល់លទ្ធផលឬអំពើ គុណនាម កិរិយាសព្ទ និងនិបាតសព្ទ។

### ៤.២.១. ទម្រង់/-អំម.ណា-/ឬ/-អ៊ំម.ន-/ បង្កើតនាមសព្ទ

នាមសព្ទនេះអាចមានប្រភពមកអំពីពាក្យឫសជា កិរិយាសព្ទ គុណនាម កិរិយាវិសេសន៍

---

[១៥] Philip N. Jenner, Dictionary of pre-Angkorian Khmer, op.cit., p.xvii <<*The infixes of Old Khmer include /-b-, -m-, -n-/ and /-əN-~əmn-/, which occur directly after the wordbase initial.*>>

[១៦] ព្រុំ ម៉ល់ ***ភាសាវិទ្យាអនុវត្តន៍៖ វេយ្យាករណ៍ទម្រង់និយនៃភាសាខ្មែរទំនើប*** ជ.ឯ.ម. ទំព័រ៦-៧។

[១៧] ឧទាហរណ៍ទាំងនេះគឺជាឧទាហរណ៍ដែលលោកសាស្ត្រាចារ្យបានយកមកពន្យល់ ហើយយើងលើកយកបង្ហាញនិងពិចារណា។

[១៨] Philip N. Jenner, ***Affixation in Modern Khmer***, op.cit., p.169-172.

នាមសព្ទ ជាដើម។

កាត់ + /-អ់ម.ណ-/ > កំណាត់
គាល់ + /-អ៊់ម.ន-/ > គំនាល់
ចារ + /-អ់ម.ណ-/ > ចំណារ
ចូរ + /-អ់ម.ណ-/ > ចំណូរ
ឲ្យ + /-អ់ម.ណ-/ > អំណោយ
អួត + /-អ់ម.ណ-/ > អំនួត

### ៤.២.២.ទម្រង់/-អ់ម.ណ-/ឬ/-អ៊់ម.ន-/បង្កើតគុណនាម

ពាក្យកម្លាយជាគុណនាមបែបនេះ អាចកើតមកអំពីពាក្យឫសជាកិរិយាសព្ទ គុណនាម

សល់ + /-អ់ម.ណ-/ > សំណល់
សាក + /-អ់ម.ណ-/ > សំណាក
សួរ + /-អ់ម.ណ-/ > សំណួរ
សែន + /-អ់ម.ណ-/ > សំណែន
អត់ + /-អ់ម.ណ-/ > អំណត់

### ៤.២.៣.ទម្រង់/-អ់ម.ណ-/ឬ/-អ៊់ម.ន-/បង្កើតកិរិយាសព្ទ

ពាក្យកម្លាយជាគុណនាមបែបនេះ អាចកើតមកអំពីពាក្យឫសជាកិរិយាសព្ទ គុណនាម

កត់ + /-អ់ម.ណ-/ > កំណត់
តែង + /-អ់ម.ណ-/ > តំណែង
ស្នាក់ + /-អ់ម.ណ-/ > សម្នាក់
សឹក + /-អ់ម.ណ-/ > សំណឹក

### ៤.២.៤.ទម្រង់/-អ់ម.ណ-/ឬ/-អ៊់ម.ន-/បង្កើតនិបាតសព្ទ

ពាក្យកម្លាយជាគុណនាមបែបនេះ អាចកើតមកអំពីពាក្យឫសជាកិរិយាសព្ទ

ជុំ + /-អ៊់ម.ន-/ > ជំនុំ
សឹក + /-អ់ម.ណ-/ > សំណឹក

## សន្និដ្ឋាន

ទិដ្ឋភាពអន្តបទនេះនៅក្នុងភាសាខ្មែរ ក៏ដូចជាទិដ្ឋភាពមួយចំនួនផ្សេងទៀតនៅក្នុងភាសាខ្មែរផងដែរ ពីព្រោះទិដ្ឋភាពនោះបានចោទជាបញ្ហានិងសម្មតិកម្មដោយឡែកៗសម្រាប់ការសិក្សាអន្តបទក៏ដូចជាអក្ខរាសបទដទៃទៀត។ អន្តបទ/-អំម.ណ-/បានក្លាយជាចំណោទផងនិងប្រធានបទនៃការសិក្សាផង។

ទម្រង់អន្តបទ /-អំម.ណ-/ឬ/-អុំម.ន-/ បានក្លាយជាប្រធានបទយ៉ាងសំខាន់សម្រាប់ការស្រាវជ្រាវសម័យទំនើប។ អន្តបទនេះ អ្នកសិក្សាស្រាវជ្រាវសម័យថ្មីបានបង្កើតសម្មតិកម្មប្លែក ដោយយល់ឃើញថា ទម្រង់អន្តបទនេះមិនមែនអន្តបទ ក៏ប៉ុន្តែ ការយល់ឃើញបែបនេះគឺប្រាសចាកសម្មតិកម្មបុរាណ ពីព្រោះថា ទម្រង់នេះមានការប្រើប្រាស់តាំងពីសម័យបុរាណមកម្ល៉េះ។ អាស្រ័យហេតុនេះ ការសិក្សារបស់យើងគឺផ្អែកលើមិនត្រឹមតែសម្មតិកម្មនិងភស្តុតាងពីបុរាណនោះទេ ហើយការសិក្សានេះ ថែមទាំងផ្អែកលើទិន្នន័យនិងន័យនៃពាក្យកម្លាយជាមួយពាក្យឫសដែលមានការជាប់ទាក់ទងគ្នាជាប្រព័ន្ធថែមទៀតផង។ ដូច្នេះ លទ្ធផលបានបង្ហាញថា ទម្រង់/-អំម.ណ-/ឬ/-អុំម.ន-/ជាអន្តបទដែលមានមុខងារវេយ្យាករណ៍សំខាន់ជាច្រើននៅក្នុងការបង្កើតពាក្យថ្មី ពោលគឺអន្តបទនេះសម្រាប់បង្កើត នាមសព្ទសម្គាល់អំពើឬលទ្ធផល កិរិយាសព្ទ គុណនាម កិរិយាវិសេសន៍ និងនិបាតសព្ទ។ ទិន្នន័យទាំងមូលនៃពាក្យកម្លាយ ដោយប្រើប្រាស់អន្តបទនេះមានទំនោរទៅរកការបង្កើតពាក្យថ្មីដែលមានប្រភេទពាក្យជានាមសព្ទ សម្រាប់សម្គាល់អំពើឬលទ្ធផលជាងប្រភេទផ្សេងៗ។

អន្តបទនេះ បើទោះបីមានទិន្នន័យនិងមានឫសគល់ច្បាស់លាស់នៅក្នុងភាសាខ្មែរទំនើបផងនិងបុរាណផងក៏ដោយ ក៏អន្តបទទាំងមូលនៅក្នុងភាសាខ្មែរឬពាក្យកម្លាយនៅក្នុងភាសាខ្មែរនៅតែចោទជាបញ្ហា ដោយសារតែបញ្ហាដែលចោទឡើងបានផ្តល់ជាអំណះអំណាងថាអន្តបទនីយកម្មនៅក្នុងភាសាខ្មែរមិនរស់រាននោះទេ។[៦៩] គំនិតនេះអាចមិនពិត ចំពោះអ្នកប្រើប្រាស់ភាសាខ្មែរ ពីព្រោះបើទោះបីជាពាក្យកម្លាយហាក់មិនមានការរីកចម្រើននៅក្នុងផ្នែកបច្ចេកសព្ទក៏ពិតមែន។ ម្យ៉ាងការប្រើប្រាស់សម័យបច្ចុប្បន្ន អ្នកប្រើប្រាស់និយមប្រើពាក្យ« អ្នកឬការ» សម្រាប់ជំនួសពាក្យកម្លាយទៅវិញ ដូចមានការប្រើប្រាស់«អ្នកសរសេរ» ជំនួសឲ្យពាក្យ«ស្មេរ» ប្រើពាក្យ«អ្នកដើរ» ជំនួសឲ្យពាក្យ«ថ្មើរ»។ផ្ទុយទៅវិញ យើងក៏សង្កេតឃើញមានការប្រើប្រាស់ពាក្យកម្លាយនៅក្នុងអត្ថបទព័ត៌មានូករណ៍មួយចំនួនផងដែរដូចជា «បំផ្ទុះគ្រាប់បែក» ជាដើម។ ម្យ៉ាងវិញទៀត គណៈកម្មាធិការខេមរយានកម្មបានធ្វើឲ្យរស់រានឡើងវិញបន្ទាប់ពីមានការអាក់ខានប្រើពាក្យកម្លាយមួយរយៈមក។ បច្ចុប្បន្ន ការប្រើប្រាស់ គឺនៅមានការលាយឡំគ្នា ទាំងពាក្យកម្លាយនិងពាក្យដែលមាន«អ្នកឬការ»នាំមុខ ដោយពេលខ្លះការប្រើប្រាស់ធ្វើឲ្យមានការភាន់ច្រឡំថែមទៀតផង។

[៦៩] Marjory Ellen Meechan, ***Register in Khmer: The Laryngeal Specification of Pharyngeal Expansion***, op.cit., p.8.

**គន្ថនិទ្ទេស**

**១.ស្នាដៃភាសាវិទ្យា**

**១.១. ស្នាដៃភាសាខ្មែរ**


ច័ន្ទ សំណព្វ «ពាក្យកម្ចាយនិងពាក្យក្លាយ» នៅក្នុង៖ ***ទស្សនាវដ្តីរាជបណ្ឌិតសភាកម្ពុជា*** លេខ១ ឆមាសទី១ ឆ្នាំ២០០៩ ទំព័រ៤៧-៥៥។

ច័ន្ទ សំណព្វ«ការបង្កើតពាក្យនិងកម្ចីពាក្យ» នៅក្នុង៖ ***ទស្សនាវដ្តីសង្គមសាស្ត្រ-មនុស្សសាស្ត្រ*** ឆ្នាំទី៣៨ លេខ៦៣ ខែមេសា ឧសភា មិថុនា ឆ្នាំ២០០៨ ទំព័រ៦-១២។

ឌឹក គាម «ភាសាសាស្ត្រនឹងអក្សរសាស្ត្រ» នៅក្នុង៖ ***ទស្សនាវដ្តីកម្ពុជសុរិយា***ឆ្នាំទី៣៤ លេខ៥ ខែឧសភា ឆ្នាំ១៩៦២ ទំព័រ៥៥៥-៥៦៥។

នៅ ស៊ុន «ភាសានិងការបែងចែកជាអំបូរភាសា» នៅក្នុង៖ ***ទស្សនាវដ្តីរាជបណ្ឌិតសភាកម្ពុជា*** លេខ១ ឆមាសទី១ ឆ្នាំ២០០៩ ទំព័រ៣៣-៤៦។

នៅ ស៊ុន ***ដំណើរការកំលាយពាក្យខ្មែរ*** អត្ថបទសិក្ខាសាលានៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩។

ព្រុំ ម៉ល់ «លទ្ធភាពបង្កើតពាក្យនិងការបង្កើតពាក្យក្នុងភាសាខ្មែរ» នៅក្នុង៖ ***ទស្សនាវដ្តីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា*** ឆ្នាំទី២ លេខ២ ខែមិថុនា ឆ្នាំ២០០១ ទំព័រ៦៥-៨២។

ឡុង សៀម«ការស្រាវជ្រាវទាក់ទងនឹងកំណកំណើតវាក្យសព្ទតាមបម្រើបម្រាស់ផ្ទត់នីយកម្ម» នៅក្នុង៖ ***សន្និសីទជាតិស្តីពី ការស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ*** រៀបចំដោយ វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ថ្ងៃទី៧-៩ ខែកញ្ញា ឆ្នាំ២០០០ ទំព័រ១១-២៩។


**១.២. ស្នាដៃជាភាសាបរទេស**


Diffloth, Gérard. "Khmer" in William Bright (ed.) ***International Encyclopedia of Linguistics*** Vol.2. Oxford University Press: New York and Oxford. 271-275. 1992.

Diffloth, Gérard. "History of the word Khmer" in Sorn Samnang (ed.) ***Khmer Studies: Knowledge of the Past and Its contributions to the Rehabilitations and Reconstructions of Cambodia*** Vol.2. Royal University Phnom Penh Press: Phnom

Penh. 644-651. 1996.

Diffloth, Gérard. "The Lexical Evidence for Austric, So Far" in ***Oceanic Linguistics***, Vol. 33, No.2, December 1994, pp.309-321, University of Hawaii' I Press, http://www.jstor.org/stable/3623131. Accessed: 16/06/2008.

Haiman, John. "Possible origins of infixation in Khmer". ***Studies in Language*** 22:597-617, 1998.

Haiman, John; and Ourn, Noeurng. "Nouns, Verbs and Syntactic Backsliding in Khmer." ***Studies in Language*** 27:3:, 505-528, John Benjamins Publishing Company, 2003.

Horwood, Graham. ***Implications of Katu Nominalization for Infixation Typology***. Thammasat University, 2008, 21 pages.

Jacob, Judith M. ***Cambodian Linguistics, Literature and History.*** (collected articles), David A. Smyth (ed.), University of London, 1993.

Ourn, Noeurng; and Haiman, John. "Creative forces in Khmer." In Shoichi Iwasaki, Andrew Simpson, Karen Adams & Paul Sidwell, eds. ***SEALSXIII: papers from the 13th meeting of the Southeast Asian Linguistics Society (2003)***. Canberra, Pacific Linguistics, 2007, pp.157-164.

Sebeok, Thomas A. "An Examination of the Austroasiatic Language Family". ***In Language, Vol. 18, No.3, (Jul.-Sep., 1942)***, Linguistic Society of America, pp. 206-217 <http://www.jstor.org/stable/409554>.

Schiller, Eric. "Khmer Nominalizing and Causativizing Infixes". ***SEALS II: papers from the 2nd meeting of the Southeast Asian Linguistics Society***. 1992, pp.309-326.

Schiller, Eric. "Khmer Writing" in Peter T. Daniels and William Bright (eds). ***The World's writing system***. New York: Oxford University Press, 1996. pp.467-473.

Sidwell, Paul (ed). ***SEALS XV: Papers from the 15th annual meeting of the Southeast Asian Linguistics Society***. Pacific Linguistics: Research School of Pacific and Asian Studies, Australian National University, 2005, 2004 pages.

Spencer, Andrew. ***Morphological Theory: An Introduction to Word Structure in Generative Grammar***, Cambridge University Press: Basil Blackwell, 1991, 512 pages.

Varasarin, Uraisi. ***Les Éléments Khmers dans La Formation de La Langue Siamoise***. Paris: SELAF, 1984.

Vong Meng, "The Evolution of Khmer Language in the Globalization Era." ***Paper presented at the International conference on Syncretism in South and Southeast Asia: Adoption and Adaptation***, The Institute of Language and Culture for Rural Development, Mahidol University, Thailand, 2007.

You sey. “Some old Khmer Affixation” in Kenneth J. Gregerson and David Thomas (ed.), ***Mon-Khmer Studies V***, Manila: the Summer Institute of Linguistics, 1976, pp. 85-95.

Yu, Alan C.L., ***A Natural History of Infixation***, Oxford University Press, 2007, 265 pages.

## ២. សារណានិងនិក្ខេបបទ

### ២.១. ស្នាដៃភាសាខ្មែរ

យៀង វីរបុត្រ៖ *ការបង្កើតពាក្យនៅក្នុងភាសាខ្មែរទំនើបតាមវិធីកម្លាយ* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី១សាកលវិទ្យាភូមិន្ទភ្នំពេញ ២០០៦។

វង្ស មេង៖ *ពាក្យផ្ទួននៅក្នុងភាសាខ្មែរទំនើប* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ ជំនាន់ទី ៧ ២០០២។

វង្ស មេង៖ *ពាក្យសមាសនៅក្នុងភាសាខ្មែរទំនើប* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី១ រាជបណ្ឌិតសភាកម្ពុជា ២០០២។

### ២.២. ស្នាដៃភាសាបរទេស

Adams, Karen Lee. ***System of Numeral Classification in the Mon-Khmer, Nicobarese and Aslian Subfamilies of Austroasiatic***. A Dissertation submitted in partial fulfillment of the requirements for the degree of Doctor o f Philosophy (Linguistics) in the University of Michigan, 1982, 495pp.

Huebner, Thomas G. ***On the Phonology of the Khmer Simple Monosyllable***. University of Pittsburgh, M.A. Thesis, 1971, 43 pages.

Huffman, Franklin E. ***An Outline of Cambodian Grammar***. Cornell University, Ph.D. thesis, 264 pages, 1967.

Jenner, Philip Norman. ***Affixation in Modern Khmer***. Ph.D. dissertation, University of Hawaii, 1969, 207 pages.

Meechan, Marjory. ***Register in Khmer: The Laryngeal Specification of Pharyngeal Expansion***. M.A. thesis, Canada: University of Ottawa, 1992.

Thach, Ngoc Minh. ***A Descriptive Grammar of Khmer in the Mekong Delta-Vietnam***. M.A. thesis, National University of Singapore, 2002.

Wayland, Ratree P. ***Acoustic and Perceptual Investigation of Breathy and Clear Phonotation in Chanthaburi Khmer: Implications for the History of Khmer Phonology***. Cornell University. Doctoral dissertation. 1997.

## ៣. ស្នាដៃវេយ្យាករណ៍

### ៣.១. ស្នាដៃភាសាខ្មែរ


កេង វ៉ាន់សាក់៖ ***មូលភាពនៃការបង្កើតពាក្យថ្មី*** ភ្នំពេញ៖ រោងពុម្ពទេព ១៩៦៤។

ឃីន សុខ៖ ***វេយ្យាករណ៍ភាសាខ្មែរ*** ភ្នំពេញ៖ការផ្សាយរបស់រាជបណ្ឌិតសភាកម្ពុជា ២០០៧។

អៀវ កើស៖ ***ភាសាខ្មែរ(ការល្បងពិនិត្យដោយរកហេតុផល)*** បោះពុម្ពផ្សាយឡើងវិញ ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ៖ រោងពុម្ពមិត្តភាពកម្ពុជា-ជប៉ុន ១៩៩៥, ៣៦៧ទំព័រ។


### ៣.២. ស្នាដៃភាសាបរទេស


Gorgoniyev, Ju.A. ***The Khmer Language***. (translated from the Russian by V. Korotky), Moscow: Nauka Publishing house, 1966, 134 pages.

Maspero, Georges. ***Grammaire de la langue Khmère***. Paris, Imprimerie Nationale, 1915, 486p.

Schiller, Eric. "Introduction to Autolexical Grammar." Ericschiller.com (2007). 12 May 2008< http://www.ericschiller.com/ling/papers/autolexical.htm>.


## ៤. វចនានុក្រម

### ៤.១. វចនានុក្រមភាសាខ្មែរ


ក្រសួងអប់រំជាតិ៖ ***សព្ទានុក្រម បារាំង-ខ្មែរ ពាក្យបច្ចេកទេស*** ផ្សាយចេញពីគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ ភ្នំពេញ៖ រោងពុម្ពមានជ័យ ១៩៦៩ ៥០៦ទំព័រ។

ជូឌីត ចាកុប៖ ***វចនានុក្រមខ្មែរ-អង់គ្លេស*** ការផ្សាយរបស់សាកលវិទ្យាល័យឡុង ដុង, ១៩៧៤, ២៤២ ទំព័រ។

នួន ប៊ុត៖ ***អក្ខរានុក្រមខ្មែរ ពី ក ដល់ អ នឹងពាក្យរាយ*** ការផ្សាយរបស់បណ្ណាគារ ប៊ុតនាង ១៩៥៤, ១៩០៦ទំព័រ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ***វចនានុក្រមខ្មែរ ភាគទី១ ភាគទី២*** ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ រោងពុម្ព កម្ពុជា ១៩៦៧-៦៨, ១៨៥៨ទំព័រ។

ហាហ្វមែន ហ្វ្រែងលីន និង ព្រំ អ៊ឹម ***អក្សរសាស្ត្រខ្មែរ*** ការផ្សាយរបស់សាកលវិទ្យាល័យ យេល ១៩៧០, ៥៦ទំព័រ។


### ៤.២. វចនានុក្រមភាសាបរទេស


Bernard, Jean Baptiste. *Dictionnaire Cambodgien-Français* Hong Kong: Imprimerie de la Société des Missions Etrangères, 1902, 386 pages.

Bussmann, Hadumod. ***Routledge Dictionary of Language and Linguistics***. (translated and edited by Gregory P. Trauth and Kerstin Kazzazi), London and New York: Solidus (Bristol) Ltd, Bristol, 2006, 530 pages.

Carr, Philip. ***A Glossary of Phonology***. Scotland: Edinburgh Univesity Press Ltd. 2008, 206 pages.

Chrystal, David. ***A Dictionary of Linguistics and Phonetics***. UK: Blackwell Publisher, 1991, 389 pages.

Jenner, Philip N. and Saveros Pou, ***A Lexicon of Khmer Morphology***, MKS 9-10:1-517, 1981, 517 pages.

Jenner, Philip N., A dictionary of Pre-Angkorian Khmer, Doug Cooper (ed.), Canberra: Pacific Linguistics, 2009, 620 pages.

Jenner, Philip N., A dictionary of Angkorian Khmer, Doug Cooper (ed.), Canberra: Pacific Linguistics, 2009, 778 pages.

Guesdon, Joseph. ***Dictionnaire Cambogien-Français***. Paris: Libairie Plon, 1930.

# គោលវិធីសិស្សមជ្ឈមណ្ឌល

**ដោយបណ្ឌិត ភាង ឱម**
សាស្ត្រាចារ្យវិទ្យាសាស្ត្រអប់រំ
ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា

**-សេចក្តីផ្តើម**

ទិសដៅ និងគោលបំណងក្នុងការអប់រំបែបថ្មីត្រូវទាមទារឱ្យមានខ្លឹមសារអប់រំ និងវិធីសាស្ត្របង្រៀនមានលក្ខណៈប្រាកដដែលឆ្លើយតបទៅនឹងសង្គមជាតិ។ ដូច្នេះ ការយល់ដឹងបានពីបញ្ញត្តិនិងប្រវត្តិនៃការបង្កើតវិធីសាស្ត្របង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល គឺជាបង្អែកមួយបានយ៉ាងរឹងមាំសម្រាប់វិភាគ និងឆ្លុះបញ្ចាំងទៅលើការអនុវត្តគោលវិធីនេះ។ ស្រង់តាមឯកសាររបស់ក្រសួងអប់រំបានបង្ហាញឱ្យយើងដឹងថា បញ្ញត្តិពាក្យគោលវិធីសិស្សមជ្ឈមណ្ឌល (Student Center Approach) ជាលំនាំនៃការបង្រៀន និងរៀន ដោយផ្តោតការយកចិត្តទុកដាក់លើសកម្មភាពសិស្សធ្វើជាមូលដ្ឋាន។ នៅក្នុងគោលវិធីនេះត្រូវទាមទារឱ្យសិស្សធ្វើសកម្មភាពស្វែងយល់ដោយខ្លួនឯង ក្រោមការដឹកនាំរបស់គ្រូសំដៅសម្រេចឱ្យបាននូវចំណេះដឹង បំណិន ឥរិយាបថ ព្រមទាំងធ្វើឱ្យមានការអភិវឌ្ឍបុគ្គលិកលក្ខណៈ។ នៅក្នុងសង្គមភាពនេះសិស្សអាចរៀន និងធ្វើការសិក្សាស្រាវជ្រាវជាលក្ខណៈបុគ្គលជាក្រុមទាំងក្នុងថ្នាក់ និងក្រៅថ្នាក់។

ដូចនេះ ដើម្បីងាយស្រួលក្នុងការប្រើពាក្យឱ្យស្របទៅនឹងវិធីបង្រៀនយើងនឹងលើកយកមកធ្វើការប្រៀបធៀបការអប់រំបែបបុរាណ (Ancient) និងបែបទំនើប (Moderns) ដែលមានដូចខាងក្រោម៖

**-ទស្សនៈគោលវិធីសិស្សមជ្ឈមណ្ឌល**

**+ទស្សនៈរបស់លោក Lev Semenovich Wgotsky (១៨៩៦-១៩៣៦)**

លោកជាចិត្តវិទូដ៏មានទេពកោសល្យជាតិរុស្ស៊ី។ លោកបានលើកឡើងពីទស្សនៈនៃការឱ្យតម្លៃទៅលើចរិតសកម្មរបស់សិស្ស នៅក្នុងគោលវិធីសិស្សមជ្ឈមណ្ឌលថា "តួនាទីរបស់គ្រូគឺត្រូវបង្កលក្ខណៈងាយស្រួលដល់សិស្សក្នុងការសិក្សា មិនមែនគ្រូជាអ្នកផ្ទេរចំណេះដឹងឱ្យសិស្សត្រង់ៗនោះទេ។ សិស្សទទួលចំណេះដឹងតាមលក្ខណៈឆ្លាស់ពីអ្នកដទៃ ពីគ្រូ ពីឪពុកម្តាយ ពីបងប្រុសស្រីពីមិត្តភក្តិរបស់គេ។

**+ទស្សនៈរបស់លោក Gallimore និង Tharp(១៩៩០)**

លោកបានបញ្ជាក់យ៉ាងច្បាស់លាស់ពីគោលវិធី៦យ៉ាងដែលគ្រូអាចឱ្យសិស្សខំរៀន៖

ក. គ្រូត្រូវប្រកាន់យកអាកប្បកិរិយាជាគំរូសំខាន់ឱ្យសិស្សត្រាប់តាម

ខ. គ្រូត្រូវផ្តល់រង្វាន់ឱ្យសិស្សណាដែលប្រកាន់យកនូវអាកប្បកិរិយាដែលគ្រូចង់បាន

គ. គ្រូត្រូវដាក់ព័ត៌មានត្រលប់ឱ្យសិស្សអំពីកិច្ចការជាស្នាដៃរបស់គេ ដើម្បីឱ្យគេមើលមេរៀនសារឡើងវិញនិងកែលម្អកម្រិតយល់ដឹងសិស្សមានភាពសុក្រឹត្យ។

ឃ. ផ្តត់ផ្តង់ឱ្យសិស្សនូវព័ត៌មានគ្រប់គ្រាន់ ដែលពួកគេត្រូវលើកយកមកបង្រៀន។

ង. គ្រូត្រូវចោទជាសំណួរសមរម្យនឹងសមត្ថភាពសិស្ស ដែលអាចឱ្យសិស្សត្រិះរិះរកចម្លើយយ៉ាងសកម្មភាព។

ច. ត្រូវផ្តត់ផ្តង់ឱ្យសិស្សនូវរចនាសម្ព័ន្ធនៃចំណេះដឹង សម្រាប់ឱ្យសិស្សយកទៅចាត់ចែងស្វែងយល់ស៊ីជម្រៅទៅលើចំណេះដឹងថ្មី។

**+ទស្សនៈរបស់លោក Car Rogers (១៩៨៣)**

លោកជាចិត្តវិទូ និងជាគ្រូពេទ្យព្យាបាលជំងឺផ្លូវចិត្តដ៏ល្បីឈ្មោះ។ ចំពោះគោលវិធីសិស្សមជ្ឈមណ្ឌលក៏ដូចជាវិធីម្ចាស់ការរបស់អ្នកជំងឺ លោកមានប្រសាសន៍ថា "គ្រូត្រូវទុកពេលឱ្យសិស្សពិចារណាដោយខ្លួនឯង សិស្សត្រូវរកចម្លើយតាមបែបកសាងចំណេះដឹងផ្ទាល់ខ្លួន។ សិស្សត្រូវរកឱ្យឃើញនូវចំណេះដឹងមានលក្ខណៈរស់រវើក និងប្រកបដោយយន្តការ។ សិស្សត្រូវមានទំនាក់ទំនងរវាងគ្នានឹងគ្នាដែលមានទំនាក់ទំនងដោយពុំចាំបាច់មានអ្នកដឹកនាំ។ សិស្សត្រូវមានការស្រុះស្រួលគ្នា ហ៊ានសម្តែងចេញនូវអ្វីៗគ្រប់បែបយ៉ាងដោយឥតលាក់លៀម។ សិស្សត្រូវស្តាប់មតិគ្នាឯង ចេះគោរពសិទ្ធិគ្នាក្នុងការនិយាយ និងស្គាល់ការលំបាករបស់គ្នាឯង។

**+ទស្សនៈរបស់លោក Abraham Maslow (១៩៦៨-១៩៨៧)**

លោកបានមានប្រសាសន៍ថា "នៅពេលដែលមនុស្សយើងមានតម្រូវការក្នុងកម្រិតទាបហើយគេនឹងឈានទៅដល់តម្រូវការកម្រិតខ្ពស់ជាមិនខាន"។ ក្នុងន័យនេះ គ្រូបង្រៀនសិស្សត្រូវបំផុសគំនិតសិស្សឱ្យចង់រៀន និងធ្វើឱ្យសិស្សមានតម្រូវការក្នុងការស្វែងយល់ពីកម្រិតទាបទៅខ្ពស់។

**+ ទស្សនៈរបស់លោក Guilford**

លោកបានលើកឡើងពីលក្ខណៈពិសេសបួនយ៉ាងនៃការគិតរបស់សិស្ស ដែលមានលក្ខណៈធ្វើឱ្យសិស្សនោះបែកគំនិត៖

-លេចចេញយ៉ាងរហ័សនូវគំនិត ពាក្យ របៀប សម្តែងចេញ

-គំនិតលេចចេញជាគំនិតដ៏កម្រ ឈ្លាសវៃ ថ្មីស្រឡាង

-ជាគំនិតអាចបត់បែនបានភ្លាមៗ ទាន់ពេល

-ផ្តុំបាននូវគំនិតដ៏ល្អិតល្អន់និងចម្លើយយ៉ាងលម្អិត

**+ ទស្សនៈរបស់លោក Torrance (១៩៧២)**

លោកបានលើកឡើងពីលក្ខណៈពិសេស៧យ៉ាងរបស់សិស្ស ដែលមានលក្ខណៈច្នៃប្រឌិតក្នុងការគិតនិងក្នុងកិច្ចការៈ

-កិច្ចការមានលក្ខណៈចម្លែក កំប្លែង និង មោទនភាព

-មានសុធន្ទៈនៅក្នុងទង្វើនៃកិច្ចការលំបាក

-ផ្តោតស្មារតីប្រុងប្រយ័ត្នក្នុងរយៈពេលដ៏យូរ និង មានចំណង់ចំណូលចិត្តក្នុងការសិក្សា

-ចូលចិត្តផ្តល់នូវគំនិតខុសពីធម្មជាតិប្រកបដោយប្រឌិតញាណ

-ឆាប់ចាប់អារម្មណ៍ប្រកបដោយសមត្ថភាពលម្អិត

-គ្មានកង្វល់ចំពោះកិច្ចការដែលពិភាក្សាតាមក្រុម

-ចោទជា មានគំនិតគម្រក់ ឬ គំនិតភ្លើតភ្លើន។

**+ ទស្សនៈរបស់លោកបណ្ឌិត Achhara Vong Sauth**

លោកជាអ្នកប្រាជ្ញវិទ្យាសាស្ត្រអប់រំជាតិថៃ បានពោលអះអាងថា "ក្នុងការរៀបចំឱ្យមានការសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល គ្រូគួរធ្វើជាអ្នកសម្របសម្រួលដល់ការសិក្សារបស់សិស្ស ជួយលើកទឹកចិត្តសិស្ស និងជួយបំផុសគំនិតសិស្សឱ្យមានសកម្មភាពរៀនដោយរៀបចំឱ្យមានសម្ភារឧបទេស ឯកសារសិក្សាឱ្យបានសមស្របទៅនឹងកម្រិតយល់ដឹងរបស់សិស្ស។ គ្រូជាអ្នកតាមដានឃ្លាំមើល និងត្រួតពិនិត្យសកម្មភាពពិភាក្សាប្តូរយោបល់របស់សិស្ស និងផ្តល់ព័ត៌មានត្រលប់ឱ្យសិស្សវិញ ដើម្បីជួយសិស្សឱ្យស៊ីជម្រៅក្នុងដំណោះស្រាយបញ្ហា សំដៅជួយសិស្សឱ្យពង្រឹងសមត្ថភាពយល់ដឹងបានពិតប្រាកដ"។

**+ទស្សនៈរបស់លោកបណ្ឌិត Tisna Khmemany**

លោកបានលើកឡើងពីគុណសម្បត្តិ នៃគោលវិធីបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌលមានដូចតទៅៈ

-គ្រូត្រូវជួយសិស្សឱ្យមានការចូលរួមចំណែកក្នុងការរៀន ដោយផ្តល់ឱកាសឱ្យសិស្សស្វែងយល់ពីអត្ថប្រយោជន៍នៃចំណេះដឹងសម្រាប់ខ្លួនឯង និងការចេះស្រាវជ្រាវ ឈានទៅដល់រកគំហើញដោយខ្លួនឯង។

-គ្រូត្រូវជួយសិស្សឱ្យមានអន្តរកម្មជាមួយមិត្តរួមថ្នាក់ បានយល់ដឹង និងបានរៀនសូត្រពីគ្នា ចេះចែករំលែកការយល់ដឹង គំនិត និង បទពិសោធន៍ទៅវិញទៅមក។

-គ្រូត្រូវជួយសិស្សឱ្យចូលរួមក្នុងការពិភាក្សាតាមក្រុមឱ្យបានច្រើនបំផុត។

-គ្រូត្រូវជួយសិស្សឱ្យចេះយកចំណេះដឹងថ្មី ទៅអនុវត្តនៅក្នុងស្ថានភាពនៃជីវភាពប្រចាំថ្ងៃ។ ក្នុងន័យនេះមានន័យថា គ្រូត្រូវបំផុសគំនិតសិស្សឱ្យចង់រៀន ចេះស្រាវជ្រាវព័ត៌មានដោយខ្លួនឯង ចេះធ្វើការរួមគ្នា ចេះចែករំលែកការយល់ដឹង និងចេះរស់នៅរួមគ្នា។

**-អត្ថន័យនៃគោលវិធីសិស្សមជ្ឈមណ្ឌល**

គោលវិធីសិស្សមជ្ឈមណ្ឌលផ្ទុយពីគោលវិធីគ្រូមជ្ឈមណ្ឌល។

**-គោលវិធីគ្រូមជ្ឈមណ្ឌល**

គឺយកសកម្មភាពគ្រូជាមូលដ្ឋាន។ គ្រូជាអ្នកធ្វើអត្ថាធិប្បាយ បកស្រាយពន្យល់លើកឧទាហរណ៍ ឯសិស្សវិញមានចរិតអសកម្ម ចាំតែស្ដាប់គ្រូ ចាំតែកត់ត្រា មិនចាំបាច់ត្រិះរិះពិចារណា ពិភាក្សាប្ដូរយោបល់គ្នា និងដោះស្រាយបញ្ហាឡើយ។ សិស្សចេះនិងចងចាំបានតែអ្វីដែលគ្រូបកស្រាយ ពន្យល់ប៉ុណ្ណោះ។

**-គោលវិធីសិស្សមជ្ឈមណ្ឌល**

គឺអ្វីៗផ្ដើមចេញពីសិស្ស គ្រូគ្រាន់តែជាអ្នកចាត់ចែង អ្នកដាក់បញ្ហាឱ្យសិស្សដោះស្រាយ ជាអ្នកគ្រប់គ្រង ដឹកនាំ អ្នកតាមឃ្លាំមើល អ្នកជួយតម្រង់ទិស ជាអ្នកជួយបូកសរុបវាយតម្លៃ និងលើកទឹកចិត្តសិស្សទៅលើការងារពិភាក្សា ប្ដូរយោបល់របស់សិស្សតែប៉ុណ្ណោះ។

**-លក្ខណៈមនុស្សនិយម**

គ្រូត្រូវគោរពតាមបំណងប្រាថ្នា និង ចំណង់ចំណូលចិត្តរបស់សិស្ស។ សិស្សជួយផ្ដល់មតិយោបល់ឱ្យគ្រូក្នុងការរៀបចំផែនការបង្រៀន។ ខ្លឹមសារនៃការបង្រៀន និង ការអប់រំមិនឃ្លាតឆ្ងាយពីតម្រូវការរបស់សិស្ស។

**-លក្ខណៈអប់រំសីលធម៌សង្គម**

គ្រូទម្លាប់ឱ្យសិស្សចេះប្រើសម្ដីទន់ភ្លន់ ប្រកាន់អត្តចរិតរួសរាយរាក់ទាក់ ស្និទ្ធស្នាល មិនប្រើសម្ដីហិង្សា ឬឥរិយាបថច្រងេងច្រងាង ទម្លាប់សិស្សឱ្យចេះសម្រួលឥរិយាបថ ចេះផ្ដល់ព័ត៌មានឱ្យគ្នាទៅវិញទៅមកក្នុងក្រុមពិភាក្សា និង ចេះជួយយកអាសាគ្នាទៅវិញទៅមក។

**-លក្ខណៈប្រជាធិបតេយ្យ**

គ្រូនិងសិស្សត្រូវគោរពតាមមតិឯកភាពភាគច្រើន និង ការចេះពិចារណាលើមតិផ្ទុយរបស់មតិក្នុងការបញ្ចេញមតិយោបល់។ គ្រូជាអ្នកសម្រុះសម្រួល និងធ្វើការបូកសរុបបំពេញបន្ថែមខ្លឹមសារមេរៀនឱ្យមានអត្ថន័យគ្រប់គ្រាន់។

**-លក្ខណៈគោរពសិទ្ធិមនុស្ស**

គ្រូបានអប់រំទម្លាប់សិស្សកុំឱ្យដណ្ដើមគ្នានិយាយ ឬ និយាយកាត់គ្នា ឬឆ្លើយជាសមូហភាព។ សិស្សម្នាក់ៗត្រូវគោរពសិទ្ធិគ្នាទៅវិញទៅមកក្នុងពេលមិត្តរួមថ្នាក់ឡើងមានយោបល់។ កាលណាចប់វេន ខ្លួនជាប្រធានក្រុម ឬដឹកនាំក្រុមពិភាក្សា ត្រូវប្រគល់តំណែងឱ្យមិត្តរួមថ្នាក់ មិនត្រូវក្រាញស្រលាញ់អំណាច ដែលជាទម្លាប់អាក្រក់ក្នុងសង្គម។

**-លក្ខណៈម្ចាស់ការក្នុងការស្រាវជ្រាវ**

គ្រូទម្លាប់សិស្សឱ្យប្រកាន់យកម្ចាស់ការក្នុងការពិភាក្សា ប្ដូរយោបល់សំដៅឈានដល់របកគំហើញណាមួយដោយខ្លួនឯង។ សិស្សម្នាក់ៗត្រូវមានលក្ខណៈសកម្មរៀងខ្លួន មិនត្រូវត្រមង់ចាំតែឯកភាពលើមតិរបស់គេទេ។ គ្រូត្រូវឃ្លាំមើល ជំរុញសិស្សប្រភេទនេះឱ្យសកម្មក្នុងការស្រាវជ្រាវ និងការឡើងបញ្ចេញយោបល់។ សិស្សអាចជួយគ្នាបានក្នុងការឡើងបញ្ចេញយោបល់ ការផ្ដល់ព័ត៌មាន និងបទពិសោធន៍ឱ្យគ្នាទៅវិញទៅមក។

**-លក្ខណៈអង់អាចក្លាហាន**

សិស្សមានទម្លាប់ឡើងនិយាយ បញ្ចេញមតិយោបល់សមូហភាព ចេះគាំទ្រមតិ និងចេះទិតៀនលើទស្សនៈ ដែលមិនបម្រើឱ្យផលប្រយោជន៍សង្គម និងផលប្រយោជន៍សមូហភាព។ សិស្សមានទម្លាប់ក្លាហានមើលឃើញល្អថាល្អ មើលឃើញអាក្រក់ថាអាក្រក់ ត្រូវហ៊ានទិតៀន ហ៊ានអារកាត់។

**- ការបង្រៀនសិស្សតាមគោលវិធីសិស្សមជ្ឈមណ្ឌល**

មានទ្រឹស្ដីចិត្តវិទ្យា និងទស្សនៈវិជ្ជាជាច្រើនដែលបានលើកឡើងពីការបង្រៀន និងការសិក្សារបស់សិស្ស ត្រូវបានពួកអ្នកចិត្តវិទូខាងទ្រឹស្ដីចំណេះដឹងលើកយកមកជជែកវែកញែក និងយកមកប្រើប្រាស់ជាគោលការណ៍សម្រាប់ធ្វើឱ្យវិធីបង្រៀនរបស់គ្រូ និងវិធីសិក្សារបស់សិស្សមានភាពសុក្រឹត ហើយទទួលបានគុណភាពល្អ។

**-ទ្រឹស្ដីអភិវឌ្ឍន៍និយម**

ទ្រឹស្ដីនេះមានចំណុច៥យ៉ាង ដែលយកចិត្តទុកដាក់ និង ការជួយគ្នាឱ្យអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល សំដៅឈានទៅសម្រេចតាមវត្ថុបំណងនៃការបង្រៀនមេរៀនណាមួយនោះគឺៈ

-ការសិក្សាត្រូវជួយសិស្សឱ្យអភិវឌ្ឍន៍លើគ្រប់វិស័យគឺ កាយសម្បទា សតិអារម្មណ៍ សង្គមនិងបញ្ញាញាណ។

-គោលបំណងនៃការសិក្សាគឺ បណ្ដុះបណ្ដាលឱ្យសិស្សនូវគំនិតប្រជាធិបតេយ្យ ចេះស្គាល់ខ្លួនឯង ស្គាល់សង្គមដែលខ្លួនកំពុងរស់នៅ និងចេះសម្របសម្រួលខ្លួនក្នុងការរស់នៅឱ្យចុះសម្រុងក្នុងសង្គម ឬទៅតាមការប្រែប្រួលរបស់សង្គម ចេះកែច្នៃប្រឌិត ចេះដោះស្រាយបញ្ហា ជួយសង្គមឱ្យអភិវឌ្ឍន៍។

-គ្រូមិនដើរតួជាអ្នកបញ្ជាឱ្យសិស្សអនុវត្តទេ តែជាអ្នកជួយជ្រោមជ្រែង ជួយណែនាំគ្រប់គ្រងវិន័យ ជួយបង្កើបដំណោះស្រាយ ជួយសម្របសម្រួល ជួយជំរុញសិស្សឱ្យយល់ និងចេះពិចារណាឈានទៅដល់របកគំហើញដោយខ្លួនឯង និង ជួយបូកសរុបវាយតម្លៃចម្លើយសិស្ស។

-ចំពោះខ្លឹមសារមេរៀនដែលត្រូវបង្រៀនសិស្សគឺ ទាមទារឱ្យគ្រូផ្តល់ចំណេះដឹងដែលមានប្រយោជន៍ ទៅតាមចំណង់ចំណូលចិត្ត តម្រូវការ និងជាប់ពាក់ព័ន្ធទៅនឹងជីវភាពរស់នៅក្នុងសង្គម។

-ការសិក្សា គឺការដកស្រង់បទពិសោធន៍រៀនដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តន៍ជាក់ស្តែង។ រៀនគឺ ការពិភាក្សាគ្នាក្នុងន័យស្វែងយល់ជាក្រុម ផ្តល់បទពិសោធន៍ និង ផ្តល់ចំណេះដឹងឱ្យគ្នាទៅ វិញទៅមក ហើយចេះគាំទ្រយោបល់ ចេះឡើងបញ្ចេញយោបល់ ចេះសម្របមតិតាមគេ ចេះជំទាស់ទិតៀន។

**-ទស្សនៈកសាងចំណេះដឹង**

យោងតាមទស្សនៈគេបានលើកឡើងថា៖

-ការសិក្សាគឺ ជាការបំប៉ន ការអភិវឌ្ឍ និងការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈរបស់មនុស្សឱ្យមានលក្ខណៈសម្បត្តិល្អ និង សមស្របទ្វេឡើង។

-គ្រូបង្រៀនត្រូវមានគំនិតស្នេហា សាមគ្គីភាពនៅក្នុងវិជ្ជាជីវៈរបស់ខ្លួនជាគ្រូបង្រៀន ចេះយកចិត្តទុកដាក់បញ្ហាសង្គម ចេះចូលរួមចំណែកដោះស្រាយបញ្ហាសង្គម មានទេពកោសល្យខ្ពស់នៅក្នុងការប្រមូលផ្តុំគំនិត ការចេះវិភាគវែកញែកបានត្រឹមត្រូវទៅលើការអភិវឌ្ឍសង្គម និងចេះស្វែងយល់ពីមជ្ឈដ្ឋានសង្គម។

-ការបង្រៀនគឺ ជាការដឹកនាំសិស្សតាមបែបប្រជាធិបតេយ្យ ហើយសំខាន់ត្រូវចេះទុកឱកាសឱ្យសិស្សចេះពិចារណា ចេះពិភាក្សា ចេះឡើងមានយោបល់ ចេះទាញហេតុផលសមស្រប ចេះសន្និដ្ឋាន និង ឈានដល់របកគំហើញដោយខ្លួនឯងនៅក្នុងដំណោះស្រាយបញ្ហា។

-សិស្សចេះមើលឃើញផលប្រយោជន៍សង្គមជាងឃើញផលប្រយោជន៍ផ្ទាល់ខ្លួន ចេះរួបរួមសាមគ្គីដើម្បីដោះស្រាយបញ្ហាសង្គមឈានឡើងអភិវឌ្ឍន៍។

-គ្រូត្រូវបណ្តុះបណ្តាលសិស្សពីបច្ចេកទេស យុទ្ធវិធី និង វិធីសាស្ត្រផ្សេងៗដែលទម្លាប់ សិស្សឱ្យចេះដោះស្រាយបញ្ហាសង្គមទៅតាមលក្ខណៈប្រជាធិបតេយ្យ។

**-ទស្សនៈអត្ថិភាពនិយម**

ពិភពលោកសំបូរពោរពេញទៅដោយសភាវៈសព្វបែបយ៉ាងឥតគណនា។ ដូចនេះមនុស្សលោកត្រូវតែស្វែងយល់ស៊ីជម្រៅឱ្យបានទូលំទូលាយ មនុស្សត្រូវមានឱកាសជ្រើសរើស និងសិក្សាមុខវិជ្ជាផ្សេងៗ ដោយខ្លួនឯងជាជាងរង់ចាំឱ្យអ្នកដទៃមកបណ្តុះបណ្តាល ឬផ្ទេរចំណេះដឹងឱ្យខ្លួន។

-ការសិក្សាមានទិសដៅអភិវឌ្ឍមនុស្សឱ្យមានឥស្សរភាព និង មានទំនួលខុសត្រូវ

-ការបង្រៀនត្រូវទុកសេរីភាពឱ្យសិស្សជ្រើសរើសចំណេះដឹងដោយខ្លួនឯង

-គ្រូត្រូវចេះបង្កើតបរិយាកាសរៀនសូត្រ ដោយបើកឱកាសឱ្យសិស្សជ្រើសរើសការសិក្សាទៅតាមបំណិន ឧបនិស្ស័យ និង ចំណង់ចំណូលចិត្តផ្ទាល់ខ្លួន។ គ្រូត្រូវបំផុសគំនិតសិស្សតាមរយៈការចោទសួរ ដើម្បីនាំគេឱ្យទៅដល់គោលដៅដែលគេត្រូវការចង់បាន។

**-ទស្សនៈមនុស្សនិយម**

មនុស្សជាអ្នកមានសេចក្ដីល្អពីកំណើត មានសមត្ថភាពជាឥស្សរភាព ដែលអាចដឹកនាំខ្លួនឯង និងជាទីពឹងលើខ្លួនឯងបាន។ មនុស្សមានសេរីភាពក្នុងការជ្រើសរើសយកអ្វីៗគ្រប់បែបយ៉ាងដោយខ្លួនបាន ដែលមិនធ្វើឱ្យអ្នកដទៃ ឬខ្លួនឯងកើតមានសេចក្ដីក្ដៅក្រហាយក្នុងចិត្ត។ មនុស្សជា អ្នកទទួលខុសត្រូវលើខ្លួនឯង និងជាអ្នកកសាងសង្គមផង។ រីឯការសិក្សាវិញគួរតែបណ្ដុះបណ្ដាល សិស្សឱ្យមានសមត្ថភាពបីយ៉ាងគឺ ចំណេះដឹង អារម្មណ៍ និង ជំនាញដ៏ប៉ិនប្រសប់។

**-គោលបំណងនៃគោលវិធីសិស្សមជ្ឈមណ្ឌល**

គោលបំណងដ៏សំខាន់របស់គោលវិធីសិស្សមជ្ឈមណ្ឌលគឺសំដៅឱ្យសិស្ស៖

-មានការជុះចេញនូវគំនិតស្រលាញ់ការសិក្សា

-ចូលចិត្ត និង ចាប់អារម្មណ៍លើការសិក្សា

-យល់ដឹងដោយខ្លួនឯងថា ជាមនុស្សដ៏មានតម្លៃនៅក្នុងសង្គម

-ចូលរួមចំណែកយ៉ាងសកម្មក្នុងការសិក្សា

-យល់ដឹងថាមានគេគាំទ្រខ្លួន ឬ គេទិតៀនលើយោបល់របស់ខ្លួន

-មានស្មារតីទទួលខុសត្រូវលើការសិក្សារបស់ខ្លួន

-បានចូលរួមចំណែកក្នុងការបញ្ចេញមតិយោបល់ដូចគេឯង

-អាចវាយតម្លៃបានលើសមត្ថភាពផ្ទាល់ខ្លួន

-មានទម្លាប់ល្អក្នុងការរស់នៅជាសមូហភាព និង ចេះសហការគ្នា សាមគ្គីគ្នា

-យល់ដឹង និង ស្គាល់ច្បាស់ពីតម្លៃនៃសីលធម៌ និង គុណធម៌នៅក្នុងសង្គម

-ចេះប្រើពេលវេលាឱ្យមានប្រយោជន៍សម្រាប់ខ្លួនឯង

**-គោលការណ៍អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល**

គោលវិធីនេះទាមទារឱ្យគ្រូឆ្លងកាត់ការបណ្ដុះបណ្ដាល ការធ្វើវិក្រឹត្យការគរុកោសល្យ សិក្ខាសាលាដើម្បីយល់ស៊ីជម្រៅឱ្យបានច្បាស់លាស់នៅក្នុងបច្ចេកទេស វិធី និង វិធីសាស្ត្រគរុកោសល្យក្នុងការចេះអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

**+ គោលការណ៍អនុវត្ត**

-គ្រូអាចយកគោលវិធីនេះទៅអនុវត្តបានគ្រប់មុខវិជ្ជា និង គ្រប់កម្រិតសិក្សាបានទាំងអស់

-ការអនុវត្តន៍គោលវិធីមជ្ឈមណ្ឌលលើគ្រប់មុខវិជ្ជា ចាប់ពីថ្នាក់ទីមួយ ទីពីរ បឋមសិក្សាឡើងទៅគឺជាបទពិសោធន៍ដ៏ល្អ ក្នុងការទម្លាប់សិស្សរបស់យើងឱ្យថ្នឹកក្នុងកិច្ចស្រាវជ្រាវ និងការស្វែងយល់តាមគោលវិធីនេះ តាំងពីវ័យកុមារ។

-គ្រូជំរុញឱ្យសិស្ស ធ្វើសកម្មភាពត្រិះរិះពិចារណាស្វែងយល់ សិក្សាស្រាវជ្រាវ ការអានមេរៀនត្រៀមទុកជាមុន ការសង្កេតគឺ ជាទម្លាប់ល្អ និង បំផុសគំនិតចេញពីខ្លួនសិស្ស។

**+ ការសង្កេត ឬ ត្រៀមលក្ខណៈសិក្សា**

-គ្រូអាចបង្គាប់សិស្សឱ្យអានមេរៀនទុកជាមុន ឬក៏បង្គាប់សិស្សឱ្យជួយរកសម្ភារៈឧបទេសទុកជាមុន ហើយតាមធម្មតាខ្លឹមសារមេរៀនតែងផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅ។

-គ្រូអាចបង្គាប់សិស្សឱ្យសង្កេតមើលសកម្មភាពសត្វ ឬ វត្ថុ បាតុភូតផ្សេងៗ ដែលស្ថិតនៅក្នុងមជ្ឈដ្ឋានរស់នៅរបស់សិស្ស។ សិស្សអាចប្រើប្រាស់ញាណទាំងប្រាំសម្រាប់សង្កេត សាកសួរអ្នកដទៃ កត់ត្រា ប្រៀបធៀប និងស្វែងយល់ឱ្យស៊ីជម្រៅ មុនពេលដែលត្រូវសិក្សាតាមបែបណាមួយទៅលើខ្លឹមសារមេរៀនណាមួយនោះ សំដៅបង្កើតបានជាបញ្ញត្តិ សញ្ញាណ ឬ និយមន័យ។

ឧទាហរណ៍ទី១៖ ស្រូវពូជដែលកសិករច្រកការុងត្រាំទឹក២៤ម៉ោង ហើយស្រង់វាយកទៅ លើគោក និង ស្រូវពូជដែលកសិករជ្រលក់ទឹកភ្លាម ហើយទុកចោលរយៈពេលដូចគ្នា មុនពេលសាបក្នុងថ្នាលពីរផ្សេងគ្នា តើស្រូវពូជប្រភេទណាផ្តល់នូវគុណភាពសំណាបល្អជាងគេ?

ឧទាហរណ៍ទី២៖ ថ្នាលសំណាបពីរ។ ថ្នាលទី១កសិកររាយអាចម៍គោ ក្របីធម្មតា និង ថ្នាលទី២កសិកររោយជីអង្កាម និងសំរាម។ តើថ្នាលមួយណាដែលផ្តល់គុណភាពសំណាបល្អជាងគេ? ហេតុអ្វី?

**+ ការឆ្លើយនឹងសំណួរ៖**

សំណួរ៖ មានកម្រិតខ្ពស់ កម្រិតមធ្យម និង កម្រិតទាប។ សំណួរកម្រិតខ្ពស់ទាមទារឱ្យសិស្សចេះបកស្រាយ ចេះវិភាគ ចេះធ្វើសំយោគ។ សំណួរដែលទាមទារឱ្យសិស្សចេះផ្តល់នូវចម្លើយវែងត្រឹមត្រូវងាយយល់។ ពេលសួរជាសំណួរធម្មតាត្រូវទុកពេលឱ្យសិស្សគិត វិភាគ ពិចារណាសិន គ្រូមិនត្រូវចង្អុលសិស្សឱ្យឆ្លើយភ្លាមៗទេ ទោះមានសិស្សខ្លះលើកដៃចង់ឆ្លើយសំណួរនោះទាំងតក់ក្រហល់ក៏ដោយ។ គ្រូអាចណែនាំសិស្សឱ្យវិភាគលើអត្ថន័យនៃពាក្យពិបាកយល់សិន។ ពេលចោទសួរសិស្សជាសំណួរធម្មតាគ្រូត្រូវសម្លឹងមើលសិស្សរៀនខ្សោយ និង សិស្សរៀនមធ្យម តើអាចឆ្លើយបានឬអត់។ គ្រូ

មិនត្រូវត្រៀមសំណួរ ឬ ចោទជាសំណួរសម្រាប់តែសិស្សដែលរៀនពូកែនោះទេ។ កាលណាអត្ថន័យនៃឃ្លាសំណួរពិបាកយល់ ឬមានតែសិស្សពូកែលើកដៃសុំឆ្លើយ គ្រូគួរតែសម្រួល ពាក្យពេចន៍ ឬ ឃ្លាឱ្យសិស្សមធ្យម និងសិស្សខ្សោយងាយយល់ តែត្រូវរក្សាខ្លឹមសារអត្ថន័យ និង គោលបំណងនៃសំណួរនោះឱ្យនៅដដែល។

ចំពោះសំណួរដែលគ្រូរៀបចំសម្រាប់សិស្សពិភាក្សាតាមក្រុម នៅពេលដែលគ្រូត្រូវអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌលត្រូវមានលក្ខណៈទាំងឡាយដូចតទៅ៖

-មានគោលបំណងបង្កើតការគិត និង ការត្រិះរិះពិចារណាស្រាវជ្រាវរកព័ត៌មាន

-ទាមទារឱ្យសិស្សវិភាគប្រៀបធៀប ទិតៀន ឬ គាំទ្រលើគំនិត ឬ ទស្សនៈណាមួយ

-ទាមទារឱ្យសិស្សបកស្រាយ ធ្វើសំយោគ បញ្ចេញមតិយោបល់ផ្ទាល់ខ្លួន តាមបែបច្នៃប្រឌិត

-ទាមទារឱ្យសិស្សរកចម្លើយដោយទាញភស្តុតាងចេញពីទៅតាមគំនិតថ្មីស្រឡាងឈានទៅរកបរកគំហើញបែបណាមួយ

-សំណួរខ្លះត្រូវបានសិក្សារកឃើញចម្លើយ ដោយបញ្ចេញបាននូវគំនិតដ៏ថ្មីស្រឡាង

-សំណួរត្រូវមានខ្លឹមសារ អត្ថន័យ និង កម្រិតអាចឱ្យសិស្សខ្សោយបញ្ចេញយោបល់បាន

-សំណួរ អត្ថន័យ និងខ្លឹមសារមិនប្រាស់ចាកពីខ្លឹមសារមេរៀន ដែលត្រូវរៀន និងវត្ថុ បាតុភូត មនុស្ស សត្វ ព្រឹត្តិការណ៍ ឬ ហេតុការណ៍ក្នុងសង្គមដែលធ្លាប់ជួបប្រទះ

-សំណួរត្រូវមានលទ្ធភាពនៃការផ្តល់ចម្លើយបានសមស្របទៅនឹងសមត្ថភាពសិស្សខ្សោយ និង សិស្សមធ្យម

-សំណួរខ្លះតម្រូវឱ្យសិស្សប្រើពេលស្រាវជ្រាវរកចម្លើយនៅក្រៅថ្នាក់រៀន ឬ នៅក្រៅសាលារៀន។

-គ្រូដាក់សំណួរផ្សេងៗគ្នាឱ្យសិស្សពិភាក្សាតាមក្រុម។ ពេលពិភាក្សាចប់តំណាងក្រុមត្រូវឡើងផ្តល់ ឬ សរសេរចម្លើយនៃសំណួរ សំដៅបង្កើតបានជាខ្លឹមសារនៃមេរៀនតែម្តង។

សំណួរ៖ អាចឱ្យសិស្សធ្វើជាដៃគូពីរនាក់ក៏បាន ឬ ធ្វើជាបុគ្គលក៏បាន ធ្វើជាក្រុមក៏បាន។ ការឱ្យសិស្សធ្វើជាដៃគូ ឬធ្វើជាបុគ្គលជាហេតុនាំឱ្យមានលក្ខណៈប្រកួតប្រជែង។ ការប្រកួតប្រជែងជាហេតុនាំឱ្យសិស្សម្នាក់ៗមានការសន្សំគំនិតក្នុងស្វ័យសិក្សាបាន ដើម្បីរៀនយកស្នាដៃ។ អ្នកធ្វើហើយមុនគេមានចម្លើយត្រឹមត្រូវពុំទទួលបានលទ្ធផលល្អ ប្រសិនបើសមាជិកពុំមានការសហការ និងចូលរួមបញ្ចេញគំនិតយោបល់។ ដូចនេះដើម្បីធ្វើឱ្យមានភាពងាយស្រួលត្រូវ៖

-មានអ្នកសម្របសម្រួល និង ដឹកនាំក្រុមពិភាក្សា

-មានលេខាកត់ត្រា ដើម្បីកត់ត្រានូវអ្វីៗដែលក្រុមបានពិភាក្សា

-អ្នកផ្ទៀងផ្ទាត់ធ្វើការជានាឧសត្រូវលើការងារពិភាក្សាក្រុមបានចប់សព្វគ្រប់

-អ្នករាយការណ៍ត្រូវសរសេររបាយការណ៍ពីលទ្ធផលការងារ

-អ្នកវិចិត្រជាអ្នកគូររូបភាព

ក្រោយមកទៀត តំណាងក្រុមសិស្សត្រូវឡើងរាយការណ៍ពីលទ្ធផលពិភាក្សាក្រុម ឱ្យដល់ក្រុមផ្សេងទៀតបានដឹង ធ្វើរបៀបនេះរហូតដល់អស់ក្រុមក្នុងថ្នាក់ បន្ទាប់មកទៀតគ្រូត្រូវធ្វើសំយោគរួមមួយលើប្រធានបទ ដែលគ្រូបានដាក់ឱ្យសិស្សធ្វើនោះ ការធ្វើរបៀបនេះគឺ សិស្សទទួលបានចំណេះដឹងមួយពេញលេញ និង ងាយស្រួលសម្រាប់ឱ្យពួកគេបានយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។

-**ចក្ខុបំណងអភិវឌ្ឍន៍**

ដើម្បីសម្រេចបាននូវការកសាង និង អភិវឌ្ឍន៍ធនធានមនុស្ស ប្រកបដោយគុណភាពផង និង សម្រេចគោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នានាឆ្នាំ២០១៥ ក្រោមរូបភាពសិក្សាឥតបង់ថ្លៃចាំបាច់ ត្រូវតែកែលំអបរិស្ថានសាលាឱ្យកាន់តែល្អប្រសើរឡើង ដើម្បីឱ្យក្លាយជាសាលាកុមារមេត្រី និង ពិតជាមជ្ឈមណ្ឌលវប្បធម៌ក្នុងមូលដ្ឋាន។

## ឯកសារយោង


-សម្តេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ ឆ្នាំ១៩៦៧

-ក្រសួងអប់រំ ការអប់រំនៅកម្ពុជា ឆ្នាំ១៩៩៩

-កង ឱម ការអភិវឌ្ឍកម្មវិធីសិក្សា ឆ្នាំ២០១២

-ចាន់ វឌ្ឍសុផា គរុកោសល្យ ឆ្នាំ២០០០

-ក្រសួងអប់រំ គោលវិធីសិស្សមជ្ឈមណ្ឌល ឆ្នាំ២០០២

-ទស្សនាវដ្តីអក្សរសាស្ត្រ-មនុស្សសាស្ត្រ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ( ឆ្នាំទី៤២ លេខ៧៩ )

# ហេតុផល១១យ៉ាងបញ្ជាក់ថា ហេតុអ្វីបានជាទស្សនវិជ្ជាសំខាន់

ដោយ បណ្ឌិត ឈត ប៊ុនថង
ប្រធានផ្នែកទំនាក់ទំនងវប្បធម៌ អប់រំ និងទេសចរណ៍នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា
និងជាប្រធានមុខវិជ្ជាទស្សនវិជ្ជានៃរាជបណ្ឌិត្យសភាកម្ពុជា

ជាទូទៅ មុនពេលមនុស្សម្នាក់ៗសម្រេចចិត្តសិក្សាមុខជំនាញណាមួយ គេតែងតែលើកឡើងនូវសំណួរដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ឬសារៈសំខាន់នៃការសិក្សាជំនាញនោះ។ ដូចជាគ្នាដែរ ចំពោះការសិក្សាជំនាញ ឬឯកទេសទស្សនវិជ្ជា ក៏មានសំណួរអំពីសារៈសំខាន់នៃការសិក្សាមុខជំនាញនេះដែរ។ ក្នុងអត្ថបទនេះ ខ្ញុំនឹងបង្ហាញការពិភាក្សាផ្អែកលើហេតុផល១១យ៉ាងដែលបញ្ជាក់ថាទស្សនវិជ្ជាមានសារៈសំខាន់។ ហេតុផលច្បាស់លាស់បំផុតដែលបញ្ជាក់ថា ទស្សនវិជ្ជាផ្តល់អត្ថប្រយោជន៍ដល់មនុស្ស គឺអាចនិយាយយ៉ាងសាមញ្ញថា ទស្សនវិជ្ជាជួយឱ្យយើងក្លាយជាមនុស្សកាន់តែមានហេតុផល។ ក្រៅពីនេះ នៅមានអត្ថប្រយោជន៍ជាច្រើនទៀតដែលវាផ្តល់ឱ្យយើង ដូចជា ការគិតហ្មត់ចត់ ការពិនិត្យសង្កេតដោយប្រុងប្រយ័ត្ន និងការវាយតម្លៃប្រកបដោយហេតុផលនិងមូលដ្ឋានច្បាស់លាស់និងគ្រប់គ្រាន់ ជាដើម។ លក្ខណៈលម្អិតនីមួយៗដែលបញ្ជាក់ថា ទស្សនវិជ្ជាមានតម្លៃ យើងនឹងពិភាក្សាតាមប្រធានបទនីមួយៗដូចខាងក្រោម។

## ១.ទស្សនវិជ្ជាជួយឱ្យយើងក្លាយជាមនុស្សប្រកបដោយហេតុផល

ការរៀនដើម្បីក្លាយទៅជាមនុស្សមានហេតុផល គឺជារឿងសំខាន់បំផុត ព្រោះយើងទាំងអស់គ្នាសុទ្ធតែត្រូវជ្រើសរើស សម្រេចចិត្ត និងសម្រេចគោលដៅ។ ការមានហេតុផល អាចជួយឱ្យយើងធ្វើការជ្រើសរើសបានល្អ សម្រេចបានគោលដៅរបស់យើង រស់នៅក្នុងជីវិតល្អប្រសើរ និងក្លាយជាមនុស្សល្អ។ ប្រសិនបើមនុស្សមួយចំនួនដែលគេស្គាល់ថា ពួកគេជាមនុស្សគ្មានហេតុផល ហើយក្រោយពីពួកគេបានរៀនមុខវិជ្ជាទស្សនវិជ្ជា ដូចជា តក្កវិជ្ជាជាដើម បានធ្វើឱ្យពួកគេក្លាយទៅជាមនុស្សចេះគិតគិតហ្មត់ចត់ ពិចារណាជ្រៅជ្រះ ប្រកបដោយហេតុផល និងមិនលម្អៀង នោះនឹងនាំឱ្យមនុស្សដទៃទៀតមើលឃើញពីប្រយោជន៍របស់ទស្សនវិជ្ជា ហើយពួកគេនឹងចង់រៀនទស្សនវិជ្ជាដែរ។

«ហេតុផល» គឺជាសារជាតិឬខ្លឹមនៃទស្សនវិជ្ជា ហើយគេអាចរៀនអំពីហេតុផលនេះតាមរយៈឯកទេសតក្កវិជ្ជា និងពុទ្ធិវិទ្យា ដែលជាមែកធាងនៃទស្សនវិជ្ជា។ តាមពិតទៅមនុស្សម្នាក់ៗសុទ្ធតែមានទស្សនវិជ្ជារៀងៗខ្លួន ឬអាចនិយាយបានថា មនុស្សគ្រប់រូបសុទ្ធតែជាទស្សនវិទូ ដូច្នេះ ពួកគេមានហេតុផលរៀងៗខ្លួន និងការគិតប្រកបដោយហេតុផល។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏គ្មានអ្នកណាម្នាក់មានហេតុផល និងទស្សនវិជ្ជាល្អឥតខ្ចោះឡើយ។ កំហុសជាច្រើនដែលមនុស្សបានធ្វើ អាចជាឧបសគ្គរាំងដល់សមត្ថភាពរបស់ពួកគេក្នុងការឈានទៅដល់ភាពសមហេតុផល កំហុសនោះគេស្គាល់ថាជា«វិរុទ្ធនិទស្សន៍»។ ការយល់ដឹងកាន់តែច្រើនអំពីភាពសមហេតុផលអាចធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់យើងក្នុងពិចារណាសមហេតុផល ពីព្រោះយើងអាចពិចារណាដោយប្រុងប្រយ័ត្ន ជាជាងគ្រាន់តែជឿលើអ្វីមួយដែល«ហាក់ដូចជាសមហេតុផល» នៅក្នុងន័យអព្ពន្តរញាណ។

ការរៀនឱ្យចេះពិចារណាសមហេតុផល អាចធ្វើឡើងតាមរយៈការយល់ដឹងអំពីទឡ្ហីកម្មល្អៗ តក្កវិជ្ជា ការអានទឡ្ហីករណ៍បែបទស្សនវិជ្ជា ការសរសេរទឡ្ហីករណ៍បែបទស្សនវិជ្ជា និងការអនុវត្តការពិភាក្សាបែបទស្សនវិជ្ជា។ ការណ៍ដែលថាមនុស្សមិនបានរៀនសូត្រគ្រប់គ្រាន់អំពីភាពសមហេតុផល បង្ហាញឱ្យឃើញតាមរយៈ (ក)ចំណាប់អារម្មណ៍របស់យើងកាន់តែច្រើនទៅលើ«ការគិតហ្មត់ចត់» (ខ)យើងមិនបានទទួល «ការគិតហ្មត់ចត់» គ្រប់គ្រាន់ពីការអប់រំរបស់យើង និង (គ)ជំនឿនិងអាកប្បកិរិយាទូទៅមិនសមហេតុផល។

ការណ៍ដែលយើងចាប់អារម្មណ៍លើ «ការគិតហ្មត់ចត់» បានបង្ហាញរួចជាស្រេចហើយពីកម្រិតដែលយើងមានភាពមិនសមហេតុផល ពីព្រោះថា ការបង្រៀនអំពី«ការគិតហ្មត់ចត់» មានទំនោរទៅរកត្រឹមតែការយល់ដឹងអប្បរមាអំពីតក្កវិជ្ជានិងទឡ្ហីកម្មប៉ុណ្ណោះ។ នរណាម្នាក់ដែលមាន«ការគិតហ្មត់ចត់» មិនចាំបាច់ដឹងពីរបៀបគិតឱ្យបានល្អទេ។ ការនិយាយបែបនេះ មិនប្រឆាំងនឹងការគិតហ្មត់ចត់ទេ ប៉ុន្តែការរៀនអំពីការគិតហ្មត់ចត់ គឺជាការរៀនស្តង់ដារមួយទាប ដូច្នេះ យើងគួររៀនឱ្យបានច្រើនបន្ថែមទៀតអំពីភាពសមហេតុផល លើសពីអ្វីដែលយើងបានរៀនក្នុងមុខវិជ្ជាការគិតហ្មត់ចត់។ បើយើងដឹងអំពីរបៀបសមហេតុផល យើងនឹងដឹងពីរបៀបគិត្មត់ចត់។ ប្រសិនបើយើងដឹងពីរបៀបគិតហ្មត់ចត់ យើងមិនចាំបាច់ដឹងពីរៀបគិតសមហេតុសមផលទេ។

ការណ៍ដែលយើងតែងតែទមិនទទួលបានការគិតហ្មត់ចត់ពីការអប់រំរបស់យើង គឺជាកង្វល់របស់អ្នកអប់រំជាច្រើន ហើយវាបង្ហាញថាយើងស្ថិតនៅផ្លូវវែងឆ្ងាយពីការរំពឹងឱ្យពលរដ្ឋរបស់យើងដឹងពីរបៀបគិតសមហេតុផល។ ការសិក្សាដ៏ទូលំទូលាយមួយដឹកនាំដោយ រីឆាដ អាតាម (Richard Arum)[1] បានរកឃើញថា «ការគិតហ្មត់ចត់, ការពិចារណាពេញលេញ និងជំនាញទំនាក់ទំនងខាងការសរសេរ ត្រូវបានគេសន្មតយ៉ាងទូលំទូលាយថាជាស្នូលនៃការអប់រំមហាវិទ្យាល័យ»។ ដូច្នេះ មុខវិជ្ជាទស្សនវិជ្ជា ត្រូវតែបង្រៀនដល់អ្នកសិក្សាទាំងអស់ ទាំងអ្នកសិក្សាខាងវិទ្យាសាស្ត្រសង្គម មនុស្សសាស្ត្រ វិទ្យាសាស្ត្រធម្មជាតិ គណិតវិទ្យា និងជំនាញផ្សេងៗទៀត។

ជំនឿនិងអាកប្បកិរិយាទូទៅដែលមិនសមហេតុផល ត្រូវបានបង្ហាញតាមរយៈឥរិយាបថមិនស្មោះត្រង់របស់អ្នកនយោបាយ អ្នកឃោសនា និងភ្នាក់ងារផ្សាយពាណិជ្ជកម្មមួយភាគច្រើន ដែលព្យាយាមបោកបញ្ឆោតប្រជាជនដោយប្រើហេតុផលខុសឆ្គង ហើយជាញឹកញាប់ពួកគេទទួលបានជោគជ័យ។

បដិសេធការគិតបែបទស្សនវិជ្ជា ស្មើនឹងស្រឡាញ់គំនិតរបស់ខ្លួនឯងជាជាងការគិតសមហេតុផលបំផុតដែលអាចកើតឡើង។ ការធ្វើបែបនេះ នាំឱ្យយើងក្លាយជាមនុស្សគម្ពីរនិយម និងប្រកាន់យកលទ្ធិណាមួយដាច់ខាត។ ការរៀនទស្សនវិជ្ជា អាចជួយឱ្យយើងដឹងពីគំនិតទស្សនវិជ្ជាកាន់តែច្រើន។

## ២.ទស្សនវិជ្ជាជួយឱ្យយើងប្រកបដោយសីលធម៌

[1] Richard Arum (born 1963) is an American sociologist of education and stratification, best known for his research on student learning, school discipline, race, and inequality in K-12 and higher education. Arum has a B.A. in Political Science from Tufts University, an M.Ed. in Teaching and Curriculum from the Harvard University Graduate School of Education, and a Ph.D. in Sociology from the University of California, Berkeley. He is currently dean of the University of California, Irvine School of Education, as well as a senior fellow at the Bill and Melinda Gates Foundation.

សីលធម៌ មានសារសំខាន់បំផុត ពីព្រោះសេចក្ដីសម្រេចចិត្តរបស់យើងអាចមានឥទ្ធិពលយ៉ាងខ្លាំងមកលើខ្លួនយើង និងអ្នកដទៃ។ ការសម្រេចចិត្តរបស់យើងអាចជួយមនុស្ស ឬធ្វើឱ្យមនុស្សឈឺចាប់។ យើងចង់ឱ្យមានឧក្រិដ្ឋជនតិចតួច មនុស្សកាន់តែច្រើនជួយដល់អ្នកក្រ ម្ចាស់រោងចក្រ សហគ្រាស និងសាជីវកម្មកាន់តែតិចដែលបោះបង់កាកសំណល់ដែលជាតិពុលទៅក្នុងបណ្ដាប្រទេសអភិវឌ្ឍតិចតួច, មនុស្សកាន់តែច្រើនទាមទារឱ្យរដ្ឋាភិបាលបញ្ឈប់ការផ្ដល់ប្រាក់រាប់ពាន់លានដុល្លារដល់ក្រុមហ៊ុនប្រេងនៅក្នុងរូបភាពជា«ការឧបត្ថម្ភធន», មន្ត្រីនគរបាល និងអ្នកនយោបាយពុករលួយកាន់តិច, ចៅក្រមកាន់តែតិចដែលទទួលយកសំណូក។ល។

អ្នកដែលដែលមាន«ជំនាញ»ខាងសីលធម៌ គឺជាទស្សនវិទូ។ មុខវិជ្ជាដែលផ្ដល់ការយល់ដឹងសមហេតុផលអំពីសីលធម៌ត្រូវបានគេស្គាល់ថាជា«ទស្សនវិជ្ជាសីលធម៌» ឬ«សីលធម៌វិជ្ជា»។ ទស្សនវិទូផ្ដល់ឱ្យយើងនូវទ្រឹស្ដីសីលធម៌នានា និងវិធីសមហេតុផលបំផុតក្នុងការធ្វើការសម្រេចចិត្តខាងសីលធម៌។ ជាពិសេស យើងត្រូវអនុវត្តភាពសមហេតុផលខាងសីលធម៌។

វិធីមួយដែលយើងអាចបង្កើនសមត្ថភាពរបស់យើងដើម្បីឱ្យប្រកបដោយសីលធម៌ គឺធ្វើឡើងតាមរយៈការអនុវត្តការពិចារណាត្រឹមត្រូវចំពោះសីលធម៌។ យើងអាចរៀនទ្រឹស្ដីសីលធម៌នានា អានទស្សនវិជ្ជាសីលធម៌ សរសេរទឡ្ហីករណ៍ទស្សនវិជ្ជាផ្ទាល់ខ្លួនទាក់ទងនឹងសីលធម៌ និងពិភាក្សាបញ្ហាបញ្ហាសីលធម៌តាមគោលការណ៍ទស្សនវិជ្ជា។

ថ្វីបើទស្សនវិទូនានាមិនមែនតែងតែយល់ស្របគ្នាអំពីអ្វីដែលហៅថាអំពើ «ត្រឹមត្រូវ» ឬ«ខុសឆ្គង»ក៏ដោយក៏ពួកគេផ្ដល់គំនិតល្អៗដែលយើងអាចជឿជាក់បាន។ រហូតដល់ពេលនេះ ពុំមានជម្រើសឬមធ្យោបាយណាមួយល្អប្រសើរសម្រាប់ការយល់ដឹងអំពីសីលធម៌ ជាងការសិក្សាទស្សនវិជ្ជាសីលធម៌ទេ។ ភាពសមហេតុផល មិនតម្រូវឱ្យមានឯកភាពទេ វាតម្រូវឱ្យយើងមានជំនឿ«សមហេតុផលគ្រប់គ្រាន់»។

លើសពីនេះទៀត ការអប់រំខាងសីលធម៌ មិនគ្រាន់តែមានតម្លៃពីព្រោះតែវាអាចជួយមនុស្សឱ្យប្រកបដោយសីលធម៌ប៉ុណ្ណោះទេ ប៉ុន្តែវាក៏ពីព្រោះតែយើងអាចរៀនអំពីកត្តាចិត្តសាស្ត្រដែលជួយលើកទឹកចិត្តឱ្យមនុស្សប្រកបដោយសីលធម៌ផងដែរ។ យើងអាចបង្រៀនកត្តាទាំងនេះ និងអនុវត្តវានៅពេលដែលអាចធ្វើទៅបាន។ ឧទាហរណ៍ យើងអាចរៀនពីរបៀបបណ្ដុះការអាណិតអាសូររបស់យើងចំពោះអ្នកដទៃ និងការបញ្ឈប់ឥរិយាបថឬរបៀបរស់នៅដែលមិនយកចិត្តទុកដាក់នឹងការអាណិតអាសូរ។

ការណ៍ដែលសីលធម៌មានសារៈសំខាន់បំផុត ហើយយើងអាចក្លាយជាមនុស្សកាន់តែប្រសើរដោយសារសីលធម៌ ខណៈដែលការអប់រំមិនត្រូវបានចាត់ទុកសីលធម៌ជាអាទិភាព ដែលអាចក្លាយជា«មុខវិជ្ជាចាំបាច់»នៅវិទ្យាល័យឬមហាវិទ្យាល័យ គឺជាប្រការគួរឱ្យសោកស្ដាយ។

## ៣.ទស្សនវិជ្ជាផ្ដល់ឱ្យយើងនូវពុទ្ធិ

ទស្សនវិជ្ជាបានផ្ដល់ឱ្យយើងនូវចំណេះដឹងចាំបាច់ដើម្បី យល់ពីតក្កវិជ្ជា, អភិវឌ្ឍវិទ្យាសាស្ត្រធម្មជាតិ, ស្វែងរកជំនឿគួរឱ្យទុកចិត្តបានដែលទាក់ទងនឹងភាពសមហេតុផល ជំនឿដែលគួរឱ្យទុកចិត្តបានទាក់ទងនឹងសីលធម៌ ។ល។ សូម្បីតែវិស័យនៃទស្សនវិជ្ជាដែលពាក់ព័ន្ធនឹងធម្មជាតិនៃតថភាព, ទំនាក់ទំនងខាងគំនិត ធម្មជាតិនៃគណិតវិទ្យា ធម្មជាតិនៃសីលធម៌ និងសីលវិជ្ជាអនុវត្តដ៏ចម្រូងចម្រាស ក៏ពាក់ពន្ធនឹងពុទ្ធិទស្សនវិជ្ជាដ៏ទូលំទូលាយដែរ។ ជាពិសេស យើងអាចដឹងថាសម្មតិកម្មខ្លះមិនអាចត្រឹមត្រូវទេ ទោះបីជានៅពេលនេះយើងគ្មានវិធីយល់ដឹងពីសច្ចភាពដាច់

ខាតក៏ដោយ។ លក្ខណៈនេះមិនខុសគ្នាពីរបៀបដែលអ្នកវិទ្យាសាស្ត្រធម្មជាតិ បង្កើតទ្រឹស្តីវិទ្យាសាស្ត្រនានានោះទេ។ ពេលខ្លះ យើងមិនអាចបញ្ជាក់ថាទ្រឹស្តីណាមួយល្អបំផុតនោះទេ ទោះបីជាយ៉ាងនេះក៏ដោយ ក៏អ្នកជំនាញបានដឹងអ្វីៗច្រើនជាងអ្នកដទៃទៀតដែលមិនមែនជាអ្នកជំនាញដែរ។

## ៤.ទស្សនវិជ្ជាអាចធ្វើឱ្យយើងរីករាយ

ហេតុអ្វីចំណេះដឹងបែបទស្សនវិជ្ជាសំខាន់ណាស់? ជាថ្មីម្តងទៀត យើងកត់សម្គាល់ថា វាជារឿងសំខាន់ណាស់ដែលយើងត្រូវតែជាមនុស្សសមហេតុផលនិងប្រកបដោយសីលធម៌។ ទោះជាយ៉ាងណាក៏ដោយ ក៏ពុទ្ធិដែលយើងទទួលបានតាមរយៈទស្សនវិជ្ជាធ្វើឱ្យយើងមានភាពរីករាយ ហើយប្រហែលជាវា«ល្អសម្រាប់ប្រយោជន៍ខ្លួន»។ ទស្សនវិជ្ជាអាចមានតម្លៃសក្តិសមនឹងត្រូវសិក្សា ដោយសារតែវាជាប្រភេទចំណេះដឹងដ៏ល្អដែលយើងត្រូវមាន ទោះបីជាពេលខ្លះ វាមិនត្រូវបានប្រើសម្រាប់អ្វីមួយក៏ដោយ។

## ៥.ទស្សនវិជ្ជាជួយឱ្យសម្រេចសមិទ្ធផលដ៏អស្ចារ្យជាច្រើន

ទស្សនវិជ្ជាខ្លួនឯងដែលជាសមិទ្ធផលដ៏ធំបំផុតរបស់មនុស្សជាតិមានការរីកចម្រើនជាបន្តបន្ទាប់ ពីព្រោះតែមនុស្សជាតិបានប្រើគំនិតរបស់ខ្លួនដើម្បីពិចារណាត្រឹមត្រូវអំពីបញ្ហានានា រួមមានស្នាដៃដ៏អស្ចារ្យបំផុតដែលបានសម្រេចកន្លងមក។ នៅពេលយើងក្រឡេកមើលប្រវត្តិសាស្ត្ររបស់យើង និងវប្បធម៌ផ្សេងៗទៀត យើងបានឃើញថាទស្សនវិជ្ជារបស់យើងបានឆ្លុះបញ្ចាំងឱ្យឃើញពីភាពអស្ចារ្យនៃអរិយធម៌ទាំងមូលរបស់យើង។ ទោះជាយ៉ាងណាក៏ដោយ ក៏ការអនុវត្តជាក់ស្តែងនៃទស្សនវិជ្ជាមានសារៈសំខាន់ផងដែរ ដូចជា ការប្រើមូលដ្ឋានទស្សនវិជ្ជា ដើម្បីបង្កើតតក្កវិជ្ជា ពុទ្ធិវិទ្យា សីលវិជ្ជា វិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រធម្មជាតិ ជាដើម។

## ៦.ទស្សនវិជ្ជាផ្តល់អត្ថន័យដល់មនុស្សជាតិដែលធ្វើមនុស្សខុសពីភាវៈដទៃ

មានអត្ថន័យនៃមនុស្សជាតិដែលទៅហួសពីការងាររបស់យើង, ហួសពីគ្រួសាររបស់យើង និងហួសពីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់យើង។ មានការស្រេកឃ្លានពុទ្ធិស្តីអំពីបញ្ហាលំបាកៗបំផុត ដូចជា ពុទ្ធិទាក់នឹងតថភាពភាពសមហេតុផល សច្ចភាព និងសីលវិជ្ជា ជាដើម។ យើងចង់ដឹងពីរបៀបដែលធ្វើឱ្យពិភពលោកក្លាយទៅជាកន្លែងមួយល្អប្រសើរ និងផ្តល់អាទិភាពដល់ជីវិតរបស់យើងតាមរបៀបល្អបំផុតដែលអាចធ្វើទៅបាន។ យើងចង់ដឹងបន្ថែមទៀតអំពីអត្ថន័យនៃការក្លាយខ្លួនជាមនុស្សជាតិ និងការសញ្ជឹងគិតពីភាពអស្ចារ្យនៃជីវិតឬអត្ថិភាពរបស់យើង។

## ៧.ទស្សនវិជ្ជាជួយឱ្យយើងរស់នៅបានល្អប្រសើរ

ទស្សនវិជ្ជាអាចជួយយើងឱ្យរស់នៅបានយ៉ាងល្អប្រសើរយ៉ាងហោចណាស់តាមវិធីពីរយ៉ាង។ ទីមួយ «ជីវិតប្រកបដោយកុសល» ដែលអាចជាផ្នែកមួយនៃជីវិតបែបទស្សនវិជ្ជា។ ទីពីរ ទស្សនវិជ្ជាអាចជួយយើងឱ្យសម្រេចចិត្តពីរបៀបដែលធ្វើឱ្យជីវិតរបស់យើងល្អប្រសើរ។ ជីវិតបែបទស្សនវិជ្ជាអាចជាជីវិតល្អប្រសើរ។ មនុស្សធ្លាប់ចង់ស្វែងរកការត្រាស់ដឹង ពីព្រោះការត្រាស់ដឹងខ្លួនឯងជាអ្វីមួយល្អបំផុតដែលយើងគួរធ្វើ។ ទស្សនវិជ្ជាបានផ្តល់នូវការត្រាស់ដឹងដ៏អស្ចារ្យបំផុត។ មិនត្រឹមតែពុទ្ធិអំពីទស្សនវិជ្ជាទេដែលអាចល្អនោះ ប៉ុន្តែ សូម្បីតែជីវិតបែបទស្សនវិជ្ជា( ជាជីវិតដែល

ព្យាយាមរស់នៅអនុលោមតាមតាមចំណេះដឹងបែបទស្សនវិជ្ជា)ក៏អាចល្អដែរ។ អ្នកដែលប្រកាន់យកជីវិតបែបទស្សនវិជ្ជា គឺជាអ្នកដែលក្លាយទៅជាមនុស្សជាតិល្អប្រសើរ។ ជីវិតបែបទស្សនវិជ្ជាអាចជួយឱ្យយើងសម្រេចគោលដៅរបស់យើង។ ទស្សនវិជ្ជាផ្តល់ឱ្យយើងនូវផ្លូវឆ្ពោះទៅរកការធ្វើឱ្យប្រសើរឡើងនូវជំនាញនៃការគិតហ្មត់ចត់ ដែលទៅហួសពីអ្វីដែលយើងដឹង។ ជំនាញទាំងនេះមានភាពពេញលេញនិងអាចអនុវត្តបាននៅគ្រប់ផ្នែកនៃជីវិតរបស់យើង។

រៀន«បង្កើតអត្ថន័យ» មានន័យថា យើងអាច«បង្កើតអត្ថន័យ»ក្នុងជីវិតផ្ទាល់ខ្លួនរបស់យើង និងស្វែងរកដំណោះស្រាយចំពោះកំហុសដែលយើងបានធ្វើពីមួយថ្ងៃទៅមួយថ្ងៃ។ យើងអាចប្រើទស្សនវិជ្ជាដើម្បីជួយយើងក្នុងការស្វែងរកដំណោះស្រាយអំពីរបៀបធ្វើឱ្យពិភពលោកល្អប្រសើរ កែលម្អខ្លួនយើង និងមានទំនាក់ទំនងល្អប្រសើរ។ ទស្សនវិជ្ជាផ្តល់វិធីមួយក្នុងចំណោមវិធីដ៏ល្អបំផុតនៃ«ស្វ័យអភិវឌ្ឍន៍» ជាស្វ័យមគ្គុទេសក៍ខាងស្មារតី ដែលអ្នកគ្មានការអត់ធ្មត់ចាំបាច់ត្រូវតែរៀន។ «ស្វ័យអភិវឌ្ឍន៍» គឺជាប្រភេទនៃ«ការជួយខ្លួនឯងដោយខ្លួនឯង» ដែលទាមទារមាន «ការគិតច្រើនពេក» និង«ការងារច្រើនពេក» នៅពេលដែលប្រជាជនចង់បាន«ដំណោះស្រាយភ្លាមៗ»។ «វិធីល្អបំផុតក្នុងការធ្វើឱ្យជីវិតរបស់យើងប្រសើរឡើង គឺមិនត្រូវលេបថ្នាំ ឬព្យាយាមក្លាយទៅជាអ្នកមានភ្លាមៗនោះទេ។ វិធីល្អបំផុតក្នុងការធ្វើឱ្យជីវិតរបស់យើងប្រសើរឡើង គឺត្រូវធ្វើបន្តិចម្តងៗទៅតាមពេលវេលា។ រៀនទស្សនវិជ្ជា គឺរៀនអំពីពិភពលោក កែលម្អការគិតហ្មត់ចត់របស់យើង និងប្រើប្រាស់ពុទ្ធិនិងជំនាញទស្សនវិជ្ជារបស់យើងក្នុងជីវិតប្រចាំថ្ងៃ។

## ៨.ទស្សនវិជ្ជាជួយឱ្យយើងកំណត់អត្តសញ្ញាណនៃការបោកបញ្ឆោត

យើងដឹងថាមានសាសនាជាច្រើនមានកំហុស ហើយប្រើបច្ចេកទេសយ៉ាងប៉ិនប្រសប់ ស្រដៀងនឹងជំនឿអរូបីផ្សេងៗទៀត។ យើងដឹងថា ភ្នាក់ងារផ្សាយពាណិជ្ជកម្ម ការឃោសនា និងអ្នកនយោបាយមួយចំនួន ព្យាយាមបោកបញ្ឆោតប្រជាជន ពីព្រោះពួកគេទទួលបានជោគជ័យពីការធ្វើដូច្នេះ។ យើងដឹងថាវិទ្យាសាស្ត្រមិនល្អខ្លះដែលមិនអាចជឿជាក់បាន។ មានហេតុផលល្អ និងហេតុផលមិនល្អ ដូច្នេះហើយយើងត្រូវតែស្វែងយល់ឱ្យបានច្រើនអំពីភាពខុសគ្នារវាងហេតុផលទាំងពីរនេះ។ នៅពេលយើងរៀនពីភាពខុសគ្នា យើងនឹងអាចកំណត់អត្តសញ្ញាណនៃការបោកប្រាស់បាន ជៀសវាងពីការបោកប្រាស់ និងជួយអ្នកដទៃឱ្យដឹងអំពីការបោកប្រាស់។ ការប្រយុទ្ធប្រឆាំងនឹងការបោកប្រាស់គឺជាផ្នែកមួយនៃការធ្វើឱ្យពិភពលោកក្លាយទៅជាកន្លែងមួយកាន់តែប្រសើរ។ អ្នកដែលប្រើការបោកបញ្ឆោតដើម្បីទទួលបានប្រាក់និងអំណាចកាន់តែច្រើន ជារឿយៗធ្វើឱ្យប្រជាជនរងគ្រោះ និងឈឺចាប់។

## ៩.ទស្សនវិជ្ជាជួយយើងឱ្យយល់អំពីប្រវត្តិសាស្ត្រនៃគំនិត

ទស្សនវិជ្ជា អាចបង្រៀនអ្នកពីប្រវត្តិសាស្ត្រ ដែលជារឿយៗត្រូវបានដកចេញពីសៀវភៅប្រវត្តិសាស្ត្រនានា ពោលគឺប្រវត្តិសាស្ត្រនៃទស្សនៈពិភពលោក និងគំនិតនានា។ អ្នកមិនអាចដឹងពីរបៀបដែលយើង «បានរីកចម្រើន» និងទទួលបានភាពអស្ចារ្យនៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដោយគ្មានការយល់ដឹងពីប្រវត្តិសាស្ត្រនៃទស្សនវិជ្ជាទេ។ លើសពីនេះទៀត ទស្សនវិជ្ជាត្រូវបានគេចាត់ទុកថាជាបិតានៃវិទ្យាសាស្ត្រ និងជាឫសគល់នៃវិទ្យាទាំងអស់ ហេតុនេះបើយើងចង់ដឹងពីប្រភពឬប្រវត្តិនៃការវិវត្តរបស់វិទ្យាសាស្ត្រទាំងនោះ ចាំបាច់យើងត្រូវតែសិក្សាមុខវិជ្ជាទស្សនវិជ្ជា។

## ១០.ទស្សនវិជ្ជាជួយឱ្យយើងមានភាពច្នៃប្រឌិតបកាន់តែខ្ពស់

ទស្សនវិជ្ជាអាចជួយឱ្យយើងរៀនពីរបៀបគិតប្រកបដោយភាពច្នៃប្រឌិត។ ការរៀនអំពីចម្លើយដែលមនុស្សបានគិតដើម្បីឆ្លើយតបទៅនឹងសំណួរដ៏ស្មុគស្មាញបំផុតពាក់ព័ន្ធនឹងជីវិត បើកលទ្ធភាពឱ្យអ្នកអាចធ្វើការសម្រេចចិត្តដោយខ្លួនឯង ជាពិសេសក្នុងគ្រាលំបាក។ ជារឿយៗ ទស្សនវិទូ រួមចំណែកចំពោះពិភពលោកតាមរយៈការគិតតាមវិធីថ្មីសន្លាង និងផ្តល់នូវចម្លើយថ្មីសន្លាង ហើយអ្នករាល់គ្នាក៏អាចរៀនធ្វើដូច្នេះបានដែរ។

## ១១.ទស្សនវិជ្ជាអាចជួយធ្វើឱ្យពិភពលោកក្លាយជាកន្លែងមួយដ៏ប្រសើរ

មនុស្សដែលមានចំណេះដឹងជ្រៅជ្រះភាគច្រើន គិតថាទស្សនវិជ្ជាមានសារៈសំខាន់បំផុត។ ភាពភ័យខ្លាចនៃពិភពលោក ជាញឹកញាប់ អាចត្រូវបានបង្កដោយកំហុសខាងវប្បធម៌ ជាជាងករណីអសីលធម៌ដោយឡែកៗ។ កង្វះភាពសមហេតុសមផល និងកង្វះចំណេះដឹងខាងសីលធម៌របស់យើង គឺជាផ្នែកមួយនៃវប្បធម៌របស់យើង។ ប្រសិនបើទស្សនវិជ្ជាបានរីករាលដាលនិងត្រូវបានផ្តល់តម្លៃគ្រប់គ្រាន់នៅក្នុងការរស់នៅរបស់ប្រជាជន នៅពេលនោះវប្បធម៌ទាំងមូលរបស់យើងនឹងត្រូវបានធ្វើឱ្យប្រសើរឡើង ហើយឥរិយាបថរបស់ប្រជាជននៅក្នុងវប្បធម៌នោះក៏នឹងត្រូវបានធ្វើឱ្យប្រសើរឡើងដែរ។ នេះគឺជាវិធីរួមមួយដែលអាចធ្វើឱ្យពិភពលោកក្លាយទៅជាកន្លែងមួយដ៏ប្រសើរ។

## សេចក្តីសន្និដ្ឋាន

យោងតាមការបង្ហាខាងលើនេះ ពិតជាបានបញ្ជាក់យ៉ាងច្បាស់ថាទស្សនវិជ្ជាមានសារៈសំខាន់ណាស់ចំពោះមនុស្ស ទាំងកម្រិតបុគ្គល គ្រួសារ សហគមន៍ រដ្ឋ តំបន់ និងពិភពលោក។ ដូច្នេះ យើងគួរតែរៀនទស្សនវិជ្ជា និងគួរព្យាយាមក្លាយទៅជាមនុស្សប្រកបដោយដោយទស្សនវិជ្ជា។ លើសពីនេះទៀត គួរតែលើកកម្ពស់ការផ្សព្វផ្សាយទស្សនវិជ្ជា សីលវិជ្ជា ទស្សនវិជ្ជាអប់រំ ការពិភាក្សាអំពីទស្សនវិជ្ជា និងការអនុវត្តទស្សនវិជ្ជាល្អៗក្នុងចំណោមអ្នកដឹកនាំ អ្នកនយោបាយ អ្នកគ្រប់គ្រងគ្រប់កម្រិត ព្រមទាំងសង្គមស៊ីវិល និងវិស័យឯកជន។

លើសពីនេះទៀត ដើម្បីឱ្យមានការយល់ដឹងអំពីទស្សនវិជ្ជាជាប្រព័ន្ធ ស៊ីជម្រៅ សព្វជ្រុងជ្រោយ និងមាននិរន្តរភាព គួរតែជំរុញឱ្យមានការសិក្សាមុខវិជ្ជាទស្សនវិជ្ជាយ៉ាងទូលំទូលាយទាំងក្នុងមធ្យមសិក្សា និងមហាវិទ្យាល័យ។ បើយោងទៅតាមស្មារតីរបស់អង្គការយូណេស្កូ(UNESCO)វិញ បានជំរុញឱ្យការអប់រំទស្សនវិជ្ជាចាប់ពីកម្រិតមត្តេយ្យហូតដល់កម្រិតមហាវិទ្យាល័យ ដោយរៀបចំខ្លឹមសារសម្រាប់បង្រៀនមុខវិជ្ជានេះពីភាពសាមញ្ញទៅដល់ភាពជ្រៅជ្រះ។

ប្រសិនបើប្រទេសណាមួយមិនបានបង្រៀនមុខវិជ្ជានេះដល់សិស្ស និស្សិតរបស់ខ្លួនទេ មានន័យថា ប្រទេសនោះមិនបានផ្តល់ឱកាសឱ្យពលរដ្ឋរបស់ខ្លួនដើម្បីក្លាយទៅជាមនុស្សមានហេតុផល, មនុស្សប្រកដោយសីលធម៌, មនុស្សមានពុទ្ធិទូលំទូលាយ និងមនុស្សដែលមានសេចក្តីរីករាយឡើយ។ លើសពីនេះទៀត ពលរដ្ឋរបស់ខ្លួនក៏អាចបាត់បង់សមត្ថភាពក្នុងការសម្រេចសមិទ្ធផលដ៏អស្ចារ្យជាច្រើន មិនអាចផ្តល់អត្ថន័យពេញលេញដល់ខ្លួនឯងដែលភាវៈប្រកបដោយវិចារញ្ញាណ, មិនអាចរស់នៅបានល្អប្រសើរ, មិនអាចកំណត់អត្តសញ្ញាណនៃការ

បោកបញ្ឆោតរបស់ជនខិលខូច, មិនយល់អំពីប្រវត្តិសាស្ត្រនៃគំនិតនិងការរីកចម្រើន, ខ្វះភាពច្នៃប្រឌិតកម្រិតខ្ពស់ ហើយក៏មិនអាចរួមគ្នាដើម្បីធ្វើឱ្យពិភពលោកក្លាយជាកន្លែងមួយដ៏ប្រសើរបានដែរ៕

# សិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យនៅកម្ពុជា

បេក្ខជនបណ្ឌិត ប៉ាត បញ្ញា ជំនាញនីតិសាស្ត្រ ជំនាន់ទី២ វគ្គទី២
នៃរាជបណ្ឌិត្យសភាកម្ពុជា

ដីធ្លី និងធនធានធម្មជាតិនៃភពផែនដី គឺជាមូលដ្ឋានដ៏ចម្បងសម្រាប់ទ្រទ្រង់ជីវិត ជីវៈចម្រុះ សង្គមជាតិ សេដ្ឋកិច្ច ការវិនិយោគ និងនយោបាយ។ ប្រទេសទាំងអស់នៅលើពិភពលោកសុទ្ធតែទទួលបានផលប្រយោជន៍អំពីវិស័យអចលនទ្រព្យ ស្មើនិងបីភាគបួននៃទ្រព្យសម្បត្តិរបស់ជាតិទាំងមូល។[១]

ផ្ទៃភពផែនដីកកើតចេញពីមណ្ឌលបរិយាកាស មណ្ឌលសិលា មណ្ឌលទឹក និងមណ្ឌលជីវៈ ដែលជាហេតុធ្វើឱ្យផែនដីរងនូវផលប៉ះពាល់ជាច្រើនពីបាតុភូតធម្មជាតិ និងការបំផ្លាញពីសំណាក់មនុស្សមានដូចជាការជីកយករ៉ែ ការបំផ្លាញព្រៃឈើ ការកាប់ទន្រ្ទានដើម្បីយកដីធ្វើជាកម្មសិទ្ធិ តាំងទីលំនៅ ធ្វើកសិកម្ម និងការទិញលក់ជាដើម។[២] ដីធ្លី នៃប្រទេសនីមួយៗ គឺមានអត្ថប្រយោជន៍ជាំទីបំផុតដែលមិនអាចខ្វះបាន និងជាទីតាំងនៅទ្រទ្រង់នៃរដ្ឋទាំងឡាយនៅលើពិភពលោក បើគ្មានដីធ្លី ក៏គ្មានរដ្ឋដែរ ដោយហេតុនេះបានជាវិស័យដីធ្លីជាជីវិត និងសេដ្ឋកិច្ចជាតិ។ អាត្រាកំណើនប្រជាជនមានការកើនឡើងយ៉ាងឆាប់រហ័ស ដែលពិភពលោកត្រូវគិតអំពីកម្មសិទ្ធិដីធ្លី ជូនប្រជាពលរដ្ឋ ការគ្រប់គ្រងដីធ្លី ការបែងចែកដីធ្លី ការប្រើប្រាស់ដីធ្លី សំណង់នានា ការវិនិយោគ ការប្រមូលកំណើននៃសេដ្ឋកិច្ចជាតិ។

អចលនទ្រព្យនៅកម្ពុជា គឺជាប្រធានបទដ៏សំខាន់ និងមានបច្ចុប្បន្នភាពជាទីបំផុតក្នុងការយកមកជជែកពិភាក្សាអំពីការអភិវឌ្ឍន៍នៃកំណើនសេដ្ឋកិច្ចសង្គមជាតិកម្ពុជា។ ការគ្រប់គ្រងលើអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជា គឺត្រូវអនុវត្តតាមបែបបទ នីតិវិធីច្បាប់ផ្សេងៗ ហើយមានការប្រែប្រួល និងមានការវិវត្តតាមរបបនៃការគ្រប់គ្រងសង្គមជាតិទៅតាមសម័យកាលផងដែរ។ ការអនុវត្ត និងការគ្រប់គ្រងនៃរបបដីធ្លីពីសម័យបុរាណរហូតដល់ឆ្នាំ១៨៦៣ ស្ថិតនៅក្រោមអំណាចរបស់ព្រះមហាក្សត្រតាមជំនាន់នៃការគ្រងរាជសម្បត្តិ។ សញ្ញាណនៃកម្មសិទ្ធិឯកជន បាននាំយកមកប្រទេសកម្ពុជានៅសម័យអាណាព្យាបាលបារាំង មានក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ដែលត្រូវបានបង្កើតតាមប្រព័ន្ធច្បាប់ភូមិបាលបារាំង គឺទទួលស្គាល់នូវទ្រព្យសម្បត្តិឯកជនទូទាំងប្រទេស។ នៅខែមីនា ឆ្នាំ១៩៧០ លោកសេនាប្រមុខលន់ នល់ បានធ្វើនូវរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ពីអំណាចដែលធ្វើឱ្យតំបន់វាលទំនាប តំបន់កសិកម្ម ស្រែ ចំការ ដំណាំស្រូវត្រូវបានម្ចាស់កម្មសិទ្ធិឯកជនធ្វើការទាមទារ និងដណ្តើមគ្នាយកមកគ្រប់គ្រង។ ប្រព័ន្ធនៃការគ្រប់គ្រងដីធ្លីក៏ត្រូវបំផ្លាញតាមការប្តូររបបនៃការដឹកនាំរដ្ឋាភិបាលថ្មីដែរ។ នៅឆ្នាំ១៩៧៦ រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ បានដាក់ដីធ្លីទាំងអស់ក្នុងដែនដីនៃប្រទេសកម្ពុជាជាកម្មសិទ្ធិរបស់រដ្ឋ រាល់កម្មសិទ្ធិឯកជនទាំងអស់ត្រូវបានដកហូតទាំងស្រុង ហើយស្ថាប័ន

[១] Kate Dalrymple: Expending Rural Land Tenures to Alleviate Poverty, PhD thesis, University of Melbourne, 2005, page 45, in ( World Bank page 87, 1989 )

[២] អ៊ូ វ៉ាឌី: ទស្សនវិជ្ជាភូមិវិជ្ជា ឯកសារថ្នាក់បណ្ឌិតទីស្តីការគណៈរដ្ឋមន្ត្រី-រាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ២។

រដ្ឋបាលសុរិយោដី បណ្ណកម្មសិទ្ធិ ឯកសារពាក់ព័ន្ធវស័យដីធ្លីត្រូវបំផ្លាញចោល។ មន្ត្រីរាជការ ប្រជាជន កងកម្លាំងត្រូវបង្ខំឱ្យធ្វើការងារបម្រើអង្គការ បើប្រឆាំងត្រូវពិន័យឬយកទៅឱ្យរៀនសូត្រគ្មានថ្ងៃត្រឡប់វិញនោះឡើយ។ ក្រោយការដួលរលំនៃរបបខ្មែរក្រហមនៅចន្លោះនៃការគ្រប់គ្រងរវាងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ រដ្ឋបានប្រគល់សិទ្ធិអំណាចឱ្យអំណាចរដ្ឋបាលគ្រប់ជាន់ថ្នាក់ មានភារកិច្ចគ្រប់គ្រង និងប្រើប្រាស់ដីធ្លីតាមព្រំប្រទល់នៃភូមិសាស្ត្ររដ្ឋបាលរបស់ខ្លួន និងធ្វើការបែងចែកដីធ្លី ជូនក្រុមសាមគ្គីបង្កបង្កើនផលនិងគ្រួសារទូទាំងប្រទេស។ នៅឆ្នាំ១៩៨៩រដ្ឋបានរៀបចំប្រព័ន្ធគ្រប់គ្រទ្រព្យសម្បត្តិឯកជនថ្មីមួយឡើង គឺប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានសិទ្ធិពេញលេញ ក្នុងការទទួលកម្មសិទ្ធិ ការប្រើប្រាស់ការធ្វើអំណោយ បែកមត៌កដីធ្លី ការទទួលស្គាល់ដោយរដ្ឋ ក្នុងគោលបំណង់រស់នៅលើដី និងអាស្រ័យផលពីដី។ នៅឆ្នាំ១៩៩២ កម្មសិទ្ធិឯកជន រួមមានទាំងដីធ្លី និងផ្ទះសម្បែងត្រូវបានផ្តល់ជូន និងកម្មសិទ្ធិរបស់រដ្ឋ ដីធ្លី អាគារសាធារណៈ ធនធានធម្មជាតិ ផ្លូវ ស្ថានីយ៍ តំបន់បេតិកភណ្ឌវប្បធម៌ ត្រូវបានការពារដោយច្បាប់ភូមិបាលផងដែរ។ ប្រទេសកម្ពុជាទទួលបានការបង្រួបបង្រួមជាតិឡើងវិញ នៅឆ្នាំ១៩៩៣ រដ្ឋប្រកាន់យករបបនៃលិទ្ធិប្រជាធិបតេយ្យ រដ្ឋឯករាជ្យ អធិបតេយ្យភាព សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនអាចបំបែកបាន មិនចូលបក្សសម្ព័ន្ធ មិនត្រូវបានរំលោភបំពានពីបរទេស និងត្រូវទទួលស្គាល់ជាអន្តរជាតិ។[៣] រដ្ឋបានទទួលស្គាល់សិទ្ធិលើអចលនទ្រព្យទាំងអស់ក្នុងប្រទេសកម្ពុជា រូបវ័ន្តបុគ្គល ឬនីតិបុគ្គលមានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងអចលនទ្រព្យរបស់ខ្លួនដោយសេរី ស្ថិតនៅក្រោមការការពារនៃច្បាប់។ អចលនទ្រព្យនៅកម្ពុជា គឺផ្សារភ្ជាប់និងការរស់នៅរបស់ប្រជាជនកម្ពុជាគ្រប់រូប ដីធ្លី សំណង់ ផ្ទះសម្បែង បុរី ខុនដូ អាគារ តំបន់ធម្មជាតិ បេតិកភណ្ឌវប្បធម៌ កសិកម្ម ឧស្សាហកម្ម ទេសចរណ៍ ជំនួញពាណិជ្ជកម្ម ហើយវិស័យ នេះបានរួមចំណែកយ៉ាងខ្លាំងនៃកំណើនសេដ្ឋកិច្ចជាតិ។

ក្នុងនាមជាសមាជិកនៃសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលជាតំបន់មានសក្តានុពលមួយរបស់ ពិភពលោក និងជាប្រទេសហត្ថលេខីនៃសេចក្តីប្រកាសអន្តរជាតិស្តីពី សិទ្ធិមនុស្ស និងអភិបាលកិច្ចល្អលើ វិស័យបរិស្ថាន ដីធ្លីនិងធនធានទឹក រដ្ឋបានខិតខំអនុវត្តគោលនយោបាយក្នុងតំបន់លើវិស័យអចលនទ្រព្យ ឱ្យស្របតាមគោលការណ៍អន្តរជាតិ ទាំងច្បាប់ និងបទដ្ឋានគតិយុត្ត ដើម្បីឱ្យមានភាពស៊ីគ្នាជាអន្តរជាតិ។ ប្រទេសកម្ពុជាកសាងផែនការអភិវឌ្ឍន៍រួមគ្នា ជាមួយប្រទេសដែលជាដៃគូវិនិយោគប្រទេសមានព្រំដែនជាប់គ្នា ដើម្បីរៀបចំគ្រប់គ្រងលំហូឆ្លងកាត់ផ្សេងៗ ការចែករំលែកព័ត៌មាន ការគ្រប់គ្រងដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ។[៤] ប្រជាជនកម្ពុជាប្រមាណ៧០% បានប្រកបមុខរបរធ្វើកសិកម្ម ដែលជាមុខរបរចម្បងមួយដើម្បីផ្គត់ផ្គង់ស្បៀងប្រើប្រាស់ក្នុងស្រុកនិងនាំចេញក្រៅប្រទេស។ ដើម្បីបានបំពេញនូវតម្រូវការនៃទីផ្សារក្នុងតំបន់ រាជរដ្ឋាភិបាលកម្ពុជាបានដាក់គោលដៅនាំចេញផលិតផលកសិកម្ម រាប់លានតោន/ឆ្នាំ ដោយពង្រីកផ្ទៃដីដាំដុះ ការបង្កើតប្រព័ន្ធស្រោចស្រពក្បែរនោះ

---

[៣] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[៤] សៀវភៅសដីធ្លី ទំព័ ៦៨, ចុះថ្ងៃ ២៨ ខែសីហា ឆ្នាំ២០១៥

ហើយក៏ជាបញ្ហាធ្ងន់ធ្ងរផងដែរនៅពេលមានគ្រោះរាំងស្ងួតដូចបច្ចុប្បន្ន។[៥] ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលមានធនធានដីធ្លី ធនធានរ៉ែ ធនធានទឹក និងធនធានធម្មជាតិមាននៅក្នុងដៃរបស់រដ្ឋ ចំនួនច្រើនជាងគេនៅអាស៊ីអាគ្នេយ៍មានរហូតដល់៨០% នៃធនធាន ទាំងមូល។[៦]

ច្បាប់ភូមិបាលឆ្នាំ២០០១ ក៏បានបានចែងកំណត់យ៉ាងច្បាស់អំពីកម្មសិទ្ធិលើអចលនទ្រព្យថា របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ១៩៧៩ មិនត្រូវបានទទួលស្គាល់។ មានតែភោគៈត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះដែលអាចនាំឱ្យបានក្លាយជាកម្មសិទ្ធិ។ ដើម្បីក្លាយជាកម្មសិទ្ធិលើអចលនវត្ថុបានលុះត្រាភោគៈត្រឹមត្រូវតាមច្បាប់ ត្រូវបំពេញតាមលក្ខខណ្ឌតាមច្បាប់ ដូចជាកាន់កាប់ដោយពិតប្រាកដគ្មានហឹង្សា ដឹងឮជា សាធារណៈ គ្មានអាក់ខាន និងដោយសុចរិត។[៧] កម្មសិទ្ធិករលើអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជាគឺជាពលរដ្ឋខ្មែរទាំងអស់ រូបវន្តបុគ្គលឬនីតិបុគ្គលមានសញ្ជាតិខ្មែរ សមូហភាពដែនដីសាធារណៈ គ្រឹះស្ថានសាធារណៈ សហគមន៍ ឬសមាគមកម្ពុជា សហគ្រាសសាធារណៈ ក្រុមហ៊ុនស៊ីវិល ឬពាណិជ្ជកម្មកម្ពុជា និងអង្គការកម្ពុជាដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល។ ជនបរទេស គឺមិនអាចជាកម្មសិទ្ធិករ លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ បានលុះត្រាតែមានសញ្ជាតិជាខ្មែរ ប៉ុន្តែប្រសិនបើជនបរទេសនោះក្លែងបន្លំប័ណ្ណសញ្ជាតិខ្មែរ ដើម្បីក្លាយជាកម្មសិទ្ធិករនៅលើដីធ្លីក្នុងប្រទេសកម្ពុជា ជននោះនិងត្រូវផ្តន្ទាទោសតាមច្បាប់ដែលមានចែង ហើយទ្រព្យសម្បត្តិនិងត្រូវបានដកហូតមកជាទ្រព្យសម្បត្តិរបស់រដ្ឋវិញដោយគ្មានសំណងអ្វីឡើយ។ រដ្ឋបានកំណត់ និងអនុញ្ញាតឱ្យជនបរទេសគ្រប់រូបមានសិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យនៅកម្ពុជា លើតែចំណែកឯកជននៃអាគារសហកម្មសិទ្ធិចាប់ពីជាន់ទី១ឡើងទៅ ចំណែកជាន់ផ្ទាល់ដី និងក្រោមដីមិនត្រូវបានអនុញ្ញាតឡើយ គឺផ្តល់ជូនត្រឹមតែចំណែកឯកជនផ្ទាល់ខ្លួន រាល់ចំណែកផ្សេងទៀតត្រូវដាក់ឱ្យប្រើប្រាស់រួមគ្នា។[៨]

---

[៥] គ្រោះរាំងស្ងួតវាយលុកខេត្តចំនួន ១៣, ភ្នំពេញប៉ុស្ដិ៍, ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥

[៦] ហ៊ុន សែន *សន្ទរកថាវេទិកាដីធ្លីថ្នាក់ជាតិ* វិមានរដ្ឋាភិបាល ភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ទំព័រ២

[៧] ច្បាប់ភូមិបាល ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១

[៨] ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិដល់ជនបរទេស ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០។

អចលនវត្ថុនៅកម្ពុជាត្រូវបានបែងចែកជាបីប្រភេទ គឺៈ

- អចលនវត្ថុពីកំណើតជាអចលនវត្ថុដែលកើតឡើងដោយធម្មជាតិមានដូចជា ដីព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរឬដីមិនអាចដាំដុះ ដីលិចទឹកដោយទឹកនៅនឹងឬទឹកហូរនិងសំណង់ឬការរៀបចំទាំងឡាយដែលស្ថិតនៅជាប់មួយកន្លែង កើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិលបាន និងផ្លាស់ប្តូរទីកន្លែងបាន។
- អចលនវត្ថុដែលកើតឡើងពីភ័ព្វវាសនា ជាវត្ថុដែលជាប់និងដី ឬបញ្ចូលជាមួយសំណង់ទាំងឡាយ ដែលមិនអាចបំបែកចេញបាន ដោយមិនធ្វើឲ្យមានការខូចខាត ឬដូរសភាពដើមមានដូចជាដើមឈើ វត្ថុ ឬឧបករណ៍តុបតែងលំអរជាដើម។
- អចលនវត្ថុតាមការកំណត់របស់ច្បាប់ ជាសិទ្ធិភណ្ឌិកទាំងឡាយលើអចលនវត្ថុ និងអចលនវត្ថុទាំងឡាយដែលបានកំណត់ដោយច្បាប់ថាជាអចលនវត្ថុ។

សិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យនៅប្រទេសកម្ពុជា មានដូចជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋ កម្មសិទ្ធិឯកជនរបស់រដ្ឋ កម្មសិទ្ធិអវិភាគ កម្មសិទ្ធិសមូហភាព សហកម្មសិទ្ធិ និងកម្មសិទ្ធិឯកជនរបស់ប្រជាជន។ កម្មសិទ្ធិករ គឺមានសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ សិទ្ធិអាស្រ័យផល សិទ្ធិប្រើប្រាស់ដីអ្នកដ៏ទៃ សិទ្ធិជួល ប្រទានកម្ម សន្តតិកម្ម សម្បទានដី សិទ្ធិដាក់បញ្ចាំ សិទ្ធិដាក់ធានា សិទ្ធិបង្កើតហ៊ីប៉ូតែក និងសិទ្ធិលើកិច្ចសន្យាជាក់ស្តែងដ៏ទៃទៀតដែលឱ្យមានផលប្រយោជន៍សម្រាប់សេដ្ឋកិច្ចគ្រួសារ និងសង្គមជាតិ។ តាមការការប៉ាន់ស្មានទូទៅលើការធ្វើចំណាត់ថ្នាក់ដីធ្លីនៅកម្ពុជា បានបង្ហាញថាប្រមាណ ៨០% នៃផ្ទៃដីប្រទេសកម្ពុជាសរុបក្នុងពេលបច្ចុប្បន្នជាកម្មសិទ្ធិរបស់រដ្ឋ និងផ្ទៃដីសរុប២០%ទៀត គឺជាកម្មសិទ្ធិរបស់ឯកជន។ កម្មសិទ្ធិសាធារណៈរបស់រដ្ឋ ដូចជាដីដែលផ្តល់ប្រយោជន៍សាធារណៈជាក់ស្តែង ផ្លូវទឹក កំពង់ផែ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ផ្លូវថ្នល់ អាកាសយានដ្ឋាន សួនច្បារ តំបន់បំរុងធនធានជីវសាស្ត្រ សំណង់អាគារ រដ្ឋបាល តំបន់បេតិកភណ្ឌបុរាណវិទ្យា និងវប្បធម៌ ព្រះរាជទ្រព្យ ព្រៃឈើ...។ ទ្រព្យទាំងនោះមិនអាចលក់ដូរបានឡើយ ប៉ុន្តែអាចជាកម្មវត្ថុនៃការចេញអាជ្ញាប័ណ្ណកាន់កាប់ដីធ្លី ការជួល ការផ្តល់សម្បទានដីសេដ្ឋកិច្ច ឬការប្រើប្រាស់ជាបណ្តោះអាសន្នដោយមានការយកតម្លៃសេវាតាមកិច្ចសន្យាសមស្របណាមួយ។

កម្មសិទ្ធិឯកជនរបស់រដ្ឋ ជាប្រភេទដីដែលរដ្ឋបម្រុងទុក ផ្តល់សម្រាប់គោលដៅឯកជនប្រើប្រាស់ ដែលត្រូវមានការទូទាត់ឱ្យរដ្ឋ លើកលែងតែប្រភេទភោគៈដែលត្រូវធ្វើលទ្ធកម្មពិសេស និងសម្បទានក្នុងគោលដៅសង្គមកិច្ចប៉ុណ្ណោះ។ កម្មសិទ្ធិឯកជនគឺកម្មសិទ្ធិករមានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលក់ដូរ ធ្វើប្រទានកម្ម ធ្វើសន្តតិកម្ម ជួល បង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើដីដោយសេរី និងត្រូវបានការពារដោយច្បាប់ចូលជាធរមាន ប៉ុន្តែក៏ត្រូវអនុវត្តទៅតាមវិធានស្តីពីការប្រើប្រាស់ដីផងដែរ។ កម្ពុជាស្វែងរកការការពារផលប្រយោជន៍សាធារណៈ ដោយរក្សាដីមួយចំនួនជាដីសាធារណៈរបស់រដ្ឋ និងបង្កើតឱ្យមានផលប្រយោជន៍ឯកជនជូនសម្រាប់ប្រជាពលរដ្ឋកម្ពុជាផងដែរ ដោយធ្វើឱ្យពួកគេអាចប្រើប្រាស់ដីដែលជាកម្មសិទ្ធិឯកជនរបស់រដ្ឋបាន និងទទួលស្គាល់កម្មសិទ្ធិស្របច្បាប់លើ

កម្មសិទ្ធិឯកជនរបស់ពួកគេ។ រដ្ឋាភិបាលកម្ពុជាបានបើកសិទ្ធិលើការដាក់ទុនវិនិយោគនៃវិស័យដីធ្លីយ៉ាងទូលំទូលាយ មានតម្លាភាព និងទទួលបានការការពារដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមានដែលបានអនុគ្រោះដល់គ្រប់រូបវន្តបុគ្គល និងនីតិបុគ្គលឱ្យមកធ្វើការដាក់ទុនរកស៊ី ធ្វើអាជីវកម្មគម្រោងលក់ទីញដីធ្លី សំណង់អាគារនានា។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលជាសេនាធិការនៃស្ថាប័ននីតិប្រតិបត្តិបានធ្វើការចុះបញ្ជីចេញប្លណ្ណកម្មសិទ្ធិដី ដោយគិតចាប់ពីពេលនៃការអនុវត្តរហូតដល់ឆ្នាំ២០១៩ ទទួលបានចំនួន ៥,៦២៥,៦៨៦បណ្ណ ស្មើនិង៨០,៣៧%នៃក្បាលដីប៉ាន់ស្មាន៧លានក្បាលដី ក្នុងនោះការចុះបញ្ជីដីរដ្ឋបានចំនួន១,៨៥៤បណ្ណ ស្មើនិងទំហំ៧៧៨,៧២៥ហិកតា សម្បទានដីសង្គមកិច្ចបានចំនួន៦,៥០៤បណ្ណ ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចបាន ចំនួន ៣០សហគមន៍ ស្មើនិង ៨១៩បណ្ណ លើទំហំ៣១,៦០៥ហិកតាសម្រាប់ ៣,០៣៣គ្រួសារ និងចុះបញ្ជីដីឯកជនបានចំនួន ៥,៦១៦,៥០៩បណ្ណ។ រដ្ឋបានផ្ដល់ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍លើដីរដ្ឋចំនួន៤៣៩បណ្ណ ស្មើនិង ៧៣,៤៤០ហិកតា ចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ចចំនួន៣៦៣បណ្ណ ស្មើនិង២៣២,៤៥១ហិកតា, ចុះបញ្ជីផ្ទេរសិទ្ធិចំនួន២០៣,១៨០ករណី និងចុះបញ្ជីសិទ្ធិប្រាតិភោគ(ដាក់បញ្ចាំ/ ហ៊ីប៉ូតែក)ចំនួន ១២១,៣២៣ករណី។

ដោយប្រកាន់ភ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អនិងធានាតុល្យភាពរវាងការអភិវឌ្ឍនិងអភិរក្សក្រៅពីលិខិតបទដ្ឋានគតិយុត្តចូលជាធរមាន ក្រសួងស្ថាប័នជំនាញដែលពាក់ព័ន្ធលើវិស័យអចលនទ្រព្យក៏នៅតែបន្តការខិតខំអនុម័តច្បាប់ បទដ្ឋានគតិយុត្តបំពេញបន្ថែម តម្រូវមានការអភិវឌ្ឍចំពោះមុខនិងធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃវិស័យដីធ្លី សំណង់ ផ្នែកពាក់ព័ន្ធផ្សេងៗឱ្យលូនជាមួយគ្នានិងជួយដល់ការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព។ ច្បាប់រួមមានច្បាប់ស្ដីពីសិទ្ធិបុព្វក្រៃ ច្បាប់ស្ដីពីការធ្វើអនុប្បយោគដី ច្បាប់រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ច្បាប់ភូមិបាល ច្បាប់សំណង់ ច្បាប់ស្ដីពីការវាស់វែង និងផលិតផែនទី ច្បាប់ស្ដីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ច្បាប់ស្ដីពី ពន្ធលើអចលនទ្រព្យ និងលិខិតបទដ្ឋានក្រោមច្បាប់ជាច្រើនទៀត ដើម្បីជួយដល់ការអនុវត្តតាមក្រសួង និងស្ថាប័នរបស់រដ្ឋ ធានាការពារសិទ្ធិកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរដ្ឋ។

សុវត្ថិភាពនៃការកាន់កាប់ដី សិទ្ធិកម្មសិទ្ធិត្រូវបានទទួលស្គាល់ និងការពារដោយច្បាប់រដ្ឋ គួបផ្សំជាមួយសំណុំលក្ខខ័ណ្ឌអំណោយផលផ្សេងទៀត បានជួយពង្រឹងដល់ការវិនិយោគលើផ្នែកអចលនទ្រព្យនៅកម្ពុជា និងលើកទឹកចិត្តដល់ការជួល ការដូរ ការងារសាងសង់សំណង់អាគារ ការទិញលក់ ទីផ្សារដើម្បីធ្វើឱ្យដី បង្កើនផលិតភាព និងជួយបង្កើនល្បឿនកំណើនសេដ្ឋកិច្ច។ ការធ្វើឱ្យមានភាពប្រសើរឡើងចំពោះសុវត្ថិភាពនៃការកាន់កាប់ប្រើប្រាស់ដីធ្លីស្របច្បាប់ ផ្ដល់ទំនុកចិត្តដល់ម្ចាស់កម្មសិទ្ធិ អ្នកវិនិយោគ កាត់បន្ថយវិវាទដីធ្លីដែលតែងតែប៉ះពាល់ដល់ប្រជាពលរដ្ឋក្រីក្រ និងជួយកាត់បន្ថយភាពក្រីក្រគឺជាតួនាទីចម្បងនៃស្ថាប័នរដ្ឋ ក្នុងការធ្វើឱ្យរដ្ឋបាលដីធ្លីកាន់តែប្រសើរឡើង និងធ្វើឱ្យឥទ្ធិពលនៃអំពើពុករលួយ សកម្មភាព ការិយាធិបតេយ្យ និងការរំលោភសិទ្ធិកាន់កាប់លើអចលនវត្ថុថយចុះ ព្រម

ទាំងធ្វើឱ្យមានភាពច្បាស់លាស់ឡើងវិញ នូវសមត្ថកិច្ចដែលជួយដល់ការងារអភិបាលកិច្ចល្អ។ តំបន់ការពារធនធានធម្មជាតិត្រូវបានបង្កើត និងការពារដោយរដ្ឋមានដូចជាតំបន់ឧទ្យានជាតិ តំបន់ការពារដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព និងតំបន់ដែលទទួលរងនូវការប្រើប្រាស់ជាច្រើនមុខ ដែលមានរដ្ឋលេខាធិការដ្ឋាននៃក្រសួងបរិស្ថានជាអ្នកទទួលខុសត្រូវ ដឹកនាំគ្រប់គ្រង ធ្វើផែនការអភិវឌ្ឍន៍ប្រព័ន្ធតំបន់ការពារធម្មជាតិរបស់ជាតិ ការការពារបរិស្ថាន ដីព្រៃឈើ តំបន់ដីសើម និងតំបន់ឆ្នេរ។[៩] តំបន់បេតិកភណ្ឌវប្បធម៌បុរាណវិទ្យា ប្រាសាទបុរាណ ដីធ្លី សំណង់និងបរិស្ថានជុំវិញតំបន់ទាំងនោះ ក៏ត្រូវបានការពារ ថែរក្សា និងអភិរក្សដោយព្រះរាជក្រឹត្យ ដោយអនុក្រឹត្យ និងលិខិតបទដ្ឋាននានា។

ការអភិវឌ្ឍលើវិស័យដីធ្លីនៅកម្ពុជា បានទាក់ទាញវិនិយោគទាំងក្នុងតំបន់ និងអន្តរជាតិបានមកដាក់វិនិយោគទុនយ៉ាងច្រើនកុះករ លើវិស័យកសិកម្ម កសិឧស្សាហកម្ម សំណង់ ផ្ទះល្វែង បុរី ខុនដូវីហ្សែត អាគារពាណិជ្ជកម្ម រោងចក្រ ទេសចរណ៍ ការលក់ទិញ ការជួល ជួលរយៈពេលវែង ជួលអចិន្ត្រៃយ៍ សម្បទានដីសេដ្ឋកិច្ច ដែលបានជួយដល់ទីផ្សារដីធ្លីកើនឡើងគួរឱ្យកត់សម្គាល់។ រដ្ឋអាចប្រមូលប្រាក់ចំណូលជាច្រើននៃសេវាការងារសុរិយោដី និងសំណង់ ជួយសម្រួលដល់ការប្រមូលចំណូលពន្ធប្រថាប់ត្រាលើអចលនទ្រព្យជូនរដ្ឋ។ ទីផ្សារដីឯកជន ត្រូវគ្រប់គ្រងឱ្យមានប្រសិទ្ធភាព និងសមធម៌ ត្រូវបានបែងចែកដីសម្រាប់ការប្រើប្រាស់ទៅតាមតម្រូវការនៃសេដ្ឋកិច្ច និងផ្តលលទ្ធភាពប្រើប្រាស់ដីសម្រាប់អ្នកដែលត្រូវការដី រាល់ការផ្ទេរកម្មសិទ្ធិ ការដោះដូរកម្មសិទ្ធិតម្រូវឱ្យមានព័ត៌មានច្បាស់លាស់អំពីកម្មសិទ្ធិដីធ្លី អំពីសិទ្ធិ ការកម្រិតសិទ្ធិត្រូវឱ្យអនុវត្តតាមនីតិវិធីច្បាប់ឱ្យបានហ្ម័ស មានតម្លៃទាប ព្រមទាំងតម្រូវឱ្យមានយន្តការលំហូរសាច់ប្រាក់ ឬហិរញ្ញប្បទានចំពោះអ្នកចូលរួមក្នុងកិច្ចការទីផ្សារដីធ្លី។ ការបង្កើនលទ្ធភាពប្រើប្រាស់ដី ដោយសមធម៌ និងបង្កើតទីផ្សារអចលនទ្រព្យសម្រាប់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ និងប្រជាជនក្រីក្រផង ជាបញ្ហាប្រឈមមួយដ៏សំខាន់ ព្រោះអ្នកក្រីក្រខ្វះលំហូរសាច់ប្រាក់ ឬហិរញ្ញប្បទានចាំបាច់ដើម្បីការជួល ឬការទិញដី។[១០]

រដ្ឋបានទទួលចំណូលថវិកាជាតិ សរុបមានចំនួន ៤៥៦,៦១៧,៦៨៦,០៧៧រៀល នៅឆ្នាំ ២០១៩ ពីអចលនទ្រព្យនៅកម្ពុជា គិតទាំងពន្ធប្រថាប់ត្រាលើការផ្ទេរអចលនទ្រព្យ សេវាសុរិយោដី សេវាសំណង់ និងការជួលអចលនទ្រព្យ។ ស្របតាមកំណើនសេដ្ឋកិច្ចនេះ អចលនទ្រព្យកម្ពុជាមិនអាចផ្តាច់ចេញពី ប្រជាពលរដ្ឋ និងរដ្ឋ ដោយការអភិវឌ្ឍន៍នៃវិស័យនេះ ត្រូវការវត្ថុធាតុដើមបានពីដីធ្លី និងធម្មជាតិមានដូចជា ព្រៃឈើ ដី ខ្សាច់ ថ្ម ទឹក រ៉ែ ដែក ស៊ីម៉ង់ និងការប្រើប្រាស់កម្លាំងពលកម្មពីអ្នកមានចំណេះជំនាញច្បាប់ បច្ចេកទេស កម្មករ ដើម្បីជួយ ទ្រទ្រង់វិស័យកសិកម្ម សំណង់ ពាណិជ្ជកម្ម ទេសចរណ៍ ដែលរដ្ឋអាចកាត់បន្ថយអត្រាប្រជាពលរដ្ឋ ភាពគ្មានការងារធ្វើ និងការអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈនៃវិស័យនេះផងដែរ។

---

[៩] ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ *មាត្រា១* ចុះថ្ងៃ ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។

[១០] ក្របខណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី *ឯកសារបឋម* ទីស្តីការគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គ ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០០២ ទំព័រ ២៥។

អចលនទ្រព្យនៅកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយលើកស្ទួយប្រទេសជាតិ ការកាន់របបនៃលិទ្ធិប្រជាធិបតេយ្យ ទ្រទ្រង់រដ្ឋ បានផ្តល់ឱ្យប្រជាជនមានសិទ្ធិសេរីភាពសព្វគ្រប់ បែបយ៉ាងសម្រាប់ការងារចិញ្ចឹមជីវិត ស្មោះស្ម័គ្រលើសន្តិភាព នាំឱ្យរដ្ឋទទួលបានផលជាច្រើន ពីប្រជាពលរដ្ឋ និងអ្នកវិនិយោគ ដែលជាការជួយជម្រុញកំណើនសេដ្ឋកិច្ចជាតិ។ ដើម្បីឱ្យមានភាពប្រសើរឡើងនៃអចលនទ្រព្យនៅកម្ពុជា លើការគ្រប់គ្រងដីធ្លី ការបែងចែក ដីធ្លី ការប្រើប្រាស់ដីឱ្យចំសេដ្ឋកិច្ច និងសុវត្ថិភាពដីធ្លី និងសំណង់ គឺផ្តើមចេញអំពីរដ្ឋ ប្រជាជន និងសេដ្ឋកិច្ច។

## បញ្ជីឯកសារយោង


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២. ច្បាប់ភូមិបាល ឆ្នាំ២០០១

៣. ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិដល់ជនបរទេស

៤. ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ, ចុះថ្ងៃ ០១ ខែវិច្ឆិការ ឆ្នាំ១៩៩៣

៥. ក្របខណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី, ឯកសារបឋម, ទីស្តីការគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គ ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០០២

៦. សៀវភៅសដីធ្លី, ចុះថ្ងៃ ២៨ ខែសីហា ឆ្នាំ២០១៥

៧. ហ៊ុន សែន *សន្ទរកថាវេទិកាដីធ្លីថ្នាក់ជាតិ* វិមានរដ្ឋាភិបាល ភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០០៤

៨. សន្និបាតបូកសរុបលទ្ធផលការងារក្នុងឆ្នាំ២០១៩ និងទិសដៅការងារក្នុងឆ្នាំ២០២០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ចុះថ្ងៃ២៥ ខែធ្នូ ឆ្នាំ២០១៩។

៩. អ៊ូ វ៉ឺត ទស្សនវិជ្ជាភូមិវិជ្ជា ទីស្តីការគណៈរដ្ឋមន្ត្រី-រាជបណ្ឌិត្យសភាកម្ពុជា, ឆ្នាំ២០០៨

១០. គ្រោះរាំងស្ងួតវាយលុកខេត្តចំនួន ១៣, ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥

១១. Kate Dalrymple: Expending Rural Land Tenures to Alleviate Poverty, PhD thesis, University of Melbourne, 2005, in ( World Bank, 1989 )

^# ការយល់ដឹងអំពីរដ្ឋបាលតុលាការកម្ពុជា

ដោយបេក្ខជនបណ្ឌិត ពៅ វិបុល
ជំនាញនីតិសាស្ត្រ ជំនាន់ទី២ វគ្គ២ នៃរាជបណ្ឌិត្យសភាកម្ពុជា

**ប្រវត្តិស្ថាប័ន និងរដ្ឋបាលតុលាការ៖** ចាប់ពីសម័យមុនអង្គរ សម័យអង្គរ និងក្រោយសម័យអង្គរ ប្រព័ន្ធតុលាការមានទម្រង់បែបសាសនា និងជាទម្រង់ច្បាប់ខ្មែរបុរាណខ្លួនឯងផ្ទាល់ ដែលទទួលរងនូវឥទ្ធិពលពីសាសនាហិណ្ឌូ និងព្រះពុទ្ធសាសនា។ ពេលកម្ពុជាដែលស្ថិតក្រោមអាណានិគមបារាំងឆ្នាំ១៨៦៣-១៩៥៣ ជាសម័យកាលដែលបារាំងនាំមកនូវការផ្លាស់ប្តូររបបគ្រប់គ្រងប្រទេសលើគ្រប់វិស័យ ពិសេសប្រព័ន្ធតុលាការត្រូវបានប្តូរ ទម្រង់ និងនីតិវិធីនៃការប្រតិបត្តិបែបបារាំងនៅឆ្នាំ១៩៣៤។ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជាថ្ងៃប្រវត្តិសាស្ត្រសម្រាប់កម្ពុជា បានផ្តួលរំលំរបបខ្មៅងងឹតកម្ពុជាប្រជាធិបតេយ្យ និងផ្លាស់ប្តូរជារបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយប្រព័ន្ធតុលាការត្រូវបានកំណត់នៅឆ្នាំ១៩៨២ ច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការនិងអយ្យការ ប្រព័ន្ធតុលាការនេះមានការទទួលខុសត្រូវចំពោះមុខគណៈកម្មាធិការប្រជាជនបដិវត្តខេត្តក្រុង។ រីឯរដ្ឋបាលតុលាការ និងដំណើរការសវនាការ មានការចូលរួមចៅក្រមជំនុំជម្រះ តំណាងរដ្ឋអាជ្ញា និងក្រឡាបញ្ជី ហើយមានទីប្រឹក្សាប្រជាជនថ្នាក់ស្មើនឹងចៅក្រមចូលរួមក្នុងដំណើរការ និងសម្រេចសេចក្តីផងដែរ។ ច្បាប់នេះពុំកំណត់អំពីភារកិច្ចរដ្ឋបាលក៏មិនជាបញ្ហាដែរ ព្រោះស្ថាប័នតុលាការមានផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធានតុលាការ ជាតួរអង្គគ្រប់គ្រងរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ។ កម្ពុជាឈានដល់ការចរចាបញ្ចប់ជម្លោះរវាងខ្មែរនិងខ្មែរ ដើម្បីស្វែងរកសន្តិភាពជូនជាតិមាតុភូមិ និងចុះកិច្ចព្រមព្រៀងស្តីពីសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលសម្របសម្រួលពីអង្គការសហប្រជាជាតិ ហៅកាត់ថាអ៊ុនតាក់ ហើយនៅឆ្នាំ១៩៩២ មានបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅកម្ពុជាក្នុងសម័យអន្តរកាល។ ទោះបីជាមានបទបញ្ញត្តិខាងលើ ក្រុមប្រឹក្សារដ្ឋកម្ពុជាបានរៀបចំឱ្យមានច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ដែលជាទម្រង់ច្បាប់កម្ពុជាសម្រាប់គ្រប់គ្រងប្រព័ន្ធតុលាការ និងមានកំណត់អំពីរចនាសម្ព័ន្ធតុលាការខេត្តក្រុង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ ទោះបីច្បាប់នេះពុំកំណត់អំពីរដ្ឋបាលតុលាការ និងតួនាទីភារកិច្ចនាយក្រឡាបញ្ជីស្ថាប័នតុលាការ ប៉ុន្តែកិច្ចការរដ្ឋបាល និងកិច្ចការបច្ចេកទេសតុលាការគ្រប់គ្រង និងគាំទ្រពីនាយកក្រឡាបញ្ជីអង្គការតុលាការ ហើយកិច្ចការអយ្យការ មាននាយកក្រឡាបញ្ជីគាំទ្រដំណើរការរបស់ស្ថាប័នតុលាការទាំងកិច្ចការរដ្ឋបាល និងកិច្ចការបច្ចេកទេសតុលាការ។

ស្ថាប័នតុលាការអាចដំណើរការតាមទម្រង់ និងនីតិវិធីតុលាការ គឺមានរដ្ឋបាលមួយគាំទ្រ និងសម្របសម្រួលកិច្ចការរដ្ឋបាលតុលាការលើការអនុវត្ត និងបេសកកម្មរបស់ចៅក្រម ព្រះរាជអាជ្ញា ហើយជាបទពិសោធន៍រដ្ឋបាលតុលាការកន្លងមក មាននាយកក្រឡាបញ្ជី ដែលជាអង្គគាំទ្រកិច្ចនីតិវិធីតុលាការ គឺនាយកក្រឡាបញ្ជីតុលាការគ្រប់គ្រងកិច្ចការរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ ហើយកិច្ចការនីតិវិធីអយ្យការ គឺនាយក្រឡាបញ្ជីអយ្យការទទួលបន្ទុកធ្វើការងារជាមួយមន្រ្តីនគរបាលយុត្តិធម៌ និងចូលរួមអនុវត្តដីកាតុលាការ។ ហើយច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីឆ្នាំ១៩៩៣ ព្រមទាំងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ ក៏ពុំបានកំណត់អំពីមុខងារនាយកក្រឡាបញ្ជីទេ គឺគ្រាន់តែមានការណែនាំរបស់រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ឆ្នាំ១៩៩៤ ឱ្យប្រធានតុលាការខេត្តក្រុងស្វ័យសម្រេចចាត់តាំងនាយកក្រឡាបញ្ជីប៉ុណ្ណោះ ដែលពុំទាន់មានច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជីគ្រប់គ្រងនៅឡើយ។

សាលាជម្រះក្តីខ្មែរក្រហម ត្រូវបានបង្កើតដោយច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្នាំ២០០១ និងកិច្ចព្រមព្រៀងអន្តរជាតិ ឆ្នាំ២០០៣ ដែលមានអាណត្តិនាំមកវិនិច្ឆ័យមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលកម្ពុជាទទួលស្គាល់ ដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អំឡុងឆ្នាំ១៩៧៥-១៩៧៩ ដែលមានឧបនិស្ស័យ និងជាធាតុចូលដ៏សំខាន់ចូលរួមចំណែកកំណែទម្រង់ប្រព័ន្ធទម្រង់ប្រព័ន្ធតុលាការកម្ពុជា ដែលជាទិដ្ឋាភាពអភិបាលកិច្ចល្អ ការជំនុំជម្រះប្រកបដោយសមធម៌ និងនីតិរដ្ឋ។ គោលដៅចំនួនទាំងពីរនៃច្បាប់សាលាក្តីខ្មែរក្រហម គឺចូលរួមចំណែកការធ្វើកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងការស្វែងរកយុត្តិធម៌ ដែលបានដើររួមគ្នាចាប់តាំងពីការកកើតសាលាក្តីខ្មែរក្រហម បានការអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវនិយាមយុត្តិធម៌អន្តរជាតិ ដូចមានចែងក្នុងសន្ធិសញ្ញា និងកតិកាសញ្ញាអន្តរជាតិជាធរមាន។ រដ្ឋបាលតុលាការមានតួនាទីសំខាន់របស់ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក មានវិធានផ្ទៃក្នុងដើម្បីការអនុវត្តការងារការិយាល័យរដ្ឋបាល ការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត និងផ្នែកតុលាការរួមមានអង្គបុរេជំនុំជម្រះ សាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ហើយកំណត់អំពីមុខងារប្រតិបត្តិការរបស់ការិយាល័យរដ្ឋបាល អង្គជំនុំជម្រះនិងគ្រប់ផ្នែកផ្សេងៗទៀត ដែលនីតិវិធីជាសារវ័ន្តដោះស្រាយបណ្តឹង និងសវនាការទាំងឡាយនៅក្នុងសាលាក្តី មានន័យថាជាវិធានផ្ទៃក្នុងកំណត់អំពីរដ្ឋបាលសុទ្ធសាធ រវាងការិយាល័យរដ្ឋបាលនិងផ្នែកនីមួយៗ ព្រមទាំងផ្នែករដ្ឋបាល និងនីតិវិធីច្បាប់។

ផ្នែករដ្ឋបាល អ.វ.ត.ក មានមុខងារដាច់ដោយឡែកពីផ្នែកតុលាការត្រង់ថាការិយាល័យរដ្ឋបាលត្រូវប្រតិបត្តិសកម្មភាពការងាររបស់ខ្លួនក្នុងនាមជាអ្នកតំណាងឱ្យតុលាការ សម្រាប់

កិច្ចការទំនាក់ទំនងជាមួយស្ថាប័នខាង ក្រៅ និងការគាំទ្រសេវាកម្មទូទៅរបស់តុលាការនៅខាងក្នុងតុលាការ។ អំពីតួនាទីភារកិច្ចរបស់ការិយាល័យរដ្ឋបាល នៃ អ ក.ត.វ.ជាផ្នែកសំខាន់មួយនេះសម្រាប់ការរៀបចំច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។[១]

**គោលនយោបាយរដ្ឋបាលតុលាការ៖** នីតិកាលទី៥ នៃរដ្ឋសភា មានការធ្វើកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ដែលច្បាប់ចំនួនបីពាក់ព័ន្ធមូលដ្ឋានតុលាការត្រូវបានព្រះមហាក្សត្រ ទ្រង់ប្រកាសដាក់ប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឆ្នាំ២០១៤ ដែលច្បាប់ទាំងបីនេះ ត្រូវរៀបចំតាមគោលការណ៍សំខាន់ៗដែលកំណត់គោលការណ៍ជាសារវ័ន្តមួយចំនួន ក្នុងគោលបំណង ធានាឯករាជ្យនៃអំណាចតុលាការ ធានារក្សាអនគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ធានាឱ្យកិច្ចដំណើរការរបស់ស្ថាប័នតុលាការប្រព្រឹត្តទៅល្អប្រសើរ និងលើកកម្ពស់ដំណើរការសេវាសាធារណៈ ក្នុងវិស័យយុត្តិធមឱ្យកាន់តែមានប្រសិទ្ធភាព និងឆាប់រហ័សឡើង។ ច្បាប់នេះមានការបែងចែកដាច់ពីគ្នានូវមុខងារជម្រះក្តីនិងរដ្ឋបាលសុទ្ធសាធ ក្នុងគោលដៅបង្កើនអព្យាក្រិត្យភាព ប្រសិទ្ធភាព តម្លាភាព និងទំនុកចិត្តរបស់អង្គការតុលាការ និងអង្គការអយ្យការក្នុងដំណើរការប្រព្រឹត្តកម្មនៃបណ្តឹងនិងរឿងក្តី។ ហើយច្បាប់ស្តីពីការរៀបចំអង្គការតុលាការ បានកំណត់ឱ្យមានរដ្ឋបាលនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ គាំទ្រដល់កិច្ចដំណើរការរបស់ស្ថាប័នតុលាការលើកិច្ចការរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ។ គោលការណ៍បែងចែកនេះ ឈរលើការកំណត់អំពីវិសាលភាពនៃអំណាចតុលាការនិងរដ្ឋបាលតុលាការ។ ជាទូទៅ និងតាមទ្រឹស្តីអំណាចតុលាការសំដៅជាពិសេសលើអំណាចជម្រះក្តី ឬអំណាចក្នុងការផ្តល់យុត្តិធម៌ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញមាត្រា១២៨ និង១២៩(ថ្មី) ក៏មានអត្ថន័យដូចនេះដែរ គឺអំណាចតុលាការដែលជាអំណាចឯករាជ្យ សំដៅលើអំណាចជម្រះក្តីផ្តល់យុត្តិធម៌ក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធី និងច្បាប់ជាធរមាន។ ការកំណត់បែបនេះមានការអនុវត្តនៅប្រទេសជាច្រើន៖ អាល្លឺម៉ង់ ស៊ុយអែត បែលហ្សិក អូស្ត្រាលីនូវែលហ្សេឡង់ជាដើម ដែលជាគោលការណ៍មួយដើម្បីធានាឯករាជ្យ ប្រសិទ្ធភាព គុណភាពនិងភាពឆាប់រហ័សក្នុងការផ្តល់សេវាយុត្តិធម៌ ហើយប្រទេសជាច្រើននោះ បានអនុវត្តគោលការណ៍នៃការបែងចែករវាង៖ ការជម្រះក្តីដោយចៅក្រម និងសេវារដ្ឋបាលនិងហិរញ្ញវត្ថុដែលជាអង្គភាពគាំទ្រឱ្យមានដំណើរការល្អរបស់ប្រព័ន្ធយុត្តិធម៌ដោយអង្គភាពស្ថិតក្រោមការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ដែលមានសមត្ថកិច្ចទូទៅក្នុងការគ្រប់គ្រង និងការទទួលខុសត្រូវលើមន្ត្រីរាជការ និងថវិកា។[២]

---

[១] អ.វ.ត.ក *អនុស្សរណៈអន្តរការិយាល័យជូនចៅក្រមអង្គជំនុំជម្រះតុលាការកំពូល ចៅក្រមអង្គជំនុំជម្រះ សាលាដំបូង ចៅក្រម អង្គបុរេជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេត* ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១១

[២] -រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣

**អង្គប្រតិបត្តិរដ្ឋបាលតុលាការ៖**[៣] ជាអង្គភាពថ្មីក្នុងរចនាសម្ព័ន្ធស្ថាប័នតុលាការ ដែលហៅថា "លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង" ជាអង្គភាពរដ្ឋបាលតួនាទីសម្របសម្រួលផ្តល់សេវាយុត្តិធម៌ និងគាំទ្រដល់ស្ថាប័នតុលាការ ហើយស្ថិតក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ដែលមានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ ជាសេនាធិការលើវិស័យរដ្ឋបាលតុលាការ។ តាមស្មារតីច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពរដ្ឋបាលនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដែលអង្គភាពសេនាធិការឱ្យសាលាដំបូង និងអយ្យការអមសាលាដំបូងលើការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ ស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។ ដើម្បីធានាប្រសិទ្ធភាពការអនុវត្តតួនាទីភារកិច្ចរដ្ឋបាលតុលាការមានគ្រាផ្លូវការ ដែលការអនុវត្តភារកិច្ចរបស់ខ្លួន និងមានទំនាក់ទំនង និងកិច្ចសហការល្អជាមួយអាជ្ញាធររដ្ឋបាលដែលខ្លួនតាំងនៅ។ លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង មានការិយាល័យចំណុះរួមការិយាល័យរដ្ឋបាល និងបុគ្គលិក ការិយាល័យកិច្ចការហិរញ្ញវត្ថុ ការិយាល័យកិច្ចការតុលាការ និងការិយាល័យកិច្ចការអយ្យការ ហើយដឹកនាំដោយប្រធាន និងអនុប្រធានការិយាល័យជាជំនួយការតាមការចាំបាច់។ ការិយាល័យមានកម្រិតថ្នាក់ស្មើនឹងការិយាល័យថ្នាក់កណ្តាលនៃក្រសួងយុត្តិធម៌។

រដ្ឋបាលតុលាការត្រូវបានអនុវត្តស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដោយគាំទ្រផ្តល់សេវាផ្ទៃក្នុងស្ថាប័នតុលាការ លើកិច្ចការរដ្ឋបាល និងបច្ចេកទេសដែលជាសកម្មភាពបេសកកម្មរបស់ចៅក្រម ព្រះរាជអាជ្ញា អាជ្ញាសាលា ឬអ្នកពាក់ព័ន្ធ និងសម្របសម្រួលផ្តល់សេវាយុត្តិធម៌ជូនសាធារណជន ហើយមានការទំនាក់ទំនងជាមួយស្ថាប័នខាងក្រៅដូចជាអ្នកសារព័ត៌មាន ពន្ធនាគារ អង្គភាពនគរបាលយុត្តិធម៌ និងអាជ្ញាធរមានសមត្ថកិច្ចក្នុងដែនដីដែលខ្លួនតាំងនៅផងដែរ។

សរុបសេចក្តីមក ការយល់ដឹងអំពីរដ្ឋបាលតុលាការកម្ពុជា ដូចដែលយើងបានបង្ហាញខាងលើ យើងអាចសង្ខេបបានថា៖ ប្រព័ន្ធតុលាការកម្ពុជា គឺមានផ្នែករដ្ឋបាលមួយជាជំនួយការទោះបីពុំមានកំណត់ឱ្យច្បាស់អំពីតួនាទីភារកិច្ចរបស់ផ្នែករដ្ឋបាលនេះយ៉ាងណាក៏ដោយ ក៏ផ្នែកនេះនៅអមជាមួយនឹងដំណើរការ និងកិច្ចនីតិវិធីរបស់ស្ថាប័នតុលាការ ដែលមានកិច្ចការរដ្ឋបាលបុគ្គលិក និងហិរញ្ញវត្ថុ។ ដោយឈរលើបទពិសោធន៍នៃប្រព័ន្ធតុលាការកម្ពុជាឆ្នាំ១៩៩៣ ដែលមាននាយកក្រឡាបញ្ជីជាសេនាធិការឱ្យស្ថាប័នតុលាការ និងច្រករដ្ឋបាលបម្រើសេវាយុត្តិធម៌

---

-ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ឆ្នាំ១៩៩៣

-ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ និងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

-ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

-ក្រសួងយុត្តិធម៌ *សន្និសីទថ្នាក់ជាតិស្តីពីការផ្សព្វផ្សាយច្បាប់គោលទាំងបីពាក់ព័ន្ធនឹងវិស័យយុត្តធម៌* ភ្នំពេញ ឆ្នាំ២០១៤។

[៣] -ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

-អនុក្រឹត្យ *លេខ២១ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង* ឆ្នាំ២០១៦។

ចំនួនពីរសម្រាប់អង្គការតុលាការ និងអង្គការអយ្យការ។ លើសពីនេះកើ្តដំណែលនៃប្រព័ន្ធតុលាការនៃសាលាក្តីខ្មែរក្រហម ដែលមានទីតាំងនៅលើដែនដីព្រះរាជាណាចក្រកម្ពុជា និងមានផ្នែករដ្ឋបាលមួយជាសេនាធិការ និងជាក្បាលម៉ាស៊ីនដ៏សំខាន់គាំទ្រសេវាផ្ទៃក្នុងតុលាការ និងសម្របសម្រួលផ្តល់សេវាយុត្តិធម៌។ ហើយនិយាមច្បាប់រដ្ឋបាលតុលាការអន្តរជាតិ រួមមាន អាល្លឺម៉ង់ ស៊ុយអែត បែលហ្សិក អូស្ត្រាលី នូវែលហ្សេឡង់ជាដើម ដែលជាគោលការណ៍មួយដើម្បីធានាឯករាជ្យ ប្រសិទ្ធភាព គុណភាព និងភាពឆាប់រហ័សក្នុងការផ្តល់សេវាយុត្តិធម៌ ហើយប្រទេសជាច្រើននោះ បានអនុវត្តគោលការណ៍នៃការបែងចែករវាង៖ ការជម្រះក្តីដោយចៅក្រម និងសេវារដ្ឋបាលនិងហិរញ្ញវត្ថុដែលជាអង្គភាពគាំទ្រឱ្យមានដំណើរការល្អរបស់ប្រព័ន្ធយុត្តិធម៌។

ផ្អែកតាមបទពិសោធន៍ និងគោលការណ៍និយាមច្បាប់អន្តរជាតិខាងលើ រាជរដ្ឋាភិបាលបានកំណត់ឱ្យមានកម្មវិធីកំណែទម្រង់ស៊ីជម្រៅ ទៅលើកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ បានធ្វើសមាហរណកម្មនៃរដ្ឋបាលតុលាការរួមតែមួយ ដែលជាច្រករដ្ឋបាលចេញចូលតែមួយសម្រាប់ស្ថាប័នតុលាការ និងដើម្បីលើកកម្ពស់ការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ។ ក្នុងនីតិកាលទី៥ នៃរដ្ឋសភា ព្រះមហាក្សត្រ ទ្រង់ប្រកាសដាក់ឱ្យប្រើច្បាប់មូលដ្ឋានតុលាការចំនួនបីពិសេសច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ជាច្បាប់មានអភិក្រមសម្រាប់ការអនុវត្តតួនាទីភារកិច្ចរបស់ស្ថាប័នតុលាការ ហើយកំណត់ឱ្យមានអង្គភាពរដ្ឋបាលតុលាការជាសេនាធិការលើការគ្រប់គ្រងរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ សម្រាប់គាំទ្រស្ថាប័នតុលាការ និងសម្របសម្រួលផ្តល់សេវាយុត្តិធម៌។

# ការចូលរួមរបស់យុវជនក្នុងនយោបាយ

## បេក្ខជនបណ្ឌិត វង្ស កែវសុធន ជំនាញវិទ្យាសាស្ត្រនយោបាយ

### ១- សេចក្តីផ្តើម

យើងទាំងអស់គ្នាជាកោសិកាសង្គមកំពុង រស់នៅជាមួយសេចក្តីប្រាថ្នានៃការរស់រានមានជីវិតមានសុខសន្តិភាពនិងការរីកចម្រើន ហើយយើងបាននឹងកំពុងប្រឹងប្រែងរួមគ្នាដើម្បីសម្រេចនូវក្តីសុបិននោះ ដូច្នេះចង់មិនចង់ក៏ស្មារតីយើងបានប្រាស្រ័យទាក់ទងទៅនឹងគំនិតស្តីពីនយោបាយរួចស្រេចទៅ ហើយ។ ការយល់ឃើញនិងចូលរួមក្នុងសកម្មភាព នយោបាយដោយភាពស្រពិចស្រពិលរបស់ពលរដ្ឋតាមរយៈការយល់ដឹងមិនមានមូលដ្ឋាន ឬដោយគ្មានការសិក្សាបែបជំហរវិទ្យាសាស្ត្រ គ្មានវត្តមានវប្បធម៌នយោបាយទំនើបដែលជាចរន្តពិភពលោក អាចនឹងនាំមកនូវភាពរឹករៃ បំផ្លិចបំផ្លាញ ការឈឺចាប់និងភាពអយុត្តិធម៌សង្គម។ ការសិក្សាស៊ីជម្រៅពីសកម្មភាពនយោបាយដែលមានអត្ថិភាពក្នុងសង្គម មានតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការចូលរួមនយោបាយពីប្រជាពលរដ្ឋដោយសុឆន្ទៈ ដើម្បីកំណត់ជោគវាសនាខ្លួន សហគមន៍ និងប្រទេសជាតិផងដែរ[1]។

រដ្ឋធម្មនុញ្ញជាតិក៏បានធានាឱ្យប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិចូលរួមក្នុងកិច្ចការនយោបាយ[2]។ គោលបំណងចម្បងៗនៃវិស័យនយោបាយជាតិគឺសម្រាប់ការពង្រឹងឯករាជ្យជាតិ សន្តិភាព ស្ថិរភាព ការរក្សាបាននូវសណ្តាប់ធ្នាប់សង្គម ការពង្រឹងនីតិរដ្ឋ ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋដើម្បីបង្កើតសង្គមស្អាតស្អំ ប្រាសចាកអំពើពុករលួយ និងបរិយាកាសនយោបាយបង្រួបបង្រួមជាតិឱ្យកាន់ តែល្អប្រសើរក្នុងការពង្រឹងឯកភាពជាតិ រក្សាសីលធម៌សង្គមនិងប្រពៃណីដ៏ល្អរបស់ជាតិសំរាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រ។ នៅក្នុងបរិបទ សង្គមវប្បធម៌ និងនយោបាយរបស់កម្ពុជា "យុវជន" ជាបុរសនិងស្ត្រីដែលមានសញ្ជាតិខ្មែរមានអាយុពី១៥ទៅ៣០ឆ្នាំនៅលីវឬរៀបការហើយ[3]។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកពួកគេថាពិតជាធនធានគន្លឹះ និងមានសក្តានុពលល្អបំផុតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌ បរិស្ថាន និងការរក្សាសុខសន្តិភាពទាំងបច្ចុប្បន្ននិងទៅអនាគត ហើយពួកគេក៏រាប់ថាជាសសរទ្រូងដ៏រឹងមាំនៃប្រទេសជាតិប្រកបដោយថាមពលស្វាហាប់ ភាពឈ្លាសវៃ និងយូរអង្វែង។

យុវជនប្រឡូកក្នុងកិច្ចការសង្គមជាតិនិងនយោបាយច្រើន គឺជាសញ្ញាណវិជ្ជមានមួយដែលបង្ហាញពីសន្ទុះនៃការកសាងភាពជាអ្នកដឹកនាំកាន់ តែច្រើន សំឡេងរបស់ពួកគេមានកម្លាំងខ្លាំងក្នុងការផ្លាស់ប្តូរសង្គមជំរុញឱ្យវិវត្តលឿន ហើយឥទ្ធិពលនេះអាចបន្តដល់មនុស្សជំនាន់ក្រោយៗទៀត[4]។ ចំពោះការលើកទឹកចិត្តនិងផ្តល់លទ្ធភាពឱ្យពួកគេចូលរួមក្នុងផ្នែកនយោបាយតាមរយៈការជ្រើសមាបរណកម្មយុវជនចូលទៅក្នុងការងារគ្រប់លំដាប់ថ្នាក់នៃស្ថាប័នជាតិត្រូវតែជាការជំរុញឱ្យពួកគេចូលរួមដោយមិនមានពុតត្បុតក្នុងការបង្ហាញនូវសមត្ថភាព ឬទស្សនៈ ចំណេះដឹង និងការយល់ឃើញដោយស្មោះត្រង់ តម្លាភាព និងមានទំនួលខុសត្រូវខ្ពស់ក្នុងកិច្ចការកំណត់ជោគវាសនាប្រទេសជាតិទាំងមូល។

---

[1] សុខ គាង៖ *វិទ្យាសាស្ត្រនយោបាយ* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ២០០២ ទំព័រ២។

[2] **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣** មាត្រាទី៣៥។

[3] ក្រសួងអប់រំ យុវជន និងកីឡា៖ ***គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា*** ខែមិថុនា ឆ្នាំ២០១១ ទំព័រ១។

[4] Heng, *Youth Participation in Cambodia* : Knowledge, Pratcice, Attitue, and Media, 2010, P.20.

## ២- វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវនេះ ព័ត៌មាននិងទិន្នន័យបឋម គឺត្រូវបានដកស្រង់ចេញពីរបាយការណ៍លទ្ធផលកម្រងសំណួរសម្ភាសន៍ និងសម្រង់សម្ដីនៃក្រុមយុវជនក្នុងតំបន់ឃុំគោលដៅនានាក្នុងខេត្ត។ ឯកសារសំណេរដែលមានស្រាប់ដូចជា មូលដ្ឋានទ្រឹស្ដីនយោបាយ បទពិសោធន៍ គោលនយោបាយ គោលការណ៍ច្បាប់នានា គឺត្រូវបានដកស្រង់ជាសំអាងសម្រាប់ការសិក្សានេះ ក៏រួមមាននូវ មេរៀននយោបាយ ទស្សនវិជ្ជា របាយការណ៍ខេត្ត ឯកសារបោះពុម្ពផ្សាយការស្រាប់ លិខិតបទដ្ឋានគតិយុត្តិ គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល បញ្ញត្តិនានាគោលការណ៍ច្បាប់ជាតិនិងអន្តរជាតិទាក់ទងនឹងលទ្ធិប្រជាធិបតេយ្យ និងនយោបាយនៅកម្ពុជា។ ក្នុងគោលបំណងឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានលទ្ធផលល្អ វិធាននៃការវិភាគគឺត្រូវបានកំណត់យកដោយកម្រិតជឿជាក់ខ្ពស់បំផុតដោយផ្អែកតាមរូបមន្ត Yamane Taro បានកំណត់យកសំណាកអ្នកឆ្លើយចំនួន ៣៣៥នាក់មកធ្វើការសិក្សាស្រាវជ្រាវ។

កម្មវិធីសម្ភាសន៍ផ្ទាល់ជាមួយក្រុមយុវជន ដោយការពន្យល់ន័យនិងបំពេញទម្រង់សំណួរ ការអង្កេតមើលឥរិយាបទរបស់អ្នកឆ្លើយសំណួរ កំឡុងពេលសម្ភាសន៍ និងការសង្កេតផ្ទាល់តាមសហគមន៍ចំពោះសកម្មភាពយុវជនសកម្មក្នុងកិច្ចការងារសង្គម ហើយទិន្នន័យដែលប្រមូលបាន ត្រូវវិភាគតាមបែបគុណភាព និងបរិមាណ ដោយផ្អែកលើគោលការណ៍គណិតវិទ្យានិងស្ថិតិវិទ្យាដោយប្រើប្រាស់នូវកម្មវិធី Microsoft Excel រួចរៀបចំបញ្ចូលទិន្នន័យក្នុងកំព្យូទ័រដើម្បីវិភាគតាមកម្មវិធីវិភាគសង្គម SPSS 20 ដែលការវិភាគព័ត៌មានទាំងនេះយើងត្រូវប្រើទិន្នន័យទាំងពីរប្រភេទខាងលើ។

## ៣- ទិដ្ឋភាពសង្គមនយោបាយនៃការចូលរួមរបស់យុវជន

ជាការណ៍ពិត គោលការណ៍នយោបាយត្រូវមានទំនាក់ទំនងទៅនឹងគោលការណ៍ប្រជាធិបតេយ្យ ស្នូលនៃតម្លៃនយោបាយគឺមានសិទ្ធិខាងនយោបាយ សិទ្ធិបោះឆ្នោត ចូលរួមសម្រេចជ្រើសរើសរដ្ឋាភិបាល និងត្រូវដើរតាមគោលនយោបាយ[5]។ របបសង្គមលទ្ធិប្រជាធិបតេយ្យនឹងគ្មានន័យនុះទេ បើសិនគ្មានការចូលរួមយ៉ាងហោចក្នុងកម្រិតអប្បបរមានៃពលរដ្ឋនិង រដ្ឋាភិបាល[6]។ នៅក្នុងសង្គមប្រជាធិបតេយ្យ យុវជនតែងសម្លឹងមើលទង្វើរបស់រដ្ឋាភិបាលក្នុងឥរិយាបទជាអ្នកធ្វើសកម្មភាពដើម្បីប្រយោជន៍ជូនដល់ពលរដ្ឋដែលជាម្ចាស់ឆ្នោត។ អត្ថន័យរួមនៃឆន្ទៈចូលរួមក្នុងជីវភាពនយោបាយរបស់យុវជនកម្ពុជាគឺជាស្មារតីពិតដែលមានលក្ខណៈបែបចូលរួមដោយមានមូលហេតុច្បាស់លាស់បង្កប់នូវខ្លឹមសារភ្ជាប់ដោយគោលបំណងជាក់លាក់ និងបទពិសោធន៍ក្នុងក្របខណ្ឌសុចន្ទៈ ដើម្បីធ្វើឱ្យសង្គមជាតិកាន់តែមានភាពប្រសើរឡើងតាមគុណតម្លៃបែបប្រជាធិបតេយ្យនិងនីតិរដ្ឋ[7]។

"ការចូលរួមក្នុងសកម្មភាពនយោបាយ" រាប់ថាជាសកម្មភាពដែលអាចទទួលយកបាន លុះត្រាតែមានការឆ្លើយតបនឹងគោលបំណងសាធារណៈ មានទិសដៅច្បាស់លាស់ ហើយសកម្មភាពទាំងនោះត្រូវលេចចេញពីគំនិតពិចារណា ពីឆន្ទៈពិត និងមានការរៀបចំត្រឹមត្រូវដើម្បីដាក់ឱ្យដំណើរការក្នុងក្របខណ្ឌសកម្មភាពអនុវត្តគោលនយោបាយដ៏ជាក់លាក់មួយ និយាយរួមត្រូវបម្រើឧត្តមប្រយោជន៍ជាតិជាធំ ធ្វើយ៉ាងណាមិនផ្ទុយនឹងច្បាប់រដ្ឋ ឬរដ្ឋធម្មនុញ្ញជាតិ។

---

[5] ដៀប សុផល៖ *មនោគមវិជ្ជានយោបាយ* ភាគ I, ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ បោះពុម្ពឆ្នាំ២០១១ ទំព័រ១៣។

[6] Minoque J., *Political Participation:* How and Why do People get Involve in Politics?, 1998, p. 2.

[7] ឈុន ណារ៉េត៖ *សេចក្ដីផ្ដើមវិទ្យាសាស្ត្រនយោបាយ,* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ២០១២ ទំព័រ១៤។

ពាក្យ "ប្រជាធិបតេយ្យ" គឺសំដៅលើការយកប្រជាជនជាធំ ជាអ្នកសម្រេចចិត្តក្នុងកិច្ចការដឹកនាំគ្រប់គ្រងប្រទេស។ លទ្ធិប្រជាធិតេយ្យ គឺជាទម្រង់នៃការគ្រប់គ្រងរដ្ឋមួយ ដែលសិទ្ធិនិងអំណាចក្នុងការចាត់ចែងកិច្ចការប្រទេសជាតិស្ថិតនៅក្នុងគំនិតរបស់ប្រជាពលរដ្ឋ ហើយដាច់ខាតត្រូវមានប្រព័ន្ធធានាដល់ការប្រើសិទ្ធិនិងអំណាចជាម្ចាស់របស់ពលរដ្ឋជាអចិន្ត្រៃយ៍[8]។

ចំណែកឯពាក្យថា "យុវជន" យើងនៅតែមិនទាន់មានការឱ្យនិយមន័យបានច្បាស់លាស់នៅឡើយទេ ដោយសារតែមានការលើកឡើងផ្សេងៗគ្នា។ បើយោងតាមក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ថាយុវជនគឺមនុស្សមានអាយុចាប់ពី១៥ទៅ៣០ឆ្នាំ[9] ដូចគ្នានឹងគណបក្សប្រជាជនកម្ពុជាដែរ។ បញ្ញវន្ត គឺជាបុគ្គលទាំងឡាយដែលបានប្រើប្រាស់នូវកម្លាំងបញ្ញាលើសម្បទាដទៃផ្សេងទៀត ដើម្បីបំពេញការងារចិញ្ចឹមជីវិតផង និងដើម្បីស្វែងរកសច្ចភាពសង្គមផង[10]។ យុវជនគឺជាទំពាំងស្នងឬស្សី ពួកគេចេះគិត ចេះវាយតម្លៃសភាពការណ៍ពិត ហើយចេះសន្និដ្ឋានបានត្រឹមត្រូវ[11]។ អ្នកចម្បាំងបើខ្លាំងគឺឈ្នះ រីឯយុវជនបើខ្លាំងគឺសង្គមរីកចម្រើន ហើយយុវជនយើងថ្ងៃនេះ គឺជាមេដឹកនាំនៅថ្ងៃស្អែក[12]។ បើតាមគំនិតរបស់ទស្សនវិទូអន្សតិរ្ថិយនិយម **ហ្វ្រីឌ្រីក និហ្សឺ** (Friedrich Nietzsche) បានចែងបែបផ្ទុយវិញថា "ប្រមុខនយោបាយបានបែងចែកមនុស្សក្នុងសង្គមនយោបាយជា២ប្រភេទគឺ ប្រភេទជនជាឧបករណ៍នយោបាយនិង ប្រភេទជនជាសត្រូវនយោបាយ"។ ក្នុងស្ថានភាពភាគច្រើន យុវជនច្រើនជាឧបករណ៍នយោបាយ និងជាកូនអុកដ៏សំខាន់បំផុតសម្រាប់អ្នកនយោបាយ ហើយពួកគេខ្លះទៀតមិនប្រឹងរុញច្រានយុវជនឱ្យទៅមុខ តែបែជាប្រឹងជាន់គ្នាឱ្យទាបនិងបាត់បង់ឱកាសនានា ដូច្នេះយុវជនគួរចេះប្រុងប្រយ័ត្នក្នុងសង្គមដែលមានមនុស្សស្រេកឃ្លានផលប្រយោជន៍ផ្ទាល់ខ្លួនជ្រុលហួសពេក។ ការលើកកម្ពស់និងជំរុញយុវជនឱ្យខ្លាំង វាក៏អាស្រ័យទៅនឹងមនុស្សជំនាន់មុនផង និងជារឿងរបស់យុវជនខ្លួនឯងផងដែរ។ អ្នកជំនាន់មុនមានតួនាទីជួយជ្រោមជ្រែងយុវជនឱ្យទៅមុខទាំងស្មារតី ចំណេះដឹង និងហិរញ្ញវត្ថុ មិនមានការរាំងខ្ទប់ការរីកចម្រើនរបស់ពួកគេ ជៀសវាងវប្បធម៌ក្លិចក្លួយ ចាប់ដៃជាន់ជើង ច្រណែន ប្រកាន់វប្បធម៌សួនតួ និងអភិរក្សនិយមជ្រុល ទាំងអស់នេះគឺមានន័យថាបានចូលរួមជួយសង្គមជាតិបាត់ទៅហើយ។ រីឯយុវជនខ្លួនឯង ក៏ត្រូវខិតខំរៀនសូត្រ បណ្ដុះសីលធម៌រស់នៅល្អមានស្មារតីស្នេហាជាតិ ស្រឡាញ់យុត្តិធម៌ ជំនាញទំនើប អភិវឌ្ឍចំណេះដឹង ចេះចែករំលែកក្នុងសង្គម កុំធ្វើត្រឹមតែជាអ្នកនយោបាយ តែត្រូវធ្វើជាអ្នកដឹកនាំមានបេះដូងបម្រើដល់មនុស្សជាតិក្នុងសង្គម។ តួនាទីអ្នកចេះដឹង គឺត្រូវធ្វើខ្លួនជាអ្នកមានឧត្តមគតិ ចេះដឹងពិតប្រាកដ តែមិនមែនពាក់ស្រោមមុខអ្នកចេះដឹងហើយបែជាទៅបម្រើអ្នកនយោបាយទុច្ចរិតនុះទេ។

ចំពោះអធិបតេយ្យភាពប្រទេសកម្ពុជាត្រូវបានទទួលស្គាល់យ៉ាងពេញលេញ។ ធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ានបានបញ្ញត្តយ៉ាងច្បាស់ថាគ្មានរដ្ឋណាមួយមានសិទ្ធិទៅលូកលាន់ដោយផ្ទាល់ឬប្រយោលលើទោះក្នុងហេតុផលណាក៏ដោយនៅក្នុងកិច្ចការផ្ទៃក្នុងឬបញ្ហាប៉ះពាល់ដល់បូរណភាពទឹកដី ជាពិសេសឯករាជភាពនយោបាយរបស់ប្រទេស។ ការកំណត់គោលការណ៍ស្នូលនៃលទ្ធិប្រជាធិបតេយ្យ ទោះបីមានការ

---

[8] ចំណេះដឹងទូទៅខ្មែរ៖ *លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា* ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៩ www.KHSearch.com/2018 ( Accessed 12 September 2019 )។

[9] ក្រសួងអប់រំ យុវជន និងកីឡា៖ *គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា* ខែមិថុនា ឆ្នាំ២០១១ ទំព័រ៣។

[10] ឡាំ លីម៖ *ប្រតិទិនទស្សនៈ២២២* បោះពុម្ពលើកទី១ ដោយគ្រឹះស្ថានសៀវភៅជីវិត ឆ្នាំ២០១៩ ទំព័រ៦៩។

[11] សុខ ទូច៖ *នយោបាយការបរទេស មិត្រលមិញ ថ្ងៃនេះ និងថ្ងៃស្អែក*, បោះពុម្ពឆ្នាំ ២០១៥ ទំព័រ២៤៨។

[12] ឡាំ លីម៖ *ប្រតិទិនទស្សនៈ២២២*, បោះពុម្ពលើកទី១ ដោយគ្រឹះស្ថានសៀវភៅជីវិត ឆ្នាំ២០១៩ ទំព័រ២១៥។

ត្រួសត្រាយដោយអង្គការសហប្រជាជាតិក្ដី កម្ពុជាខ្លួនឯងនៅតែចាត់ទុកនិងទទួលស្គាល់នូវគោលការណ៍លទ្ធិប្រជាធិបតេយ្យដោយបានកំណត់នូវសកម្មភាពនយោបាយសំខាន់ៗស្របតាមបញ្ញត្តិនិងបរិបទកម្ពុជា[13]។ ក្នុងបំណងស្វែងរកនូវបណ្ដាអថេរឯករាជ ឬកត្តាដ៏មានប្រសិទ្ធភាពបំផុតក្នុងការជំរុញឱ្យយុវជនចូលរួមក្នុងការងារសង្គមនិងនយោបាយជាតិ សម្មតិកម្មនៃការសិក្សាស្រាវជ្រាវត្រូវបានកំណត់ដូចមានជាអាទិ៍ ការអនុវត្តសិទ្ធិពលរដ្ឋក្នុងសង្គម ស្មារតីលះបង់សម្រាប់ប្រទេសជាតិ ការឱ្យតម្លៃខ្លួនឯងក្នុងការដឹកនាំប្រទេស ការទទួលស្គាល់ក្នុងសង្គម ការបង្កើនកិច្ចសហការ និងការធានាសុវត្ថិភាពការងារ ការសំដៅផលប្រយោជន៍ថ្ងៃអនាគត និងការបង្កើនអំណាចការងារ ដែលកត្តាទាំងនេះសុទ្ធសឹងតែមានទំនាក់ទំនងវិជ្ជមានលើការសំដែងសិទ្ធិនយោបាយតាមរយៈការបោះឆ្នោតជ្រើសរើសតំណាងដែលគេគាំទ្រ។

## ៤- លទ្ធផលនៃការសិក្សាស្រាវជ្រាវ

ផ្អែកលើលទ្ធផលនៃការវិភាគបានបង្ហាញថា ក្នុងបណ្ដាអ្នកឆ្លើយភាគច្រើនជាយុវជននិងយុវនារីដែលមានអាយុចាប់ពី១៨ទៅ៣៣ឆ្នាំ ដែលចំនួន៧៥%នៃពួកគេគឺមានចំណេះដឹងទូទៅខ្ពស់កម្រិតបរិញ្ញាបត្រ ហើយពួកគេភាគច្រើនជាមន្ត្រីរាជការនិងជាសិស្សនិស្សិត សុទ្ធសឹងជាធនធានយុវជនល្អដែលកំពុងធ្វើការងារសង្គមយ៉ាងសកម្មនៅតាមមូលដ្ឋាននិងស្ថាប័នជាតិនានា ជាមន្ត្រីបម្រើសេវាសាធារណៈនៅកម្រិតភូមិឃុំ ស្រុក និងខេត្ត រួមទាំងកម្មវិធីអភិវឌ្ឍនៃអង្គការមិនមែនរដ្ឋាភិបាលផងដែរ។







យុវជនក្នុងខេត្តកំពង់ឆ្នាំង ពួកគេមានការយល់ដឹងស្ដីអំពីបញ្ហាសិទ្ធិជាមូលដ្ឋានមានលក្ខណៈចម្រុះបែបទូលំទូលាយទៅលើសមាសភាពនៃសិទ្ធិជាមូលដ្ឋានមានសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិ

---

[13] ច្បាប់សិទ្ធិមនុស្សកម្ពុជា អង្គការសហប្រជាជាតិ ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សការិយាល័យប្រចាំកម្ពុជា ឆ្នាំ២០០៨។

សង្គម តែមិនមានការបង្ហាញពីសិទ្ធិវប្បធម៌នុះទេ។ ប្រជាពលរដ្ឋភាគច្រើនបំផុតស្ទើរតែទាំងអស់បានផ្តល់តម្លៃខ្លាំងក្លាលើសិទ្ធិនិងការអនុវត្តសិទ្ធិសេរីក្នុងនាមជាប្រជាពលរដ្ឋនៃប្រទេសជាតិមួយដែលមានរបបដឹកនាំបែបប្រជាធិបតេយ្យពិតៗ ដែលគេចាំបាច់ត្រូវតែសំដែងក្នុងកិច្ចការចូលរួមដឹកនាំសង្គមជាតិរបស់គេតាមរយៈតំណាងឆ្ពោះទៅកាន់គោលដៅដែលគេចង់បានរួមគ្នា។




យុវជនភាគច្រើនតែងយល់ដឹងជាទូទៅថាសំឡេងពួកគេម្នាក់ៗពិតជាមានតម្លៃមិនអាចកាត់ថ្លៃបានក្នុងការត្រួសត្រាយផ្លូវដឹកនាំជោគវាសនាសង្គមជាតិ និងប្រជាជនទាំងមូលតាមរយៈតំណាងរបស់ពួកគេក្នុងថ្ងៃប្រជុំឃុំ វេទិកាសាធារណៈ ជាពិសេសថ្ងៃបោះឆ្នោតឃុំសង្កាត់និងបោះឆ្នោតជាតិក្នុងក្របខ័ណ្ឌនៃសង្គមប្រជាធិបតេយ្យហើយពួកគេមានសកម្មភាព ចូលរួមក្នុងសង្គមយ៉ាងផុលផុសទាំងការងារសង្គម សេដ្ឋកិច្ច មនុស្សធម៌ និងនយោបាយដោយមិនអាត្មានិយមពេកនុះទេ។






តែគួរឱ្យសោកស្តាយ មានលទ្ធផលបង្ហាញថាអ្នកមិនយល់ដឹងពីគោលនយោបាយបក្សមានចំនួនច្រើនគួរសម(អាចថាលើសលប់)បើធៀបនឹងអ្នកដែលមានការយល់ដឹងច្បាស់។ ក្នុងន័យនេះអាចបញ្ជាក់ពីសញ្ញាណនៃការយល់ដឹងពីទិសដៅ ឬក៏ផ្លូវនៃដំណើរនយោបាយដែលពួកគេកំពុងគាំទ្រគឺមិនច្បាស់លាស់ អាចថាគាំទ្រតាមគ្នីតាមគ្នាតែប៉ុណ្ណោះ ដោយមិនបានពិចារណាឱ្យល្អិតល្អន់ពិតប្រាកដ សម្រាប់គាំទ្រយន្តការនយោបាយបក្សនុះទេ។




តាមលទ្ធផលនៃការវិភាគក៏បានបង្ហាញផងដែរពីចំនួនអ្នកធ្លាប់រំពឹងទុកពីផលប្រយោជន៍នានាពី សកម្មភាពនយោបាយដែលមានចំនួន៤៨.៤% រីឯអ្នកដែលមិនគិតពីផលត្រឡប់វិញនៃសកម្មភាពនយោបាយមានចំនួន៤៣.៧% នេះបញ្ជាក់ថា ចំនួនអ្នកធ្វើសកម្មភាពនយោបាយសំដៅប្រយោជន៍ផ្ទាល់ខ្លួន និងអ្នកដែលលះបង់ដោយមិនគិតពីប្រយោជន៍មានចំនួនអាចថាប្រហាក់ប្រហែលគ្នា តែទោះជាយ៉ាងណាក្តី វានៅតែបញ្ជាក់ថាការគិតសំដៅរំពឹងពីប្រយោជន៍មានចំនួនច្រើនជាងអ្នកលះបង់។




ក៏មានការបញ្ជាក់ដែរថា មន្ត្រីដែលជាប្រតិបត្តិករសេវាសាធារណៈជាអ្នកបម្រើរាស្ត្រស្ទើរគ្រប់ស្ថាប័នមិនអាចកាត់ផ្តាច់ចេញពីការងារបក្សឡើយ ចង់ឬមិនចង់គេត្រូវចំណាយពេលរួមទាំងធនធានដើម្បីចូលរួមក្នុងការងារនយោបាយតាមរយៈបក្សកាន់អំណាចតែមួយគត់ ក្នុងន័យធានាបាននូវលក្ខខ័ណ្ឌសុវត្ថិភាពខ្ពស់លើការងារឬមុខតំណែងដែលខ្លួនកំពុងមាន។ រីឯឥទ្ធិពលបក្សពិតជាបង្កើនឥទ្ធិពលបុគ្គល ហើយវាក៏ជំរុញដល់ការសម្រេចចិត្តនានាទាំងក្នុងការងារស្ថាប័ននិងឯកជនផងដែរ ដែលទាំងនេះជាការប្រាថ្នាចង់បាននៃបណ្តាអ្នកគាំទ្រនយោបាយបក្សកាន់អំណាចក្នុងរដ្ឋាភិបាល ដើម្បីបញ្ច្រាបខ្លួនគេទៅក្នុងការងារសង្គមនយោបាយតាមការណែនាំនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្សនៅកម្រិតមូលដ្ឋាន។




ចំពោះការវិភាគលើបរិយាកាសគាំទ្រវិញ បង្ហាញថាលក្ខខ័ណ្ឌនយោបាយសព្វថ្ងៃពិតជាមានការគាំទ្រដល់ការអនុវត្តសិទ្ធិនយោបាយនានាស្ថិតក្នុងរង្វង់ខ្លាំងគួរសម តែមិនទាន់ដល់កម្រិតខ្លាំងណាស់ណាទេ។ បញ្ជាក់ថាសន្តិភាពនិងស្ថិរភាពនយោបាយសព្វថ្ងៃពិតជាផ្តល់ឱ្យនូវសេរីភាពនិងការអភិវឌ្ឍ ដោយស្រុកទេសមានសន្តិភាពល្អនិងស្ថិរភាពនយោបាយនឹងនរ ពិតជាគន្លឹះក្នុងការជំរុញដល់ការងារអភិវឌ្ឍដល់គ្រប់វិស័យ ជាពិសេសយុវជនអាចមានសិទ្ធិសេរីភាពគ្រប់បែបយ៉ាងក្នុងការបង្កើតជម្រើសទាំងសង្គម វប្បធម៌និងនយោបាយ។ រីឯការជំរុញការចូលរួមរបស់យុវជនក្នុងនយោបាយគឺអាស្រ័យតាមរយៈការបើកចំហររបស់រដ្ឋាភិបាលនិងអាជ្ញាធរ ជាសញ្ញាជំរុញវិជ្ជមានក្នុងការបើកផ្លូវដល់ការចូលរួមរបស់ប្រជាពលរដ្ឋនានផងដែរ។




ដោយឡែកសម្រាប់ដំណើរការនៃការបោះឆ្នោតនៅកម្ពុជា ឃើញថាទោះបីមានអ្នកឆ្លើយថាពិបាកនិងមិនដឹង តែចំនួននៃអ្នកទទួលស្គាល់ថាការបោះឆ្នោតមានដំណើរការងាយស្រួលមានចំនួនច្រើនជាងដល់ទៅ២ដង អាចសន្និដ្ឋានជារួមថាវាងាយស្រួលបាន តែបើក្រឡេកមើលចំនួនអ្នកដែលឆ្លើយថាពិបាកក៏មានចំនួនច្រើនគួរសមដែរ ជិតពាក់កណ្តាល ៩៦/២០១នាក់ ទាំងនេះក៏នៅតែចាត់ទុកថានៅមានការលំបាក ដែលអាចថាមកពីអ្នកទៅបោះឆ្នោតថ្មីៗមិនទាន់យល់ពីដំណើរការបានល្អ ឬការចូលរួមនេះអាចមានផលលំបាកដោយសារការសម្របសម្រួល ទីកន្លែង ការរកមណ្ឌលបោះឆ្នោតខ្លួន ការរងចាំ ឬតម្រូវការឯកសារផ្លូវច្បាប់ផ្សេងៗដែលត្រូវភ្ជាប់ទៅជាមួយ។ ចំពោះការយល់ឃើញលើលទ្ធផលនៃការបោះឆ្នោត ចំណុចនេះក៏គួរមានការចាប់អារម្មណ៍ផងដែរ ព្រោះមានអ្នកមិនយល់ស្របថាល្អ រួមទាំងអ្នកថាមិនដឹង អាចថាមានដល់ទៅជាង១០% នៃអ្នកយល់ឃើញចំពោះលទ្ធផលនៃការបោះឆ្នោត ដែលគួរត្រូវបានសម្រួលបំភ្លឺនិងដោះស្រាយតាមរយៈពាក្យ បណ្តឹងតំណាង

គណបក្ស ឬភ្នាក់ងារសង្កេតការណ៍នៅតាមមណ្ឌលបោះឆ្នោត ជាពិសេសតម្លាភាពគណនេយ្យភាពនៃគ.ជ.ប ពេលប្រកាសលទ្ធផលគួរមានការប្រុងប្រយ័ត្នផ្នែកបច្ចេកទេស។ល។







សញ្ញាចង្អុលបង្ហាញដោយលទ្ធផលវិភាគទិន្នន័យក៏បានបញ្ជាក់ថា ទោះបីជាមានការផ្តល់នូវសេរីភាពក្នុងការបញ្ចេញមតិដោយសេរីក៏ដោយ ហើយមានអ្នកទទួលស្គាល់ពីដែនសេរីភាពនោះក្តី ប៉ុន្តែនៅមានការកត់សំគាល់លើភាពរារាំងឬរឹតត្បិតដោយអន្លើសម្រាប់យុវជនមួយចំនួនផ្សេងទៀតផងដែរ ដែលជាលទ្ធផលយល់ឃើញផ្នែកអារម្មណ៍ឬជាក់ស្តែងក្នុងការបញ្ចេញតាមរយៈការឆ្លើយនូវសំណួរស្រាវជ្រាវនេះ។



## ៥- សន្និដ្ឋាននិងអនុសាសន៍

ចេញពីលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឃើញថាពេលមុនយុវជនខ្មែរដែលមិនសូវចូលរួម ឬចាប់អារម្មណ៍នឹងកិច្ចការនយោបាយទេ មកពីពួកគេគិតតែការងារគ្រួសារផ្ទាល់ខ្លួន ការសិក្សាឬការកម្សាន្តនានា និងក៏មានការដាក់សម្ពាធពីក្រុមគ្រួសារនិងសង្គមផងដែរ។ ប៉ុន្តែដល់ពេលនេះគេគិតថាលទ្ធផលសង្គមសព្វថ្ងៃគឺបានមកអំពីសកម្មភាពនយោបាយដែលបានចូលរួមដោយប្រជាពលរដ្ឋ ដែលនេះជាឱកាសល្អនិងជាការសម្រេចចិត្តត្រឹមត្រូវដែលពួកគេចាប់ផ្ដើមចូលរួមក្នុងរឿងនយោបាយកាន់តែផុសផុលខ្លាំងឡើង ម៉្យាងទៀតដោយសារបច្ចុប្បន្នយុវជនមានទស្សនៈជាតិនិយម ចង់ចូលរួមកំណត់វាសនាជាតិដោយខ្លួនឯង ស្រឡាញ់ការអភិវឌ្ឍ និងមានការបើកទូលាយពីគ្រួសារ រួមទាំងទទួលបានព័ត៌មានផង។ ការចូលរួមរបស់យុវជនពេលនេះ គឺត្រូវចំពេលដែលយុវជនត្រូវបង្ហាញប្រាប់ទៅបក្សនយោបាយទាំងអស់ឱ្យយកចិត្តទុកដាក់លើយុវជន ពួកគេនឹងនៅជាកណ្ដាលសម្លឹងមើលលើគណបក្សដែលមានគោលនយោបាយដឹកនាំល្អមានទស្សនវិស័យច្បាស់លាស់។

យើងឃើញថាកត្តាដែលជំរុញឱ្យយុវជនចាប់អារម្មណ៍ និងប្រឡូកក្នុងនយោបាយដោយឆន្ទៈគឺបណ្ដាលមកពីយុវជនយល់ឃើញថាបញ្ហានៅក្នុងសង្គម វាជាប់ទាក់ទងជាមួយជីវភាពរស់នៅរបស់ពួកគេ ដែលបញ្ហាទាំងនេះធ្វើឱ្យគេគិតថា សំឡេងភាពជាពលរដ្ឋរបស់គេមានឥទ្ធិពលលើយន្តការនៃការដោះស្រាយបញ្ហាទាំងនោះ។

សរុបមក យើងឃើញថាការអនុវត្តសិទ្ធិពលរដ្ឋក្នុងសង្គម ស្មារតីលះបង់សម្រាប់ប្រទេសជាតិ ការឱ្យតម្លៃខ្លួនឯងក្នុងការដឹកនាំប្រទេស ការទទួលស្គាល់ក្នុងសង្គមរស់នៅ ការបង្កើនកិច្ចសហការ និងការធានាសុវត្ថិភាពការងារ សំដៅផលប្រយោជន៍ថ្ងៃអនាគត និងបង្កើនអំណាចការងារ ដែលកត្តាទាំងនេះសុទ្ធសឹងតែជាកត្តាដ៏មានប្រសិទ្ធភាពបំផុតក្នុងការជំរុញឱ្យយុវជនចូលរួមក្នុងការងារសង្គមជាតិ និងសកម្មភាពនយោបាយហើយមានទំនាក់ទំនងវិជ្ជមានលើការអនុវត្តសិទ្ធិនយោបាយនានា តាមរយៈការបោះឆ្នោតជ្រើសរើសតំណាងដែលគេសម្រេចគាំទ្រនៅក្នុងថ្ងៃបោះឆ្នោតក្រុមប្រឹក្សាឃុំ និងបោះឆ្នោតជាតិ។ រីឯកត្តាសន្តិភាពនិងស្ថិរភាពនយោបាយនិងការបើកចំហឱ្យមានការចូលរួមពីសំណាក់អាជ្ញាធរនិងគ្រួសារ ពិតជាកត្តាជំរុញសិទ្ធិសេរីភាពដល់ការចូលរួមការងារអភិវឌ្ឍដល់គ្រប់វិស័យដោយយុវជន ដោយសារតែវប្បធម៌នយោបាយបើកទូលាយ។

ក្នុងគោលបំណងជំរុញទឹកចិត្តក៏ដូចជាបំផុសស្មារតីលះបង់ និងចូលរួមដោយឆន្ទៈខ្ពស់ពីសំណាក់យុវជនក្នុងការអភិវឌ្ឍខេត្តប្រកបដោយនិរន្តរភាព រដ្ឋបាលខេត្តគួររៀបចំនិងលើកកម្ពស់គោលនយោបាយអភិវឌ្ឍយុវជនដោយស្វែងរកយន្តការដ៏មានប្រសិទ្ធភាពក្នុងការផ្ដល់ការយកចិត្តទុកឱ្យឱវាទណែនាំប្រកបដោយសុចរិតភាព កែសម្រួលការរៀបចំគោលការណ៍អភិវឌ្ឍយុវជនសំដៅផ្ដល់ឱកាសនានាឱ្យយុវជនទទួលបាននូវការអភិវឌ្ឍសមត្ថភាពប្រកបដោយឆន្ទៈ សេចក្ដីព្យាយាម និងមនសិការវិជ្ជាជីវៈ ទាំងនេះគឺជាប្រយោជន៍មួយសម្រាប់ការងារអភិវឌ្ឍខេត្តក៏ដូចជាប្រទេសជាតិទាំងមូល។

# ឯកសារពិគ្រោះ


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ច្បាប់សិទ្ធិមនុស្សកម្ពុជាអង្គការសហប្រជាជាតិ ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំកម្ពុជា ឆ្នាំ២០០៨។
- ក្រសួងអប់រំ យុវជន និងកីឡា៖ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ២៤មិថុនា ឆ្នាំ ២០១១។
- ចំណេះដឹងទូទៅខ្មែរ៖ *លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា* ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៩។
- ឈុន ណារ៉េត៖ *សេចក្តីផ្តើមវិទ្យាសាស្ត្រនយោបាយ,* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ២០១២។
- ដៀប សុផល៖ *មនោគមវិជ្ជានយោបាយ* ភាគI, ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ បោះពុម្ពឆ្នាំ២០១១។
- សុខ គាង៖ *វិទ្យាសាស្ត្រនយោបាយ* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ២០០២។
- សុខ ទូច៖ *នយោបាយការបរទេស ម្សិលមិញ ថ្ងៃនេះ និងថ្ងៃស្អែក,* បោះពុម្ពឆ្នាំ ២០១៥។
- ឡាំ លីម៖ *ប្រតិទិនទស្សនៈ២២២* បោះពុម្ពលើកទី១ ដោយគ្រឹះស្ថានសៀវភៅជីវិត ឆ្នាំ២០១៩។
- Heng, *Youth Participation in Cambodia* : Knowledge, Pratcice, Attitue, and Media, 2010.
- Minoque J., *Political Participation:* How and Why do People get Involve in Politics? 1998.

# ការវិវត្តនៃឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌលក្ខណៈសកល

បេក្ខជនបណ្ឌិត វង្ស ពេជ្របុរី

## ១. សេចក្តីផ្តើម

### ១.១ ការវិវត្តនៃឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ពិភពលោក

ឧស្សាហកម្មកាត់ដេរបានក្លាយជា វិស័យឈានមុខគេក្នុងការជម្រុញបដិវត្តឧស្សាហកម្មក្នុងសតវត្សទី១៨ ពីព្រោះមានការផ្លាស់ប្តូរពីការផលិតសំលៀកបំពាក់ជាលក្ខណៈសិប្បកម្មឱ្យក្លាយទៅជាការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យា និងការបង្កើតរោងចក្រនៅអង់គ្លេសហើយក្រោយមកទៀតក៏ដោយឃើញកាលានុវត្តភាពនៃកំណើនសេដ្ឋកិច្ចពីវិស័យនេះ សហរដ្ឋអាមេរិកចាប់ផ្តើមចាប់យកឧស្សាហកម្មក្នុងការជំរុញសេដ្ឋកិច្ចរបស់ខ្លួន [1] ។ នៅក្នុងសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក កំឡុងសតវត្សទី១៨ ឧស្សាហកម្មកាត់ដេរគឺជាឧស្សាហកម្មមួយដែលមានការរីកចម្រើនយ៉ាងឆាប់រហ័សបំផុតព្រមទាំងមានផលិតភាពយ៉ាងខ្លាំង ក្នុងចំណោមឧស្សាហកម្មដែលកំពុងមានវត្តមានក្នុងប្រទេសចំនួន១១ទៀត [2] ។ ឧស្សាហកម្មកាត់ដេរក៏ត្រូវបានចាប់ផ្តើមនៅតាមបណ្តាប្រទេសអឺរ៉ុប ជាពិសេសប្រទេសបារាំង ប្រទេសអាល្លឺម៉ង់ ប្រទេសអ៊ីតាលី និងចក្រភពអង់គ្លេស។ ការឈោងចាប់យកនូវកាលានុវត្តភាពនៃវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់នេះ គឺព្រោះតែប្រទេសទាំងនោះបានរងឥទ្ធិពលពីបដិវត្តឧស្សាហកម្មនិងការច្នៃប្រឌិត នៅក្នុងវិស័យសេដ្ឋកិច្ចផ្សេងៗទៀត។ បន្ទាប់មកទៀត នៅពេលដែលបណ្តាប្រទេសនោះឈានដល់ដំណាក់កាលមួយដែលមានភាពប្រកួតប្រជែងខ្លាំងនោះដំណើរការផលិតឧស្សាហកម្មកាត់ដេរមួយផ្នែកឬទាំងស្រុង ត្រូវបានផ្លាស់ប្តូរទៅកាន់ប្រទេសដែលមានកម្លាំងពលកម្មទាបហើយត្រូវបានគេបែងចែកនៅតាមទីតាំងភូមិសាស្ត្រផ្សេងៗគ្នានៅជុំវិញពិភពលោក [3]។

**បដិវត្តឧស្សាហកម្មកាត់ដេរលើកទី១ ៖** គឺនៅក្នុងទសវត្សឆ្នាំ១៩៥០ នៅពេលដែលអាមេរិកខាងជើង និងអឺរ៉ុបខាងលិចបាន បោះទីតាំងរោងចក្រសហគ្រាសផលិតកម្មនៅក្នុងប្រទេសជប៉ុនដែលជាហេតុធ្វើឱ្យការនាំចេញមានចំនួនគួរឱ្យកត់សម្គាល់ ពីប្រទេសជប៉ុនទៅកាន់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងកំឡុងសម័យនោះ [4]។ ដូច្នេះការផ្លាស់ប្តូរ ឬ បម្លាស់ទីនៅក្នុងឧស្សាហកម្មកាត់ដេរកត្តាចម្បង គឺពឹងផ្អែកជាទៅលើទីតាំងដែលជាមូលដ្ឋាននៃទិសដៅក្នុងការនាំចេញ។

---

[1] Dickerson, K. G. (1999). Textiles and apparel in the global economy. Columbus, Ohio: Merill.

[2] Hughes, J. R. T., and Cain L. P. (2011). American Economic History 8th ed. Boston: MA

[3] Dicken P. (2011). Global shift: mapping the changing contours of the world economy (eds). New York: NY. P.304

[4] Dicken P. (2011). Global shift: mapping the changing contours of the world economy (eds). New York: NY. P.317

**បដិវត្តឧស្សាហកម្មកាត់ដេរលើកទី២ ៖** បានធ្វើឱ្យជប៉ុនបានបង្កើតការរៀបចំកិច្ចសន្យាម៉ៅការក្នុងការកាត់ដេរបន្តដោយមានការចូលរួមក្នុងការធ្វើពាណិជ្ជកម្មដោយរួមមានវត្តមានរបស់បណ្តាប្រទេសឧស្សាហកម្មថ្មី (NIC)[5]។ កត្តាតម្លៃពលកម្មទាប គឺជាការផ្តល់អាទិភាពព្រមទាំងជម្រុញឱ្យក្រុមហ៊ុនជប៉ុនផ្លាស់ប្តូរខ្សែចង្វាក់ផលិតកម្មខ្លួនទៅតាមបណ្តាប្រទេសនៅឯនាយសមុទ្រ ពោលគឺបណ្តាប្រទេសឧស្សាហកម្មថ្មី(NIC)។ កត្តាមួយទៀតគឺគោលនយោបាយកូតាការនាំចូលដែលត្រូវបានផ្តល់ដោយប្រទេសអភិវឌ្ឍន៍ធំ (ភាគច្រើនគឺសហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប) ។ គោលនយោបាយរបស់រដ្ឋាភិបាលនៃបណ្តាប្រទេសឧស្សាហកម្មថ្មី(NIC) បានផ្តល់នូវការអនុគ្រោះនូវបរិយាកាសវិនិយោគដ៏មានភាពទាក់ទាញយ៉ាងខ្លាំងដល់ក្រុមហ៊ុនសហគ្រាសរបស់ជប៉ុន ព្រមទាំងទទួលបាននូវកិច្ចព្រមព្រៀង MFAs[6] ពីសហរដ្ឋអាមេរិក ប្រទេសកាណាដា និងសហភាពអ៊ឺរ៉ុប។ តួនាទីរបស់រដ្ឋាភិបាលបណ្តាប្រទេសឧស្សាហកម្មថ្មី (NIC) នាពេលនោះ គឺដើម្បីទាក់ទាញវិនិយោគិនឱ្យបានច្រើនពីព្រោះបណ្តាប្រទេសទាំងនោះមានភាពខ្វះខាតក្នុងការចាប់ផ្តើមដោយខ្លួនឯង។

**ការវិវត្តនៃឧស្សាហកម្មកាត់ដេរលើកទី៣ ៖** បានកើតឡើងជាទម្រង់នៃចង្វាក់ផលិតកម្មដែលមានលក្ខណៈត្រីកោណ។ " ចង្វាក់ផលិតកម្មជាលក្ខណៈត្រីកោណ" គឺជាពាក្យមួយដែលត្រូវបានកំណត់ដើម្បីពិពណ៌នាអំពីវដ្តនៃការវិនិយោគនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ ដោយបណ្តាប្រទេសឧស្សាហកម្មថ្មី (NIC) ឆ្ពោះទៅរកប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីអាគ្នេយ៍ [7]។ ខ្សែចង្វាក់ផលិតកម្មនេះនៃទម្រង់ថ្មីនេះ បានចាប់ផ្តើមពីក្រុមហ៊ុនជប៉ុនដែលបានផ្លាស់ប្តូរខ្សែចង្វាក់ផលិតកម្មកាត់ដេរទេសតំបន់ហុងកុង តៃវ៉ាន់ និងកូរ៉េខាងត្បូង ក្នុងកំឡុងទសវត្សឆ្នាំ១៩៥០។ជប៉ុនបានសម្របសម្រួលក្នុងការផ្ទេរនូវចំណេះដឹង ការដឹកជញ្ជូនគ្រឿងម៉ាស៊ីន និងទុនវិនិយោគទៅបណ្តាប្រទេសឧស្សាហកម្មថ្មី (NIC) ។ បន្ទាប់មកទៀតក្នុងសតវត្សរ៍ទី២០ សហរដ្ឋអាមេរិក និងសហភាពអ៊ឺរ៉ុប គឺជាអ្នកបញ្ជាទិញពីបណ្តាប្រទេសឧស្សាហកម្មថ្មី (NIC) ព្រមទាំងបានបង្កើតនូវទំនាក់ទំនងដ៏ជិតស្និទ្ធដោយសារឈរលើមូលដ្ឋានគុណភាពនៃផលិតផលសំលៀកបំពាក់របស់បណ្តាប្រទេសទាំងនោះ។ បន្ទាប់មកនៅពេលដែលបណ្តាប្រទេសឧស្សាហកម្មថ្មី (NIC) ពោលគឺតំបន់ហុងកុង តៃវ៉ាន់ និងកូរ៉េខាងត្បូង មានការអភិវឌ្ឍកាន់តែខ្លាំងថែមទាំងតម្លៃពលកម្មបានកើនឡើងយ៉ាងឆាប់រហ័សបណ្តាប្រទេសទាំងនោះបានសម្រេចចិត្ត ផ្លាស់ប្តូររោងចក្ររបស់ខ្លួនសម្រាប់វិនិយោគទៅទីតាំងដែលមានកម្លាំងពលកម្មមានកម្រិតទាប និងថែមទាំងមានកូតាស្រាប់។

---

[5] បណ្តាប្រទេសឧស្សាហកម្មថ្មី គឺសំដៅទៅកាន់ប្រទេសនិងតំបន់ដូចជា ហុងកុង ប្រទេសសិង្ហបុរី តៃវ៉ាន់ និងកូរ៉េខាងត្បូង។

[6] Multi-fiber Arrangements (MFA) កិច្ចព្រមព្រៀងពាណិជ្ជកម្មបង្កើតដោយរដ្ឋាភិបាលសហរដ្ឋអាមេរិកនៅឆ្នាំ១៩៧៤ មានគោលដៅក្នុងការផ្តល់សិទ្ធិក្នុងការនាំចេញនូវសំលៀកបំពាក់មួយចំនួនដែលមានតម្លៃកំណត់

[7] Gereffi, G. (2002, February). The International competitiveness of Asian economies in the apparel commodity chain. ERD Working Paper Series No. 5. Manila: Asian Development Bank.
Dicken P. (2011). Global shift: mapping the changing contours of the world economy (eds). New York: NY.

## ១.២ សកលភាវូបនីយកម្មនៃឧស្សាហកម្មកាត់ដេរ

ឧស្សាហកម្មកាត់ដេរបានវិវត្តខ្លួនក្លាយជាឧស្សាហកម្មដែលមានការនាំចេញដ៏ធំ និងមានសារៈសំខាន់បំផុតមួយនៅលើសកលលោក។ ជាលទ្ធផលនៃសកលភាវូបនីយកម្មពាណិជ្ជកម្មបានជំរុញឧស្សាហកម្មកាត់ដេរក្នុងកម្រិតមួយដែលអាចសមាហរណកម្មពង្រីកខ្លួន និងផ្លាស់ប្តូររូបរាងសង្វាក់ផលិតកម្មពីក្នុងកម្រិតតំបន់ឬប្រទេសទៅជាអន្តរជាតិទាំងដែលពាក់កណ្តាលសតវត្សរ៍ទី២០ផលិតផលកាត់ដេរត្រូវបានផលិតក្នុងស្រុកដើម្បីបំពេញតំរូវការអ្នកប្រើប្រាស់នៅក្នុងប្រទេសអភិវឌ្ឍន៍តែប៉ុណ្ណោះ[8] ។ ឧស្សាហកម្មនៃវិស័យសំលៀកបំពាក់និងវាយនភណ្ឌ គឺជាឧស្សាហកម្មដែលពឹងផ្អែកលើកម្លាំងពលកម្មច្រើនបំផុតព្រមទាំងទាមទារនូវប្រាក់ឈ្នួលពលកម្មទាប ទោះបីជាមានមានការកើនឡើងនូវគួរឱ្យកត់សម្គាល់នូវផលិតកម្មបច្ចេកវិទ្យានិងផលិតកម្មកុំព្យូទ័រជំនួយក៏ដោយ។

ឧស្សាហកម្មកាត់ដេររបស់ប្រទេសមួយមានការរីកចម្រើនតាមរយៈ ៦ ដំណាក់កាលដែលចាប់ផ្តើមចេញពីដំណាក់កាល "អំប្រ៊ីយ៉ុង(Embryonic) រហូតដល់ដំណាក់កាលនៃការធ្លាក់ចុះ(Declining)"[9] ៖

**១. ដំណាក់កាលដំបូង អំប្រ៊ីយ៉ុង (Embryonic)** ៖ នៅក្នុងដំណាក់កាលនេះ វិសាលភាពនៃឧស្សាហកម្មគឺមានភាពតូចចង្អៀតហើយផលិតតែសម្រាប់ផ្គត់ផ្គង់ក្នុងស្រុកតែប៉ុណ្ណោះហើយ ជាទូទៅគេសង្កេតឃើញថាដំណាក់កាលដំបូងនេះភាគច្រើនគឺស្ថិតនៅក្នុងប្រទេសក្រីក្រ និងអភិវឌ្ឍន៍តិចតួចជាពិសេសនៅទ្វីបអាហ្វ្រិក។ ដំណើរការផលិតផលិតផលកាត់ដេរមានលក្ខណៈសាមញ្ញហើយការនាំចេញវត្ថុធាតុដើមមូលដ្ឋានដូចជាកប្បាសគឺជាប្រភពចំណូលដ៏សំខាន់។

**២. ដំណាក់កាលទី២ ការនាំចេញសំលៀកបំពាក់ដំបូង (Early Export of Apparel)** ៖ កាត់-ច្នៃ-ទ្រីម (Cut-Make-Trim, Known as CMT)ឬ បច្ចុប្បន្នកម្ពុជាបានសម្គាល់ទម្រង់បែបនេះជារោងចក្រកាត់ដេរ វេចខ្ចប់ គឺជាដំណាក់កាលដែលសាមញ្ញមួយដែលត្រូវបានអនុវត្តនៅក្នុងដំណាក់កាលនៃឧស្សាហកម្មកាត់ដេរ ពីព្រោះដំណាក់កាលនេះទាមទារនូវកម្លាំងពលកម្មដែលមានប្រាក់ឈ្នួលទាប កម្មករដែលមានជំនាញទាបនិងដំណើរការខ្សែសង្វាក់ផលិតកម្មទាប។ ប្រទេសដែលធ្វើការនាំចេញនៅក្នុងដំណាក់កាលនេះ គឺនាំចេញនូវផលិតផលកាត់ដេរដែលមានតំលៃថោកទៅកាន់ប្រទេសអភិវឌ្ឍន៍។ ប្រទេសខ្លះនៅដំណាក់កាលនេះ គឺប្រទេសនេប៉ាល់ បង់ក្លាដែស ស្រីលង្ការ ឡាវ និងកម្ពុជាព្រមទាំងប្រទេសមួយចំនួនដែលស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ជាដើម។

**៣. ដំណាក់កាលទី៣ ការផលិតក្រណាត់និងសំលៀកបំពាក់ដែលមានលក្ខណៈជឿនលឿនជាងមុន (More Advance production of fabric and apparel)** ៖ ផលិតកម្មសំលៀកបំពាក់នៅ

---

[8] Kunz, G. I., and Garner, M. B. (2007). Going global: the textiles and apparel industry. New York: Fairchild Publications, Inc.
[9] Dickerson, K. G. (1999). Textiles and apparel in the global economy. Columbus, Ohio: Merill.

ដំណាក់កាលនេះត្រូវបានធ្វើឱ្យមានភាពប្រសើរឡើង ព្រមទាំងមានភាពផ្អែកលើបច្ចេកវិទ្យាកាន់តែច្រើនឡើងដែលមានផលិតកម្មកាន់តែធំ និងមានលក្ខណៈចម្រុះ។ ប្រទេសដែលស្ថិតនៅក្នុងដំណាក់កាលនេះ គឺមានចិន និងឥណ្ឌា ពីព្រោះប្រទេសទាំងនោះបានអភិវឌ្ឍបច្ចេកវិទ្យានិងឧស្សាហូបនីយកម្មទំនើប។

**៤. ដំណាក់កាលទី៤ យុគសម័យមាស** (The Golden Age Stage) ៖ ឧស្សាហកម្មកាត់ដេរនៅដំណាក់កាលនេះគឺកំពុងតែរីកដុះដាលកាន់តែខ្លាំងឡើងៗ ហើយមិនមានការផលិតក្នុងស្រុកនៅក្នុងស្រុកទៀតនោះទេ។ នៅដំណាក់កាលនេះឧស្សាហកម្មសំលៀកបំពាក់និងវាយនភណ្ឌបានកំពុងចាប់ផ្តើមវិនិយោគនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលមានលទ្ធភាពផ្គត់ផ្គង់សរសៃនិងក្រណាត់។ ក្នុងដំណាក់កាលសមាហរណកម្មនេះ ការធ្វើពិពិធកម្មការនាំចេញរបស់បណ្តាសហគ្រាសនៃឧស្សាហកម្មទាំងនេះ គឺផ្តោតលើបច្ចេកវិទ្យាឬវត្ថុមានតម្លៃបន្ថែមខ្ពស់ទៅកាន់ទីផ្សារអន្តរជាតិ។

**៥. ដំណាក់កាលទី៥ ភាពពេញលេញ** (Full Maturity) ៖ ផលិតកម្មនៅដំណាក់កាលនេះគឺចំណាយដើមទុនច្រើនជាងកម្លាំងពលកម្ម ទោះបីជាផលិតកម្មនៅតែកើនឡើងដោយសារបច្ចេកវិទ្យាកាន់តែជឿនលឿន។ សហរដ្ឋអាមេរិក ជប៉ុន និងអ៊ីតាលីគឺស្ថិតនៅក្នុងដំណាក់កាលនេះប៉ុន្តែបណ្តាប្រទេសទាំងនេះ អាចត្រូវបានដាក់បញ្ចូលទៅក្នុងជំហានចុងក្រោយនៃការអភិវឌ្ឍនៅក្នុងឧស្សាហកម្មកាត់ដេរពិភពលោក។

**៦. ដំណាក់កាលទី៦ ការធ្លាក់ចុះគួរឱ្យកត់សម្គាល់** (Significant Decline) ៖ ផលិតកម្មដែលសកម្មភាពវិនិយោគទុននៅបណ្តាប្រទេសនៅឯនាយសមុទ្របានកើនឡើងយ៉ាងខ្លាំងនៅដំណាក់កាលនេះ។ វិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌ លែងដើរតួនាទីជាប្រភពចំណូលដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ចរបស់ប្រទេសទៀតឡើយ។ ក្នុងដំណាក់កាលនេះ ការធ្វើពិពិធកម្មការនាំចេញគឺត្រូវបានផ្តោតទៅលើឧស្សាហកម្មធុនធ្ងន់រីឯវិស័យកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌត្រូវបានប្តូរទៅប្រទេសដែលកម្លាំងពលកម្មដែលមានប្រាក់ឈ្នួលពលកម្មទាប ក្នុងគោលបំណងកាត់បន្ថយថ្លៃផលិត។ ឧទាហរណ៍សហរដ្ឋអាមេរិកត្រូវបានពិចារណានៅក្នុងដំណាក់កាលនេះផងដែរ[10] ។

ការវិវត្តនៃពាណិជ្ជកម្មពិភពលោកក្នុងវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌ គឺមានការផ្លាស់ប្តូរដោយផ្តោតទៅលើការសិក្សាអំពីភូមិសាស្ត្រ និងបច្ចេកវិទ្យា ដែលជាមូលហេតុដែលធ្វើឱ្យបណ្តាប្រទេសនៅតំបន់អាស៊ីនិងអាមេរិកខាងត្បូងក្លាយជាអ្នកនាំចេញផលិតផលកាត់ដេរដ៏ធំ។ ផ្អែកលើការផ្លាស់ប្តូរនៃសកល-ភាវូបនីយកម្មនៃឧស្សាហកម្មកាត់ដេរនេះ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍បានផ្តោតសំខាន់ទៅលើផលិតកម្មសំលៀកបំពាក់ដែលជា "**អ្នកចាប់ផ្តើម**" ឆ្ពោះទៅរកផលិតកម្មដែលផ្តោតលើការនាំចេញ[11] ។

[10] Dickerson, K. G. (1999). Textiles and apparel in the global economy. Columbus, Ohio: Merill.
[11] Gereffi G. (1999). International trade and inustrial upgrading in the apparel commodity chain. Journal of International Economics 48, p. 37-70.

ទោះយ៉ាងណាក្តី ដំណាក់កាលទាំង៦នៃការវិវត្តឧស្សាហកម្មកាត់ដេរ គឺមានភាពហួសសម័យបន្តិច ប៉ុន្តែនៅតែមានការចាប់អារម្មណ៍ក្នុងការពិនិត្យមើលមូលហេតុដែលប្រទេសខ្លះលេចធ្លោជាអ្នកនាំចេញផលិតជាអ្នកនាំចេញផលិតផលកាត់ដេរធំៗ ខណៈប្រទេសខ្លះទៀតបានបាត់បង់ឋានៈនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ទោះយ៉ាងណា បរិការណ៍បច្ចុប្បន្ន ដំណាក់កាលនៃឧស្សាហកម្មកាត់ដេររបស់ប្រទេសមួយចំនួនមានការប្រែប្រួលទៅតាមផលិតភាពនៃបច្ចេកវិទ្យា និងការកើនឡើងនៃការវិនិយោគដើមទុន។

© ២០២១ រាជបណ្ឌិត្យសភាកម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង
គ្មានផ្នែកណាមួយនៃទស្សនាវដ្ដីនេះនឹងត្រូវបានបោះពុម្ពឡើងវិញ
ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរាជបណ្ឌិត្យសភាកម្ពុជាឡើយ។

©2021 Royal Academy of Cambodia

All rights reserved,
no part of this book may be reproduced,
in any form, by any means, without permission in writing from
Royal Academy of Cambodia.



**Royal Academy of Cambodia**

Russian Federation Blvd
P.O.Box: 531 Phnom Penh
Kingdom of Cambodia
Tel: (855) 23 890 180
Fax: (855) 23 890 180
Email: info@rac.gov.kh
Website: www.rac.gov.kh

**រាជបណ្ឌិត្យសភាកម្ពុជា**

**មហាវិថីសហព័ន្ធរុស្ស៊ី**
**ប្រអប់សំបុត្រលេខ ៥៣១ ភ្នំពេញ**
**ព្រះរាជាណាចក្រកម្ពុជា**
**ទូរសព្ទលេខ**: (៨៥៥)២៣ ៨៩០១៨០
**ទូរសារលេខ**: (៨៥៥)២៣ ៨៩០១៨០
**អ៊ីម៉ែល**: info@rac.gov.kh
**វេបសាយ**: www.rac.gov.kh